**អង្គការសហប្រជាជាតិ** **A S**

**មហាសន្និបាត**
**ក្រុមប្រឹក្សាសន្តិសុខ**

ការចែកចាយជាទូទៅ
A/53/850
S/1999/231
ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ១៩៩៩
អត្ថបទដើម: អង់គ្លេស

មហាសន្និបាត
សម័យប្រជុំលើកទី ៥៣
ចំណុចនៃរបៀបវារៈលេខ ១១០(ខ)
បញ្ហាសិទ្ធិមនុស្ស: បញ្ហាសិទ្ធិមនុស្សរួមទាំង
វិធីដោះស្រាយដែលអាចមាន ដើម្បីធ្វើឱ្យ
ប្រសើរឡើងការប្រើប្រាស់ដោយប្រសិទ្ធភាព
នូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន

ក្រុមប្រឹក្សាសន្តិសុខ
ឆ្នាំទី ៥៤

**លិខិតមានខ្លឹមសារដូចគ្នា ចុះថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៩៩ ដែល**
**លោកអគ្គលេខាធិការផ្ញើជូនប្រធានមហាសន្និបាត និងប្រធានក្រុមប្រឹក្សាសន្តិសុខ**

តាមសេចក្តីសំរេចចិត្តលេខ ៥២/១៣៥ របស់ខ្លួន មហាសន្និបាតបានស្នើឱ្យខ្ញុំពិនិត្យការស្នើសុំជំនួយរបស់អាជ្ញាធរកម្ពុជា ក្នុងការឆ្លើយតបទៅនឹងការរំលោភនានាដ៏ធ្ងន់ធ្ងរពីអតីតកាល ទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ និងការរំលោភដែលបានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហមជាពិសេស ហើយក្នុងន័យនេះឱ្យពិនិត្យមើលលទ្ធភាពនៃការតែងតាំងឡើងនូវក្រុមអ្នកជំនាញការមួយក្រុម ។ ខ្ញុំក៏បានយល់ស្របតែងតាំងឡើងនូវក្រុមអ្នកជំនាញការមួយក្រុមមានគ្នា ៣ នាក់ ដើម្បីធ្វើការវាយតម្លៃទៅលើភស្តុតាងទាំងឡាយដែលមានស្រាប់ ដើម្បីកំណត់អំពីប្រភេទនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហមនៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ ដើម្បីធ្វើការវាយតម្លៃនូវលទ្ធភាពនៃការចាប់ខ្លួនពួកគេ និងដើម្បីរិះរកជំរើសខាងផ្លូវច្បាប់សំរាប់នាំខ្លួនពួកគេទៅកាន់តុលាការ នៅចំពោះមុខយុត្តាធិការអន្តរជាតិ ឬជាតិណាមួយនោះ ។

ក្រុមអ្នកជំនាញការនេះ បានអញ្ជើញមកបំពេញទស្សនៈកិច្ចនៅប្រទេសកម្ពុជា និងប្រទេសថៃ ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ កន្លងទៅនេះ ។ ក្រុមនេះ បានជួបពិភាក្សាជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាមួយតំណាងនានានៃរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលជាឯកជនផ្សេង ៗ ផង។ ក្រុមនេះ ក៏បានទៅទស្សនាមជ្ឈមណ្ឌលឯកសារ កន្លែងតំកល់ឯកសារជាតិ និងព័ន្ធនាគារទួលស្លែង (ដែលហៅថា "សារមន្ទីរប្រល័យពូជសាសន៍") ។ ក្រុមអ្នកជំនាញការបានដាក់ជូនដល់ខ្ញុំនូវរបាយការណ៍របស់ពួកគេនៅ ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ១៩៩៩ (សូមមើលឧបសម្ព័ន្ធ) ។ នៅក្នុងថ្ងៃជាមួយគ្នានេះ របាយការណ៍ក៏ត្រូវបាន ផ្ញើជូនរដ្ឋាភិបាលកម្ពុជាមួយច្បាប់ដែរ ដើម្បីធ្វើការពិនិត្យ ។

ឈរលើមូលដ្ឋាននៃការពិនិត្យមើលសម្ភារៈ និងឯកសារ ដែលត្រូវបានផ្តល់ជូនពួកគេ ក្រុមអ្នកជំនាញការបានសន្និដ្ឋានថា ភស្តុតាងដែលប្រមូលបានរហូតមកទល់ពេលនេះ បញ្ជាក់ដល់គណៈកម្មការថា ពិតជាមានអំពើឧក្រិដ្ឋដ៏ធ្ងន់ធ្ងរមែន តាមច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា ហើយថាមានភស្តុតាងជារូបិយ និងជាសាក្សីគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់តាមផ្លូវច្បាប់ប្រឆាំងទៅលើមេដឹកនាំខ្មែរក្រហម ស្តីអំពីឧក្រិដ្ឋកម្មទាំងនេះ ។ ក្រុមអ្នកជំនាញការបានចាត់ទុកថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយពួកមេដឹកនាំខ្មែរក្រហមនៅក្នុងរយៈពេល ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ រួមមាន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបង្ខំឱ្យធ្វើការធ្ងន់ ទារុណកម្ម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សដែលត្រូវបានការពារជាអន្តរជាតិ ក៏ដូចជាឧក្រិដ្ឋកម្មនានាដែលមានចែងនៅក្នុងច្បាប់កម្ពុជាដែរ ។

តាមទស្សនៈរបស់ក្រុមអ្នកជំនាញការ បញ្ហានៃលទ្ធភាពនៃការចាប់ខ្លួនពួកមេដឹកនាំខ្មែរក្រហម គឺស្ថិតនៅក្នុងសមត្ថកិច្ច និងឆន្ទៈ របស់រដ្ឋាភិបាល ដើម្បីធ្វើការចាប់ខ្លួន ឬធ្វើបត្យប័ន នៅលើទឹកដីដែលជនជាប់សង្ស័យបានរស់នៅ ។ ក្រុមអ្នកជំនាញការបានសន្និដ្ឋានថា រដ្ឋាភិបាលកម្ពុជា មានលទ្ធភាពអាចចាប់ខ្លួនពួកមេដឹកនាំខ្មែរក្រហម នៅលើទឹកដីរបស់ពួកគេដែលទីកន្លែងពិតប្រាកដត្រូវបានដឹងហើយនោះ និងដែលមិនមានការការពារខាងរូបរាងកាយពីការចាប់ខ្លួននោះទេ ។ នៅក្នុងការជួបប្រជុំរបស់ពួកគេជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន លោកហ៊ុន សែន បានសំដែងនូវបំណង និងការត្រៀមខ្លួនជាស្រេចរួចហើយ របស់រដ្ឋាភិបាល ដើម្បីចាប់ខ្លួនមនុស្សទាំងឡាយណាដែលត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញាឯករាជ្យ នៃ

តុលាការឯករាជ្យមួយ បើសិនណាជាតុលាការនោះត្រូវបានបង្កើតឡើងនោះ ។ ការសំដែងចេញនូវបំណងដូចគ្នានេះ ក៏ត្រូវបានធ្វើឡើងដោយរដ្ឋាភិបាលថៃដែរ ។

ក្រុមអ្នកជំនាញការបានវិភាគជំរើសខាងផ្លូវច្បាប់ដូចខាងក្រោមនេះ ដើម្បីនាំខ្លួនខ្មែរក្រហមទៅកាន់តុលាការ មានៈ តុលាការមួយបង្កើតឡើងតាមច្បាប់នៃប្រទេសកម្ពុជា តុលាការមួយបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ ឬដោយមហាសន្និបាត ដែលជាតុលាការចំពោះកិច្ចមួយ ជំរើសចំរុះមួយនៃតុលាការកម្ពុជាដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ តុលាការអន្តរជាតិមួយបង្កើតឡើងដោយសន្ធិសញ្ញាពហុភាគីមួយ និងធ្វើការកាត់ទោសនៅក្នុងប្រទេសទី ៣ ណាមួយ ។

ក្រុមអ្នកជំនាញការបានស្នើយោបល់ថា ដើម្បីឆ្លើយតបទៅនឹងការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជា អង្គការសហប្រជាជាតិត្រូវបង្កើតតុលាការអន្តរជាតិចំពោះកិច្ចមួយ ដើម្បីកាត់ទោសពួកមេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តឡើងពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ ថាក្រុមប្រឹក្សាសន្តិសុខត្រូវបង្កើតតុលាការនេះ ស្របតាមជំពូកទី ៦ ឬទី ៧ នៃធម្មនុញ្ញសហប្រជាជាតិ ឬមួយបើមិនដូច្នោះទេ មហាសន្និបាតត្រូវបង្កើតតុលាការនេះ ។ ពួកគេបានស្នើបន្ថែមទៀតថា អង្គការសហប្រជាជាតិ ដោយសហការជាមួយរដ្ឋាភិបាលកម្ពុជា និងផ្នែកក្រៅរដ្ឋាភិបាល ជំរុញឱ្យមានកិច្ចដំណើរការមួយសំរាប់ធ្វើការពិចារណា ក្នុងចំណោមជនកម្ពុជា ដើម្បីកំណត់អំពីគោលបំណងរបស់ពួកគេ ហើយបើសិនជាឱកាសហុចឱ្យនោះ រៀបចំបែបបទនានាដើម្បីឱ្យមានយន្តការនៃការនិយាយការពិតមួយដើម្បីផ្តល់ឱ្យឃើញនូវរូបភាពដ៏ពេញលេញនៃអំពើឃោរឃៅ ដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ក្រោយពីបានពិនិត្យពិច្ច័យរបាយការណ៍នេះហើយ នៅក្នុងលិខិតមួយច្បាប់ផ្ញើមកជូនខ្ញុំ ចុះថ្ងៃទី ៣ ខែមីនា ឆ្នាំ ១៩៩៩ រដ្ឋាភិបាលកម្ពុជាបានក្រើនរំលឹកថា សេចក្តីសំរេចណាមួយដើម្បីនាំខ្លួនមេដឹកនាំខ្មែរក្រហមទៅកាន់តុលាការនោះ ត្រូវតែគិតគូរអំពីសេចក្តីត្រូវការសន្តិភាព ការបង្រួបបង្រួមជាតិរបស់ប្រទេសកម្ពុជា ហើយថាបើសិនជាការនេះធ្វើទៅមិនស្រួលទេ ការកាត់ទោសមេដឹកនាំខ្មែរក្រហម នឹងបង្កើតឱ្យមានការភ័យស្លន់ស្លោ នៅក្នុងចំណោមអតីតនាយទាហានខ្មែរក្រហម និងពួកនៅថ្នាក់ក្រោម ៗ ហើយនឹងនាំទៅ

ឱ្យមានសង្គ្រាមឈ្លបជាថ្មីទៀត ។ នៅក្នុងការប្រជុំមួយរវាងខ្ញុំ ជាមួយនិងលោក ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិកម្ពុជា លោក ហោ ណាំហុង បានពាំនាំមកជូនខ្ញុំនូវទស្សនៈរបស់រដ្ឋាភិបាលលោកដែលថា ផ្អែកលើមាត្រាទី ៦ នៃអនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍ និងមាត្រាទី ៣៣ នៃរដ្ឋធម្មនុញ្ញកម្ពុជា តុលាការកម្ពុជាមានសមត្ថភាពពេញលេញនឹងធ្វើការកាត់ទោសបែបនេះ ។ លោកបានរំលឹកថា ឧក្រិដ្ឋជនជាជនជាតិកម្ពុជា អ្នករងគ្រោះជា ជនកម្ពុជា ហើយអំពើឧក្រិដ្ឋបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា ។ ហេតុដូច្នេះ លោករដ្ឋមន្ត្រីការបរទេស បានប្រាប់ខ្ញុំអំពីសេចក្តីសំរេចរបស់រដ្ឋាភិបាលលោក គឺថានឹងធ្វើការកាត់ទោស តាម៉ុក អតីតមេបញ្ជាការកងទ័ពខ្មែរក្រហមនៅភូមភាគនិរតី និងជាសាមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍មួយរូបនោះនៅក្នុងតុលាការកម្ពុជា តាមច្បាប់កម្ពុជា ហើយសុខចិត្តទទួលយកជំនួយ និងជំនាញការបរទេសដើម្បីធ្វើកិច្ចការនេះ ។

នៅក្នុងការប្រជុំនេះដែរ ខ្ញុំបានរំលឹកលោករដ្ឋមន្ត្រីការបរទេសថា ក្រុមអ្នកជំនាញការបានពិនិត្យពិច័យយ៉ាងប្រយ័ត្នប្រយែងបំផុតអំពីលទ្ធភាពនៃការបង្កើតតុលាការជាតិមួយនោះ តែពួកគេបានសន្និដ្ឋានថាស្ថានភាពបច្ចុប្បន្ននៃតុលាការកម្ពុជាមិនអាចបំពេញនូវបទដ្ឋានអន្តរជាតិអប្បបរមាបានទេ ទោះបីជាមានជំនួយពីខាងក្រៅក៏ដោយ ។ ខ្ញុំនៅតែមានសេចក្តីបារម្ភអំពីភាពទុកចិត្តទៅលើដំណើរការកាត់ក្តីណាមួយបែបនេះបាននោះ ។

របាយការណ៍នេះ បានដាក់ជូនមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ ក្នុងន័យជាការអនុវត្តន៍អនុសាសន៍ ដែលបានចែងនូវការអំពាវនាវឱ្យអង្គការណាមួយ និងអង្គទាំង ២ នេះ ចាត់វិធានការក្នុងបញ្ហានេះឡើង ។ ប៉ុន្តែ នៅពេលដែលអាណត្តិនៃក្រុមអ្នកជំនាញការបានចេញពីមហាសន្និបាតមក សមាជិកនៃក្រុមប្រឹក្សាបានរំលឹកឡើងវិញថាកាស្នើសុំជំនួយលើកទី ១ របស់កម្ពុជាដល់អង្គការសហប្រជាជាតិក្នុងការនាំខ្លួនមេ ដឹកនាំខ្មែរក្រហមទៅកាត់ទោសត្រូវខ្ញុំដាក់ជូនទៅអង្គការទាំង ២ នេះ (A/51/930-S/1997/488) ហើយថាក្រោយមកខ្ញុំបានជូនដំណឹងដល់ក្រុមប្រឹក្សាអំពីការបង្កើត អំពីអាណត្តិ និងសមាសភាពរបស់ក្រុម អ្នកជំនាញការនេះ ។

ការសំរេចស្តីពីការបង្កើតតុលាការអន្តរជាតិមួយ ទោះបីជាស្របតាមជំពូកទី ៦ ឬទី ៧ របស់ធម្មនុញ្ញសហប្រជាជាតិក៏ដោយ គឺក្រុមប្រឹក្សាសន្តិសុខ ឬមហាសន្និបាតទេដែលជាអ្នកបង្កើត ។ ខ្ញុំមានជំនឿជឿជាក់ថា ពួកគេនឹងយកចិត្តទុកដាក់លើរបាយការណ៍យ៉ាងពេញបន្ទុក ក្នុងការកំណត់របស់ពួកគេថាតើអ្វីដែលល្អជាងគេបំផុតដើម្បីតម្រូវទៅតាមគោលការណ៍នៃយុត្តិធម៌ និងការបង្រួបបង្រួមជាតិនៅកម្ពុជា ។ ក៏ប៉ុន្តែតាមទស្សនៈរបស់ខ្ញុំ ការកាត់ទោសមេដឹកនាំយោធាខ្មែរក្រហមណាតែម្នាក់ឯង ដោយទុកឱ្យថ្នាក់ដឹកនាំនយោបាយទាំងអស់គ្មានការទទួលទោសនោះ វាមិនបំរើដល់មូលហេតុនៃយុត្តិធម៌ និងនៃការទទួលខុសត្រូវទេ ។ អាស្រ័យហេតុនេះ តាមទស្សនៈរបស់ខ្ញុំ គឺថាមេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតនោះ ត្រូវតែបញ្ជូនខ្លួនទៅកាន់តុលាការ និងកាត់ទោសនៅចំពោះមុខតុលាការមួយត្រឹមត្រូវទៅតាមបទដ្ឋានអន្តរជាតិ ខាងយុត្តិធម៌ ខាងភាពត្រឹមត្រូវ និងស្របទៅតាមនីតិវិធីច្បាប់ ។ បញ្ហានិទ័ណ្ឌភាពមិន អាចទទួលយកបានទេនៅចំពោះមុខនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដ៏ទៃទៀត ។

ខ្ញុំមានទស្សនៈយ៉ាងម៉ឺងម៉ាត់ថា បើសិនជាបទដ្ឋានអន្តរជាតិនៃភាពយុត្តិធម៌ ការត្រឹមត្រូវ និងនីតិវិធីខាងផ្លូវច្បាប់ ត្រូវបានគោរព ក្នុងការនាំយកអ្នកបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សែនធ្ងន់ធ្ងរបែបនេះឱ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន តុលាការដែលយើងកំពុងនិយាយនេះត្រូវតែមានលក្ខណៈជាអន្តរជាតិ ។ នេះមិនចាំបាច់តែមានន័យថា តុលាការនេះត្រូវយកតាមគំរូតុលាការចំពោះកិច្ចដែលមានស្រាប់មកហើយ ឬក៏ភ្ជាប់ទៅនឹងតុលាការទាំងនោះ ជាផ្នែកស្ថាប័ន រដ្ឋបាល ឬហិរញ្ញវត្ថុនោះទេ ។ ជំរើសដ៏ទៃទៀតក៏ត្រូវស្វែងរកដែរ ដោយភ្ជាប់ទៅនឹងការវិភាគ និងសេចក្តីសន្និដ្ឋានរបស់ក្រុមអ្នកជំនាញការ ។ តែជោគជ័យរបស់តុលាការអន្តរជាតិណាមួយ ទោះបីជាវាមានលក្ខណៈបែបណាក៏ដោយ គឺត្រូវមានកិច្ចសហប្រតិបត្តិការដោយពេញលេញរបស់រដ្ឋាភិបាលកម្ពុជា និងការដែលរដ្ឋាភិបាលនេះត្រៀមខ្លួនជាស្រេចដើម្បីចាប់ខ្លួមមេដឹកនាំខ្មែរក្រហមដែលស្ថិតនៅលើទឹកដីរបស់ខ្លួន និងបញ្ជូនខ្លួនពួកគេទៅកាន់តុលាការអន្តរជាតិបើសិនជាមានការស្នើសុំ ។ ខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីជួយដល់មហាសន្និបាត ក្រុមប្រឹក្សាសន្តិសុខ និងរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជាក្នុងការនាំទៅឱ្យមានកិច្ចដំណើរការនៃការទទួលខុសត្រូវផ្នែកយុត្តិធម៌មួយ ដែលមានតែការនេះមួយទេដែលអាចផ្តល់នូវមូលដ្ឋានសំរាប់សន្តិភាព ការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍន៍ ។

(ហត្ថលេខា) ខូហ្វី អាណាន់

# ឧបសម្ព័ន្ធ

## របាយការណ៍របស់ក្រុមអ្នកជំនាញការ សំរាប់ប្រទេសកម្ពុជា អនុលោមទៅតាមសេចក្តីសំរេចចិត្តរបស់មហាសន្និបាត លេខ ៥២/១៣៥

មាតិកា


| | វាក្យខ័ណ្ឌ | ទំព័រ |
|---|---|---|
| I- សេចក្តីផ្តើម | ១ - ៣ | ៧ |
| II- អាណត្តិ សមាសភាព និងកម្មវិធីការងារ | ៤ - ១២ | ៨ |
| III- ប្រវត្តិនៃព្រឹត្តិការណ៍ | ១៣ - ៤៥ | ១៣ |
| IV- ការវាយតម្លៃលើភស្តុតាង | ៤៦ - ៥៨ | ២៨ |
| V- ប្រភេទនៃឧក្រិដ្ឋកម្មនៃអំពើដែលបានប្រព្រឹត្ត | ៥៩ - ៩១ | ៣៤ |
| VI- ខ្មែរក្រហម ក្នុងនយោបាយ និងសង្គមកម្ពុជានាសម័យបច្ចុប្បន្ន | ៩២ - ១០១ | ៥៥ |
| VII- លទ្ធភាពនៃការនាំខ្លួនពួកមេដឹកនាំខ្មែរក្រហមទៅកាន់តុលាការ | ១០២ - ១២១ | ៦១ |
| VIII- ជំរើសនានាក្នុងការនាំខ្លួនមនុស្សទៅកាន់តុលាការ | ១២២ - ១៩៧ | ៧០ |
| IX- រូបភាពដ៏ទៃទៀតនៃការទទួលខុសត្រូវរបស់បុគ្គល | ១៩៨ - ២១២ | ១០៣ |
| X- ទិដ្ឋភាពដ៏ទៃទៀតនៃការកាត់ទោស | ២១៣ - ២១៨ | ១១០ |
| XI- អនុសាសន៍សំខាន់ ៧ ដោយសង្ខេប | ២១៩ - ២២០ | ១១៣ |

<u>ឧបសម្ព័ន្ធ</u>: បញ្ជីឈ្មោះនៃក្រុមអ្នកជំនាញការតែងតាំង

## I- សេចក្ដីផ្ដើម

១- កាលពី ៣៤ ឆ្នាំ មុននេះ រដ្ឋាភិបាលថ្មីមួយបានឡើងកាន់អំណាចនៅក្នុងប្រទេសកម្ពុជា ហើយបានប្រព្រឹត្តនៅក្នុងរយៈពេលនៃការកាន់អំណាចមួយរយៈខ្លី ៣ ឆ្នាំ ៩ ខែ របស់គេនេះ នូវការរំលោភសិទ្ធិមនុស្សដ៏សែនរន្ធត់បំផុត ដែលគេមិនធ្លាប់បានជួបប្រទះតាំងពីក្រោយសង្គ្រាមលោកលើកទី ២ មក ។ នាទីបញ្ចប់នៃការភ័យរន្ធត់នៅក្នុងខែមករា ឆ្នាំ ១៩៧៩ សកម្មភាពរបស់របបនេះបានបណ្ដាលឱ្យមានការស្លាប់ដល់ប្រជាពលរដ្ឋកម្ពុជាអស់ចំនួនជិតពាក់កណ្ដាល ។ រហូតដល់រយៈពេលមនុស្សមួយជំនាន់ក្រោយមកហើយ ក៏ពួកអ្នកទទួលខុសត្រូវក្នុងការរៀបចំ ក្នុងការផ្ដើមគំនិត និងក្នុងការប្រព្រឹត្តនូវឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងនេះ កំពុងបន្តទទួលបាននូវនិទ័ណ្ឌភាពទាំងស្រុង ។ កេរ្តិ៍ដំណែលនៃឧក្រិដ្ឋកម្មរបស់ពួកគេ ហើយមិនតែប៉ុណ្ណោះ ការបន្សល់ទុកនូវនិទ័ណ្ឌភាពនោះ កំពុងបន្តបន្ទាចដល់កម្ពុជារហូតពេលសព្វថ្ងៃនេះ ។

២- ការនាំខ្លួនមនុស្សទាំងនេះទៅកាន់តុលាការ មិនមែនគ្រាន់តែជាបញ្ហានៃកាតព្វកិច្ចខាងសីលធម៌ប៉ុណ្ណោះទេ ប៉ុន្តែវាមានសារៈសំខាន់ខាងនយោបាយ និងសង្គម យ៉ាងជ្រាលជ្រៅបំផុតចំពោះប្រជាពលរដ្ឋកម្ពុជាទៀតផង ។ ទីមួយគឺសំរាប់ជាការទទួលខុសត្រូវ ហើយមុនគេបង្អស់ទៅទៀតនោះ វាគឺជាសេចក្ដីថ្លែងមួយទៅកាន់ជនកម្ពុជារងគ្រោះ និងសាច់ញាតិ ព្រមទាំងមិត្តភក្តិរបស់ពួកគេរាប់លាននាក់ ថានៅទីបំផុតសំរែករបស់ពួកគេត្រូវបានគេដឹងឮហើយ ដែលជាការផ្ដល់អ្នកដែលនៅរស់រានមានជីវិតនៅឡើយនោះ នូវខ្លឹមសារនៃពាក្យយុត្តិធម៌ និងបំភ្លេចចោលបានខ្លះអតីតកាល ។ ពាក្យថាយុត្តិធម៌ ក៏គឺជាកត្តាដ៏សំខាន់មួយសំរាប់ជួសជុលការខូចខាតដែលបានកើតមានឡើងចំពោះសង្គមនោះ ដោយការរំលោភសិទ្ធិមនុស្សដោយទ្រង់ទ្រាយធំ និងដើម្បីជាការលើកតម្កើងដល់សន្តិភាពផ្ទៃក្នុង និងការបង្រួបបង្រួមជាតិ ។ ដោយការរកឃើញ និងការផ្ដន្ទាទោសអ្នកដែលបានប្រព្រឹត្តនូវអំពើរំលោភទាំងនេះ ជនកម្ពុជាអាចយល់បានកាន់តែល្អប្រសើរឡើងនូវអតីតកាលផ្ទាល់ខ្លួនរបស់ពួកគេ ដែលនៅទីបំផុតទៅនឹងដាក់រយៈពេលនៃសោកនាដ្យកម្មធំបំផុត និងអ្នកទទួលខុសត្រូវចំពោះអំពើទាំងនេះឱ្យស្ថិតនៅពីក្រោយពួកគេ ហើយនឹងរួបរួមគ្នាធ្វើការដើម្បីកសាងឡើងនូវអនាគតមួយ ប្រកបដោយសន្តិភាព និងល្អប្រសើរ ។ ការដាក់ឱ្យមានការទទួលខុសត្រូវ អាចដើរតួនាទីបង្ការដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា - វាជាការបង្ហាញឱ្យអ្នកដែលមានបំណងប្រព្រឹត្តអំពើអាក្រក់ ថា

នៅទីបំផុតពួកគេនឹងអាចទទួលការផ្តន្ទាទោស និងធ្វើឱ្យមានការយល់ដឹងក្នុងចំណោមប្រជាពលរដ្ឋស្តីអំពីអត្ថន័យនៃយុត្តិធម៌ និងនីតិរដ្ឋ ។

៣- ដូច្នេះ ការទទួលខុសត្រូវចំពោះអតីតកាល និងការបង្រួបបង្រួមជាតិសំរាប់អនាគតមិនមែនគ្រាន់តែជាជាទិសដៅ ឬក៏ជាគូប្រជែងគ្នាពីកំណើតប៉ុណ្ណោះទេ ។ ការទាក់ទងរវាងវា គឺស្ថិតនៅពីក្រោយការស្នើសុំជំនួយរបស់រដ្ឋាភិបាលដល់សហគមន៍អន្តរជាតិដើម្បីនាំមកនូវយុត្តិធម៌ - គឺជាការស្នើសុំមួយដែលឆ្លើយតបដោយផ្ទាល់ទៅនឹងបំណងរបស់ប្រជាពលរដ្ឋកម្ពុជា និងដែលទទួលបាននូវការគាំទ្រយ៉ាងខ្លាំងក្លាពីសំណាក់ព្រះមហាក្សត្រកម្ពុជា ព្រះបាទនរោត្តម សីហនុ ។ ហើយបើសិនជាយុត្តិធម៌នេះត្រូវបានផ្តល់ជូនដោយក្តីរំភើបដោយស្ថានភាពផ្ទាល់របស់ប្រទេសមួយនោះ ក្នុងការជាក់ស្តែង ការទទួលខុសត្រូវ និងបង្រួបបង្រួមជាតិនោះវាជាការជួយបំពេញគ្នាទៅវិញទៅមក រហូតដល់មិនអាចផ្តាច់ចេញពីគ្នាបានផង ។ ដោយមានការយល់ដឹងបែបនេះអំពីយុត្តិធម៌នៅក្នុងក្របខ័ណ្ឌនៃប្រទេសកម្ពុជានេះហើយ ដែលអង្គការសហប្រជាជាតិបានបង្កើតក្រុមជំនាញការនេះឡើង ហើយក៏នៅក្នុងស្មារតីនេះដែរដែលយើងខ្ញុំសូមដាក់ជូននូវរបាយការណ៍នេះ ។

## II- អាណត្តិ សមាសភាព និងកម្មវិធីការងារ

៤- នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៩៧ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តសេចក្តីសំរេចចិត្តលេខ ៥២/១៣៥ ក្រោមចំណងជើងថា "ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា" ។ សេចក្តីសំរេចចិត្តនេះ បានលើកឡើងអំពីស្ថានភាពសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា និងបានដាក់បញ្ចូលនូវវាក្យខ័ណ្ឌចំនួន ២ ដូចតទៅនេះ :

"១៥- <u>យល់ស្រប</u>ចំពោះអត្ថាធិប្បាយរបស់លោកតំណាងពិសេស ដែលថាការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងដំណាក់កាលប្រវត្តិសាស្ត្រថ្មី ៗ នេះ ត្រូវបានប្រព្រឹត្តឡើងដោយខ្មែរក្រហម និងថាឧក្រិដ្ឋកម្មរបស់ពួកគេ ក្នុងនេះរួមមានការចាប់ និងការសម្លាប់ចំណាប់ខ្មាំងផង បានបន្តធ្វើឡើងរហូតដល់ពេល បច្ចុប្បន្ននេះ ហើយកត់សំគាល់ដោយសេចក្តីព្រួយបារម្ភថា

ពុំទាន់មានមេដឹកនាំខ្មែរក្រហមណាម្នាក់ត្រូវបាន
ចាប់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មរបស់ពួកគេនេះនៅឡើយទេ ។

"១៦- ស្នំលោកអគ្គលេខាធិការពិនិត្យការស្នើសុំជំនួយរបស់អាជ្ញាធរកម្ពុជា ក្នុងការដោះស្រាយការរំលោភដ៏ធ្ងន់ធ្ងរទាំងឡាយពីអតីតកាល ទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក្នុងនេះរួមមានលទ្ធភាពនៃការតែងតាំងដោយលោកអគ្គលេខាធិការ នូវក្រុមអ្នកជំនាញការមួយក្រុម ដើម្បីធ្វើការវាយតម្លៃទៅលើភស្តុតាងទាំងឡាយដែលមានស្រាប់ និងលើកស្នើនូវវិធានការបន្ថែម ដើម្បីជាមធ្យោបាយមួយនាំមកនូវការបង្រួប បង្រួមជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការដោះស្រាយបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ។

៥- ការស្នើសុំជំនួយរបស់អាជ្ញាធរកម្ពុជានេះ បានធ្វើឡើងនៅលិខិតមួយច្បាប់ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៩៩៧ ដោយសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទីមួយកម្ពុជានាពេលនោះ និងដោយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២ នាពេលនោះ ដែលបានចែងនៅក្នុងផ្នែកមានពាក់ព័ន្ធថាៈ

"ក្នុងនាមរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា យើងខ្ញុំសរសេរមកឯកឧត្តម ដើម្បីសុំជំនួយពីសំណាក់អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិ ដើម្បីនាំខ្លួនទៅកាន់តុលាការ នូវមនុស្សទាំងឡាយដែលទទួល ខុសត្រូវក្នុងការសម្លាប់រង្គាល និងក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងរយៈពេលនៃការកាន់អំណាចរបស់ខ្មែរ ក្រហម ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។

"សេចក្តីសំរេចចិត្តខែមេសា ឆ្នាំ ១៩៩៧ ស្តីពីកម្ពុជា របស់គណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានសុំៈ

"លោកអគ្គលេខាធិការ តាមរយៈតំណាងពិសេសរបស់លោក ដោយសហការជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្ស ពិនិត្យសេចក្តីស្នើសុំជំនួយទាំងឡាយណាដើម្បីដោះស្រាយការរំលោភដ៏ធ្ងន់ធ្ងរទាំងឡាយពីអតីត

កាលទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដើម្បីជាមធ្យោបាយនាំទៅឱ្យមានការបង្រួបបង្រួមជាតិ ការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការដោះស្រាយបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ ៗ" ។

"ប្រទេសកម្ពុជាពុំមានធនធាន ឬក៏ជំនាញការ ដើម្បីដឹកនាំធ្វើកិច្ចការដ៏សំខាន់នេះទេ ។ អាស្រ័យហេតុនេះ យើងខ្ញុំយល់ឃើញថា ជាការចាំបាច់ត្រូវស្នើជំនួយពីសំណាក់អង្គការសហប្រជាជាតិ ។ យើងខ្ញុំបានដឹងថាការខិតខំបែបនេះត្រូវបានធ្វើឡើង ដើម្បីដោះស្រាយបញ្ហានៃការសម្លាប់រង្គាល និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសរ៉្វាន់ដា និងនៅក្នុងអតីតប្រទេសយូហ្គោស្លាវី ហើយមានសំណូមពរសុំឱ្យជំនួយដូចគ្នានេះត្រូវបានផ្តល់ជូនដល់ប្រទេសកម្ពុជាផងដែរ ។

"យើងខ្ញុំជឿជាក់ថា ឧក្រិដ្ឋកម្មក្នុងទ្រង់ទ្រាយធំបែបនេះ គឺជាការព្រួយបារម្ភចំពោះមនុស្សគ្រប់រូបនៅក្នុងពិភពលោក ដោយសារថាវាបានធ្វើឱ្យថមថយដល់ការគោរពសិទ្ធិមនុស្សជាមូលដ្ឋានបំផុត ពោលគឺសិទ្ធិនៃការរស់រានមានជីវិត ។ យើងខ្ញុំសង្ឃឹមថា អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិអាចជួយដល់ប្រជាពលរដ្ឋកម្ពុជា ក្នុងការស្វែងរកការពិតនារយៈពេលនោះ និងនាំខ្លួនអ្នកទទួលខុសត្រូវចំពោះអំពើទាំងនោះទៅកាន់តុលាការជាមិនខាន ។ មានតែវិធីមួយនេះទេ ដែលអាចធ្វើឱ្យសោកនាដ្យកម្មនេះអាចបានដល់ទី បញ្ចប់មួយដោយពេញលេញ និងសព្វមុខទៅបាន" ។

សេចក្តីសំរេចចិត្តរបស់គណៈកម្មការសិទ្ធិមនុស្ស លេខ ១៩៩៧/៤៩ ដែលបានអនុម័តនៅថ្ងៃទី១១ ខែមេសា ឆ្នាំ ១៩៩៧ បានធ្វើការយោងទៅលើលិខិតខាងលើនេះ ។

៦- ដោយអនុលោមទៅតាមសេចក្តីសំរេចចិត្តលេខ ៥២/១៣៥ នៅក្នុងខែកក្កដា ឆ្នាំ ១៩៩៨ លោកអគ្គលេខាធិការបានបង្កើតឡើងនូវអ្នកជំនាញការមួយក្រុមរបស់លោក ដែលមានអាណត្តិដូចតទៅនេះ :

（ក） ធ្វើការវាយតម្លៃទៅលើភស្តុតាងដែលមានស្រាប់ ក្នុងទិសដៅកំណត់នូវប្រភេទនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយមេដឹកនាំខ្មែរក្រហម នៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ ។

(ខ) ធ្វើការវាយតម្លៃ បន្ទាប់ពីបានសាកសួរយោបល់ជាមួយអជ្ញាធររដ្ឋាភិបាលមានពាក់ព័ន្ធ នូវលទ្ធភាពនៃការនាំខ្លួនមេដឹកនាំខ្មែរក្រហមទៅកាន់តុលាការ ការចាប់ខ្លួន ការឃុំខ្លួន និងការធ្វើបត្យាប័នពួកគេ ឬការសុំចុះចាញ់របស់ពួកគេចំពោះយុត្តាធិការព្រហ្មទ័ណ្ឌដែលបានបង្កើតឡើង ។

(គ) រិះរកជំរើសសំរាប់នាំខ្លួនមេដឹកនាំខ្មែរក្រហមទៅកាន់តុលាការ នៅចំពោះមុខយុត្តាធិការអន្តរ-ជាតិ ឬជាតិ ។

លោកអគ្គលេខាធិការបានតែងតាំងជាសមាជិកនៃក្រុមនេះ មានលោក នីនៀន ស្ទីហ្វិន (អូស្ត្រាលី) ជាប្រធានក្រុម លោកចៅក្រម រ៉ាហ្ស៊ីស៊ូម៉ី ឡាឡា (ម៉ូរីជូស) និងលោកសាស្ត្រាចារ្យស្ទីវិន រ៉ាណើរ (សហរដ្ឋអាមេរិក) ។ នៅក្នុងលិខិតចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៨ លោកអគ្គលេខាធិការបានជំរាបដល់ប្រធានមហាសន្និបាត ប្រធានក្រុមប្រឹក្សាសន្តិសុខ និងនាយករដ្ឋមន្ត្រីទី១ និងទី ២ នៃប្រទេសកម្ពុជា អំពីការបង្កើតក្រុមនេះ អាណត្តិរបស់ក្រុមនេះ និងសមាសភាពរបស់វា ។

៧- ការងារនៃក្រុមនេះ ត្រូវបានចែកជា ៣ ដំណាក់កាលៈ ទី ១ ការស្រាវជ្រាវខាងច្បាប់ និងប្រវត្តិសាស្ត្រ ស្តីពីបញ្ហាទាក់ទិនទៅនឹងអាណត្តិរបស់ខ្លួន ទី ២ ការសាកសួរយោបល់ និងការជួបប្រជុំជាមួយមន្ត្រីជាច្រើនប្រភេទរបស់រដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល និងទី ៣ ការពិចារណា និងការរៀបចំរបាយការណ៍នេះ ។ ការប្រមែប្រមូលការសាកសួរយោបល់ និងការប្រជុំនានា ត្រូវបានធ្វើឡើងក្នុងរយៈពេលនៃបេសកកម្មចំនួន ២ លើករបស់ក្រុមនេះៈ នៅទីចាត់ការធំរបស់អង្គការសហប្រជាជាតិ ពីថ្ងៃទី ៧ ដល់ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ១៩៩៨ នឹងនៅទីក្រុងភ្នំពេញ និងទីក្រុងបាងកក ពីថ្ងៃទី ១៤ ដល់ថ្ងៃទី ២៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ កន្លងទៅនេះ ។ បន្ថែមពីលើទៀត សមាជិកមួយរូប ១ ជាបុគ្គលនៃក្រុម បានជួបប្រជុំជាមួយមនុស្សទាំងឡាយដែលមានទស្សនៈដែលអាចកំណត់ថាមានសារៈសំខាន់ចំពោះកិច្ចការរបស់ក្រុម ហើយក្រុមនេះបានជួបប្រជុំគ្នានៅការិយាល័យធំ របស់ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស នៅទីក្រុងហ្សឺណែវ ពីថ្ងៃទី២៧ ដល់ទី២៩ ខែមករា ដើម្បីបញ្ចប់នូវអនុសាសន៍របស់ពួកគេ ។ បញ្ជីឈ្មោះមនុស្សដែលក្រុមបានជួប នឹងមានភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍នេះ ។

៨- ក្រុមសូមធ្វើការកត់សំគាល់ដោយការពេញចិត្ត នៅផ្នែកខាងដើមនៃរបាយការណ៍នេះ នូវជំនួយដ៏មានសារសំខាន់ពីសំណាក់លោក ដេវីដ អាស្លេ ដែលមាននាទីជាទីប្រឹក្សារបស់ក្រុមស្តីពីបញ្ហាកម្ពុជា និងបញ្ហាខ្មែរក្រហម ក៏ដូចជាក្នុងឋានៈជាអ្នកបកប្រែភាសានៅក្នុងការប្រជុំជាច្រើននៅក្នុងប្រទេសកម្ពុជា ការិយាល័យខាងកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ និងជាពិសេសលោកស្រី ដាហ្វណា ស្រាហ្កា មន្ត្រីថ្នាក់ខ្ពស់ខាងច្បាប់ ការិយាល័យនៃឧត្តមស្នងអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស និងជាពិសេស លោកស្រី រ៉ូហ្ស៊ីម៉ារី ម៉ាក់គ្រីរី នាយកការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា និងលោកស្រី ហាណា វូ មន្ត្រីទទួលបន្ទុកប្រទេសកម្ពុជាប្រចាំទីក្រុងហ្សឺណែវ និងចុង ក្រោយ តែមិនមែនជាទីបញ្ចប់ទេ លោក ថូម៉ាស់ ហាំម៉ាប៊ឺក តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួល បន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះជំនួយដ៏ល្អឥតខ្ចោះរបស់ពួកគេ ដល់កិច្ច ការទាំងមូលរបស់យើងខ្ញុំ ។

៩- មុននឹងបញ្ចប់សេចក្តីផ្តើមនេះ មានការកត់សំគាល់លើការបកស្រាយលើចំណុចមួយចំនួនស្តីអំពីអាណត្តិ ។ ទី ១ អាណត្តិផ្ទាល់របស់ក្រុម គឺត្រូវគិតគូរទៅលើការរំលោភសិទ្ធិមនុស្សរបស់ពួកខ្មែរក្រហមតែនៅក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ប៉ុណ្ណោះ ។ យើងខ្ញុំធ្វើការបកស្រាយនេះ គឺចង់និយាយអំពីរយៈពេលនៃការកាន់អំណាចរបស់ពួកខ្មែរក្រហម ក្នុងឋានៈជារដ្ឋាភិបាលនៃប្រទេសកម្ពុជា ឬកម្ពុជាប្រជាធិបតេយ្យ ដូចដែលគេហៅឈ្មោះរបស់គេនាពេលនោះ ពោលគឺពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ ។ ការរំលោភសិទ្ធិមនុស្សរបស់ពួកខ្មែរក្រហមនៅពេលមុន និងក្រោយរយៈពេលនេះ គឺស្ថិតនៅក្រៅវង្វង់នៃការស្រាវជ្រាវរបស់ក្រុម លើកលែងតែលុះត្រាតែវាមានការចាំបាច់ត្រូវពិភាក្សាក្នុងការដោះស្រាយបញ្ហានៃអាណត្តិសំខាន់ជាចំបងរបស់ក្រុម ។

១០- ទី ២ អាណត្តិត្រូវកំរិតព្រំដែនតែចំពោះអំពើរបស់ពួកខ្មែរក្រហមតែប៉ុណ្ណោះ និងមិនមែនជាអំពើរបស់អ្នកដ៏ទៃណាផ្សេងទៀត ឬមិនតែប៉ុណ្ណោះរបស់រដ្ឋនានាដែលអាចបានប្រព្រឹត្តអំពើរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា នៅរយៈពេលមុន នៅក្នុងរយៈពេល និងនៅក្រោយរយៈពេលនៃឆ្នាំ ១៩៧៥-១៩៧៩។ អាណត្តិនេះ គឺឈរលើមូលដ្ឋាននៃការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជាដូចដែលបានលើកឡើងខាងលើ

នេះ ។ ក្រុមបានគាំទ្រចំពោះការកំណត់ព្រំដែននេះ ដើម្បីផ្តោតអារម្មណ៍ទៅលើតែធាតុពិតដ៏អស្ចារ្យនៃឧក្រិដ្ឋកម្ម របស់ពួកខ្មែរក្រហមប៉ុណ្ណោះ ។

១១- ទី ៣ ការប្រើឈ្មោះដោយចំនៅក្នុងអាណត្តិថាយុត្តាធិការព្រហ្មទណ្ឌ មានន័យថាទិសដៅនៃរបាយការណ៍នេះ គឺជាការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើពួកមេដឹកនាំខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមានជំនឿជឿជាក់ថា អាណត្តិដែលត្រូវបានផ្តល់ឱ្យដល់យើងខ្ញុំដោយលោកអគ្គលេខាធិការនោះ គឺវាមានភាពច្បាស់លាស់ហើយនៅក្នុងសេចក្តីសំរេចចិត្តលេខ ៥២/១៣៥ ដូច្នេះក្រុមពិភាក្សាវិធីនៃការ ទទួលខុសត្រូវដ៏ទៃទៀតនៅក្នុងរបាយការណ៍នេះ ។ លើសពីនេះទៅទៀត ពាក្យពេចន៏នៅក្នុងសេចក្តី សំរេចចិត្តនោះក៏បានប្រាប់ផងដែរអំពីទស្សនៈរបស់យើង ចំពោះទិសដៅសមស្របនៃយន្តការដែលត្រូវចោទ ប្រកាន់ និងមិនត្រូវចោទប្រកាន់ ដែលជាបញ្ហាមួយដែលយើងត្រូវកក្កូរកកាយរកដោយហ្មត់ចត់ដោយលំអិត
បំផុតនៅផ្នែកខាងក្រោយនៃរបាយការណ៍នេះ ។

១២- របាយការណ៍របស់យើងនេះ គឺបានរៀបចំស្របទៅតាមអាណត្តិរបស់យើង ។ បន្ទាប់ពីធ្វើការពិភាក្សាលើប្រវត្តិនៃបញ្ហាមក របាយការណ៍បានលើកយកមកពិចារណាអំពីស្ថានភាពនៃភស្តុតាង ប្រភេទនៃឧក្រិដ្ឋដែលបានប្រព្រឹត្តលទ្ធភាពនៃការនាំយកមេដឹកនាំទៅកាន់តុលាការ និងការជ្រើសរើសមនុស្សដែលត្រូវនាំខ្លួនទៅកាន់តុលាការ ។ របាយការណ៍នឹងបញ្ចប់ដោយសេចក្តីសង្ខេបនូវអនុសាសន៏សំខាន់ ៧ របស់យើងខ្ញុំ ។

## III- ប្រវត្តិនៃព្រឹត្តិការណ៍

ការយល់ដឹងនូវបញ្ហាដ៏ច្រើនលើសលប់ដែលប្រឈមមុខនឹងក្រុមអ្នកជំនាញការទាមទារនូវប្រវត្តិខ្លះនៃប្រវត្តិសាស្ត្រនាពេលថ្មី ៗ កន្លងមកនេះនៃប្រទេសកម្ពុជា សកម្មភាពរបស់ពួកខ្មែរក្រហមក្នុងពេលនៃការគ្រប់គ្រងរបស់ពួកគេ និងអវត្តមាននៃការទទួលខុសត្រូវណាមួយរហូតមកទល់ពេលនេះចំពោះអំពើរបស់

ពួកគេ[១] ។ ទោះបីជាទិដ្ឋភាពជាច្រើននៃរយៈពេលនេះ ស្ថិតនៅជាប្រធានបទមួយនៃការច្របូកច្របល់ នៅក្នុងចំណោមមហាជន និងអ្នកស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រក៏ដោយ ក៏ទ្រង់ទ្រាយជាទូទៅនៃព្រឹត្តិការណ៍នេះ ត្រូវបានគេដឹងឮអស់ហើយ ។

ថ្ងៃទី ១៧ ខែមេសាគឺជាផ្លូវបត់ដ៏សែនរន្ធត់មួយ នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។ នៅថ្ងៃនោះ ទីក្រុងភ្នំពេញបានធ្លាក់ទៅក្នុងកណ្តាប់ដៃនៃគណបក្សកុម្មុយនិស្តកម្ពុជា (គកក) ដែលគេស្គាល់ជាទូទៅថាជាខ្មែរក្រហមនោះ ។ ការតស៊ូដោយអាវុធរបស់ពួកខ្មែរក្រហម បានចាប់ផ្តើមឡើងនៅចុងទសវត្សទី ៦០

---

[១] ការពិភាក្សាទាំងនេះត្រូវបានលើកឡើងដោយអ្នកស្រាវជ្រាវដ៏ល្បីឈ្មោះមួយចំនួន ដែលធ្វើការអំពីពួកខ្មែរក្រហមនៅក្នុងរយៈពេលនោះ លោក ដេវីដ ឆិនឡឺរ ក្រោមចំណងជើងថា សោកនាដ្យកម្មនៃប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាៈ នយោបាយ សង្គ្រាម និងបដិវត្តន៍ ចាប់តាំងពីឆ្នាំ ១៩៤៥ មក (ញូវហេវិនៈ រោងពុម្ពនៃសកលវិទ្យាល័យយេល ឆ្នាំ ១៩៩១) ខាល ហ្សាក់សុនៈ កម្ពុជា ១៩៧៥-១៩៧៨ៈ ការណាត់ជួបគ្នាជាមួយសេចក្តីស្លាប់ (ព្រីនស្តុនៈ រោងពុម្ពនៃសកលវិទ្យាល័យព្រីនស្តុន ឆ្នាំ ១៩៨៩) អេលីហ្សាបែត បេខឺៈ នៅពេល ដែលសង្គ្រាមត្រូវបានបញ្ចប់ៈ សម្លេងរបស់បដិវត្តន៍ និងប្រជាពលរដ្ឋកម្ពុជា (ញូវយ៉ក : នៃម៉ុន និងស៊ុសទឺរ ឆ្នាំ ១៩៨៦) បេន គៃរណាន់ : ប្រវត្តិសាស្ត្រមួយនៃរបបកុម្មុយនិស្តនៅកម្ពុជា (ឡុងដ៏រ៍ វែរសូ ឆ្នាំ ១៩៨៥) ណាយ៉ាន់ ចាន់ដា បងសត្រូវៈ សង្គ្រាមបន្ទាប់ ពីសង្គ្រាម (សាន ឌីយេហ្គោ ហាកួរ ប្រេស៍ ហ្សូវ៉ណូវីក) បែន គៃរណាន់ របបប៉ុល ពត (ញូវហេវ៉ិនៈ រេងពុម្ពសកលវិទ្យាល័យ) ។

ប្រភពដ៏ទៃទៀតដែលត្រូវបានប្រើក្នុងការពិភាក្សាគ្នានេះមានៈ ផ្នែកស្រាវជ្រាវសហព័ន្ធ បណ្ណាល័យរបស់សភា កម្ពុជាៈ ការសិក្សាប្រទេសមួយ (បោះពុម្ពដោយរោងពុម្ព វ៉ែសែលរ៉ូស) (វ៉ាស៊ីនតោនៈការិយាល័យបោះពុម្ពរដ្ឋាភិបាលសហរដ្ឋអាមេរិក(ឆ្នាំ ១៩៩០) វីលីយ៉ាំ សាវក្រូសៈ សាយសួរៈ គីស៊ីងហ្គឺរ នីកសិន និងការកំទេចប្រទេសកម្ពុជា (ការបោះពុម្ព ដោយពិនិត្យឡើងវិញ) (ញ៉ូវយ៉កៈ សាយម៉ុន និងសិស្ទ័រ ឆ្នាំ ១៩៨៧) ហ្វ្រង់ស្វា ប៉ុងសូ កម្ពុជាៈ ឆ្នាំសូន្យ (បកប្រែដោយ ណាន់ស៊ី អំហ្វូស) (ញ៉ូវយ៉ក ហុល វ៉ានហាត និងវិនស្តុន ឆ្នាំ ១៩៧៨) បេន គៃណាន់ "ការសម្លាប់រង្គាលនៅកម្ពុជាៈ បញ្ហា និងចម្លើយ " ក្នុងការបោះពុម្ពផ្សាយដោយ ហ្សិក អង់ឌ្រេអ្រូប៉ូលូស ការសម្លាប់រង្គាលៈ ទំហំជាទស្សនៈ និងជាប្រវត្តិសាស្ត្រ ១៩១ (ហ្វីឡាដែលហ្វា : បោះពុម្ពដោយសកលវិទ្យាល័យផិនសីលវ៉ានីញ៉ា ឆ្នាំ ១៩៩៤) ដេវីដ ហ៊ក "សិទ្ធិមនុស្សអន្តរជាតិ និងកម្ពុជាប្រជាធិបតេយ្យ "១៦ សារពិតមាននយោបាយអន្តរជាតិ ៣ (ឆ្នាំ ១៩៨៦) ហាំង ង៉ោ រឿងព្រេងកម្ពុជាមួយ (ញ៉ូវយ៉កៈ វ៉ារន័រប៊ុក ឆ្នាំ ១៩៨៧) ហ៊ឹក ហាននុម "ច្បាប់អន្តរជាតិ និងការសម្លាប់រង្គាលនៅកម្ពុជា : សម្លេងនៃការស្ងាត់ស្ងៀម" ១១ សិទ្ធិមនុស្សចេញផ្សាយរាលក់ឆមាស ៨២ (ឆ្នាំ ១៩៨៩) បេន គៃណាន់ កម្ពុជាៈ ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា (ញ៉ូវយ៉កៈ មជ្ឈមណ្ឌលសំរាប់សិក្សាសិទ្ធិមនុស្ស សាកលវិទ្យាល័យកូឡុំប៊ីយ៉ា ឆ្នាំ ១៩៨៦) ស្ទីវ៉ុន រ៉ាត់ណឺរ "កិច្ចព្រមព្រៀងដោះស្រាយបញ្ហាកម្ពុជា" ៨៧ ទិន្នានុប្បវត្តិអាមេរិកនៃច្បាប់អន្តរជាតិ I (ឆ្នាំ ១៩៩៣) ស្ទីវ៉ុន រ៉ាត់ណឺរ កាថែរក្សាសន្តិភាពថ្មីរបស់អង្គការសហប្រជាជាតិៈ ការស្ថាបនាសន្តិភាព នៅលើទឹកដីដែលមានជម្លោះ បន្ទាប់ពីសង្គ្រាមត្រជាក់ ១៩៧-២០៦ (ញ៉ូវយ៉កៈ រោងពុម្ពម៉ាទីន ឆ្នាំ ១៩៩៥) ។

ហើយបានបង្កើនល្បឿនបន្ទាប់ពីរដ្ឋប្រហារទម្លាក់ប្រមុខរដ្ឋ គឺសម្តេច នរោត្តម សីហនុ នាថ្ងៃទី ១៨ ខែមីនា ឆ្នាំ ១៩៧០ ហើយដាក់ជំនួសលោកដោយរបបថ្មីមួយ ដែលមានឈ្មោះថាសាធារណរដ្ឋខ្មែរ ។ ដោយឆ្លៀតយកចំណេញពីប្រជាប្រិយភាពរបស់សម្តេច សីហនុ (ដែលនៅពេលក្រោយមក ពួកខ្មែរក្រហមបានដាក់ឃុំរូបលោកនៅក្នុងព្រះបរមរាជវាំង នៅពេលពួកគេឡើងកាន់អំណាច) និងដោយមានការគាំទ្រពីសំណាក់បរទេសផងនោះ ចលនានេះបានដណ្តើមកាន់កាប់បាននូវទឹកដីដ៏ធំទូលាយ ។ ជាមួយនឹងការដកថយ និងការបំបាត់ជាយថាហេតុនៅក្នុងឆ្នាំ ១៩៧៥ នូវជំនួយរបស់សហរដ្ឋអាមេរិកដល់សាធារណរដ្ឋខ្មែរ នោះ ពួកខ្មែរក្រហមបានដណ្តើមបានជ័យជំនះ ។

## ក- ទស្សនៈវិជ្ជា និងរចនាសម្ព័ន្ធរបស់ពួកខ្មែរក្រហម

១៥- អំពើឃោរឃៅដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ជាទូទៅ មិនមែនជាអំពើដែលធ្វើឡើងដោយឡែកដោយមន្ត្រីក្នុងឋានៈជាបុគ្គលណាមួយនោះទេ តែផ្ទុយទៅវិញវាជាលទ្ធផលនៃនយោបាយដោយចេតនារបស់គណបក្សកុម្មុយនិសកម្ពុជា ។ គណបក្សកុម្មុយនិសកម្ពុជាបានប្រកាសជ័យជំនះរបស់ខ្លួន ដោយបញ្ចប់នូវរយៈពេល ២ ០០០ ឆ្នាំ នៃការដែលកសិករខ្មែរស្ថិតនៅក្រោមការជិះជាន់របស់សត្រូវបរទេស និងសត្រូវវណ្ណៈ ។ ក៏ប៉ុន្តែ ពួកគេនៅតែបន្តមើលឃើញសត្រូវទាំងនេះ ថាជាការគំរាមកំហែងយ៉ាងជ្រៅនៅក្នុងសង្គមរបស់គេ និងស្រមើស្រមៃចង់បាន "ឯករាជ្យភាពមួយដោយពេញលេញ" និងភាពដូចគ្នាខាងសង្គម និងខាងជាតិពន្ធនៃប្រទេសកម្ពុជា ។

១៦- ដើម្បីទប់ទល់នឹងការគំរាមកំហែងដែលគេបានកំណត់ច្បាស់ហើយនេះ និងដើម្បីកសាង "ប្រព័ន្ធសង្គមដ៏ស្អាតស្អំ" [២] របបនេះបានវាយសំរុកទៅតែលើបដិវត្តន៍ដ៏ជ្រាលជ្រៅតែមួយមុខប៉ុណ្ណោះ ដោយកំទេចចោលស្ថាប័នសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលមានស្រាប់ទាំងអស់ ឥទ្ធិពលបរទេសទាំងអស់ត្រូវបានកំទេចចោល ហើយប្រជាជនត្រូវបានប្រែក្លាយឱ្យទៅជាកម្លាំងការងាររួមទាំងអស់គ្នា តម្រូវឱ្យធ្វើការដោយល្បឿនលឿន

---

[២] សេវាប្រព័ន្ធផ្សព្វផ្សាយពិតមានបរទេស ថ្ងៃទី ៩ ខែឧសភា ឆ្នាំ ១៩៧៥ នៅ HI ដកស្រង់ដោយ ហ្សាក់សុន "មនោគមវិជ្ជានៃបដិវត្តន៍ទាំងស្រុង" (The Ideology of Total Revolution) នៅក្នុង កម្ពុជា: ១៩៧៥-១៩៧៨ ដូចបានលើកឡើងខាងលើ ចំណុច ៣៧ ៦៧ ។

ដើម្បីកសាងឡើងនូវសេដ្ឋកិច្ចប្រទេសដ៏ខ្លាំងក្លាមួយ ។ ព្រមពេលជាមួយគ្នានេះ របបនេះបានប្រព្រឹត្តយ៉ាងធ្ងន់ធ្ងរប្រឆាំងទៅលើមនុស្សទាំងអស់ដែលសង្ស័យថាជាសត្រូវនឹងរបបថ្មីរបស់ពួកគេ ។ មនុស្សទាំងនេះរួមមានអ្នកដែលមានខ្សែរយៈទាក់ទងជាមួយបរទេស ក្នុងនោះរួមមានប្រទេសវៀតណាម ដែលពួកអ្នកជាតិនិយមប្រកាន់ខ្សែតឹងនៃគណបក្សកុម្មុយនិសកម្ពុជា - ដូចជារបបកម្ពុជាមុន ៗ ដែរ - ដោយខ្លាចពួកទាំងនោះដណ្តើមកាន់កាប់កម្ពុជាឡើងវិញ ។ គណបក្សកុម្មុយនិសកម្ពុជា បានលាក់ខ្លួន ដោយប្រើឈ្មោះ <u>អង្គការបដិវត្តន៍</u> ឬ "អង្គការបដិវត្តន៍" រហូតដល់ខែកញ្ញា ឆ្នាំ ១៩៧៧ ហើយលុះត្រាតែរហូតដល់ខែមេសា ១៩៧៦ ប៉ុណ្ណោះទេ ដែលរដ្ឋធម្មនុញ្ញថ្មី និងអង្គការរដ្ឋផ្សេងៗ ថ្មី ត្រូវបានប្រកាសឡើង ហើយប្រទេសត្រូវដាក់ឈ្មោះថ្មីថា កម្ពុជាប្រជាធិបតេយ្យ ។

១៧- ដើម្បីអនុវត្តការត្រួតត្រាលើប្រទេសជាតិ គណបក្សកម្មុយនិស្តកម្ពុជា បានបែងចែកប្រទេសជាភូមិភាគផ្សេង ៗ ដែលមានចំនួនទាំងអស់ ៧ នៅក្នុងឆ្នាំ ១៩៧៨ ហើយភូមិភាគទាំងនេះត្រូវបានចែកជា ៣២ តំបន់ ។ នៅក្រោមតំបន់មានចែកចេញជាស្រុក ឃុំ និងសហករណ៍ ។ ប្រជាពលរដ្ឋម្នាក់ ៗ បានត្រូវបានបញ្ចូលទៅក្នុងអង្គភាពរដ្ឋបាល ឬការងារមួយ ដឹកនាំដោយគណៈកម្មាធិការមួយដែលបានចាត់តាំងឡើងដោយគណបក្សកុម្មុយនិស្តកម្ពុជា ដោយប្រជាពលរដ្ឋស្ទើរតែទាំងអស់ត្រូវបានរៀបចំឱ្យនៅក្នុងសហករណ៍កសិកម្ម។ មជ្ឈមណ្ឌលភ្នំពេញ ដឹកនាំនយោបាយតាមរយៈការណែនាំជាច្រើនទៅកាន់មន្ត្រីតំបន់ និងមូលដ្ឋាន។ អ្វីដែលជាការគួរឱ្យកត់សំគាល់បំផុតនោះ គឺថាសេចក្តីណែនាំទាំងនេះបានកំណត់អំពីនយោបាយសេដ្ឋកិច្ចជាមូលដ្ឋាន របស់ប្រទេស និងបានបញ្ជាឱ្យធ្វើការបោសសំអាតនូវកត្តាទាំងឡាយដែលយល់ថាជាការប្រឆាំងនឹងបដិវត្តន៍ ដែលជាលក្ខណៈរបស់កម្ពុជាប្រជាធិបតេយ្យ ។ នៅក្នុងពេលជាមួយគ្នានេះ មជ្ឈឹមមិនបានត្រួតត្រាដោយផ្ទាល់នូវការងាររបស់សហករណ៍ជាច្រើននោះ ហើយអ្នកប្រវត្តិសាស្រ្តជាច្រើននាក់មានទស្សនៈខុសគ្នាអំពីកំរិតនៃការត្រួតត្រាពិតប្រាកដរបស់មជ្ឈឹម ។ កាលណាភ្នំពេញដឹងថាមានកម្មាភិបាលណា មិនបានអនុវត្តន៍ការណែនាំរបស់គេទេ ឬក៏ថានយោបាយទាំងនោះត្រូវបរាជ័យមិនអាចកែបាននូវបញ្ហា របស់ ប្រទេសជាតិទេនោះ (ជាពិសេសបំផុតនោះគឺលើបញ្ហាផលិតកម្មស្បៀង) គេឆ្លើយតបដោយធ្វើការបោសសំអាតមន្ត្រីផ្ទាល់របស់គេរាប់ពាន់នាក់តែម្តង ។

## ខ- រូបភាពនៃការរំលោភ

១៨- ដំណាក់កាលនៃការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ ត្រូវបានកំណត់ដោយការរំលោភសិទ្ធិមនុស្សជាបុគ្គល និងជាក្រុម ៗ ក្នុងទ្រង់ទ្រាយមួយដ៏ធំមហិមា និងយ៉ាងសាហាវ ។ សំរាប់ជាទិសដៅនៃរបាយការណ៍នេះ យើងប្រមូលផ្តុំការរំលោភទាំងនោះជា ៤ ប្រភេទ ។

### ១- ការធ្វើការផ្លាស់ប្តូរទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋដោយបង្ខំ

១៩- អាទិភាពទី ១ នៃការដឹកនាំថ្មីចាប់តាំងពីបានឡើងកាន់កាប់អំណាចមក គឺការជន្លៀសប្រជាពលរដ្ឋចេញពីទីក្រុង និងទីប្រជុំជន នៃប្រទេសកម្ពុជា ។ នៅក្នុងអាទិត្យបន្ទាប់ពីការទទួលបានជ័យជំនះរបស់ពួកគេ រដ្ឋាភិបាលបានបង្ខំប្រជាពលរដ្ឋពី ២ ទៅ ៣ លាននាក់ឱ្យចេញពីតំបន់ទាំងនេះ ឱ្យទៅនៅតាមជនបទដោយ មិនគិតពីមនុស្សចាស់ មនុស្សមានជម្ងឺ ឬក្មេងតូច ៗ ឡើយ ។ ពួកអ្នកដឹកនាំមើលឃើញទីក្រុងថាជាកន្លែង
បង្កាត់ពូជនៃអ្នកដែលគំរាមកំហែងដល់ទស្សនៈវិស័យនៃកម្ពុជារបស់ពួកគេ - បុគ្គលិកស៊ីវិល និងយោធា នៃសាធារណរដ្ឋខ្មែរ អ្នកមានសមានចិត្តចំពោះជនបរទេស (ជាពិសេសពួកបច្ចឹមប្រទេស) ពួកមនុស្សវណ្ណៈកណ្តាល បញ្ញាវ័ន្ត និងគ្រូបង្រៀន និងពួកអ្នកប្រកបវិជ្ជាជីវៈផ្សេងទៀត ។ ការបោសសំអាតប្រជាពលរដ្ឋចេញពីទីក្រុង - ដោយហៅថា "ប្រជាជនថ្មី" - គឺមានទិសដៅរំលាយអំណាចរបស់ពួកអ្នកដែលគេមើលឃើញថាជាជាពួកប្រឆាំងបដិវត្តន៍ និងលើសពីនេះទៅទៀតសំរេចផែនការរបស់រដ្ឋាភិបាលក្នុងការបង្កើតសង្គមមួយដោយផ្អែកជាសំខាន់លើសហគមន៍កសិកម្ម ។

២០- ការជន្លៀសប្រជាពលរដ្ឋចេញពីភ្នំពេញ គឺជាឧទាហរណ៍ដ៏សែនសោកសៅប៉ុណ្ណោះ ។ ពួកទាហានរបស់ខ្មែរក្រហមបានសំអាតរាជធានីយ៉ាងឆាប់រហ័សបំផុត ដែលពោរពេញទៅដោយមនុស្សប្រមាណ ២ លាននាក់ បណ្តាលមកពីការហូរចូលនៃជនភៀសសឹកក្នុងពេលសង្គ្រាម ។ គេជឿជាក់ថាមានមនុស្សរាប់ពាន់នាក់ពិសេសក្នុងចំណោមមនុស្សចាស់ និងកូនក្មេង បានស្លាប់នៅពេលនោះដោយសារការខ្វះអាហារ ទឹក និងជំនួយផ្នែកពេទ្យ នៅក្នុងពេលដែលត្រូវបានបង្ខំឱ្យដើរទៅកាន់តំបន់ជនបទ ។ សាក្សីទាំងឡាយបានរាយការណ៍ថា

មានករណីច្រើនណាស់ដែលអ្នកជម្ងឺក្នុងពេទ្យត្រូវបានអូសចេញពីលើគ្រែ និងស្លាប់នៅតាមផ្លូវនៅខាងក្រៅទីក្រុង ។ នៅទីបញ្ចប់នៃការជន្លៀសនេះ នៅក្នុងទីក្រុងនៅសល់មនុស្សតែប្រមាណ ២ ០០០ នាក់ប៉ុណ្ណោះ ។

២១- ប៉ុន្តែ ការជន្លៀសនាខែមេសានេះ មិនមែនជាការកើតឡើងតែម្តងទេ ។ ពួកខ្មែរក្រហមបានបង្ខំឱ្យមនុស្សផ្លាស់ប្តូរទីកន្លែងពីភូមិមួយទៅភូមិមួយទៀត ពីភូមិភាគមួយទៅភូមិភាគមួយទៀត នៅក្នុងរយៈពេលនៃការកាន់អំណាចរបស់ពួកគេ ។

## ២- ការបង្ខំឱ្យធ្វើការងារធ្ងន់ និងលក្ខណៈរស់នៅដោយអមនុស្សធម៌

២២- ប្រព័ន្ធសេដ្ឋកិច្ចដែលត្រូវអនុវត្តន៍នៅទូទាំងប្រទេស ដោយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គឺឈរលើការបង្ខំឱ្យធ្វើការងារធ្ងន់ ។ អតីតអ្នករស់នៅក្នុងទីក្រុង បានចូលទៅរស់នៅជាមួយប្រជាពលរដ្ឋជនបទក្នុងសហករណ៍កសិកម្ម ដែលនៅទីចុងបញ្ចប់នៃរបបនេះ សហករណ៍និមួយ ៗ មានទំហំជាស្រុកតែម្តង ។ ជនកម្ពុជាទាំងឡាយត្រូវបញ្ចូលឱ្យទៅនៅក្នុងក្រុមការងារ ដែលជាទូទៅត្រូវស្ថិតនៅក្រោមការត្រួតត្រាដោយអាវុធ ហើយត្រូវបានបង្ខំឱ្យធ្វើស្រែ និងដាំដំណាំផ្សេងទៀត ឬធ្វើការសាងសង់គំរោងរចនាសម្ព័ន្ធដែលមានទ្រង់ទ្រាយធំ ៗ ។ ពេលម៉ោងធ្វើការមានរយៈពេលវែង ជាទូទៅចាប់ផ្តើមនៅមុនថ្ងៃរះ និងបន្តរហូតដល់យប់ ហើយក្នុងមួយអាទិត្យធ្វើការ ៧ ថ្ងៃ របបអាហារដែលផ្តល់ឱ្យតិចតួចស្តួចស្តើងណាស់ ដោយប្រទេសមានការខ្វះខាតស្បៀងអាហារ ។ ការងារមានលក្ខណៈធ្ងន់ធ្ងរណាស់សំរាប់អ្នកទីក្រុងដែលមិនដែលធ្លាប់ជួបប្រទះសោះនឹងជីវភាពជាកសិករនេះ ។ កម្មសិទ្ធិឯកជន និងលុយកាក់ ត្រូវបាត់រូបរាងជាស្ថាប័នហើយ ។ ការប៉ុនប៉ងដើម្បីស្វែងរកអាហារបន្ថែម ឬថ្នាំពេទ្យ ត្រូវហាមឃាត់ ។ ពួកខ្មែរក្រហមបានរៀបចំឱ្យមានជីវភាពរួម ក្នុងទិសដៅបំបាត់ដានរចនាសម្ព័ន្ធគ្រួសារជាប្រពៃណី ។ បាយសម្លត្រូវចំអិន និងបរិភោគជារួម ពោលគឺមិនមែនធ្វើជាក្រុមគ្រួសារទេ ហើយកុមារត្រូវបានបំបែកចេញពីគ្រួសាររបស់គេ ហើយបង្ខំឱ្យរាយការណ៍អំពីសាច់ញាតិណាដែល "ខ្លួនមានការសង្ស័យ" ។ ការរៀបអាពាហ៍ពិពាហ៍ ទាមទារឱ្យមានការយល់ព្រមពីអាជ្ញាធរបក្ស ការទាក់ទងផ្លូវភេទដោយលួចលាក់ អាចត្រូវទទួលទោសដល់ជីវិតទាំង ២ នាក់ ។

២៣- ទុក្ខវេទនាបណ្តាលមកពីវិធីដែលបានប្រើប្រាស់ដោយពួកខ្មែរក្រហម ក្នុងការអនុវត្តនីនយោបាយកែរបបសេដ្ឋកិច្ចកម្ពុជា គឺជាប្រភពដ៏ធំធេងតែមួយគត់នៃការស្លាប់នៅដំណាក់កាលនៃខ្មែរក្រហមកាន់អំណាច ។ ការអត់ឃ្លាន ជម្ងឺដំកាត់ និងការបាក់កម្លាំងកាយ បណ្តាលមកពីការធ្វើការហួសកម្លាំង និងម្ហូបអាហារ ថ្នាំពេទ្យ និងអានាម័យមិនគ្រប់គ្រាន់ បានសម្លាប់ជីវិតមនុស្សរាប់រយពាន់នាក់ ។ យោងតាមសេចក្តីរាយការណ៍របស់សាក្សី ពួកអ្នកត្រួតត្រាជាខ្មែរក្រហមបានសម្លាប់មនុស្សជារៀងរាល់ថ្ងៃអស់ជាច្រើនពាន់នាក់ ចំពោះអ្នកដែលជំទាស់ ឬមិនអាចធ្វើការតទៅទៀតបាន ហើយជាញឹកញយពួកវាសម្លាប់ទាំងសមាជិកគ្រួសាររបស់ពួកគេទៀតផង ។

## ៣- ការវាយកំទេចខ្មាំងបដិវត្តន៍

២៤- ក្រៅពីការស្លាប់ជាច្រើនបណ្តាលមកពីការផ្លាស់ប្តូរទីកន្លែងរបស់ប្រជាពលរដ្ឋ និងការធ្វើកម្មុយនិស្តភាវូបនីយកម្មដោយបង្ខំរបស់ពួកខ្មែរក្រហមចេញ របបនេះក៏មានទិសដៅកំទេចក្រុមដ៏ទៃទៀតខ្លះដែរ ដោយប្រវត្តិនៃនិន្នាការនយោបាយ ឬសង្គម ឬជាតិព័ន្ធរបស់ពួកគេ ។ ដោយមិនចាំបាច់ត្រូវការឱ្យមានប្រព័ន្ធតុលាការជាផ្លូវការណាមួយ ក្នុងការជាក់ស្តែង អង្គភាពនិមួយ ៗ នៃរបបនេះហាក់ដូចជាមានសិទ្ធិ ឬរហូតដល់មានភារកិច្ច ដើម្បីស្វែងរក ឃុំខ្លួន និងសម្លាប់អ្នកដែលពួកគេយល់ថាជាសត្រូវរបស់ពួកគេ ។ ក្នុងចំណោមប្រភេទទាំងនេះនៃសង្គម ដែលត្រូវចាត់ថាត្រូវមានការសង្ស័យជាពិសេសនោះមានដូចតទៅ:

២៥- <u>មន្ត្រីទាំងឡាយនៃរបបមុន</u> ។ អតីតមេដឹកនាំរដ្ឋាភិបាល នាយទាហាន និងរដ្ឋការរបស់សាធារណរដ្ឋខ្មែរ គឺជាទិសដៅនៃការត្រូវសម្លាប់ចោលភ្លាម ។ ក្នុងរយៈប៉ុន្មានខែដំបូងនៃរបបនេះ មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ក្រៅច្បាប់ ជាបុគ្គលដោយឡែក ឬជាក្រុម ៗ ។ មនុស្សជាច្រើននាក់ត្រូវសម្លាប់នៅឆ្ងាយពីភ្នែកមហាជន ដោយវាយនឹងដំបង ឬបាញ់នៅកន្លែងដាច់ឆ្ងាយពីគេឯង មនុស្សខ្លះទៀតត្រូវសម្លាប់នៅចំពោះមុខគ្រួសាររបស់គេតែម្តង ។ រហូតដល់ឆ្នាំ ១៩៧៧ ការបោសសំអាតនេះ ត្រូវពង្រីករហូតដល់អ្នកមានឋានៈទាបបំផុតនៃកងទ័ពសាធារណរដ្ឋខ្មែរ ព្រមទាំងសាច់ញាតិ និងមិត្តភក្តិរបស់ពួកគេទៀតផង ។

២៦- <u>ជនជាតិភាគតិច</u> ។ ទន្ទឹមនឹងការហាមជាទូទៅមិនឱ្យមានជំនឿខាងសាសនា និងវប្បធម៌ណាមួយក្រៅពីគំរូបដិវត្តន៍នោះ ពួកខ្មែរក្រហមមានទិសដៅបង្ខំឱ្យជនជាតិភាគតិចឱ្យរស់នៅលាយឡំជាមួយគេឯងជាទូទៅ ឬអាក្រក់ជាងនេះទៅទៀត ។ ជនជាតិចាម ដែលជានិកាយមួយនៅក្នុងប្រទេសកម្ពុជាតាំងពី ៥០០ ឆ្នាំមកហើយនោះ ក៏ត្រូវបង្ខំឱ្យរស់នៅបែកគ្នា ភាសា និងទំនៀមទម្លាប់របស់ពួកគេក៏ត្រូវហាមឃាត់មិនឱ្យមានតទៅទៀត ហើយអ្នកដឹកនាំរបស់ពួកគេ និងអ្នកដទៃទៀតដែលប្រឆាំងនឹងនយោបាយរបស់រដ្ឋាភិបាលត្រូវបានសម្លាប់ចោល ។ ជនជាតិចិន ដែលត្រូវបានគេឃើញថាមានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងសេដ្ឋកិច្ចនាយទុននៅក្នុងទីក្រុង ពេលខ្លះត្រូវបានប្រឈមមុខនឹងការរើសអើងជាពិសេស ។ វាសនាដ៏អាក្រក់បំផុតបានកើតមានឡើងចំពោះជនជាតិវៀតណាម ដែលធ្លាប់បានរស់នៅនៅក្នុងប្រទេសកម្ពុជាតាំងពីច្រើនជំនាន់មកហើយ ហើយបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ។ ភាគច្រើននៃពួកគេត្រូវបានបណ្ដេញចេញនៅក្នុងឆ្នាំ ១៩៧៥ ។ នៅឆ្នាំ ១៩៧៧ នៅពេលចាប់ផ្ដើមមានការប្រយុទ្ធគ្នាដោយទ្រង់ទ្រាយធំជាមួយវៀតណាម របបខ្មែរក្រហមបានចាប់ផ្ដើមសម្លាប់ជនជាតិវៀតណាមដែលមាននៅសេសសល់បន្តិចបន្តួចនៅក្នុងប្រទេស ។

២៧- <u>គ្រូបង្រៀន និស្សិត និងអ្នកធ្លាប់បានទទួលការអប់រំដទៃទៀត</u> ។ របបបានកំណត់ថាផ្នែកប្រជាពលរដ្ឋដែលបានទទួលការអប់រំ ថាជាផ្នែកមួយនៃវណ្ណៈពុករលួយ ដែលបានធ្វើឱ្យប្រទេសកម្ពុជាជាអាយ៉ងនៃឥទ្ធិពលមកពីខាងក្រៅ និងបានគៃប្រវ័ញ្ចទៅលើកសិករក្រ ហើយដោយហេតុនេះ ពួកគេគឺជាពួកប្រឆាំងបដិវត្តន៍ជាសក្ដានុពល ។ នៅពេលដែលមនុស្សរាប់ពាន់នាក់បានស្លាប់រួមគ្នាជាមួយអ្នកដទៃទៀតនោះ អ្នកផ្សេងទៀតក៏ត្រូវជាទិសដៅនៃការដែលត្រូវយកទៅសម្លាប់ចោលដែរ ។ នៅពេលដែលពួកគេរកឃើញតាមរយៈប្រើល្បិច ឬវិធីផ្សេងទៀត នូវមនុស្សដែលធ្លាប់ជាគ្រូបង្រៀន សិស្សវិទ្យាល័យ និងអ្នកប្រកបវិជ្ជាជីវៈផ្សេង ៗ នោះ ជាទូទៅពួកនេះត្រូវសម្លាប់ចោល ។ ជនជាតិខ្មែរណាដែលចេះនិយាយភាសាបរទេស ឬដែលមានការទាក់ទងជាមួយបរទេស ត្រូវបានកំណត់ថាជាភ្នាក់ងារសម្ងាត់ ហើយក៏ត្រូវសម្លាប់ចោលដែរ ។ យ៉ាងណាក៏ដោយ ការរស់នៅលាយឡំគ្នាដោយជនជាតិច្រើនសាសន៍នៅក្នុងទីក្រុងនានានៃប្រទេសកម្ពុជានោះ ត្រូវរលប់បាត់អស់ទៅហើយនៅក្នុងរយៈពេលជាង ៣ ឆ្នាំក្រោយមក ។

២៨- អ្នកដឹកនាំ និងស្ថាប័នសាសនា ។ ដើម្បីផ្តល់វាំលរំលំរចនាសម្ព័ន្ធសង្គមខ្មែរ រដ្ឋាភិបាលក៏បានតម្រង់ចក្ខុវិស័យទៅលើសាសនាដែលមានការរៀបរយផងដែរ ក្នុងនេះរួមមានព្រះពុទ្ធសាសនា ដែលជាសាសនារបស់ខ្មែរភាគច្រើនលើសលប់នោះ ។ របបបានបង្ខំឱ្យព្រះសង្ឃលាចាកសិក្ខាបទ ហើយសម្លាប់ចោលលោកណាដែលជំទាស់មិនព្រមសឹក ។ របបបានកំទេចចោលព្រះវិហារព្រះពុទ្ធសាសនាជាច្រើន និងបានប្រែក្លាយព្រះវិហារខ្លះទៅជាឃ្លាំងផ្ទុកសម្ភារៈ ឬរហូតដល់យកទៅធ្វើជាគុកថែមទៀត កំទេចបំបាត់ដានវត្ថុ និងអត្ថបទជាទីសក្ការៈទាំងឡាយ នៅក្នុងកិច្ចដំណើរការនេះ ។ ជាលទ្ធផល ទីវត្តអារាមដែលមានការរៀបរយទាំងអស់នៅក្នុងប្រទេសត្រូវបានបែកខ្ញែកខ្ទេចខ្ទីអស់រលីង ។ រដ្ឋាភិបាលក៏បានកំទេចចោលនូវវិហារសាសនាអ៊ីស្លាម និងវិហារសាសនាកាតូលិកអស់ជាច្រើនរយផងដែរ ។

## ៤- ការបោសសំអាតផ្ទៃក្នុងគណបក្ស

២៩- ការដែលចេះតែមានការសង្ស័យមិនទុកចិត្តទៅលើអ្នកណាទាំងអស់ នៃរបបខ្មែរក្រហម បានបង្ហាញឱ្យឃើញដោយខ្លួនឯងយ៉ាងច្បាស់បំផុត នៅក្នុងការដែលពួកគេប្រព្រឹត្តទៅលើកម្មាភិបាលផ្ទាល់របស់ពួកគេ។ នៅក្នុងការចាប់ផ្តើមធ្វើការបោសសំអាតដ៏រាលដាលមិនធ្លាប់ដែលមានពីមុនមកមួយ នាចុងឆ្នាំ ១៩៧៦ និងបន្តរហូតដល់ពេលដួលរលំនៃរបបនោះ គឺពួកមេដឹកនាំស្វែងរកសត្រូវនៅក្នុងបក្សរបស់ខ្លួន ដោយចោទប្រកាន់ ពួកគេថាជាភ្នាក់ងារសេអ៊ីអា កាហ្សេបេ ឬភ្នាក់ងាររបស់វៀតណាម ។ កិច្ចដំណើរការនេះ បានពាក់ព័ន្ធមិនត្រឹមតែជាមួយនឹងការសម្លាប់បុគ្គលទាំងឡាយដែលសង្ស័យនៅក្នុងចំណោមអ្នកដឹកនាំនៃអង្គភាពនិមួយ ៗ ប៉ុណ្ណោះនោះទេ (រួមមានសមាជិកជាច្រើននាក់នៃរដ្ឋាភិបាល និងរបស់គណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនិស្តកម្ពុជា) តែវាក៏បានកើតមានឡើងជាទូទៅផងដែរ នូវការចាប់ខ្លួន និងការសម្លាប់ចំពោះកម្មាភិបាលរបស់បក្សទាំងអស់នៅក្នុងអង្គភាពណាមួយដែលត្រូវបានកំណត់ថាក្បត់ ដូចជាតំបន់ពិសេស ឬកងពលណាមួយ ។

៣០- ការប៉ុនប៉ងធ្វើការបោសសំអាតនេះមួយនៅភូមិភាគបូ៌ា កាលពីខែឧសភា ឆ្នាំ ១៩៧៨ បានបណ្តាលឱ្យមានការបះបោរនៅក្នុងមូលដ្ឋានដោយទ្រង់ទ្រាយធំបំផុតជាច្រើនលើកច្រើនសា នៅក្នុងរយៈពេលនៃរបបនេះ ។ ពួកយោធានៅភូមិភាគបូព៌ា ដែលស្ថិតនៅជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម បានងើបឡើង

ប្រឆាំងរដ្ឋធានី ដែលនាំទៅឱ្យមានការប្រយុទ្ធគ្នាចាប់ពីខែមិថុនា រហូតដល់ខែកញ្ញា ឆ្នាំ ១៩៧៨ ។ ការប្រយុទ្ធគ្នាមានលក្ខណៈរំលោភសិទ្ធិមនុស្សយ៉ាងខ្លាំង ពីសំណាក់កងកម្លាំងរបស់រដ្ឋាភិបាល ដោយបានសម្លាប់ប្រជាពលរដ្ឋនៅក្នុងតំបន់យ៉ាងតិចណាស់ ១០០ ០០០ នាក់ ដែលភាគច្រើនគឺជាជនស៊ីវិលនៅក្នុងតំបន់ ដោយពួកគេមើលឃើញ "សាកសពខ្មែរទាំងនេះ ជាជនវៀតណាមនៅក្នុងអារម្មណ៍របស់ពួកគេ" [៣] ។ កម្មាភិបាលរបស់បក្ស ក្រុមគ្រួសាររបស់ពួកគេ និងអ្នកភូមិនានា ត្រូវបានរំលាយចោល ។ មនុស្សរាប់រយពាន់នាក់ផ្សេងទៀតត្រូវបានជន្លៀសពីឧត្តរ ទៅបស្ចឹម ដែលនៅទីនោះពួកគេបានស្លាប់ ដោយសារការខ្វះស្បៀង និងដោយជម្ងឺ ឬត្រូវបានសម្លាប់នៅពេលក្រោយមកទៀត ។

៣១ នៅពេលនោះ ហាក់ដូចជាមានប្រព័ន្ធពន្ធនាគារមួយត្រូវបានដាក់ឱ្យមាននៅទូទាំងប្រទេស ឬក៏យ៉ាងហោចណាស់នៅត្រឹមថ្នាក់ស្រុក ។ មជ្ឈមណ្ឌលឃុំឃាំង និងសួរចម្លើយ ត្រូវបានបង្កើតឡើងឱ្យស្ថិតនៅក្រោមការដឹកនាំរបស់ក្រសួងសន្តិសុខ ឈ្មោះថា ស-២១ នៅក្នុងអតីតសាលារៀនមួយនៅទួលស្លែង ក្នុងទីក្រុងភ្នំពេញ ។ អ្នកដែលត្រូវជាប់ឃុំនៅទីនោះ បានត្រូវសួរចម្លើយដូច ៗ គ្នា ទទួលរងទារុណកម្មយ៉ាងឃោរឃៅបំផុត ហើយក្រោយមកត្រូវបានសម្លាប់ចោលតែម្តង ។ ចាប់តាំងពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨ មនុស្សដែលត្រូវសង្ស័យថាជាខ្មាំងចំនួនប្រមាណ ២០ ០០០ នាក់ ភាគច្រើនបំផុតជាកម្មាភិបាលរបស់បក្ស និងក្រុមគ្រួសាររបស់ពួកគេ បានឆ្លងកាត់ទួលស្លែងនេះ ក្នុងនេះត្រូវបានគេដឹងថាមានតែ ៦ នាក់ទេដែលនៅរស់រានមានជីវិតនៅឡើយ ។

## ៥- សេចក្តីសង្កេតទូទៅ

៣២- សេចក្តីសង្កេតទូទៅមួយចំនួន អាចធ្វើបាន ទាក់ទងទៅនឹងវិធីដែលពួកខ្មែរក្រហមបានយកទៅប្រើប្រាស់ ។ ទី ១ កម្មាភិបាលបានសម្លាប់ភ្លាម ៗ គោលដៅពិសេសមួយចំនួន ដូចជាសមាជិកកងទ័ពរដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរ និងមន្ត្រីរាជការធ្វើការនៅក្នុងរដ្ឋបាល ជនជាតិវៀតណាម អ្នកដឹកនាំព្រះពុទ្ធសាសនាមនុស្សនៅក្នុងគណបក្សដែលសង្ស័យថាក្បត់ ជនដែលប្រព្រឹត្តបំពានលើវិន័យ ឬប្រឆាំងនឹងនយោបាយរបស់

---

[៣] ដកស្រង់ពីណាយ៉ាន់ ចាន់ដា ដូចបានលើកឡើងខាងលើនេះ ត្រង់លេខ ២៥៤ ។ តួលេខចំនួន ១០០ ០០០ នាក់ គឺបានមកពីឃែរណាន់ ដូចបានរៀបរាប់ខាងលើ ត្រង់លេខ ៧ ។

របប និងមនុស្សនៅក្នុងផ្នែកចារកម្ម ។ អ្នកខ្លះត្រូវបានសម្លាប់បន្ទាប់ពីវិគ្គទារុណកម្ម ឬឃុំឃាំង ។ ទី ២ របបបានជំរុញ ឬអនុគ្រោះឱ្យមានការរំលោភដោយទ្រង់ទ្រាយធំ រហូតដល់ស្លាប់នូវមនុស្សភាគច្រើននៅក្នុងរយៈពេលនេះ ។ ទាំងនេះបានកើតចេញមកពីការធ្វើដំណើរដោយជើងដោយបង្ខំ ការធ្វើការច្រើនម៉ោងពេក និងចំណីអាហារ និងថ្នាំពេទ្យមិនគ្រប់គ្រាន់ ដែលជនខ្មែរបានជួបប្រទះ ពិសេសក្នុងចំណោម "ប្រជាជនថ្មី" ។

៣៣- ទី ៣ ការរំលោភខ្លះហាក់ដូចជាបានកើតមានឡើងដោយពុំមានលំនាំណាមួយដែលអាចត្រូវបានដឹងដោយច្បាស់លាស់បានទេ ។ កម្មាភិបាលមូលដ្ឋាន ជាពិសេសពួកក្មេង ៗ ត្រូវបានផ្តល់ឱ្យមានអំណាចលើជីវិត និងការស្លាប់របស់ប្រជាពលរដ្ឋ ដែលជាញឹកញាប់ណាស់បានប្រព្រឹត្តនូវអំពើឃោរឃៅហួសពីការស្មានមិនសមហេតុសមផល ឬការភ័យខ្លាចទៅទៀត ។ ទី ៤ ជនកម្ពុជាទាំងអស់មិនមែនទទួលរងនូវការឈឺចាប់ក្នុងកំរិតដូច ៗ គ្នានោះទេ ។ មន្ត្រីរបស់អតីតសាធារណរដ្ឋខ្មែរ និងជនជាតិភាគតិចទទួលរងការឈឺចាប់ ខ្លាំងជាងគេ រីឯប្រជាពលរដ្ឋតាមជនបទខ្លះទទួលការឈឺចាប់តិចជាង ។ ទោះបីជាចំនួនដ៏គួរឱ្យរន្ធត់នៃការស្លាប់ (សូមអានខាងក្រោមនេះ) យ៉ាងណាក៏ដោយ ក៏ជនកម្ពុជាភាគច្រើនក្រាស់ក្រែលដែលបានរួចជីវិតពីរយៈពេលនេះ មានការប៉ះពាល់រយៈពេលវែងទៅលើប្រទេសជាតិនៅតែមិនអាចវាស់វែងបានទេ ពីព្រោះអ្នកដែលមានការអប់រំ និងមានជំនាញត្រូវបានជាទិសដៅជាពិសេសក៏ដោយ ក៏ស្លាកស្នាមខាងផ្លូវចិត្ត និងផ្លូវកាយបានបន្សល់ទុកដល់អ្នកដែលនៅរស់រានមានជីវិតជានិច្ច ។

៣៤- ទី ៥ ការស្រាវជ្រាវរកឱ្យឃើញអ្នកចូលរួម និងជនរងគ្រោះទាំងអស់ នៃអំពើឃោរឃៅនេះ ហាក់ដូចជាមិនអាចធ្វើទៅកើតទេ ។ ក្រៅតែអំពីសេចក្តីសារភាពដោយផ្ទិតផ្ទង់ដែលរក្សាទុកនៅទួលស្លែងចេញ ពួកខ្មែរក្រហមពុំបានប្រមូលទុកនូវការកត់ត្រាលំអិតនៃសកម្មភាពភាគច្រើនរបស់ពួកគេទេ ឬមួយក៏ការកត់ត្រាទាំងនោះត្រូវបានបាត់បង់អស់ទៅហើយ ។ ឈ្មោះនៃអ្នកប្រព្រឹត្ត និងជនរងគ្រោះទាំងអស់ នឹងមិនអាច ត្រូវបានដឹងជារៀងរហូត ។

៣៥- ជាទីបញ្ចប់ អ្នកស្រាវជ្រាវ និងរដ្ឋាភិបាលនានា បានផ្តល់តួលេខខុស ៗ គ្នា អំពីចំនួនសរុបនៃជនជាតិខ្មែរដែលត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម ។ អ្នកសិក្សាស្រាវជ្រាវផ្សេង ៗ បានផ្តល់ដោយឡែក ៗ ពីគ្នា

នូវចំនួន ពី ១ លាន ៥ សែន ទៅ ជិត ១ លាន ៧ សែននាក់[៤] ។ មានទ្រង់ទ្រាយអាចផ្ទុះផ្តងគ្នាមួយបាន ក្នុងចំណោមក្រុមជនរងគ្រោះ ។ ការសិក្សាមួយឱ្យអត្រាជិត ១០០ ភាគរយ ទៅលើជនជាតិភាគតិច វៀតណាមនៅតាមជនបទ និងនៅក្នុងទីក្រុង ២៥ ភាគរយ ទៅលើ"ប្រជាជនថ្មី" ជាខ្មែរនៅទីក្រុង និងនៅ តាមជនបទ និង ១៥ ភាគរយទៅលើ "ប្រជាជនមូលដ្ឋាន" ជាខ្មែរនៅតាមជនបទ[៥] ។ សរុបមក ការប៉ាន់ប្រមាណផ្សេង ៗ នៃអត្រានៃការស្លាប់ប្រមាណ ២០ ភាគរយ នៃប្រជាពលរដ្ឋចំនួន ៧ លាន ៣ សែន ទៅ ៧ លាន ៩ សែន នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ ។ ប្រវត្តិវិទូនៃប្រទេសកម្ពុជា បានបដិសេធចោល នូវតួលេខ ពី ២ ទៅ ៣ លាននាក់ ដែលត្រូវបានប្រើជារឿយ ៗ ដោយរដ្ឋាភិបាលកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៧៩ មក ក៏ដូចជាការរាប់ចំនួនប្រជាពលរដ្ឋដ៏ទៃមួយចំនួនទៀត ។

## គ- ការរលំរលាយ និងសកម្មភាពនៃរបប ចាប់តាំងពីឆ្នាំ ១៩៧៩ មក

៣៦- ការទាក់ទងរវាងប្រទេសកម្ពុជា និងវៀតណាម បាននាំទៅឱ្យមានការផ្តួលរំលំរបបនេះជាយថា ហេតុ។ សម្ព័ន្ធភាពរអូករអឺននឹងគ្នា រវាងពួកកម្មុយនិស្តខ្មែរ និងវៀតណាម បានចាប់ផ្តើមស្ថិតស្រពោនទៅ វិញ នៅពេលភ្លាម ៗ បន្ទាប់ពីជ័យជំនះរបស់ពួកគេរៀង ៗ ខ្លួន នារដូវផ្ការីក ឆ្នាំ ១៩៧៥ ដោយបានប្រែក្លាយ ទៅជាមានការស្អប់គ្នា ជារូបភាពដូចការទាក់ទងកម្ពុជា-វៀតណាមដូចនៅក្នុងប្រវត្តិសាស្ត្រកន្លងមកអ៊ីចឹង ។

៣៧- ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ កម្ពុជាប្រជាធិបតេយ្យ និងវៀតណាម បានធ្វើសង្គ្រាមនឹងគ្នាអំពី បញ្ហាព្រំដែនដោយទ្រង់ទ្រាយតូចមួយ ។ នាឆ្នាំ ១៩៧៧ កម្ពុជាបានតម្លើងថ្នាក់សង្គ្រាម ដោយបញ្ចូលការ វាយប្រហារនានា ដែលក្នុងនោះពួកគេបានសម្លាប់រង្គាលជនជាតិវៀតណាមរាប់រយនាក់នៅក្នុងភូមិនានាតាម បណ្តោយព្រំដែន ។ វៀតណាមបានឆ្លើយតបវិញជាយថាហេតុ ដោយបញ្ជូនកងទ័ពចូលក្នុងប្រទេសកម្ពុជា នៅក្នុងខែធ្នូ ឆ្នាំ ១៩៧៧ ។ ការកាន់កាប់ផ្នែកខ្លះនៃភូមិភាគបូពាដោយវៀតណាម បាននាំឱ្យមជ្ឈិមធ្វើការ បោសសំអាតអ្នកដឹកនាំនៃភូមិភាគនេះ ដែលជាការនាំទៅឱ្យមានការងើបឡើងបះបោររបស់ពួកមន្ត្រីនៃភូមិ

---

[៤] សូមមើល ខាល ហ្សាក់សុន "សេចក្តីផ្តើម: ខ្មែរក្រហមក្នុងក្របខ័ណ្ឌរបស់វា" នៅកម្ពុជា ឆ្នាំ ១៩៧៥-១៩៧៨ ដូចបានដកស្រង់រួច មកហើយ ត្រង់លេខ ៣ របស់ ឃៃរណាន់ ដូចបានដកស្រង់រួចមកហើយត្រង់លេខ ១៩១-៩២ ។

[៥] សូមមើល ឃៃរណាន់ (ឆ្នាំ ១៩៩៤) ដូចបានដកស្រង់រួចមកហើយ ត្រង់លេខ ១៩៣ (តារាងលេខ ៥) ។ តួលេខទាំងនេះត្រង់បាន ឆ្លុះបញ្ចាំងអត្រានៃការស្លាប់ចំនួន ៥០ ភាគរយ ចំពោះជនជាតិភាគតិចចិន ៣៦ ភាគរយ ជាចាម និង ៤០ ភាគរយជាជនជាតិថៃ ។

ភាគបូព៌ា នៅក្នុងខែឧសភា ឆ្នាំ ១៩៧៨។ នៅរដូវស្លឹកឈើជ្រុះ និងបរាជ័យនៃឆ្នាំ ១៩៧៨ បាននាំឱ្យមេដឹកនាំភូមិភាគបូព៌ាមួយក្រុម នាំគ្នារត់គេចខ្លួនទៅប្រទេសវៀតណាម ដែលនៅទីនោះពួកគេបានក្លាយទៅជាស្នូលនៃក្រុមប្រឆាំងមួយ ។ វៀតណាមបានរៀបចំកម្លាំងរបស់ខ្លួននៅតាមបណ្តោយព្រំដែនកម្ពុជា ហើយនៅខែធ្នូ ឆ្នាំ ១៩៧៨ វៀតណាមបានធ្វើការវាយលុកដោយទ្រង់ទ្រាយធំចូលប្រទេសកម្ពុជា ។ នៅថ្ងៃទី ៦ ខែមករា ឆ្នាំ ១៩៧៩ កងទ័ពរបស់គេបានចូលដល់ទីក្រុងភ្នំពេញ ហើយបានលើកបន្តុបក្រុមប្រឆាំងឱ្យឡើងកាន់អំណាចនៅពេលនោះទៅ ដែលក្រោយមកបានប្រកាសខ្លួនឯងថាជាសាធារណរដ្ឋប្រជាមានិតកម្ពុជា (ដែលនៅក្រោយឆ្នាំ ១៩៨៩ ហៅថារដ្ឋកម្ពុជា ) រដ្ឋនេះបានដឹកនាំប្រទេសកម្ពុជាអស់រយៈពេលជាងមួយទសវត្សដោយមានជំនួយយ៉ាង ខ្លាំងក្លាពីសំណាក់កងទ័ពវៀតណាម ។

៣៨- ដោយការរលំយ៉ាងរហ័សនៃកម្ពុជាប្រជាធិបតេយ្យ ពួកខ្មែរក្រហមដែលនៅសេសសល់ជាច្រើននាក់ រួមទាំងអ្នកដឹកនាំកំពូលផង បាននាំគ្នារត់គេចខ្លួន ដើម្បីរៀបចំខ្លួនឯងឡើងវិញ នៅតាមបណ្តោយទាំងសង្ខាងនៃព្រំដែនកម្ពុជា-ថៃ ។ វិធីរំលោភរបស់ពួកគេប្រឆាំងទៅលើអ្នកដែលនៅក្នុងតំបន់របស់ពួកគេ នៅតែបន្តប្រព្រឹត្តតទៅទៀត (ទោះបីជាទ្រង់ទ្រាយរបស់វាបានធ្លាក់ចុះក៏ដោយ) ហើយពួកគេក៏ទទួលបានការទុកចិត្តមួយក៏រិតនៅក្នុងតំបន់ និងនៅទីកន្លែងដ៏ទៃទៀត ថាជាកម្លាំងយោធាដ៏ខ្លាំងជាងគេបំផុតប្រឆាំងកងទ័ពវៀតណាម ។ ការគាំទ្រផ្នែកយោធាដ៏សំខាន់មកពីប្រទេសមួយចំនួននៅក្នុងតំបន់ បានរក្សាពួកខ្មែរក្រហមឱ្យនៅជាកម្លាំងប្រយុទ្ធដ៏សកម្មមួយ ។ កម្ពុជាប្រជាធិបតេយ្យ បានរក្សាអាសនៈរបស់កម្ពុជានៅក្នុងអង្គការសហប្រជាជាតិនៅក្នុងទសវត្សឆ្នាំ ១៩៨០ (ទោះបីជាពាក្យថា អំពើឃោរឃៅរបស់ពួកគេ ត្រូវបានចាប់ផ្តើមដឹងជាសកលហើយក៏ដោយ) ដោយសម្ព័ន្ធប្រឆាំងវៀតណាមដ៏មានប្រសិទ្ធភាពមួយដឹកនាំដោយប្រទេសចិន សមាគមនៃប្រទេសអាស៊ីអគ្នេយ៍ និងសហរដ្ឋអាមេរិក និងបានទទួលការគាំទ្រពីសំណាក់ប្រទេសមិនចូលបក្សសម្ព័ន្ធជាច្រើន ដែលបានធ្វើការថ្កោលទោសការឈ្លានពានប្រឆាំងប្រទេសតូច ។

៣៩- នៅឆ្នាំ ១៩៨២ នៅពេលដែលជនភៀសខ្លួន និងក្រុមសិទ្ធិមនុស្សនានា បានផ្សព្វផ្សាយបន្ថែមអំពីពិតមានស្តីពីជីវភាពនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ពួកបរទេសជាអ្នកគាំទ្រខ្មែរក្រហម បានសង្កត់ពួកនេះឱ្យចូលរួមជាមួយកម្លាំងនៃចលនាតស៊ូមិនមែនកុម្មុយនិស ២ ទៀត បង្កើតរដ្ឋាភិបាលចំរុះនៅក្រៅប្រទេសមួយ គឺរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំរុះ ។ ទោះបីជាមានវត្តមាននៅក្នុងរដ្ឋាភិបាលចំរុះនេះ នូវក្រុមមិនមែន

កុម្មុយនិស ២ ទៀតក៏ដោយ ពោលគឺរណសិរ្សរួបរួមជាតិដើម្បីកម្ពុជាមួយឯករាជ្យ អព្យាក្រិត រុងរឿង និង សហប្រតិបត្តិ នៃកម្ពុជា (ហ៊្វុនស៊ីនប៉ិច) និងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ក៏ដោយ ក៏ខ្មែរក្រហម នៅតែជាសមាជិកមានលក្ខណៈគ្របដណ្តប់ដដែល ។

៤០- ពួកខ្មែរក្រហមបានប្រយុទ្ធជាមួយវៀតណាមពេញមួយទសវត្សឆ្នាំ ១៩៨០ តែសាធារណរដ្ឋប្រជា-មានិតុកម្ពុជា និងវៀតណាម បានព្យាយាមរក្សាការត្រួតត្រាទឹកដីប្រមាណ ៩០ ភាគរយនៃទូទាំងប្រទេស ។ កិច្ចខិតខំនានាខាងផ្លូវទូតដើម្បីបញ្ចប់ជម្លោះនេះ មិនបាននាំមកនូវផ្លែផ្កាទេក្នុងរយៈពេលស្ទើរតែមួយទសវត្សឆ្នាំ ១៩៨០ នេះ ។ នៅឆ្នាំ ១៩៨៧ ប្រទេសឥណ្ឌូណេស៊ីបានផ្តើមគំនិតឱ្យមានកិច្ចដំណើរការសន្តិភាពនៅក្នុងតំបន់មួយ ហៅថាការប្រជុំក្រៅផ្លូវការទីក្រុងហ្សាកាតា និងសេចក្តីប្រកាសរបស់វៀតណាមនាដើមឆ្នាំ ១៩៨៩ ថាខ្លួននឹងដកកម្លាំងប្រយុទ្ធរបស់ខ្លួនចេញពីកម្ពុជា នៅមុនខែកញ្ញា ឆ្នាំ ១៩៨៩ បាននាំទៅឱ្យមានការកោះ ប្រជុំសន្និសិទទីក្រុងប៉ារីស៍ស្តីពីកម្ពុជា ក្នុងខែកញ្ញា ឆ្នាំ ១៩៨៩ ។ ពួកខ្មែរក្រហមគឺជាភាគីមួយនៃ គណៈប្រតិភូទាំង ៤ (ជាមួយរដ្ឋកម្ពុជា ហ៊្វុនស៊ីនប៉ិច និងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ) ដែលតំណាងឱ្យ ប្រទេសកម្ពុជា ។ បន្ទាប់ពីការងារផ្លូវទូតដ៏ខ្លាំងក្លាស្តីពីផែនការសន្តិភាពថ្មីមួយ ត្រូវបានស្នើឡើងដោយ ប្រទេសអូស្រ្តាលី សមាជិកអចិន្ត្រៃយ៍ទាំង ៥ នៃក្រុមប្រឹក្សាសន្តិសុខ និងប្រទេសឥណ្ឌូណេស៊ីក្នុងឆ្នាំ ១៩៩០- ១៩៩១ មក ការដោះស្រាយដោយសព្វមុខមួយ ត្រូវបានសំរេចឡើង នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ នាថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ ។ ភាគីខ្មែរទាំង ៤ បានចុះហត្ថលេខាក្នុងនាមប្រទេសកម្ពុជា ។

៤១- កិច្ចព្រមព្រៀងសន្តិភាពនេះ បានសុំឱ្យអជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិសំរាប់ប្រទេសកម្ពុជា (អ៊ុនតាក់) រៀបចំ និងដឹកនាំការបោះឆ្នោតក្នុងបរិយាកាសមួយសន្តិភាព និងអព្យាក្រិតខាងនយោបាយ ។ នៅក្នុងខែមិថុនា ឆ្នាំ ១៩៩២ ពួកខ្មែរក្រហមបានបដិសេធមិនចូលរួមក្នុងកិច្ចដំណើរការរំសាយកងទ័ព និងបានឈប់ធ្វើសហប្រតិបត្តិការជាមួយអង្គការសហប្រជាជាតិ ចំពោះបេសកកម្មដែលនៅសេសសល់ទាំងអំបាលមាណ (លើកលែងតែកិច្ចដំណើរការមាតុភូមិនិវត្តន៍នៃជនភៀសខ្លួនចេញ) ។ ពួកគេបានធ្វើពហិកាមិនចូលរួមក្នុងកិច្ចដំណើរការបោះឆ្នោត ហើយក្រោយមកបានធ្វើការកាប់សម្លាប់ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា ក៏ដូចជាធ្វើការវាយប្រហារដោយមានកំរិតទៅលើអ៊ុនតាក់ថែមទៀត ។

ប៉ុន្តែ ចាប់តាំងពីឆ្នាំ ១៩៩៣ មក ពួកខ្មែរក្រហមលែងជាកម្លាំងប្រយុទ្ធដ៏សកម្មមួយហើយ ដោយទាហាន របស់ពួកគេបានវិលត្រឡប់ទៅរកជីវភាពស៊ីវិលវិញ ឬចូលរួមជាមួយកងទ័ពជាតិ ។ នៅថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ១៩៩៤ សភាជាតិបានអនុម័តច្បាប់ដាក់ខ្មែរក្រហមនៅក្រៅច្បាប់ ។

## ឃ- ការពុំមានការទទួលខុសត្រូវរហូតមកទល់ថ្ងៃនេះ

៤២- ក្នុងពេលនៃការកាន់អំណាចរបស់ពួកខ្មែរក្រហម សហគមន៍អន្តរជាតិមិនបានតាមដានដោយពិនិត្យពិច័យទៅលើពួកខ្មែរក្រហមទេ ។ ការខ្វះខាតនូវព័តមាន បណ្តាលមកពីភាពឯកោនៃរបបនេះ ការមិនយកចិត្តទុកដាក់ចំពោះផលប្រយោជន៍នៃរដ្ឋជាច្រើននៅឥណ្ឌូចិន និងការមិនយកចិត្តទុកដាក់របស់អ្នកដ៏ទៃផ្សេងទៀត ចំពោះបញ្ហានៃការអនុវត្តន៍សិទ្ធិមនុស្សរបស់រដ្ឋាភិបាលបដិវត្តន៍ថ្មីមួយ ទាំងអស់នេះបានដាក់ប្រទេសកម្ពុជាឱ្យនៅឆ្ងាយពីក្រសែភ្នែករបស់ពួកគេ ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានលើកបញ្ហានេះនៅក្នុងឆ្នាំ ១៩៧៨ នៅពេលដែលប្រទេសលោកខាងលិចមួយក្រុមបានបញ្ជូនរបាយការណ៍នានាបានមកពីជនភៀសខ្លួនដែលបានរត់គេចខ្លួនរួច ជូនដល់អនុគណៈកម្មការស្តីពីការបង្កាការរើសអើង និងការការពារជនជាតិភាគតិច ។ ការណ៍នេះ បាននាំទៅឱ្យមានត្រឹមតែរបាយការណ៍ជាផ្លូវការមួយរបស់អង្គការសហប្រជាជាតិនៃរយៈពេលនោះប៉ណ្ណោះ ដែលបានធ្វើឡើងដោយអនុគណៈកម្មការនេះ[៦] ។ គណៈកម្មាធិការមិនបានពិនិត្យរបាយការណ៍នេះ ដោយសារការរលំរលាយរបស់រដ្ឋាភិបាលខ្មែរក្រហម ។

៤៣- បន្ទាប់ពីបានផ្តួលរំលំពួកខ្មែរក្រហមមក នៅក្នុងឆ្នាំ ១៩៧៩ សាធារណរដ្ឋប្រជាមានិតុកម្ពុជា បានធ្វើការកាត់ទោស<u>ដោយកំបាំងមុខ</u> ចំពោះ ប៉ុល ពត និង អៀង សារី ។ ប៉ុន្តែ ការកាត់ទោសនេះគឺគ្រាន់តែជាឆាកល្ខោមួយប៉ុណ្ណោះ ដោយពុំអើពើដល់នីតិវិធីត្រឹមត្រូវឡើយ ។ នៅខាងក្រៅប្រទេសកម្ពុជាឯណោះវិញ កម្លាំងនយោបាយដដែលនេះ ដែលបានធានាឱ្យកម្ពុជាប្រជាធិបតេយ្យរក្សាអាសនៈរបស់ខ្លួននៅក្នុង អង្គការសហប្រជាជាតិ

[៦] សូមមើល ការវិភាគរៀបចំឡើងក្នុងនាមអនុគណៈកម្មការ ដោយប្រធានអនុគណៈកម្មការ ទៅលើឯកសារទាំងឡាយដែលបានដាក់ជូនអនុគណៈកម្មការនេះ និងសេចក្តីសំរេច លេខ ៩ (XXXIV) របស់គណៈកម្មាធិការសិទ្ធិមនុស្ស ចុះថ្ងៃទី ៣0 ខែមករា ឆ្នាំ ១៩៧៩ ឯកសារអង្គការសហប្រជាជាតិលេខ E/CN./1335 .

ក៏ពុំបានចាត់វិធានការអ្វីទៅលើអង្គការនេះ ទាក់ទិនទៅនឹងការទទួលខុសត្រូវរបស់ពួកមេដឹកនាំខ្មែរក្រហមក៏ទេដែរ ។ នៅក្នុងពេលចរចាកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ខ្មែរក្រហមស្ថិតនៅជាអ្នកចូលរួមមួយដោយពេញសិទ្ធិ ហើយកិច្ចព្រមព្រៀងទាំងនោះពុំមានដាក់បញ្ចូលនូវកាតព្វកិច្ចច្បាស់លាស់ណាមួយដល់ប្រទេសកម្ពុជាឱ្យធ្វើការវិនិច្ឆ័យទោស ហើយអ៊ុនតាក់ក៏មិនត្រូវបានផ្តល់ឱ្យនូវអាណត្តិនោះដែរ ។ ផ្ទុយទៅវិញ រដ្ឋទាំងឡាយដែលបានចូលរួមក្នុងកិច្ចដំណើរការសន្តិភាព បានទុកបញ្ហានេះសំរាប់រដ្ឋាភិបាលអនាគតនៃកម្ពុជា ។

៤៤- ចាប់តាំងពីការបោះឆ្នោតឆ្នាំ ១៩៩៣ មក រដ្ឋាភិបាលបានធ្វើយុទ្ធនាការដើម្បីឱ្យមានការរត់ចោលជួររបស់កងឈ្លបខ្មែរក្រហម តាមរយៈនៃការផ្តល់នូវការលើកលែងការចោទប្រកាន់តាមច្បាប់ដាក់ខ្មែរក្រហមឱ្យនៅក្រៅច្បាប់ ឆ្នាំ ១៩៩៤ និងបញ្ចូលពួកគេទៅក្នុងកងយោធពលខេមរភូមិន្ទ ។ នយោបាយនេះ រួមជាមួយនឹងការបញ្ចប់ជំនួយយោធាបរទេសដល់ពួកខ្មែរក្រហម និងការរត់ចោលជួរមួយចំនួនចេញពីចលនាមកបាននាំទៅឱ្យមានការចុះចូល និងការផ្តាច់ខ្លួន នៃកងទ័ពខ្មែរក្រហមស្ទើរតែទាំងអស់ និងការបញ្ចប់នូវការបះបោររបស់ពួកគេ ។ នៅក្នុងខែកញ្ញា ឆ្នាំ ១៩៩៦ រដ្ឋាភិបាលកម្ពុជាបានផ្តល់ការលើកលែងទោសដល់ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីនៃរដ្ឋាភិបាលខ្មែរក្រហម គ្របដណ្តប់ការផ្តន្ទាទោសលើរូបគាត់ឆ្នាំ ១៩៧៩ និងច្បាប់ឆ្នាំ ១៩៩៤ ។ ការលើកលែងទោសនេះ ក៏ដូចជាការអនុញ្ញាតិឱ្យអតីតអង្គភាពខ្មែរក្រហម រក្សានូវអាវុធរបស់ខ្លួនបាន និងបន្តត្រួតត្រាលើតំបន់របស់ពួកគេ ក៏បង្កើតបាននូវការទាក់ទងរបស់កងកម្លាំងខ្មែរក្រហមដែលស្មោះត្រង់នឹងរូបគាត់ និងទឹកដីដែលពួកគេត្រួតត្រា ឱ្យបញ្ចូលមកក្នុងក្របខ័ណ្ឌរដ្ឋាភិបាលជាផ្លូវការ ។ គំរូនៃការរួមបញ្ចូលដូចគ្នានេះ ទោះបីជាគ្មានការលើកលែងទោសជាផ្លូវការណាមួយក៏ដោយ ត្រូវបានយកទៅប្រើប្រាស់នៅតំបន់ខ្មែរក្រហមដ៏ទៃទៀតដែរ ។

៤៥- ការស្លាប់របស់ ប៉ុល ពត នៅក្នុងឆ្នាំ ១៩៩៨ បានបង្វែងទិសនៃការយកចិត្តទុកដាក់ ទៅលើវាសនានៃពួកមេដឹកនាំខ្មែរក្រហមដែលនៅសល់ ។ នៅក្នុងខែធ្នូ ឆ្នាំ ១៩៩៨មន្ត្រីជាន់ខ្ពស់បំផុត ២ នាក់ របស់កម្ពុជាប្រជាធិបតេយ្យ គឺ នួន ជា និង ខៀវ សំផន ក៏បានសុំចុះចូលដែរ ។ នៅថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ១៩៩៩ បានបញ្ចូលនូវអ្វីដែលគេបានកំណត់ថាជាខ្មែរក្រហមដែលនៅសេសសល់នោះ ទៅក្នុងកងយោធពលខេមរភូមិន្ទ ។ មានតែអ្នកដឹកនាំថ្នាក់ខ្ពស់ម្នាក់គត់ ដែលត្រូវបានគេស្គាល់ជាទូទៅថា តាម៉ុក នៅមិនទាន់បានសុំចុះ

ចូលជាផ្លូវការជាមួយរដ្ឋាភិបាលនៅឡើយទេ នៅក្នុងពេលសរសេររបាយការណ៍នេះ ។ ទោះបីជាមានការដឹងដ៏រាលដាលថាពួកមន្ត្រីខ្មែរក្រហមនៅឯណាក៏ដោយ ក៏រាប់ឆ្នាំមកហើយ ពុំមានអ្នកណាម្នាក់ត្រូវបានចាប់ខ្លួន ឬបញ្ជូនទៅកាន់តុលាការនៅឡើយទេ ស្តីពីការចោទប្រកាន់ពីបទព្រហ្មទ័ណ្ឌទាក់ទងទៅនឹងពេលដែលពួកគេនៅកាន់អំណាចនោះ ។

## IV- ការវាយតម្លៃលើភស្តុតាង

៤៦- ផ្នែកទី ១ នៃអាណត្តិរបស់អ្នកជំនាញការ គឺធ្វើការវាយតម្លៃទៅលើភស្តុតាងដែលមានស្រាប់ ក្នុងទិសដៅកំណត់នូវប្រភេទនៃឧក្រិដ្ឋកម្មរបស់ពួកមេដឹកនាំខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។ ផ្នែកនេះគឺជាការវាយតម្លៃរបស់ក្រុមទៅលើភស្តុតាង ។ ខាងក្រោមនេះ គឺជាផ្នែកនានាទាក់ទងទៅនឹងធាតុនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ។

## ក- <u>សេចក្តីអត្ថាធិប្បាយទូទៅ</u>

៤៧- រហូតមកទល់ពេលនេះ ២០ ឆ្នាំហើយ ដែលខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាចនៅក្នុងប្រទេសកម្ពុជា ហើយរយៈពេលតាំងពីមានអំពើឃោរឃៅរបស់ពួកគេមក បានបង្កើតឱ្យមានការលំបាកភ្លាម ៗ មួយក្នុងការនាំខ្លួនមេដឹកនាំពួកគេទៅកាន់តុលាការ ។ ការណ៍នេះ បានសំដែងឱ្យឃើញដោយខ្លួនឯងតាមបែបផែនមួយចំនួន រួមមាន ការស្លាប់របស់សាក្សីសំខាន់ ៗ ក៏ដូចជាការលំបាកក្នុងការធ្វើឱ្យសាក្សីដែលនៅរស់ រំលឹកឡើងវិញនូវព្រឹត្តិការណ៍ពិសេស ៗ នារយៈពេលនោះ លើសពីនេះទៅទៀតមានការរលេះរលួយ និងការ បាត់បង់នូវភស្តុតាងជារូបិយខ្លះ ។ ទោះបីយ៉ាងណាក៏ដោយ ការកាត់ទោស និងការផ្តន្ទាទោស ចំពោះការ រំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរធ្លាប់ត្រូវបានធ្វើឡើងនៅក្នុងប្រទេសមួយចំនួនមកហើយ ទោះបីជាពេលវេលាបានកន្លងផុតទៅឆ្ងាយហើយក៏ដោយ ទាំងនេះរួមមានការកាត់ទោសពួកណាហ្ស៊ី នៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ដ៏នៅក្នុងទសវត្សឆ្នាំ ១៩៦០ និងការកាត់ទោសពួកណាហ្ស៊ីដោយប្រទេសបារាំង នៅក្នុងទសវត្ស ឆ្នាំ ១៩៨០ និង ១៩៩០ ជាដើម ។ ដូច្នេះ ការកន្លងផុតទៅនៃពេលវេលា មិនមែនជាឧបសគ្គផ្ទាល់ចំពោះការ

រកឱ្យឃើញនូវការទទួលខុសត្រូវ ឬយុត្តិធម នោះទេ ។ មិនតែប៉ុណ្ណោះ សារសំខាន់នៃការរក្សាទ្វារនៃការទទួលខុសត្រូវឱ្យនៅចំហ ទោះបីជាពេលវេលាបានកន្លងផុតទៅយូរហើយក៏ដោយ វានឹងរក្សាទុកមិនឱ្យមានការលប់បំបាត់នូវស្ថានភាពឱ្យរួញតូចមកវិញនៅក្នុងរដ្ឋជាច្រើន នូវឧក្រិដ្ឋកម្មជាអន្តរជាតិខ្លះនោះ ការអំពាវនាវឱ្យមានការលប់បំបាត់បែបនេះ នៅក្នុងអនុសញ្ញាស្តីពីការមិនអនុវត្តន៍នូវការកំរិតព្រំដែននៃលក្ខន្តិកៈចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឆ្នាំ ១៩៦៨[៧] និងការដកចេញនូវឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការ នៃតុលាការព្រហ្មទ័ណ្ឌអន្តរជាតិ ពីការកំរិតព្រំលក្ខន្តិកៈបែបនេះ[៨] ។

៤៨- អវត្តមាននៃការប៉ុនប៉ងដោយមានការរៀបចំណាមួយ ស្តីពីការទទួលខុសត្រូវរបស់មន្ត្រីខ្មែរក្រហម នឹងនាំទៅឱ្យមានការពន្យាពេលនៃការខិតដើម្បីរក្សាទុកនូវភស្តុតាង ដែលអាចមានប្រយោជន៍ចំពោះកិច្ចដំណើរការនៃនីតិវិធិច្បាប់ ។ ជាង ២០ ឆ្នាំ កន្លងមកនេះ ការប៉ុនប៉ងផ្សេង ៗ ត្រូវបានធ្វើឡើងដើម្បីប្រមូលភស្តុតាងនៃអំពើឃោរឃៅរបស់ពួកខ្មែរក្រហម ដើម្បីស្ថាបនាឡើងនូវការកត់ត្រាទុកដើម្បីជាប្រវត្តិសាស្ត្រនៃអំពើទាំងនេះ ។ រយៈពេលជិត ២០ ឆ្នាំនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលភស្តុតាងបែបនេះ តាមរយៈការនិយាយជាមួយអ្នកនៅរស់រានមានជីវិត និងអ្នកដែលបានចូលរួមក្នុងអំពើឃោរឃៅនេះ និងការពិនិត្យឯកសារ រូបថត និងរណ្តៅផ្នូរផ្សេង ៗ ។ ការខិតខំដោយមានការយកចិត្តទុកដាក់ និងមានការរៀបចំល្អជាងគេបំផុត ក្នុងបញ្ហានេះ គឺត្រូវបានធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលស្ថិតនៅក្នុងទីក្រុងភ្នំពេញ ។ ជាដំបូងមជ្ឈមណ្ឌលនេះ ត្រូវបានបង្កើតឡើងដោយសលកវិទ្យាល័យយេល ដោយមានការឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ឥឡូវនេះមជ្ឈមណ្ឌលដំណើរការជាវិជ្ជាស្ថានស្រាវជ្រាវឯករាជ្យមួយ ដោយមានការឧបត្ថម្ភថវិកាដោយរដ្ឋាភិបាល និងមូលនិធិមួយចំនួន ។ វិជ្ជាស្ថាន បានដឹកនាំគំរោងការណ៍ស្រាវជ្រាវឯកសារ ដើម្បីប្រមូល ចុះបញ្ជី និងរក្សាទុកឯកសារនានារបស់កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាធ្វើគំរោងគូសវាសជាផែនទី ដើម្បីគូសទីកន្លែងពិឃាត និងផ្នូររួម ។

៤៩- ទោះបីយ៉ាងណាក៏ដោយ វាជាការសំខាន់ណាស់ដែលត្រូវកត់សំគាល់ថា ទាំងមជ្ឈមណ្ឌលឯកសារ ឬការខិតខំទាំងឡាយក្នុងការធ្វើការស្រាវជ្រាវដ៏ទៃទៀត មិនត្រូវបានតម្រង់ទិសឆ្ពោះទៅធ្វើការស៊ើបអង្កេត

---

[៧] សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ២៣៩១ (XXIII) ឧបសម្ព័ន្ធ ។

[៨] A/CONF.183/9, មាត្រាទី ២៩ ។

ដើម្បីរៀបចំធ្វើការចោទប្រកាន់ទៅលើបុគ្គលណាមួយនោះទេ ។ នៅពេលដែលការខិតខំរបស់ពួកគេ បានផ្តល់នូវសារតាដ៏មានសារសំខាន់ និងដ៏លំអិតនៃព្រឹត្តិការណ៍ របស់កម្ពុជាប្រជាធិបតេយ្យនោះ ក៏ការណ៍នេះមានលក្ខណៈមិនគ្រប់គ្រាន់ដើម្បីកសាងឡើងនូវបែបបទប្រឆាំងទៅបុគ្គលណាមួយបាននោះទេ ។

៥០- ក្រុមអ្នកជំនាញការ បានពិនិត្យឃើញថាអាណត្តិរបស់ខ្លួនក្នុងការពិនិត្យឡើងវិញនូវភស្តុតាងទាំងឡាយ ក្នុងទិសដៅដើម្បីកំណត់ថាតើសព្វថ្ងៃនេះមានភស្តុតាងគ្រប់គ្រាន់ហើយឬនៅ ឬថាតើអាចប្រមូលវាបានឬទេនាពេលអនាគត ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវក្នុងការនាំមេដឹកនាំខ្មែរក្រហមណាពិសេសម្នាក់ទៅកាន់តុលាការនោះ ។ ដូច្នេះ កិច្ចការរបស់ពួកគេ គឺមិនមែនជាការស្រាវជ្រាវពិនិត្យឡើងវិញនូវភស្តុតាងដែលមានស្រាប់ដើម្បីធ្វើការវិនិច្ឆ័យអំពីការពាក់ព័ន្ធរបស់បុគ្គលជាពិសេសណាមួយ ឬក៏ដើម្បីប្រមូលភស្តុតាងទាក់ទិនទៅនឹងការជាប់ពាក់ព័ន្ធរបស់បុគ្គលណាមួយនោះក៏ទេដែរ ។

៥១- ដោយហេតុដូចបានពោលមកខាងលើនេះ បច្ចុប្បន្នយើងកំពុងពិនិត្យមើលទៅលើភស្តុតាង ២ ប្រភេទ ដែលពាក់ព័ន្ធទៅនឹងនីតិវិធីច្បាប់ប្រឆាំងទៅលើមេដឹកនាំខ្មែរក្រហម នោះគឺៈ ភស្តុតាងជារូបសាស្ត្រ និងជាសាក្សី ។

## ខ- <u>ភស្តុតាងជារូបសាស្ត្រ</u>

៥២- ភាគច្រើននៃភស្តុតាងជារូបសាស្ត្រ ទាក់ទិនទៅនឹងនីតិវិធីច្បាបលណាមួយនោះ អាចចែកចេញជា ៣ ប្រភេទគឺៈ សំណល់នៃសាកសពរបស់មនុស្ស វត្ថុដែលមានជារចនាសម្ព័ន្ធ ឬជាយន្តសាស្ត្រ និងឯកសារនានា។ ចំពោះការសេសសល់នៃសាកសពរបស់មនុស្ស មជ្ឈមណ្ឌលឯកសារ បានរកឃើញទីកន្លែងនៃការសម្លាប់ និងរណ្តៅកប់ខ្មោច ជាច្រើនពាន់កន្លែងមកហើយ ។ (នៅក្នុងពេលបេសកកម្មរបស់គេមកកម្ពុជា ក្រុមអ្នកជំនាញការបានទៅមើលទីកន្លែងសម្លាប់ និងទីកន្លែងរំលឹនអនុស្សាវរីយនៅភូមិត្រពាំងស្វា ក្នុងខេត្តកណ្តាល ។ ទោះបីជាឆ្អឹងមនុស្សជាច្រើនស្ថិតក្នុងភាពពុករលួយទៅហើយក៏ដោយ ក៏វិធីដ៏សាហាវនៃការស្លាប់ទាំងនេះអាចត្រូវកំណត់បានចំពោះករណីជាច្រើនករណី ។ ភស្តុតាងជារចនាសម្ព័ន្ធ និងជាយន្តសាស្ត្រ គឺជាការកសាងឡើងនូវអាគារនានានៅទូទាំងប្រទេស ធ្វើជាមជ្ឈមណ្ឌលឃុំឃាំង ធ្វើទារុណកម្ម និងសម្លាប់ ក៏ដូចជា

ឧបករណ៍ ជារូបសាស្ត្រនានាទាក់ទិនទៅនឹងកិច្ចប្រតិបត្តិការនៃមជ្ឈមណ្ឌលប្រភេទនេះ ។ មជ្ឈមណ្ឌលដែលល្បីល្បាញជាងគេនោះ គឺស្ថិតនៅទួលស្លែងក្នុងទីក្រុងភ្នំពេញ ដែលត្រូវបានប្រែក្លាយទៅជាសារមន្ទីរមួយកាលពីដើមទសវត្សឆ្នាំ ១៩៨០ ហើយដែលក្រុមអ្នកជំនាញការក៏បានទៅទស្សនាដែរនោះ ។ មជ្ឈមណ្ឌលប្រភេទនេះតូច ៗ ត្រូវបានរកឃើញនៅនៅកន្លែងដ៏ទៃទៀតនៃប្រទេស ។ ឧបករណ៍រូបសាស្ត្រនានា នៅតែស្ថិតមាននៅឡើយ ដោយខុសគ្នាតែខាងផ្នែកនៃការទុកដាក់របស់វាតែប៉ុណ្ណោះ ។

៥៣- ភស្តុតាងជាឯកសារ គឺឯកសារផ្ទៃក្នុងរបស់បេបកម្ពុជាប្រជាធិបតេយ្យ ដែលបង្ហាញអំពីតួនាទី របស់បុគ្គលពិសេស ៗ ក្នុងកលាររំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរទាំងឡាយ ។ នៅក្នុងប្រទេសកម្ពុជា ឯកសារទាំងឡាយបែបនេះ អាចត្រូវបានរកឃើនៅមជ្ឈមណ្ឌលឯកសារ នៅកន្លែងដំកល់ទុកឯកសារជាតិ សារមន្ទីរទួលស្លែង និងនៅក្រសួងមហាផ្ទៃ ។ លើសពីនេះទៅទៀត ក្រុមអ្នកជំនាញការបានដឹងថាកងទ័ពប្រជាជនវៀតណាម បានផ្លាស់ប្តូរទីកន្លែងដាក់ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យចេញពីភ្នំពេញ បន្ទាប់ពួកគេបានកាន់កាប់ទីក្រុងនេះ ។ នាទីបញ្ចប់ ក្រុមអ្នកជំនាញការត្រូវបានដឹងថាឯកសារដ៏ទៃទៀត អាចស្ថិតនៅក្នុងដៃជនកម្ពុជា ឬពួកអ្នកស្រាវជ្រាវបរទេស ។

៥៤- ក្រុមអ្នកជំនាញការបានពិនិត្យឯកសារនានា នៅក្នុងមជ្ឈមណ្ឌលឯកសារ ដែលហាក់ដូចជាមានលក្ខណៈសព្វមុខអស់ហើយ ហើយក៏បានទទួលផងដែរនូវការចងក្រងមួយសំណុំពីមជ្ឈមណ្ឌល ដែលក្នុងនោះមានការដកស្រង់ចេញពីឯកសារនានាដែលមានការពាក់ព័ន្ធជាងគេបំផុតនោះ ។ ក្រុមអ្នកជំនាញការក៏បានទៅមើលកន្លែងរក្សាទុកឯកសារជាតិ តែឯកសារនានាមានពាក់ព័ន្ធដែលពួកគេបានអាននៅទីនោះ មិនមែនជាឯកសារច្បាប់ដើមរបស់កម្ពុជាប្រជាធិបតេយ្យទេ តែសុទ្ធសឹងជារបាយការណ៍ និងសេចក្តីថ្លែងការណ៍នានាស្តីពីកម្ពុជាប្រជាធិបតេយ្យ ដែលបានដាក់ជូននៅក្នុងពេលធ្វើការជំនុំជំរះ <u>ដោយកំបាំងមុខ</u> នៃប៉ុល ពត និងអៀង សារី កាលពីឆ្នាំ ១៩៧៩ ។ ទោះបីជាខ្លឹមសារនៅក្នុងឯកសារទាំងនេះ អាចមានប្រយោជន៍ក្នុងការធ្វើឡើងវិញនូវនីតិវិធីច្បាប់នោះ វានៅតែមិនមែនជាច្បាប់ដើមនៃភស្តុតាងជាឯកសារដែរ ។ ច្បាប់ចម្លងនៃឯកសារដែលមានពាក់ព័ន្ធបំផុតនៃសារមន្ទីរទួលស្លែងនោះ អាចរកបាននៅមជ្ឈមណ្ឌលឯកសារ ។

៥៥- ឯកសារដើមដែលបានពិនិត្យដោយក្រុមអ្នកជំនាញការ បានផ្តល់នូវភស្តុតាងយ៉ាងសំខាន់ ទាក់ទិនទៅនឹងរូបភាពនៃការរំលោភសិទ្ធិមនុស្ស នៅក្នុងរបបកម្ពុប្រជាធិបតេយ្យ ។ ទាំងនេះ រួមមាន បែបបទលំអិតនៃកាកិរិយាធិបតេយ្យខាងរដ្ឋបាលផ្សេង ៗ នៅក្នុងប្រទេស (រដ្ឋាភិបាល យោធា និងបក្ស) សភាពការណ៍នៅតាមភូមិភាគផ្សេង ៗ ទាក់ទងទៅនឹងការបង្កបង្កើនផលកសិកម្ម និងជីវភាពប្រជាជន និងការខិតខំដែលត្រូវបានចាត់ឱ្យមានឡើងប្រឆាំងទៅនឹងសត្រូវរបស់របប ។ ចំពោះការកត់ត្រាខាងឯកសារ ដែលសង្កត់ធ្ងន់ទៅលើតួនាទីជាក់ស្តែងរបស់បុគ្គល ដូចជាអ្នកចូលរួមក្នុងការជាក់ស្តែង ឬថ្នាក់លើ ការណ៍នេះហាក់ដូចជាមានលក្ខណៈទូលំទូលាយណាស់ចំពោះអំពើឃោរឃៅខ្លះ ជាពិសេសបំផុតប្រតិបត្តិការសួរចម្លើយនៅក្នុងមជ្ឈមណ្ឌលទួលស្លែង ។ ចំពោះអំពើឃោរឃៅដ៏ទៃទៀត ភស្តុតាងជាឯកសារដែលជាប់ពាក់ព័ន្ធផ្ទាល់ទៅលើបុគ្គល ទោះបីជានៅថ្នាក់ខ្ពស់ក្នុងរដ្ឋាភិបាល ឬតំបន់ ឬមូលដ្ឋានក្តី មិនអាចរកបានទេនៅពេលនេះ ហើយអាចនឹងមិនអាចនឹងរកឃើញទាល់តែសោះតែម្តង ដោយសារថានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យគេមិនចេះរៀបចំកត់ត្រាឯកសារទុកទេ និងដោយសារថាវាហាក់ដូចជាមានការបាត់បង់ឯកសារជាច្រើន ចាប់តាំងពីឆ្នាំ ១៩៧៩ មក ។

## គ- ភស្តុតាងជាសាក្សី

៥៦- ដូចដែលធ្លាប់បង្ហាញឱ្យឃើញ នៅក្នុងការកាត់ទោសនៅក្នុងស្រុក និងជាអន្តរជាតិ ទៅលើអ្នករំលោភសិទ្ធិមនុស្ស ចាប់តាំអពីសង្គ្រាមលោកលើកទី ២ មក ជាធម្មតាចម្លើយរបស់សាក្សីដែលអាចយកជាការបាន គឺមានសារសំខាន់ណាស់ចំពោះជោគជ័យនៃការកាត់ទោសនោះ ។ ចំពោះករណីនៃប្រទេសកម្ពុជាប្រទេសជាច្រើនគឺជាសាក្សីនៃអំពើឃោរឃៅមួយ ឬអំពើឃោរឃៅណាមួយផ្សេងទៀត មិនថាជាការជន្លៀសប្រជាពលរដ្ឋចេញពីទីក្រុង ការធ្វើការដោយបង្ខំ ឬការសម្លាប់អ្នកដែលមិនព្រមសហការជាមួយរបបគេ ។ ប៉ុន្តែ ដូចជាភស្តុតាងជារូបសាស្ត្រ ត្រូវធ្វើការបែងចែករវាងសាក្ខីកម្មដែលថាវាមានអំពើឃោរឃៅ និងសាក្ខីកម្មដែលភ្ជាប់បុគ្គលដោយឡែកណាមួយទៅនឹងអំពើឃោរឃៅនោះ ។ ដោយឈរលើបទសម្ភាសន៍របស់យើងជាមួយជនកម្ពុជានានា និងជាមួយអ្នកស្រាវជ្រាវដ៏ទៃទៀត ក្រុមអ្នកជំនាញការសង្ឃឹមថាសាក្សីដែលអាចបំភ្លឺទៅលើការកើតមាននូវអំពើឃោរឃៅ និងអត្តសញ្ញាណរបស់បុគ្គលដែលបានប្រព្រឹត្តអាចបង្ហាញឱ្យឃើញអំពីអ្នកដែលអាចបំភ្លឺអំពីតួនាទីរបស់របស់មេដឹកនាំខ្មែរក្រហមដែលនាំឱ្យកើតមានឡើង

នូវអំពើឃោរឃៅ ដោយអ្នកដឹកនាំប្រភេទនេះគួរតែត្រូវជាទិសដៅនៃការស៊ើបអង្កេត និងការកាត់ទោស (នេះជាបញ្ហាមួយ ដែលយើងធ្វើការវិភាគយ៉ាងលំអិតបំផុត នៅក្នុងផ្នែក VII.A. ខាងក្រោមនេះ) ។ ការនេះតម្រូវឱ្យរកឱ្យឃើញមនុស្ស ដែលបានឃើញដោយផ្ទាល់ផ្នែកសកម្មភាពរបស់មេដឹកនាំខ្មែរក្រហម (ដែលជាការផ្ទុយគ្នាយ៉ាងខ្លាំងទៅនឹងមន្ត្រីថ្នាក់ទាប ដែលអាចជាអ្នកប្រព្រឹត្តដោយជាក់ស្តែងនូវអំពើឃោរឃៅ) និងអាចបំភ្លឺ ទៅតាមការយល់ដឹងរបស់ពទកគេ និងបញ្ហាដែលពួកគេបានធ្វើឡើង ។

៥៧- កត្តាដែលកាន់តែស្មុគស្មាញថែមទៀតមួយទាក់ទិនទៅនឹងកសិណសាក្សីនេះ គឺសេចក្តីត្រូវការឱ្យមានការធានាថា រាក្តីកម្មរបស់គេគឺជាការពិត និងបង្កើតឡើងនូវចេតនាមួយចង់បង្វែងផ្លូវរបស់តុលាការ ឬបង្កឱ្យមានការសងសឹកណាមួយទៅលើអ្វីដែលពួកគេបាននិយាយនោះ ។ ក្រុមអ្នកជំនាញការ សង្ឃឹមថាយន្តការណាក៏ដោយសំរាប់ធ្វើឱ្យមានការទទួលខុសត្រូវ នឹងត្រូវរួមបញ្ចូលបទបញ្ញត្តិនៃការការពារសន្តិសុខរបស់សាក្សី ហើយយើងបានពិភាក្សាបន្ថែមធំពីបញ្ហានេះនៅក្នុងផ្នែក X.C ខាងក្រោមនេះ ។ ប៉ុន្តែ ទិសដៅបច្ចុប្បន្ននេះ ទស្សនៈរបស់យើងខ្ញុំ គឺថាបញ្ហានៃការធានាការជឿទុកចិត្ត និងសិវត្ថិភាព របស់សក្សី មិនមែនជាឧបសគ្គដែលដោះស្រាយមិនរួសនោះទេ ក្នុងការបង្កើតឡើងនូវយន្តការច្បាប់មួយសំរាប់ធ្វើការកាត់ទោសពួកខ្មែរក្រហមនោះ ។

## ឃ- សេចក្តីសន្និដ្ឋាន

៥៨- ក្រុមអ្នកជំនាញការ អាចទាញបានសេចក្តីសន្និដ្ឋាន ២ ដោយឡែកពីគ្នា ។ ទី ១ ភស្តុតាងដែលប្រមូលបានរហូតមកទល់ពេលនេះដោយអ្នកស្រាវជ្រាវ អ្នកសិក្សា មជ្ឈមណ្ឌលឯកសារ និងអ្នកដ៏ទៃទៀតបានបង្ហាញឱ្យឃើញយ៉ាងច្បាស់ដល់គណៈកម្មការ អំពីឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ ទៅលើច្បាប់អន្តរជាតិ និងច្បាប់កម្ពុជា ។ សេចក្តីសន្និដ្ឋាននេះ ត្រូវបានកំណត់ឡើងដោយល្អិតល្អន់ថែមទៀត នៅក្នុងការវិភាគរបស់យើងទៅលើក្រមព្រហ្មទ័ណ្ឌមានពាក់ព័ន្ធ ក្នុងផ្នែកទី ៥ ខាងក្រោមនេះ ។ ទី ២ ក្រុមអ្នកជំនាញការមានមតិថាបច្ចុប្បន្នមានភស្តុតាងខាងរូបសាស្ត្រ និងខាងសាក្សីគ្រប់គ្រាន់ហើយ ឬអាចកំណត់ទីកន្លែងនៅក្នុងប្រទេសកម្ពុជា វៀតណាម ឬទីណាដ៏ទៃទៀត ដើម្បីកំណត់នូវនីតិវិធីច្បាប់ ប្រឆាំងទៅលើពួកមេដឹកនាំខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មទាំងនេះបានហើយ ។ ទាំងនេះទាមទារឱ្យមានការប្រើប្រាស់ពេលវេលាដ៏ច្រើនមួយ សំរាប់

អ្នកស៊ើបអង្កេតដ៏ជំនាញ ប៉ុន្តែយើងខ្ញុំមិនគិតថា ស្ថានភាពនៃភស្តុតាងមានអ្វីមួយធ្វើឱ្យមានឧបសគ្គដល់ការចោទប្រកាន់នោះទេ ។ ផលប្រយោជន៍ចុងក្រោយបំផុតនៃភស្តុតាងជាពិសេស គឺអាស្រ័យទៅលើក្រិត្យក្រមនៃភស្តុតាង និងបទបញ្ញត្តិសំរេចដោយតុលាការណាមួយនោះទេ ដែលជាបញ្ហាមួយដែលយើងនឹងលើកយកមកនិយាយ នៅក្នុងផ្នែកទី X.B. ខាងក្រោមនេះ ។

## V- ប្រភេទនៃឧក្រិដ្ឋកម្ម នៃអំពើដែលបានប្រព្រឹត្ត

៥៩- ដោយមានការកត់ត្រាទុកដែលប្រមូលបានដោយពួកអ្នកប្រវត្តិវិទូ និងភស្តុតាងជារូបសាស្ត្រ និងជាឯកសារ ដែលប្រមូលបានរហូតមកទល់ពេលនេះ វាជាការចាំបាច់ដែលឥឡូវនេះ ត្រូវត្រឡប់ទៅមើលខាងផ្នែកច្បាប់សំខាន់ ៗ ទាក់ទិនទៅនឹងការទទួលខុសខាងផ្នែកព្រហ្មទ័ណ្ឌ ចំពោះអំពើទាំងឡាយដែលបានរៀបរាប់មកខាងលើនេះ ។ ការពិនិត្យមួយបែបនេះ គឺជាការចាំបាច់សំរាប់ចាប់ឱ្យមន្ត្រីខ្មែរក្រហម ទទួលខុសត្រូវចំពោះអំពើរបស់ពួកគេ ។

៦០- មុននឹងនិយាយដល់ច្បាប់មានពាក់ព័ន្ធ ត្រូវលើកឡើងនូវចំណុច ៣ ជាបឋម ។ ទី ១ ទាំងចំពោះច្បាប់អន្តរជាតិ ទាំង ចំពោះក្នុងស្រុក ព្រំដែនរបស់វាគឺថា ពុំមានបទល្មើសព្រហ្មទ័ណ្ឌទេ បើបទល្មើសមិនត្រូវបានប្រព្រឹត្តទេនោះ - គោលការណ៍ទូទៅនៃច្បាប់ ហាមមិនឱ្យកំណត់ថាមានកំហុសទេចំពោះអំពើ ដែលមិនត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្ម នៅពេលដែលអំពើនោះបានប្រព្រឹត្តឡើង - ទាមទារឱ្យមើលនៅក្នុងច្បាប់អន្តរជាតិ និងច្បាប់ជាតិ ដែលកំពុងអនុវត្តនៅក្នុងឆ្នាំ ១៩៧៥ នៅពេលដែលពួកខ្មែរក្រហមចាប់ផ្ដើមការត្រួតត្រារបស់ពួកគេ ជាជាងបច្ច័យរបស់វានាពេលបច្ចុប្បន្ននេះ ។ ទី ២ ការពិនិត្យទៅលើច្បាប់ណាមួយនៅក្នុងរបាយការណ៍ណាមួយដូចជារបាយការណ៍នេះនោះ ត្រូវតម្រង់ទិសឆ្ពោះទៅកាន់តែការកំណត់ថាតើភស្តុតាងត្រឹមត្រូវឬទេ ខាងផ្លូវច្បាប់ ក្នុងការបញ្ចូលឧក្រិដ្ឋកម្មនានាទៅក្នុងយុត្តាធិការរបស់តុលាការមួយដែលនឹងត្រូវកាត់ ទោសមេដឹកនាំខ្មែរក្រហមនោះ ។ វាមិនអាចដើរទៅដល់សេចក្ដីសន្និដ្ឋាន ស្ដីពីថាតើមានភស្តុតាងគ្រប់គ្រាន់ហើយឬនៅដើម្បីធ្វើការចោទប្រកាន់ទៅលើបុគ្គលដោយឡែកណានោះ ត្រូវទុកឱ្យភស្តុតាងវាបញ្ជាក់ខ្លួនវានូវការរកឃើញនៃកំហុស ។ ការរកឃើញទៅទីបំផុត ទាក់ទិនទៅនឹងកំហុសរបស់បុគ្គល ទាមទារនូវការពិនិត្យនូវភស្តុតាងលំអិតដែលចាតិទុកថាទទួលយកបានដោយវេទិកាពិសេសមួយ ទៅលើ

ព្រឹត្តិការណ៍ច្បាស់លាស់ និងតួនាទីរបស់តួអង្គបុគ្គលនៅក្នុងព្រឹត្តិការណ៍នោះ ។ ទី ៣ ផ្នែកនេះមិនត្រូវធ្វើការផ្តល់មតិ ចំពោះតើឧក្រិដ្ឋប្រភេទណាត្រូវបញ្ចូលទៅក្នុងយុត្តាធិការរបស់តុលាការ តែគ្រាន់តែអាចនិយាយបានថាឧក្រិដ្ឋកម្មបែបណាដែលហាក់ដូចជាត្រឹមត្រូវខាងផ្លូវច្បាប់សំរាប់បញ្ចូលវាទៅក្នុងនោះបាន ។ ចំពោះការស្នើយោបល់របស់យើងខ្ញុំស្តីពីបញ្ហាប្រភេទតុលាការដែលត្រូវបង្កើតឡើងនោះ យើងខ្ញុំទុកនិយាយនៅចុងរបាយការណ៍នេះ ។

## ក- អំពើដែលនាំមកនូវការទទួលខុសត្រូវពីបទព្រហ្មទ័ណ្ឌរបស់បុគ្គល តាមច្បាប់អន្តរជាតិ

### ១- អំពើប្រល័យពូជសាសន៍

៦១- អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឆ្នាំ ១៩៤៨ ប្រកាសថា អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មមួយ ស្ថិតនៅក្រោមច្បាប់អន្តរជាតិ និងកំហិតឱ្យរដ្ឋនានាផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ដែលបានកើតមានឡើងនៅលើទឹកដីរបស់ខ្លួន ។ និយមន័យរបស់ពាក្យប្រល័យពូជសាសន៍ មានកត្តា ៣ ជាចំបង គឺ:

(ក) ជនជាប់ចោទបានប្រព្រឹត្តនូវអំពើមួយចំនួន - ឃាតកម្ម ការធ្វើឱ្យប៉ះពាល់ដ៏ធ្ងន់ធ្ងរលើរូបរាងកាយ ឬខាងផ្លូវចិត្ត ការធ្វើឱ្យរបួសដោយចេតនាដល់ស្ថានភាពនៃជីវិតបណ្តាលទៅឱ្យមានការកំទេចខាងរូបរាងកាយ បង្ខំដាក់វិធានការក្នុងបំណងបង្ការកុំឱ្យមានការចាប់កំណើត និងបង្ខំយកកុមារចេញពីគុមរបស់គេ។

(ខ) ជនជាប់ចោទបានប្រព្រឹត្តដូចខាងលើ ប្រឆាំងទៅនឹង "ជនជាតិ ជាតិពន្ធ ពូជសាសន៍ ឬក្រុមសាសនា" ណាមួយ ។

(គ) ជនជាប់ចោទបានប្រព្រឹត្តអំពើទាំងនេះ "ក្នុងបំណងចង់កំទេច ទាំងមូល ឬដោយផ្នែក" ក្រុមមួយក្នុងចំណោមក្រុមទាំងនេះ "ដូចគ្នា" [៩] ។

៦២- ប្រទេសកម្ពុជា គឺជាភាគីមួយនៃអនុសញ្ញានេះ ដោយពុំមានធ្វើការរក្សាមតិអ្វីទាំងអស់ ចាប់តាំងពីអនុសញ្ញានេះបានចូលជាធរមានភាព ក្នុងឆ្នាំ ១៩៥១ មក [១០] ។ កម្ពុជាប្រជាធិបតេយ្យ ហាក់ដូចជាមិនដែលបានបកអាក្រាតសោះ នូវអនុសញ្ញានេះ នៅពេលខ្លួនកាន់អំណាច ។ នៅក្នុងរយៈពេលនៃការកាន់អំណាចរបស់ពួកខ្មែរក្រហម រដ្ឋាភិបាលហាក់ដូចជាបានធ្វើទៅប្រជាពលរដ្ឋកម្ពុជា នូវអំពើដែលបានរៀបរាប់នៅក្នុងអនុសញ្ញាស្ទើរតែទាំងអស់ ។ កិច្ចការលំបាកបំផុត គឺការកំណត់ថាតើពួកខ្មែរក្រហម បានប្រព្រឹត្តអំពើទាំងនេះដោយចេតនា និងប្រឆាំងទៅនឹងក្រុមដែលត្រូវបានការពារដោយអនុសញ្ញានេះ ឬយ៉ាងណា ។

៦៣- តាមទស្សនៈរបស់ក្រុមអ្នកជំនាញការ ការស្រាវជ្រាវខាងប្រវត្តិសាស្ត្រដែលមានស្រាប់នោះ គឺត្រឹមត្រូវ ដោយរួមទាំងអំពើប្រល័យពូជសាសន៍ ដែលមាននៅក្នុងយុត្តាធិការនៃតុលាការមួយ ដើម្បីធ្វើការចោទប្រកាន់ទៅលើមេដឹកនាំខ្មែរក្រហមផង ។ ជាពិសេស ភស្តុតាងតម្រូវឱ្យមានព្រះរាជអាជ្ញា ដើម្បីធ្វើការស៊ើបអង្កេតគណៈកម្មការប្រល័យពូជសាសន៍ ប្រឆាំងទៅលើជនជាតិចាម វៀតណាម និងក្រុមជនជាតិភាគតិចដ៏ទៃទៀត និងព្រះសង្ឃព្រះពុទ្ធសាសនាផង [១១] ។ ពួកខ្មែរក្រហមដាក់ក្រុមទាំងនេះឱ្យនៅក្រោមវិធានការ

---

[៩] សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ 260 A (III) ឧបសម្ព័ន្ធ មាត្រាទី ២ ។

[១០] <u>សន្និសញ្ញាពហុភាគីដំកល់ទុកនៅជាមួយលោកអគ្គលេខាធិការ</u> (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ Sale No E.98.V.2)

[១១] សូមមើល របាយការណ៍ពិនិត្យឡើងវិញ ស្តីពី បញ្ហាបង្ការ និងការផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មប្រល័យពូចសាសន៍ រៀបចំឡើងដោយលោក វ៉ាយថេខឺរ ថ្ងៃទី ២ ខែកក្កដា ឆ្នាំ ១៩៨៥ E/CN.4/Sub.2/1985/6) ហាន់ណុន ដូចបានរៀបរាប់ខាងលើ ទំព័រ ១១០-១២ ឃៃរណាន; (1994) ដូចបានរៀបរាប់ខាងលើ ទំព័រ ១៩១-៩៣ ។ តែសូមមើល ដេវីដ ឆេនឡឺរ <u>ប្រវត្តិសាស្ត្រមួយនៃប្រទេសកម្ពុជា ទំព័រ ២១៨-១៩ (ប៊ូលឌ័រ រេងពុម្ព វ៉ែសវីយូ ១៩៩២) ។</u>

១២ <u>សូមមើល</u> e.g. ឃៃរណាន់ (១៩៩៤បានរៀបរាប់ខាងលើ ទំព័រ ១៩១-៩៣ ហាន់ណុម រៀបរាប់ខាងលើ ទំព័រ ១១០-១២ ខាធ្រិន វ៉ែសបាក់ "សកម្មភាពរបស់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ប្រឆាំងទៅលើពួកខ្មែរក្រហមៈ ការបង្កានូវការកើតឡើងវិញវ៉ៃវាលពិឃាត" <u>ច្បាប់អន្តរជាតិនៃកាសែតកុនណិកទីគុត</u> សៀវភៅទី ៥ ទំព័រ ៤៥៧ ៤៦៥ (១៩៩០) ។ តែ សូមមើល ឆាន់ឡឺរ (១៩៩២) ដូចបានរៀចរាប់ខាងលើ ។ ស្តីពីគោលបំណងទាញយកមកវិញ សូមមើល ព្រះព្រជអាជ្ញា អាកាយេស៊ូ សេចក្តីសំរេច តុលាការព្រហ្មទ័ណ្ឌអន្តរជាតិ សំរាប់ប្រទេសរ្វាន់ដា បន្ទប់កាត់សេចក្តី ថ្ងៃទី ២ ខែកញ្ញា ១៩៩៨ វាក្យខ័ណ្ឌ ៥២៣ ។

ឃោរឃៅ និងយ៉ាងខ្លាំងជាពិសេស នូវអំពើដែលបានរៀនរាប់នៅក្នុងអនុសញ្ញា ។ ការតម្រូវដោយបង្ខំនេះ មានភស្តុតាងដោយផ្ទាល់ និងដោយប្រយោល រួមមានសេចក្តីថ្លែងការណ៍នានារបស់ខ្មែរក្រហម ការរៀបរាប់របស់សាក្សីដែលបានឃើញផ្ទាល់ភ្នែក ព្រមទាំងប្រភេទ និងចំនួននៃជនរងគ្រោះក្នុងក្រុមនិមួយៗ ទាំងក្នុងន័យ ជារួម និងទាំងក្នុងចំនួនប្រភាគនៃប្រជាពលរដ្ឋក្នុងក្រុមនិមួយ ៗ [១២] ។ ក្រុមទាំងនេះត្រូវបានកំណត់ថាជា ក្រុមត្រូវទទួលបាននូវការការពារ នៅក្នុងអនុសញ្ញាៈ ក្រុមចាម មូស្លីម គឺជាក្រុមជាតិពន្ធ និងសាសនា សហ គមន៍វៀតណាមជាជនជាតិភាគតិច និងប្រហែលជាក្រុមជាតិសាសន៍មួយផង ហើយនឹងលោកសង្ឃព្រះពុទ្ធ សាសនា គឺជាក្រុមសាសនាមួយ ។

៦៤- ជាពិសេស នៅក្នុងករណីព្រះសង្ឃខាងពុទ្ធសាសនា គោលបំណងរបស់ពួកគេគឺច្បាស់ណាស់ តាមរយៈនៃសេចក្តីថ្លែងការណ៍ជាសត្រូវដ៏ខ្លាំងក្លារបស់ពួកខ្មែរក្រហមទៅលើសាសនា និងទៅលើព្រះសង្ឃព្រះពុទ្ធសាសនាជាពិសេស នយោបាយរបស់ពួកខ្មែរក្រហម គឺបំបាត់ទាំងទិដ្ឋភាព និងការប្រណិបត្តិ ខាងព្រះពុទ្ធសាសនា ដោយការចាប់ផ្សឹកលោកសង្ឃ និងការបំបាត់លោកសង្ឃ ចំនួនអ្នករងគ្រោះ និងការសម្លាប់អ្នកដឹកនាំព្រះពុទ្ធសាសនា និងលោកសង្ឃដែលកែមិនឡើង ។ ដូចគ្នានេះដែរ បន្ថែមពីលើជនរងគ្រោះ ទិសដៅកំទេចជនជាតិចាម និងជនជាតិភាគតិចដ៏ទៃទៀត ហាក់ដូចជាមានការច្បាស់លាស់ណាស់ ដោយអំពើបែបនេះរបស់ពួកខ្មែរក្រហម ដូចជានយោបាយរបស់ពួកគេធ្វើឱ្យមានសភាពដូច ៗ គ្នា ការហាមឃាត់ជាស្ថាពរនូវក្រុមដែលមានវប្បធម៌ដោយឡែក ៗ ការបំបែកពួកគេឱ្យទៅរស់នៅជាមួយប្រជាពលរដ្ឋជាទូទៅ និងការសម្លាប់មេដឹកនាំរបស់ពួកគេ [១៣] ។

៦៥- ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងប្រឆាំងទៅលើប្រជាពលរដ្ឋកម្ពុជាជាទូទៅ ពួកអ្នកធ្វើអត្ថាធិប្បាយខ្លះ បានអះអាងថាពួកខ្មែរក្រហម បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ប្រឆាំងទៅលើក្រុមជន

---

[១៣] សូមមើល ហឿក ហានុម និងដេវីដ ហ៊ក ករណីប្រឆាំងនឹងគណៈកម្មាធិការអចិន្ត្រៃយ៍របស់គណបក្សកុម្មុយនិសកម្ពុជា ថ្ងៃទី ១៥ ខែកញ្ញា ១៩៨៦ ទំព័រ ១៤៧-៤៩ (ពង្រាង ជំនួនស្មារតី រៀបចំឡើងដើម្បីករណីដែលអាចមានតុលាការអន្តរជាតិ ប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ) ។

ជាតិខ្មែរ ក្នុងបំណងកំទេចពួកនេះចោលមួយផ្នែក [១៤] ។ ប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសកម្ពុជា គឺជាជនជាតិមួយក្រុម ដូចដែលបានចែងនៅក្នុងអនុសញ្ញា ។ ក៏ប៉ុន្តែ អ្វីដែលពួកខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ចំពោះផ្នែកនៃក្រុមជនជាតិខ្មែរ បណ្តាលឱ្យមានបញ្ហាបកស្រាយយ៉ាងស្មុគ្រស្មាញ ជាពិសេសទាក់ទិនទៅនឹងគោលបំណងរបស់ពួកខ្មែរក្រហម ចំពោះជនរងគ្រោះនៅក្នុងក្រុមដែលមិនមែនជាជនជាតិភាគតិចរបស់ខ្លួននោះ ។ ក្រុមនេះឥតបានប្រកាន់ជំហរអ្វីមួយទេនៅក្នុងបញ្ហានេះ តែសង្ឃឹមថាតុលាការណាមួយដែលត្រូវដោះស្រាយបញ្ហានេះ ត្រូវតែចោទប្រកាន់មន្ត្រីខ្មែរក្រហមអំពីបទប្រល័យពូជសាសន៍ ប្រឆាំងនឹងក្រុមជនជាតិខ្មែរ ។

## ២- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

៦៦- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំណត់ច្រើនបែបយ៉ាង នៅក្នុងឯកសារអន្តរជាតិសំខាន់ ៗ នានា - នៅក្នុងធម្មនុញ្ញរបស់តុលាការយោធាអន្តរជាតិ នៅក្នុងច្បាប់របស់ក្រុមប្រឹក្សាត្រួតពិនិត្យសហព័ន្ធលេខ ១០ នៅក្នុងលក្ខន្តិកៈតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងនៅក្នុងតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ្វាន់ដា នៅក្នុងពង្រាងក្រមព្រហ្មទ័ណ្ឌប្រឆាំងនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សលោករបស់គណៈកម្មការច្បាប់អន្តរជាតិ ឆ្នាំ ១៩៩៦ ហើយនឹងកាលពីពេលថ្មី ៗ បំផុតនេះលក្ខន្តិកៈតុលាការព្រហ្មទ័ណ្ឌអន្តរជាតិទីក្រុងរ៉ូម ។ ទោះបីជាយ៉ាងណាក៏ដោយ គេអាចមើលឃើញកត្តាធំ ៗ ចំនួន ៥ ដែលហាក់ដូចជាអាចចាត់ទុកថាជានិយមន័យមួយ ឬច្រើនបាន -ទោះបីជាវាមិនមែនទាំងអស់ក៏ដោយ-របស់ពាក្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពោលគឺ:

(ក) អំពើនានាដែលមានពាក់ព័ន្ធដល់ការវាយដំដ៏ធ្ងន់ធ្ងរម្តង ឬច្រើនដង ទៅលើបុគ្គលណាម្នាក់ រួមមានការសម្លាប់ ការធ្វើឱ្យសាបសូន្យ ការនិរទេសខ្លួន ការចាប់រំលោភ ព្រមទាំងអំពើអមនុស្សធម៌ដទៃទៀត និងការធ្វើទុក្ខបុកម្នេញប្រភេទផ្សេង ៗ ដទៃទៀត ។

[១៤] សូមមើល ដេវីដ ហ៊ក "ការប្រល័យពូជសាសន៍កម្ពុជា" នៅក្នុងអ៊ីស្រាអែល ឆានី ការប្រល័យពូជសាសន៍ ទស្សនាវដ្តីបណ្ណាល័យទិទ្បេន ទំព័រ ១៣៧ ១៣៩-៤០ (ញ៉ូវយក្ស ព្រឹត្តិការណ៍ជាក់ស្តែងនៃការផ្សព្វផ្សាយឯកសារ ឆ្នាំ ១៩៨៨) ឃៃរណាន់ (១៩៩៤) ដូចបានរៀបរាប់ខាងលើ ទំព័រ ២០១-០២ ហានុន ដូចបានរៀបរាប់ខាងលើ ទំព័រ ១១១-១២ ។

(ខ) អំពើទាំងនេះ អាចមានលក្ខណៈជាចំនួនច្រើន ឬជាខ្សែសង្វាក់ ប្រឆាំងទៅលើប្រជាពលរដ្ឋស៊ីវិលណាម្នាក់ ។

(គ) អំពើទាំងនេះ អាចត្រូវបានប្រព្រឹត្តឡើងដោយមូលហេតុនៃការរើសអើង ដោយឈរលើពូជសាសន៍ សាសនា ទស្សនៈនយោបាយ ឬកេតនភ័ណ្ឌដ៏ទៃទៀតរបស់ប្រជាពលរដ្ឋ ។

(ឃ) អំពើទាំងនេះ អាចពាក់ព័ន្ធទៅនឹងសកម្មភាពរបស់រដ្ឋាភិបាល ។

(ង) អំពើទាំងនេះ បានត្រូវបានប្រព្រឹត្តឡើងនៅក្នុងពេលមានជម្លោះដោយអាវុធ ។

ដូចបានកត់សំគាល់ខាងលើ ការទទួលខុសត្រូវរបស់ពួកខ្មែរក្រហម ត្រូវកំណត់ដោយឈរលើច្បាប់ដែលមានរហូតមកទល់ឆ្នាំ ១៩៧៩ ដោយមិនគិតពីការវិវត្តន៍របស់ច្បាប់អន្តរជាតិចាប់តាំងពីក្រោយពេលនោះមកទេ ។

៦៧- ចំពោះអំពើដែលបានប្រព្រឹត្តឡើង (កត្តា ក ខាងលើ) ការកត់ត្រាខាងប្រវត្តិសាស្ត្រ និងខាងភស្តុតាង នាំឱ្យយល់ថាគឺជាករណីនៃការសម្លាប់ (ដែលមានកំរិតខ្លាំងរហូតដល់ការកំទេចអ្នកនយោបាយប្រឆាំង) ការបង្ខំឱ្យធ្វើការជាទម្ងន់ ទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត ។ ចំពោះការជន្លៀសប្រជាពលរដ្ឋដោយបង្ខំ ភស្តុតាងបានបញ្ជាក់ឱ្យឃើញថា វាជាមធ្យោបាយដ៏ឃោរឃៅ និងខុសច្បាប់ នៃការអនុវត្តន៍ផែនការ ក៏ដូចជាបំណងមិនត្រឹមត្រូវមួយប្រឆាំងទៅលើអ្នករស់នៅក្នុងទីក្រុង ។

៦៨- ចំពោះលក្ខណៈជាការប្រមូលផ្តុំ ឬជាខ្សែសង្វាក់ នៃអំពើទាំងនេះ ( កត្តា ខ ខាងលើ) ភាគច្រើននៃ អំពើទាំងនេះហាក់ដូចជា ផ្នែកមួយនៃនយោបាយដោយចេតនា ដែលត្រូវបានដឹងឮជាទូទៅ ។ នៅក្នុងពេល ជាមួយគ្នានេះ មនុស្សខ្លះបានលើកឡើងថា អំពើឃោរឃៅជាច្រើន ជាពិសេសនៅតំបន់ដាច់ស្រយ៉ាល មានការខ្វះខាតនូវការណែនាំ

និងមិនបានធ្វើអ្វីដោយប្រសិទ្ធភាពចំពោះអំពើឃោរឃៅដ៏ងងឹតងងល់នេះ[១៥] ។ តែបើរដ្ឋាភិបាលមិនបានធ្វើអ្វីនៅចំពោះមុខនៃអំពើបែបនេះទេនោះ វាគឺជាមូលហេតុនៃការស្អប់ខ្ពើមចំពោះជនរងគ្រោះខាងនយោបាយ ឬជនដ៏ទៃទៀតណាមួយ ការណ៍នេះវាដូចគ្នាទៅនឹងការធ្វើដោយខ្មែរសង្គ្រាក់ដែរ ។

៦៩- ចំពោះមូលហេតុ (កត្តា គ ខាងលើ) - ការសំអប់ចំពោះជនរងគ្រោះ - យោងតាមឯកសារច្បាប់សំខាន់ ៧ ដែលកំណត់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាគឺជាមូលហេតុដែលមិនទាក់ទិនទៅនឹងការវាយដំយ៉ាងធ្ងន់ធ្ងរខ្លះទៅលើមនុស្ស ដូចជាការសម្លាប់ ឬទារុណកម្មទេ ដូច្នេះសកម្មភាពជាច្រើនរបស់ពួកខ្មែរក្រហម ទោះបីជាការប្រឆាំងទៅលើអ្នកដែលមិនត្រូវបានមើលឃើញថាជាសត្រូវនយោបាយក៏ដោយ ក៏នឹងត្រូវបានបិទបាំងទាំងអស់[១៦] ។ ទោះបីមូលហេតុនេះគឺជាកត្តាមួយសំរាប់ឧក្រិដ្ឋកម្មទាំងអស់ប្រឆាំងមនុស្សជាតិក៏ដោយ ក៏ទស្សនៈរបស់ជនរងគ្រោះត្រូវបញ្ចូលទៅក្នុងចំណោមបញ្ជីនៃមូលហេតុនានា ហើយកត្តានេះហាក់ដូចជាសំរាប់បំពេញចិត្តអំពើជាច្រើននៃរបបតែប៉ុណ្ណោះ ។ ទាំងនេះមានរួមបញ្ចូលអំពើឃោរឃៅប្រឆាំងទៅលើមនុស្សចំនួនច្រើនរាប់រយពាន់នាក់ ដែលត្រូវរបបកំណត់ថាជាសត្រូវនយោបាយរបស់គេ ។ អំពើប្រឆាំងជនជាតិចាម វៀតណាម និងជនជាតិភាគតិចដ៏ទៃទៀត នឹងត្រូវកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដោយមិនចាំបាច់ពន្យល់ ដូចដែលអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍តម្រូវនោះទេ ដែលរបបមាន បំណងកំទេចពួកគេចោល ។

៧០- ចំពោះវិធានការរបស់រដ្ឋវិញ (កត្តា ឃ ខាងលើ)[១៧] វាហាក់ដូចជាការធ្វើតាមភស្តុតាងនៃខ្មែរសង្គ្រាក់និយម ដោយសារថាមានតែរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមួយប៉ុណ្ណោះទេ មានការត្រួតត្រាប្រទេស ដែលត្រូវការប្រព្រឹត្តនូវអំពើទាំងនេះបាននោះ ។ វិធានការរបស់អាជ្ញាធរតាមភូមិភាគ ក៏អាចយកជា

---

[១៥] សូមមើល ទស្សនៈប្រឆាំងគ្នា រៀបរាប់ដោយ បែនឃៃណាន់ (១៩៩៤) ដូចបានរៀបរាប់ខាងលើ ទំព័រ ២០៥-០៦ ។

[១៦] ធម្មនុញ្ញតុលាការយោធាអន្តរជាតិនៅនុយរំប៊ែរ មាត្រាទី ៦ (គ) ច្បាប់របស់ពួកណាហ្ស៊ី និងអ្នករួមចំណែកជាមួយពួកណាហ្ស៊ី ៥៧១០/១៩៥០ មាត្រាទី ១ (ខ) (អ៊ីស្រាអែល) ។

[១៧] កត្តានេះមិនមានការចាំបាច់សំរាប់បច្ចុប្បន្ននេះទេ ។ សូមមើល លក្ខន្តិកៈតុលាការព្រហ្មទ័ណ្ឌអន្តជាតិសំរាប់ប្រទេសវ៉្វាន់ដា មាត្រាទី ៣ លក្ខន្តិកៈតុលាការព្រហ្មទ័ណ្ឌអន្តរជាតិ មាត្រាទី ៧ ។

ការបានដែរ ដូចជាការអនុវត្តន៏នយោបាយតាមរយៈសាខារបស់បក្ស ជាជាងទីភ្នាក់ងារជាផ្លូវការរបស់រដ្ឋ ដោយសារថាបក្សគឺជាអ្នកត្រួតត្រាលើរដ្ឋ ។

៧១- ជាចុងក្រោយ ការទាមទារឱ្យមានការទាក់ទងទៅនឹងជម្លោះដោយអាវុធ (កត្តា ង ខាងលើ) បានចាប់ផ្តើមមានជាមួយធម្មនុញ្ញនុយ៉រមបឺរ និងត្រូវបានបញ្ជាក់ដោយទាំងតុលាការយោធាអន្តរជាតិ និងតុលាការក្រុមប្រឹក្សាត្រួតពិនិត្យខាងច្បាប់របស់សម្ព័ន្ធមិត្តលេខ ១០ [១៨] ។ ការផ្លាស់ប្តូរដ៏សំខាន់បំផុតមួយ នៅក្នុងច្បាប់នេះចាប់តាំងពីឆ្នាំ ១៩៤៥ មក គឺការបំបាត់នូវការទាក់ទងគ្នាដ៏សាំញ៉ាំនៅក្នុងនិយមន័យនានា នាសម័យបច្ចុប្បន្នរបសលពាក្យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បើសិនជាភាពស្មុគ្រស្មាញនោះ នៅតែត្រូវទាមទារឱ្យដូចជាកាលពីឆ្នាំ ១៩៧៥ ភាគច្រើនលើសលប់នៃអំពើឃោរឃៅរបស់ពួកខ្មែរក្រហម មិនត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ។ ពួកអ្នកប្រវត្តិវិទូ បានភ្ជាប់ទ្រង់ទ្រាយនៃភាពឃោរឃៅ របស់ពួកខ្មែរក្រហមទៅនឹងជម្លោះខាងយោធា ដែលពួកគេបានធ្វើនោះ (ជាមួយវៀតណាម ឬជាមួយពួកឧទ្ទាមនៅក្នុងស្រុក ដូចជាពួកភូមិភាគបូព៌ាជាដើម )លើកលែងតែការពោលសង្កត់ថា ទស្សនៈខ្លួនទីពឹងខ្លួននៃអ្នកដឹកនាំខ្មែរក្រហម ដែលបញ្ចូលកត្តានៃការសំអប់ជនបរទេស និងជនវៀតណាម ដែលពួកគេបានសំដែងចេញតាមរូបភាពផ្សេង ៗ រួមមានការសម្លាប់មនុស្សជាច្រើននាក់ដោយចោទប្រកាន់ថាជាភ្នាក់ងាររបស់វៀតណាម [១៩] ។ ក៏ប៉ុន្តែ ក្រុមអ្នកជំនាញការមានជំនឿជឿជាក់ថា ដើម្បីជាទិសដៅកំណត់ នូវយុត្តាធិការនៃតុលាការណាមួយ ដែលត្រូវកាត់ទោសពួកមន្ត្រីខ្មែរក្រហមនោះ ការដាក់បញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាការត្រឹមត្រូវតាមផ្លូវច្បាប់ ។ ចំណងរវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះដោយអាវុធត្រូវកំណត់ត្រឹមឆ្នាំ ១៩៧៥ ។ ការវិវត្តន៏ជាគន្លឹះមួយចំនួន ចាប់តាំងពីសង្គ្រាមលោកលើកទី ២ មក

---

[១៨] ធម្មនុញ្ញតុលាការយោធាអន្តរជាតិនូរំបឺរ មាត្រាទី ៦ (គ) ការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាមធំ ៗ ដោយតុលាការយោធាអន្តរជាតិ សៀវភៅទី ២២ ទំព័រ ៤៩៨ ៥៤៧-៤៩ ៥៦៣-៦៦ (១៩៤៦) សហរដ្ឋអាមេរិក V. Flick et al. ការកាត់ទោសឧក្រិដ្ឋកម្ម សង្គ្រាម នៅចំពោះមុខតុលាការនូរំបឺរ តាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យ លេខ ១០ សៀវភៅទី ៦ ទំព័រ ១១៨៧ ១២១៣ (១៩៤៧) តែសូមមើល សហរដ្ឋអាមេរិក v. Ohlendorf et al. ការកាត់ទោសឧក្រិដ្ឋកម្មសង្គ្រាម នៅចំពោះមុខតុលាការយោធា នូរំបឺរ តាមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ សៀវភៅលេខ ៤ ទំព័រ ៤១១ ៤៩៩ (១៩៤៨) ។

[១៩] សូមមើល ហ្សាក់សុន "ឧត្តមគតិ នៃបដិវត្តន៏សព្វមុខ" ដូចបានរៀបរាប់ខាងលើ ទំព័រ ៣៩-៤៩ ឃៃរណាន់ (១៩៩៦) ទំព័រ ៦៥-១២៥ ។

វាបញ្ជាក់ អំពីចលនាមួយបែបនេះ ។ ទី ១ ទស្សនៈរបស់ប្រទេសនានា ក្នុងពេលធ្វើសេចក្តីព្រាងអនុសញ្ញាឆ្នាំ ១៩៦៨ ស្តីអំពីការមិនអនុវត្តន៍ ការកំរិតព្រំដែនលក្ខន្តិកៈ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នាំឱ្យយល់ថា ភាពស្មុគ្រស្មាញ មិនជាការចាំបាច់ទេ[២០] ។ ទី ២ គណៈកម្មការច្បាប់អន្តជាតិ បានបោះបង់ ចោលភាពស្មុគ្រស្មាញនៅក្នុងជម្លោះដោយអាវុធ នៅក្នុងពង្រាងច្បាប់ស្តីពីបទល្មើសប្រឆាំងទៅនឹងសន្តិភាព និងសន្តិសុខរបស់មនុស្សលោក ឆ្នាំ ១៩៥៤[២១] ។ និន្នាការដែលត្រូវបានរឹងប៉ឹងមកដល់សព្វថ្ងៃនេះ គឺបានកើត មានឡើងកាលពីឆ្នាំ ១៩៧៥ ដោយហេតុនេះហើយបានជាថាការកាត់ទោសមេដឹកនាំខ្មែរក្រហម ចំពោះបទ រំលោភបែបនោះ នឹងមិនមែនជាការរំលោភទៅនឹងការបកស្រាយដោយត្រឹមត្រូវ និងសមហេតុសមផល នៃគោលការណ៍ការចាត់ទុកឧក្រិដ្ឋកម្មជាមោឃៈ នោះទេ ។

## ៣- ឧក្រិដ្ឋកម្មសង្គ្រាម

៧២- វិស័យនេះនៃច្បាប់ ស្ថិតនៅត្រឹមត្រូវដដែល ពីព្រោះអំពើឃោរឃៅរបស់ពួកខ្មែរក្រហម បានកើតមានឡើង នៅក្នុងពេលមានសង្គ្រាមជាមួយរដ្ឋដ៏ទៃទៀត ជាពិសេសជាមួយវៀតណាម ក៏ដូចជាជាមួយកម្លាំងអ្នកតស៊ូនៅក្នុងស្រុកខ្លះដែរ ជាសំខាន់នៅក្នុងពេលមួយឆ្នាំកន្លះចុងក្រោយនៃការកាន់អំណាចរបស់ពួកគេ ។ នៅក្នុងពេលជាមួយគ្នានេះដែរ ទិដ្ឋភាពនេះនៃសកម្មភាពរបស់ពួកខ្មែរក្រហម គឺគ្រាន់តែជាផ្នែកតូចមួយនៃការរំលោភសិទ្ធិមនុស្សរបស់ពួកគេតែប៉ុណ្ណោះ ។

៧៣- ប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម សុទ្ធតែជាភាគីនៃអនុសញ្ញាទាំង ៤ នៃទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ទាំងអស់គ្នា នៅក្នុងរយៈពេលនៃការចេញផ្សាយអនុសញ្ញាទាំងនេះ ទោះបីជាគ្មានភាគីណាមួយបាន

---

[២០] ជាឧទាហរណ៍ សូមមើល ស្ទីវិន រ៉ាត់ណើរ និងហ្សេសុន អាប្រាម ការទទួលខុសត្រូវចំពោះអំពើឃោរឃៅទៅសិទ្ធិមនុស្ស នៅក្នុងច្បាប់អន្តរជាតិ : អ្វីដែលទៅហួសពីកេរ្តិ៍ដំណែលនូរំប៊ែរ ទំព័រ ៩៣-៩៤ (អុកស្វ៊ត: រោងពុម្ពខ្លៃរ៉ាន់ដុន ១៩៩៧) ។

[២១] របាយការណ៍របស់គណៈកម្មការច្បាប់អន្តរជាតិ ជូនមហាសន្និបាត A/2693 (1954) បោះជាថ្មីឡើងវិញ នៅឆ្នាំ ១៩៥៤ (II) សៀវភៅប្រចាំឆ្នាំ នៃគណៈកម្មការច្បាប់អន្តរជាតិ ទំព័រ ១៤០ ១៥០ ។

ក្លាយទៅជាភាគីនៃពិធីសារបន្ថែម ឆ្នាំ ១៩៧៧ នៅមុនឆ្នាំ ១៩៨០ ក៏ដោយ[២២] ។ ដូច្នេះ ការប្រព្រឹត្តល្មើសដ៏ធ្ងន់ធ្ងរចំពោះបទបញ្ញត្តិអនុសញ្ញាទីក្រុងហ្សឺណែវបានកើតមានឡើងហើយ ទោះបីជាក៏រិតនៃឧក្រិដ្ឋកម្មបានពង្រីកហួសពីការល្មើសធ្ងន់ធ្ងរចំពោះច្បាប់ធម្មតានាពេលនោះក៏ដោយ ។ ការកត់ត្រានៃប្រវត្តិសាស្ត្រ បានឱ្យដឹងថាជម្លោះដោយអាវុធរវាងប្រទេសវៀតណាម និងកម្ពុជា បានចាប់ផ្តើមកើតមានឡើងតាំងពីខែកញ្ញា ឆ្នាំ ១៩៧៧ ម្ល៉េះ ហើយអាចមុននេះផង ។ ការប៉ះទង្គិចគ្នាតាមព្រំដែន នៅក្នុងខែឧសភា ឆ្នាំ ១៩៧៥ និងឧប្បត្តិហេតុជាបន្តបន្ទាប់មកទៀត បានបង្កើតទៅជាករណីដ៏ធ្ងន់ធ្ងរមួយ ចំពោះការអនុវត្តន៏អនុសញ្ញាទាំងនេះក្នុងការទាក់ទង រវាងប្រទេសកម្ពុជា និងវៀតណាម ជិតពេញមួយរយៈពេលនៃការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ[២៣] ។ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើបទបញ្ញត្តិនានានៃអនុសញ្ញាទីក្រុងហ្សឺណែវ ក៏ត្រូវបានប្រព្រឹត្តតែទៅលើអំពើដែលចាត់ឡើងប្រឆាំងជាមួយ "មនុស្ស ឬទ្រព្យសម្បត្តិដែលត្រូវការពារ" តែប៉ុណ្ណោះ ។ នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវទី១ និងទី ២ វាគឺជាសមាជិកកងកម្លាំងប្រដាប់អាវុធរបួស និងមានជម្ងឺ ដោយមានការកំណត់យ៉ាងត្រឹមត្រូវ ហើយនៅក្នុងអនុសញ្ញាទី ៣ គឺជាអ្នកទោសសង្គ្រាម[២៤] ។ ក៏ប៉ុន្តែ ធាតុពិតនៃអំពើរបស់ពួកខ្មែរក្រហមប្រឆាំងទៅលើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ត្រូវបានស្រាវជ្រាវច្បាស់លាស់ហើយ ទោះបីជាគេដឹងថាទាហានវៀតណាមដែលត្រូវចាប់ខ្លួនបាន ត្រូវបានសួរចម្លើយ និងសម្លាប់នៅទួលស្លែងក៏ដោយ ។ អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ ការពារជនស៊ីវិល ដែលបានធ្លាក់ទៅនៅក្នុងកណ្តាប់ដៃនៃភាគីណាមួយក្នុងជម្លោះ ឬក៏នៅក្នុងកម្លាំងកាន់កាប់ដែលមិនមែនជាជនជាតិ

---

[២២] M.J. Bowman និង D.J. Harris សន្ធិសញ្ញាពហុភាគី តារាងរាយតាមអក្សរ និងលក្ខន្តិកៈបច្ចុប្បន្ន ទំព័រ ១៩៤-៩៥ ៤១៩ (ឡុងដ៍ Butterworths ១៩៨៤) រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ននៃសាធារណៈរដ្ឋវៀតណាម បានក្លាយទៅជាភាគីមួយ នៅក្នុងឆ្នាំ ១៩៧៤ ។ សាធារណរដ្ឋសង្គមនិយមវៀតណាម បានបញ្ជាក់ការបន្តចូលរួមរបស់វៀតណាមជាមួយសន្ធិសញ្ញានេះនៅថ្ងៃទី ៤ ខែកក្កដា ឆ្នាំ ១៩៧៦ ។

[២៣] ចាន់ដា ដូចបានរៀបរាប់ខាងលើ ទំព័រ ១១-១៣ ៨៦-៨៧ ១៩២-២២៥ ៣៣៣-៤៣ ឆាន់ឡឺរ (១៩៩១) ដូចបានរៀបរាប់ខាងលើ ទំព័រ ២៥៦-៥៧ ២៧១-៧២ ។

[២៤] អនុសញ្ញាទីក្រុងហ្សឺណែវ ស្តីពីការកែលំអលក្ខណៈនៃកងកម្លាំងប្រដាប់អាវុធរបួស និងឈឺនៅលើសមរភូមិ ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ អង្គការសហប្រជាជាតិ សេរីសន្ធិសញ្ញា សៀវភៅ ៧៥ លេខ ៩៧០ មាត្រាទី ១៣ ៣១ ៤០ អនុសញ្ញាទីក្រុងហ្សឺណែវទាក់ ទងទៅនឹងប្រព្រឹត្តកម្មចំពោះអ្នកទោសសង្គ្រាម ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ អង្គការសហប្រជាជាតិ សេរីសន្ធិសញ្ញា សៀវភៅ ៧៥ លេខ ៩៧២ មាត្រាទី ៦ ។

របស់របស់ខ្លួនក៏ដោយ[២៥] ។ ទាំងនេះមានរួមបញ្ចូលជនជាតិវៀតណាមនៅក្នុងប្រទេសវៀតណាម ក៏ដូចជានៅក្នុងប្រទេសកម្ពុជា ក្នុងពេលមានជម្លោះខាងយោធា ។ ដោយជនជាតិវៀតណាមភាគច្រើននៅក្នុងប្រទេសកម្ពុជា គឺជាអ្នករស់នៅដោយពុំមានសញ្ជាតិកម្ពុជា អនុសញ្ញាទាំងនេះត្រូវការពារពួកគេ[២៦] ។

៧៤- អំពើប្រឆាំងជនជាតិវៀតណាមនៅក្នុងប្រទេសវៀតណាម និងនៅក្នុងប្រទេសកម្ពុជា ហាក់ដូចជាសមស្របទៅនឹងបទដ្ឋាននៃការប្រព្រឹត្តបំពានទៅនឹងមាត្រាទី ១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី ៤ ដូចនេះវាគឺជាឧក្រិដកម្មសង្គ្រាម ។ ជាពិសេស កងទ័ពកម្ពុជាហាក់ដូចជាត្រូវបានធ្វើឡើងដោយការសម្លាប់យ៉ាងសាហាវ ធ្វើទារុណកម្ម និងប្រព្រឹត្តកម្មយ៉ាងអមនុស្សធម៌ បណ្តាលឱ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរ ធ្វើការនិរទេស ឬឃុំឃាំងដោយខុសច្បាប់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយទ្រង់ទ្រាយធំ ។ មាត្រាទី ១៤៧ ក៏ត្រូវបានអនុវត្តន៍ទៅលើការសម្លាប់រង្គាលអ្នកភូមិថៃ ដោយកងទ័ពខ្មែរក្រហមដែរ ក្នុងពេលមានការប៉ះទង្គិចគ្នាជាញឹកញាប់នៅតាមព្រំដែជាមួយប្រទេសថៃ ។ លើសពីអនុសញ្ញាទីក្រុងហ្សឺណែវទៅទៀតនោះ ការកត់ត្រាក៏បាននាំឱ្យគណៈកម្មការដឹងអំពីឧក្រិដ្ឋកម្មដ៏ទៃទៀត ដែលរំលោភទៅលើច្បាប់ និងរបៀបរបបធ្វើសង្គ្រាមផងដែរ ដូចជាការបំផ្លាញទីក្រុងនានា និងការឆក់ប្លន់ទ្រព្យសម្បត្តិសាធារណៈ ឬឯកជនយ៉ាងព្រៃផ្សៃថែមទៀត ។ ដូច្នេះ ឧក្រិដ្ឋកម្មសង្គ្រាម តាមផ្លូវច្បាប់ ត្រូវបញ្ចូលទៅក្នុងយុត្តាធិការនៃតុលាការដែលកាត់ទោសពួកមេដឹកនាំខ្មែរក្រហមផងដែរ ។

៧៥- ចំពោះច្បាប់មនុស្សធម៌អន្តរជាតិ ទាក់ទិនទៅនឹងជម្លោះផ្ទៃក្នុងវិញ បទបញ្ញត្តិនៃសន្ធិសញ្ញាដែលមានពាក់ព័ន្ធតែមួយគត់ ទាក់ទិនទៅនឹងរយៈពេលនៃខ្មែរក្រហម ជាទូទៅគឺមាត្រាទី ៣ នៃអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ ។ ការរំលោភនោះ មិនមែនជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញានោះទេ ហើយក៏ហាក់ដូចជាមិនត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មតាមច្បាប់ទម្លាប់ ដូចដែលវាបានកើតឡើងនៅក្នុងឆ្នាំ ១៩៧៥

---

[២៥] អនុសញ្ញាទីក្រុងហ្សឺណែវទាក់ទិនទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ថ្ងៃទី ១២ ខែសីហា ឆ្នាំ ១៩៤៩ អង្គការសហប្រជាជាតិ សេរីសន្ធិសញ្ញា សៀវភៅ ៧៥ លេខ ៩៧៣ មាត្រាទី ៤ ។

[២៦] សូមមើល ក្រមលេខ ៩១៣ នស មាត្រាទី ២២ សៀវភៅព្រះរាជកិច្ចកម្ពុជា ថ្ងៃទី ២ ខែធ្នូ ឆ្នាំ ១៩៥៤ ។ និយមន័យនៃពាក្យមនុស្សត្រូវបានទទួលការការពារ ក្នុងមាត្រាទី ៤ នៃអនុសញ្ញាទីក្រុងហ្សឺណែវទី ៤ ក៏គ្របដណ្តប់មនុស្សដែលគ្មានប្រទេសដែរ ។ ហ្សង់ ពិកតេ អត្ថាធិប្បាយ អនុសញ្ញាទីក្រុងហ្សឺណែវទី ៤ ទាក់ទិនទៅនឹងការការពារជនស៊ីវិលក្នុងពេលសង្គ្រាម ទំព័រ ៤៧ (ហ្សឺណែវ្ គណៈកម្មាធិការអន្តរជាតិកាកបាតក្រហម ឆ្នាំ ១៩៥៨) ។

នោះទេ[២៧] ។ ការនេះបានកើតឡើង ២ ឆ្នាំ មុនគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ បញ្ចប់ការបង្កើតឡើងជាលើកទី ១ របស់ខ្លួន នូវច្បាប់ស្តីពីជម្លោះផ្ទៃក្នុង (ឧទាហរណ៍ ពិធីសារបន្ថែមទី ២ នាឆ្នាំ ១៩៧៧) ការវិវត្តន៍ច្បាស់លាស់នាពេលថ្មី ៗ នៃច្បាប់ក្នុងបញ្ហានេះ និងការខ្វះខាតនូវបទបញ្ញត្តិនៅក្នុងពិធីសារទី ២ ចំពោះឧក្រិដ្ឋបទនាំឱ្យយល់ឃើញថា ឧក្រិដ្ឋកម្មនេះមិនត្រូវបានទទួលស្គាល់នាពេលនោះទេ ។ ចំពោះបទឧក្រិដ្ឋនៃការរំលោភទៅលើច្បាប់ និងទម្លាប់នៃសង្គ្រាម នៅក្នុងជម្លោះផ្ទៃក្នុង បើសិនជាមាន ដូចជាតុលាការអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី ត្រូវបានធ្វើឡើង ចំពោះករណី តាឌីក ច្បាប់ជាប្រពៃណីបានទទួលស្គាល់បទឧក្រិដ្ឋបែបនេះ នៅពេលសង្គ្រាមនៅយូហ្គោស្លាវី[២៨] ។ នេះមិនមែនមានន័យថា ដោយសារហេតុផលដូចបានពោលខាងលើ បទឧក្រិដ្ឋនោះមិនត្រូវបានទទួលស្គាល់កាលពី ១៥ ឆ្នាំ មុននោះទេ ។ ដូច្នេះ វាជាការលំបាកក្នុងការកំណត់អំពីលក្ខណៈនៃអំពើនានា នៅក្នុងជម្លោះផ្ទៃក្នុង ថាជាឧក្រិដ្ឋកម្មសង្គ្រាម បើយោងទៅតាមច្បាប់នាពេលនោះ ។

## ៤- អំពើដ៏ទៃទៀតដែលជាការទទួលខុសត្រូវរបស់បុគ្គល

៧៦- ការបំផ្លាញសម្បត្តិវប្បធម៌ នាំមកនូវការទទួលខុសត្រូវរបស់បុគ្គលថាជាបទព្រហ្មទណ្ឌ យោងតាមអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ ១៩៥៤ ស្តីពីការការពារសម្បត្តិវប្បធម៌ នៅក្នុងពេលមានជម្លោះដោយអាវុធ ដែលប្រទេសកម្ពុជាជាភាគីមួយដែរចាប់តាំងពីឆ្នាំ ១៩៦២ មក[២៩] ។ ប៉ុន្តែ គំនិតនៃអនុសញ្ញាស្តីពីជម្លោះដោយអាវុធមានន័យថា ទោះបីជាមានការកត់ត្រាឃើញថាការបំផ្លាញបែបនេះ ដែលជាផ្នែកមួយនៃការវាយប្រហារជាខ្សែសង្វាក់ទៅលើសាសនា[៣០] មានតែការពិពិណនាទាក់ទិនទៅនឹងជម្លោះរវាងប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម (ឬប្រហែលជាជម្លោះផ្ទៃក្នុងផងដែរ)

[២៧] ចំពោះការវិភាគលំអិត សូមមើល រ៉ាត់ណើរ និងអាប្រាម ដូចបាបរៀបរាប់ខាងលើ ទំព័រ ៩៤-៩៥ ។

[២៨] រដ្ឋអាជ្ញា តាឌីក សេចក្តីសំរេចស្តីពីញ្ញត្តិកាពារសំរាប់ការការពាររបស់សហភាគីទៅលើយុត្តាធិការ តុលាការអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី សាលាឧទ្ធរ ថ្ងៃទី ២ ខែតុលា ឆ្នាំ ១៩៩៥ វាក្យខ័ណ្ឌ ១២៨-៣៦ (នៅក្នុងនេះហៅថា ការតវ៉ារបស់សហភាគីតាឌីក) ។

[២៩] អង្គការសហប្រជាជាតិ សេរីសន្ធិសញ្ញា សៀវភៅ ២៤៩ លេខ ៣៥១១ (ដែលនៅទីនេះហៅថា អនុសញ្ញាទីក្រុងឡាអេ) បូវម៉ាន់ និងហារីស ដូចបានរៀបរាប់ខាងលើ ទំព័រ ១៩២ ១៩៣ ។

[៣០] សូមមើល បេគែរ ដូចបានរៀបរាប់ខាងលើ ទំព័រ ២៦៤-៦៥ បណ្ណាល័យព្រឹទ្ធសភា ដូចបានរៀបរាប់ខាងលើ ទំព័រ ១១៨-១១៩ ។

អាចធ្វើឱ្យកើតមានឡើងនូវការទទួលខុសត្រូវ ផ្នែកព្រហ្មទណ្ឌបាន[៣១] ។ ត្រូវប្រមូលភស្តុតាងបន្ថែមចំពោះបញ្ហានេះ ។

៧៧- ការបង្ខំឱ្យធ្វើការជាទម្ងន់ ជាការទទួលខុសត្រូវពីបទព្រហ្មទណ្ឌរបស់បុគ្គល តាមអនុសញ្ញាស្តីពីការបង្ខំឱ្យធ្វើការជាទម្ងន់ ឆ្នាំ ១៩៣០ ដែលប្រទេសកម្ពុជាជាភាគីមួយដែរក្នុងសម័យខ្មែរក្រហម[៣២] ។ អនុសញ្ញាឆ្នាំ ១៩៣០ កំណត់ថាជាបទឧក្រិដ្ឋនៃការបង្ខំឱ្យធ្វើការជាទម្ងន់ មិនសមស្របទៅតាមកំរិតអាយុ ចំនួនថ្ងៃធ្វើការ ម៉ោងធ្វើការមិនផ្ទេរចេញពីកន្លែងមានគ្រោះថ្នាក់ និងការមិនបានទទួលការថែរក្សាផ្នែកពេទ្យ ។ របបមិនអើពើនឹងការទាមទារជាពិសេសចំពោះការធ្វើការជាទម្ងន់ ទាក់ទិនទៅនឹងការងារជាសាធារណៈ ដូចជាការហាមឃាត់មិនឱ្យផ្លាស់ប្តូរទីកន្លែងរស់នៅ និងការទាក់ទងទៅនឹងសាសនា និងជីវភាពសង្គម[៣៣] ។ អំពើទាំងនេះ ក៏ហាក់ដូចជាមិនធ្លាក់ចូលទៅក្នុងការលើកលែង ទៅនឹងនិយមន័យចំពោះការងារ ដែលជាផ្នែកនៃ "កាតព្វកិច្ចនៃពលរដ្ឋធម្មតា" របស់ប្រជាពលរដ្ឋទេ លើកលែងតែការបកស្រាយដោយមូលបង្កាច់នូវពាក្យនេះប៉ុណ្ណោះ[៣៤] ។ ឬមួយវាក៏មិនត្រូវធ្លាក់ទៅក្នុងករណីពិសេសនៃការងារ "ដែលធ្វើឡើងក្នុងករណីបន្ទាន់ណាមួយនោះ"[៣៥] ទោះបីស្ថិតនៅក្នុងសេណារីយោដ៏អាក្រក់បំផុតនៃការខ្វះខាតអាហារដ៏ធ្ងន់ធ្ងរក៏ដោយ ក៏វាមិនបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបង្ខំឱ្យធ្វើការជាទម្ងន់ ឱ្យទៅជាបន្ទុករបស់ប្រជាពលរដ្ឋនៅតាមជនបទនោះទេ ជាពិសេសនៅក្នុងរបបមួយដែលបដិសេធមិនទទួលយកជំនួយបរទេសនោះ[៣៦] ។ ដូច្នេះ ឧក្រិដ្ឋកម្មនេះ ក៏អាចបញ្ចូលទៅក្នុងយុត្តាធិការនៃតុលាការដែរ ។

---

[៣១] អនុសញ្ញាទីក្រុងឡាអេ បុព្វកថា មាត្រាទី ៣ ៤ (១) ៥ ៧-១០ ។

[៣២] <u>សន្ធិសញ្ញាពហុភាគីដកល់ទុកនៅជាមួយអគ្គលេខាធិការ</u> ដូចបានរៀបរាប់ខាងលើ ទំព័រ ៧០៥ បូវម៉ាន់ និងហារីស ដូចបាបរៀបរាប់ខាងលើ ទំព័រ ៨៧ ។ ការនេះមានការលំបាកនឹងសន្និដ្ឋានថា ខ្មែរក្រហមបានប្រព្រឹត្តទាសភាពដូចដែលបានកំណត់នៅក្នុងអនុសញ្ញា អន្តរជាតិ ។ សូមមើល អនុសញ្ញាបន្ថែម ស្តីពីការបំបាត់ទាសភាព ការជួញដូរទាសករ និងស្ថាប័ន និងការអនុវត្តន៍ប្រហាក់ប្រហែល គ្នានឹងទាសភាព ថ្ងៃទី ៧ ខែកញ្ញា ឆ្នាំ ១៩៥៦ អង្គការសហប្រជាជាតិ <u>សេរីសន្ធិសញ្ញា</u> សៀវភៅ ២៦៦ លេខ ៣៨២២ មាត្រាទី ៧ (ក) ។

[៣៣] អនុសញ្ញាស្តីពីការបង្ខមឱ្យធ្វើការធ្ងន់ (អង្គការការងារអន្តរជាតិ លេខ ២៩) មាត្រាទី ២ ១១-១៣ ១៦ ១៨ ១៩ ៣៩ ។

[៣៤] ដូចខាងលើ មាត្រាទី ២ (ខ) ។

[៣៥] ដូចខាងលើ មាត្រាទី ២ (ឃ) ។

[៣៦] សូមមើលហ្សាក់សុន " ឧត្តមគតិនៃបដិវត្តន៍ដោយសព្វមុខ" ដូចបានរៀបរាប់ខាងលើ ទំព័រ ៤៨-៤៩

៧៨- បច្ចុប្បន្ន ទារុណកម្មនាំមកដល់បុគ្គលនូវការទទួលខុសត្រូវខាងបទព្រហ្មទ័ណ្ឌ ស្របតាមអនុសញ្ញាប្រឆាំងទារុណកម្ម និងប្រព្រឹត្តកម្ម ឬទ័ណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់នូវតម្លៃជាមនុស្ស របស់អង្គការសហប្រជាជាតិ តែអនុសញ្ញានេះត្រូវបានសំរេចឡើងតែនៅក្នុងឆ្នាំ ១៩៨៤ ប៉ុណ្ណោះ[៣៧] ។ ដោយសារថា បទព្រហ្មទ័ណ្ឌ នៃទារុណកម្ម ដែលស្ថិតនៅក្រោមច្បាប់អន្តរជាតិជាទម្លាប់មកហើយនៅពេលមានអំពើឃោរឃៅរបស់ពួកខ្មែរក្រហម សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ បានហាមឃាត់មិនឱ្យមានអំពើទារុណកម្ម និងក្រោយមកបានទាមទារឱ្យរដ្ឋនានាផ្តល់នូវការអនុវត្តន៍សិទ្ធិរបស់មនុស្សដែលមិនត្រូវជាកម្មវត្ថុនៃអំពើទាំងនេះ[៣៨] ។ សេចក្តីថ្លែងការណ៍ស្តីពីការការពារមនុស្សទាំងអស់ឱ្យរួចចាកពីអំពើទារុណកម្ម និងប្រព្រឹត្តកម្ម និងទ័ណ្ឌកម្មដែលឃោរឃៅ អមនុស្សធម៌ ឬដែលធ្វើឱ្យបាត់បង់តម្លៃជាមនុស្ស បានប្រកាសថាទារុណកម្ម គឺជា "ការរំលោភទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស" ដែលរដ្ឋនានាត្រូវតែដាក់វាថាជាឧក្រិដ្ឋកម្មនៅក្នុងច្បាប់របស់ខ្លួន ។ សេចក្តីថ្លែងការណ៍កំណត់ថា "អំពើណាក៏ដោយ ដែលធ្វើឱ្យមានការឈឺចាប់ធ្ងន់ធ្ងរ ខាងផ្លូវកាយ និងខាងផ្លូវចិត្ត ដែលបានប្រព្រឹត្តឡើងដោយចេតនាដោយផ្ទាល់ខ្លួនឯង ឬដោយមានការចាក់រុកពីមន្ត្រីសាធារណៈទៅលើ មនុស្សណាម្នាក់ ក្នុងទិសដៅដូចជាដើម្បីទទួលបានពិតមាន ឬសេចក្តីសារភាពពីមនុស្សនោះ ឬពីមនុស្សទី ៣ ណាម្នាក់ទៀតនោះ ដើម្បីជាការដាក់ទ័ណ្ឌកម្មទៅលើបុគ្គលនោះចំពោះអំពើមួយដែលគេបានប្រព្រឹត្ត ឬ សង្ស័យថាបានប្រព្រឹត្តនោះ ឬដើម្បីបំភិតបំភ័យរូបគេ ឬអ្នកដ៏ទៃណាម្នាក់ទៀត"[៣៩] ។ ការអនុម័តអនុសញ្ញានេះដោយការស្រុះស្រួលមូលមតិគ្នា ដោយមហាសន្និបាត បានផ្តល់ជាភស្តុតាងនៃការលេចឡើងនូវបទដ្ឋាននៃឧក្រិដ្ឋកម្មជាអន្តរជាតិ នៅឆ្នាំ ១៩៧៥ ។ ការកាត់ត្រារបស់ប្រវត្តិសាស្ត្រ បានគូសបញ្ជាក់យ៉ាងច្បាស់ដល់គណៈកម្មការកម្ពុជាប្រជាធិបតេយ្យ អំពីការប្រព្រឹត្តអំពើទារុណកម្មជាអាលជ្ជីទៅលើមនុស្សដែលពួកគេសន្និដ្ឋានថាជាសត្រូវនៃរបបគេជាច្រើនរយពាន់នាក់ ។ ទោះបីជាតុលាការ ត្រូវពិនិត្យយ៉ាងជិតដល់ថាតើបទព្រហ្មទ័ណ្ឌនៃទារុណកម្មដូចដែលវាបានកើតឡើងនៅក្នុងឆ្នាំ ១៩៧៥ នោះ វាត្រឹមត្រូវតាមបទដ្ឋានអំពី

[៣៧] សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ៣៩/៤៦ ឧបសម្ព័ន្ធ ។

[៣៨] សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ២២០០ A (XXI) ។

[៣៩] សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ៣៤៥២ (XXX) ឧបសម្ព័ន្ធ មាត្រាទី ១ និតទី ២ ។

ថា "ពុំ មានបទល្មើសព្រហ្មទ័ណ្ឌទេ បើបទល្មើសមិនត្រូវបានប្រព្រឹត្តទេនោះ ការដាក់បញ្ចូលទារុណកម្មទៅក្នុងលក្ខន្តិកៈរបស់តុលាការណាមួយនោះ គឺជាការត្រឹមត្រូវ" ។

៧៩- នៅទីបញ្ចប់ ពួកមេដឹកនាំ និងក្របខ័ណ្ឌរបស់ខ្មែរក្រហម ហាក់ដូចជាបានប្រព្រឹត្តយ៉ាងហោចណាស់នូវឧក្រិដ្ឋកម្មមួយផ្សេងទៀតដែលមានកំរិតតូចជាងបន្តិច - ពោលគឺ ឧក្រិដ្ឋកម្មប្រឆាំងទៅនឹងមនុស្សដែលត្រូវបានការពារជាអន្តរជាតិ[៤០] ។ នៅក្នុងខែមេសា ឆ្នាំ ១៩៧៥ របបបានឃុំខ្លួនបុគ្គលិក នៅក្នុងស្ថានទូតបារាំង ហើយបន្ទាប់មកយកចេញ ឬសម្លាប់ស្វាមីជាជនជាតិខ្មែរ នៃបុគ្គលិកទូតបរទេស[៤១] ។

## ៥- វិសាលភាពនៃការទទួលខុសត្រូវរបស់បុគ្គល

៨០- ច្បាប់អន្តរជាតិ បានទទួលស្គាល់យូរមកហើយថា មនុស្សទាំងឡាយត្រូវទទួលខុសត្រូវចំពោះអំពើទោះបីគេមិនបានប្រព្រឹត្តដោយផ្ទាល់ក៏ដោយ ។ គោលការណ៍ហាក់ដូចជាត្រូវបានបញ្ចូលទៅក្នុងឯកសារផ្សេង ៗ ដែលប្រកាសថា មនុស្សនានាត្រូវតែទទួលខុសត្រូវ បើសិនជាគេមានបំណង អុជអាល បញ្ជា ជួយ ឬជំរុញ ឬរួមគំនិត ប្រព្រឹត្តអំពើឧក្រិដ្ឋណាមួយនោះ[៤២] ។ បញ្ហានៃការបកស្រាយមួយចំពោះឯកសារទាំងនេះគឺការខ្វះខាតនូវការឯកភាពគ្នាក្នុងចំណោមប្រព័ន្ធច្បាប់នានា ក្នុងការបកស្រាយនូវពាក្យពេចន៍ទាំងនោះ ។ ចំពោះករណីខ្មែរក្រហម អ្នកដែលមានគំនិតចង់ធ្វើការចោទប្រកាន់ ត្រូវការធ្វើសេចក្តីសំរេចជាគន្លឹះ ទាក់ទិនទៅនឹងទ្រង់ទ្រាយនៃការស៊ើបអង្កេត ដូចជាអំពើឃោរឃៅ ត្រូវបានប្រព្រឹត្តឡើងដោយមនុស្សជាច្រើននាក់ណាស់ តាមថ្នាក់ផ្សេង ៗ ពីគ្នា នៅក្នុងអាជ្ញាធររដ្ឋាភិបាល ។

---

[៤០] សូមមើល អនុសញ្ញាស្តីពីការបង្កា និងទ័ណ្ឌកម្ម ឧក្រិដ្ឋកម្មប្រឆាំងទៅលើមនុស្សដែលត្រូវបានការពារជាអន្តរជាតិ ក្នុងនេះរួមមានបុគ្គលិកទូត សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ៣១៦៦ (XXVIII) ឧបសម្ព័ន្ធ ។

[៤១] សូមមើល សូចក្រួស ដូចបានរៀបរាប់ខាងលើ ទំព័រ ៣៦៦-៦៧ ។

[៤២] សូមមើល ធម្មនុញ្ញតុលាការយោធាអន្តរជាតិ មាត្រាទី ៦ (ក) ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ មាត្រាទី ២ (២) អនុសញ្ញាស្តីពីការបង្ការ និងការធ្វើទ័ណ្ឌកម្ម ស្តីឱ្យក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រាទី ៣ លក្ខន្តិកៈតុលាការអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី មាត្រាទី ៧ (១) ឆ្នាំ ១៩៩៦ គណៈកម្មការច្បាប់អន្តរជាតិ សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងសន្តិភាព និងសន្តិសុខរបស់មនុស្សលោក មាត្រាទី ២ (៣) លក្ខន្តិកៈរបស់តុលាការព្រហ្មទ័ណ្ឌអន្តរជាតិ មាត្រាទី ២៥ ។

៨១- មេបញ្ជាការយោធា និងមេដឹកនាំស៊ីវិល ត្រូវទទួលខុសត្រូវពីបទព្រហ្មទ័ណ្ឌ ក្នុងករណីជាក់ស្តែង ដែលពួកគេបានបញ្ជាឱ្យឱ្យប្រព្រឹត្តអំពើឃោរឃៅ ហើយពួកគេក៏មានការទទួលខុសត្រូវក្នុងន័យជាទូទៅផង ដែរ បើសិនជាពួកគេដឹង ឬបានដឹងថាអំពើឃោរឃៅបានប្រព្រឹត្តឡើងដោយពួកអ្នកនៅក្រោមបញ្ជារបស់ពួក គេ ហើយពួកគេមិនបានទប់ស្កាត់បញ្ឈប់ឬដាក់ទ័ណ្ឌកម្មលើពួកទាំងនោះ[៤៣] ។ ការនេះទាមទារឱ្យមានការ ស៊ើបអង្កេតអំពីតួនាទីរបស់ពួកមន្ត្រីខ្មែរក្រហម ដែលទទួលខុសត្រូវនៅក្នុងរដ្ឋាភិបាល សំរាប់យល់ដឹងបច្ចុប្បន្ន និងដោយមានលក្ខណៈស្ថាបនា នូវអំពើឃោរឃៅទាំងនោះ ។

៨២- ការពិភាក្សាគ្នាអំពីពិរុទ្ធភាព ឱ្យហួសពីអ្នកដែលបានប្រព្រឹត្តអំពើឃោរឃៅ គឺជាលទ្ធភាពដែល ថាអ្នកទាំងឡាយដែលបានប្រព្រឹត្តវា នៅក្នុងកាលៈទេសៈខ្លះ អាចឱ្យរួចទោសបាន ដោយឈរលើថាជាការ ការពារខ្លួនដោយស្របច្បាប់ ដោយការខ្វះនូវ"ជំរើសខាងសីលធម៌" ក្នុងការប្រព្រឹត្តនូវអំពើទាំងនោះ[៤៤] ។ ទោះជាបន្ទាប់ពីទទួលបញ្ជាហើយក៏ដោយ ក៏ជាការការពារដែលមិនអាចទទួលយកបានឡើយ[៤៥] ច្បាប់ព្រហ្ម ទ័ណ្ឌអន្តរជាតិ បានទទួលស្គាល់ការដែលអាចហៅថាការការពារខ្លួនដ៏ទៃទៀតបាន ។ និយាយជារួម ទាំងនេះ រួមមាន (ក) ភាពធ្ងន់ធ្ងរ និងភាពបង្ខិតបង្ខំ (ដោយឈរលើថាជាការគំរាមកំហែងដែលអាចនឹងកើតមាន គ្រប់ពេលវេលា ឬការធ្វើឱ្យប៉ះពាល់ដល់ខ្លួនប្រាណយ៉ាងធ្ងន់ធ្ងរ) (ខ) ការប៉ះពាល់ដល់ផ្លូវចិត្ត (គ) ស្ម័យ

---

[៤៣] បទដ្ឋានច្បាស់លាស់នានា ប្រែប្រួលទៅតាមករណី និងឯកសារច្បាប់នានា ។ សូមមើល សហរដ្ឋអាមេរិក V. list et al. ការកាត់ទោសពួកក្រិដ្ឋជនសង្គ្រាមនៅពេលមុនតុលាការយោធានូរំបែរ តាមក្រុមប្រឹក្សាត្រួតពិនិត្យច្បាប់លេខ ១០ សៀវភៅ ២២ ទំព័រ ១២៣០ ១២៨៦ ១៣០៣ (ឆ្នាំ ១៩៤៨) ពិធីសារទី ១ បន្ថែមទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩ និងទាក់ទិនទៅនឹង ការការពារជនរងគ្រោះដោយជម្លោះដោយអាវុធអន្តរជាតិ ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៧៧ អង្គការសហប្រជាជាតិ សេរីសន្ធិសញ្ញា សៀវភៅ ១១២៥ លេខ ១៧៥២ លក្ខន្តិកៈតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី មាត្រាទី ៧ (៣) លក្ខន្តិកៈតុលាការព្រហ្មទ័ណ្ឌអន្តរជាតិ មាត្រាទី ២៨ សូមមើលផងដែរ រដ្ឋអាជ្ញា ជឺឡាលិក និង អាល់ តុលាការកាត់ក្តីអន្តរជាតិ សំរាប់អតីតប្រទេស យូហ្គោស្លាវី បន្ទប់កាត់ក្តី ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ វាក្យខ័ណ្ឌ ៣៣០-៤០១ ។

[៤៤] ការកាត់ទោសឧក្រិដ្ឋករសង្គ្រាមធំ ៗ នៅពេលមុនតុលាការអន្តរជាតិ សៀវភៅ ២២ ទំព័រ ៤៦៦ យ៉ារ៉ាំ ដាំងស្តាំង ការការពារដោយការស្តាប់ឱវាទពីថ្នាក់លើ នៅក្នុងច្បាប់អន្តរជាតិ ទំព័រ ៥១-៥៧ ៧៦-៨៣ (ឡិដិន្ធ ស៊ីកតុហ្វ ឆ្នាំ ១៩៦៥) ។

[៤៥] សូមមើល ធម្មនុញ្ញតុលាការអន្តរជាតិ មាត្រាទី ៨ ក្រុមរបឹក្សាត្រួតពិនិត្យច្បាប់លេខ ១០ មាត្រាទី ២ (៤) (ខ) លក្ខន្តិកៈតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី មាត្រាទី ៧ (៤) ។

ការពារខ្លួន និង (ខ) ការមិនយល់នូវការណែនាំរបស់រដ្ឋាភិបាល គឺជាការខុសច្បាប់ ស្ដីកណាតែបញ្ហានោះជាការខុសច្បាប់ជាជាក់ស្ដែងតែម្ដង[៤៦] ។

៨៣- ក្នុងករណីនៃប្រទេសកម្ពុជា អ្នកប្រព្រឹត្តបទល្មើសខ្មែរក្រហមខ្លះ ជាពិសេសអ្នកដែលនៅថ្នាក់ក្រោម ៗ ត្រូវប្រឈមមុខនឹងការគំរាមកំហែង ពិកម្មាភិបាលដ៏ទៃទៀត អាចទទួលបាននូវភាពការពារខ្លួនពីការបង្ខិតបង្ខំ ។ លើសពីនេះទៅទៀត តួអង្គខ្មែរក្រហមថ្នាក់ក្រោមជាច្រើននាក់ ជាពិសេសអ្នកកំប៉ិកកំប៉ុក ត្រូវបានកំណត់ជាមុនបានថាមិនអាចដឹងនូវភាពខុសច្បាប់នៃបញ្ហាខ្លះ ៗ របស់ពួកគេថាខុសនឹងច្បាប់ជាតិ និងអន្តរជាតិ ទេ (ជាពិសេស ដោយរបបកម្ពុជាប្រជាធិបតេយ្យជាការចាប់ផ្ដើមថ្មីមួយសំរាប់ប្រទេសជាតិ) ។ ប៉ុន្តែ ការ នេះអាចធ្វើទៅបានតែចំពោះអំពើរំលោភតូចតាចប៉ុណ្ណោះ ហើយមិនមែនឧក្រិដ្ឋកម្មណាដែលឃោរឃៅខ្លាំង នោះទេ ដែលការធ្វើមិនដឹងមិនឮថាជាការអត់ឱនឱ្យបានទាល់តែសោះ ។ នៅក្នុងសភាពការណ៍មួយ ដែលការខ្វះខាតនូវការយល់ដឹងអំពីច្បាប់មិនមែនជាការការពារខ្លួននោះទេ ក៏ប៉ុន្តែការទទួលបញ្ជាយកទៅអនុវត្ត មិនអាចយកទៅប្រើដើម្បីសំរាលទោសនោះទេ[៤៧] ។ ដូចបានបញ្ជាក់នៅខ្ទរំបែរមកហើយ ថាមេដឹកនាំត្រូវតែចាប់ឱ្យទទួលដឹងឮ ចំពោះឧក្រិដ្ឋកម្មនៃអំពើរបស់ពួកគេ ចំពោះមុខច្បាប់កម្ពុជាដែលមានពីមុនមក ឬច្បាប់អន្តរជាតិ ។ កត្តាច្បាប់ទាំងនេះ មានទាក់ទងទៅនឹងអនុសាសន៍របស់យើងខ្ញុំ នៅខាងក្រោមនេះ ទាក់ទិនទៅនឹងទិសដៅសមស្របនៃការស្រាវជ្រាវសំរាប់តុលាការណាមួយនោះ ។

## ខ- ឧក្រិដ្ឋកម្មក្រោមច្បាប់កម្ពុជា

---

[៤៦] ចំពោះការរៀបចំជាច្បាប់ទំនើបនៃការការពារខ្លួនទាំងនេះ សូមមើលលក្ខន្តិកៈតុលាការព្រហ្មទ័ណ្ឌអន្តរជាតិ មាត្រាទី ៣១-៣៣ សូមមើលផងដែរ រដ្ឋអាជ្ញាអែដូម៉្វរិក ការវិនិច្ឆ័យ តុលាការអន្តរជាតិសំរាបលប្រទេសអតីតយូហ្គោស្លាវី សាលាឧទ្ធរ ថ្ងៃទី ៧ តុលា ឆ្នាំ ១៩៩៧ (ដោយមានសម្លេង ៣ ទល់នឹង ២ ការបង្ខិតបង្ខំ មិនមែនជាការការពារ សំរាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ) ។

[៤៧] គ្មានច្បាប់ដែលមានស្រាប់ណាមួយហាក់ដូចជាសំរាប់យកទៅរៀបចំជាក្រមទេ ។ ក្រម ឆ្នាំ ១៩៥៦ មិនដាក់ទោសក្នុងរូបភាពមួយ ដែលបង្ហាញអំពីរិសោធនកម្ម និងការផ្លាស់ប្តូរផ្សេងណាទៀតទេ ចាប់តាំងពីការបោះពុម្ពផ្សាយជាលើកដំបូងមក ។

៨៤- តាមច្បាប់ក្នុងស្រុក ឧក្រិដកម្មមានខ្វះខាតនូវកត្តាពិសេស ៧ នៃឧក្រិដ្ឋអន្តរជាតិជាច្រើន ដូច្នេះ វាងាយនឹងធ្វើការចោទប្រកាន់ណាស់ ។ ក៏ប៉ុន្តែ ចំពោះករណីនៃប្រទេសកម្ពុជា មានឧបសគ្គចំនួន ២ ដែលធ្វើឱ្យមានការស្មុគ្រស្មាញ ។ ទី ១ ប្រភពរបស់ច្បាប់កម្ពុជាមានតិចតួចបំផុត ។ ប្រភពទី ១ គឺក្រម ព្រហ្មទ័ណ្ឌមុនយុគសម័យខ្មែរក្រហម គឺក្រម និងច្បាប់ព្រហ្មទ័ណ្ឌ ឆ្នាំ ១៩៥៦ ផ្សព្វផ្សាយដោយក្រសួង យុត្តិធម នៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាវាហាក់ដូចជាថាពុំមានប្រភពដ៏ទៃទៀត ដែលធ្វើឱ្យច្បាប់នេះនាំ ឱ្យមានការជឿទុកចិត្តបាន និងមានលក្ខណៈសព្វមុខនៃច្បាប់នេះនៅក្នុងឆ្នាំ ១៩៧៥ ក៏ដោយ ។ រីឯច្បាប់ជា បន្តបន្ទាប់មកទៀត ដែលអនុវត្តនីដោយពួកខ្មែរក្រហម ពោលគឺកម្ពុជាប្រជាធិបតេយ្យ ហាក់ដូចជាពុំមានធ្វើ ការផ្សព្វផ្សាយទាល់តែសោះ ។ ពុំមានប្រភពដ៏ទៃណាផ្សេងទៀត នៅក្នុងច្បាប់ព្រហ្មទ័ណ្ឌកម្ពុជាត្រូវបាន ពង្រីកថែមទៀតទេ ។ ទី ២ ពីព្រោះប្រទេសកម្ពុជាបានឆ្លងកាត់យ៉ាងតិចណាស់ក៏ ៦ របបមកហើយ ចាប់តាំងពីបានទទួលឯករាជ្យមកវិសាលភាពនៃច្បាប់ដែលកើតមុនរបបនិមួយ ៗ ស្ថិតនៅជាធរមានភាពជា និច្ច គឺវាគ្រាន់តែធ្វើឱ្យប៉ះពាល់ដល់ករណីជាច្រើនតែប៉ុណ្ណោះ[៤៨] ។

៨៥- នៅពេលនោះ យ៉ាងហោចណាស់ ក្រុមបានកំណត់ ឈរលើមូលដ្ឋាននៃគោលការណ៍ ពុំមានបទល្មើស ព្រហ្មទ័ណ្ឌទេ បើបទល្មើសមិនត្រូវបានប្រព្រឹត្តទេនោះថាច្បាប់ព្រហ្មទ័ណ្ឌកម្ពុជាមុនឆ្នាំ ១៩៧៥ គឺតំណាងឱ្យ ច្បាប់ក្នុងស្រុកទី ១ ទាក់ទិនទៅនឹងពួកខ្មែរក្រហម ចំពោះអំពើដែលពួកគេបានប្រព្រឹត្ត ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[៤៩] ។ ទោះបីជាយ៉ាងដូច្នេះក៏ដោយ ក៏តុលាការកម្ពុជាមិនបានអនុវត្តនីច្បាប់ឆ្នាំ ១៩៥៦ អស់រយៈ ពេលមួយជំនាន់មនុស្ស វាស្ថិតនៅតែប្រភពទី ១ នៃច្បាប់ សំរាប់យកមកធ្វើការកាត់សេចក្តីនៅក្នុងស្រុក ។ ជាក់ស្តែង នៅក្នុងការសន្មត់ដែលថាឧក្រិដ្ឋកម្មធំ ៧ នៅក្នុងក្រមព្រហ្មទ័ណ្ឌឆ្នាំ ១៩៥៦ បានស្ថិតនៅតែជាបទ ឧក្រិដ្ឋនៅក្នុងឆ្នាំជាបន្តបន្ទាប់មកទៀតដដែល ។ ទាំងនេះ ហាក់ដូចជា ករណីដែលបានកើតឡើងនៅក្នុងឆ្នាំ

[៤៨] របបទាំងនេះ គឺព្រះរាជាណាចក្រកម្ពុជា (១៩៥៣-១៩៧០) សាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) សាធារណរដ្ឋប្រជាមានិតកម្ពុជា/រដ្ឋកម្ពុជា (១៩៧៩-១៩៩១) ក្រុមប្រឹក្សាជាតិទាន់ខ្ពស់/អាជ្ញាធរបណ្តោះ អាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (១៩៩១-១៩៩៣) និងជាថ្មីម្តងទៀត ព្រះរាជាណាចក្រកម្ពុជា (១៩៩៣-បច្ចុប្បន្ន) ។

[៤៩] ច្បាប់ព្រហ្មទ័ណ្ឌកម្ពុជា ឈរលើមូលដ្ឋានច្បាប់នៃប្រទេសបារាំង បានទទួលស្គាល់ផងដែរនូវគោលការណ៍នៃការមិនអនុវត្តនីថយ ក្រោយ ។ ក្រមព្រហ្មទ័ណ្ឌ មាត្រាទី ៦ យោងលើរដ្ឋធម្មនុញ្ញកម្ពុជា (១៩៤៧) មាត្រាទី ១៩ (២) ។

ក្រោយ ៧ មកទៀត នៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋខ្មែរ ។ ចំពោះបច្ច័យនៃរយៈពេលខ្មែរក្រហម ពុំមានភស្តុតាងណាដែលឱ្យឃើញថាកម្ពុជាប្រជាធិបតេយ្យ បានលប់ចោល ឬក៏បកអាក្រាតជា ផ្លូវការនូវច្បាប់ព្រហ្មទ័ណ្ឌដែលមានប្រសិទ្ធិភាពនៅក្នុងពេលពួកគេឡើងកាន់អំណាចនោះទេ ។ ទោះបីជាកម្ពុជាប្រជាធិបតេយ្យ មានបំណងយ៉ាងច្បាស់បង្កើតនូវការចាប់ផ្តើមថ្មីមួយនៅកម្ពុជាក៏ដោយ (″ឆ្នាំសូន្យ″) គេមិនអាចសន្និដ្ឋានថារបបនេះបានលប់បំបាត់ចោលនូវឧក្រិដ្ឋកម្ម នៃអំពើអាក្រក់ដែលត្រូវរដ្ឋទាំងអស់កំណត់ថាជាឧក្រិដ្ឋកម្មនោះទេ ។ លើសពីនេះទៅទៀត ទោះបីមានការបកអាក្រាតមួយដ៏ត្រឹមត្រូវ វាមិនជាការស្តីបន្ទោសទៅលើអំពើរបស់ពួកខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មស្របតាមច្បាប់កម្ពុជាពីមុន ៧ មកទេ ជាពិសេសបើសិនជារបបមានបំណងចង់កែតម្រូវការរំលោភទៅលើការការពារសេចក្តីថ្លៃថ្នូរជាមូលដ្ឋានបំផុត របស់មនុស្សយ៉ាងណាក៏ដោយ[៥០] ។

## ១- ឧក្រិដ្ឋកម្មសំខាន់ ៧

៨៦- ក្រមព្រហ្មទ័ណ្ឌឆ្នាំ ១៩៥៦ គ្របដណ្តប់លើឧក្រិដ្ឋកម្មសំខាន់ ៧ ទទួលស្គាល់ដោយរដ្ឋភាគច្រើន ។ យោងតាមការអនុវត្តន៍របស់ប្រទេសបារាំង ក្រមធ្វើចំណាត់ថ្នាក់បទល្មើស ទៅតាមទម្ងន់របស់វានៅក្នុង ឧក្រិដ្ឋកម្ម (បទឧក្រិដ្ឋ) បទមជ្ឈិម និងបទលហុ (បទល្មើសខាងប៉ូលីស) ។ បទឧក្រិដ្ឋ និងបទលហុ ត្រូវបានកំណត់ជាកំរិតទី១ ទី ២ ឬទី ៣ គឺថាវាកើនឡើងទៅតាមលំដាប់នៃទម្ងន់របស់វា យោងទៅតាមកំរិតនៃការដាក់ទ័ណ្ឌកម្ម[៥១] ។ បទឧក្រិដ្ឋត្រូវផ្តន្ទាទោសឧក្រិដ្ឋ : ចំពោះអ្នកដែលចូលដល់កំរិតទី ៣ ត្រូវជាប់ទោសប្រហារជីវិត បទឧក្រិដ្ឋទី ២ ត្រូវផ្តន្ទាទោសជាប់គុកមួយជីវិតដោយធ្វើការជាទម្ងន់ និងបទឧក្រិដ្ឋកំរិតទី ១ ត្រូវជាប់ទោសឱ្យធ្វើការជាទម្ងន់ក្នុងរយៈពេលមួយមានកំណត់ ។ បទមជ្ឈិម ត្រូវផ្តន្ទាទោសមជ្ឈិម ហៅថាដាក់គុក ធ្វើការផាកពិន័យ ឬទាំង ២ ទោសនិមួយ ៗ ឈរលើកំរិតនៃបទល្មើស ។ បទល្មើសលហុ ត្រូវទទួលទោសលហុ ហៅថាការឃុំខ្លួនរដោយប៉ូលីស ការផាកពិន័យ ឬទាំង ២ ។[៥២]

---

[៥០] សូមមើល ការកាត់ទោសឧក្រិដ្ឋជនសង្គ្រាមធំ ៗ នៅចំពោះមុខតុលាការយោធាអន្តរជាតិ សៀវភៅ ២២ ទំព័រ ៤៦៥-៦៦ អគ្គមេធាវីរបស់រដ្ឋាភិបាលអ៊ីស្រាអែល អិឆ្មាន់ របាយការណ៍ច្បាប់អន្តរជាតិ សៀវភៅ ៣៦ ទំព័រ ២៧៧ (អ៊ីស្រាអែល ឆ្នាំ ១៩៦២) ករណីកាត់ទោសឆ្មាំការពារព្រំដែន របាយការណ៍ច្បាប់អន្តរជាតិសៀវភៅ ១០០ ទំព័រ ៣៦៦ ៣៧៩-៨៦ (អាល្លឺម៉ង់ ឆ្នាំ ១៩៩២) ។

[៥១] ក្រមព្រហ្មទ័ណ្ឌ មាត្រាទី ៥ ។

[៥២] ដូចខាងលើ មាត្រាទី ៤ ទំព័រ ២១-២៣ ។

ឧក្រិដ្ឋកម្មដែលមានពាក់ព័ន្ធខ្លាំងជាងគេបំផុតនៅក្នុងច្បាប់កម្ពុជា អាចសង្ខេបបានដូចតទៅ :

- មនុស្សឃាត ( មាត្រាទី ៥០១-៥០៨)
- ទារុណកម្ម ( មាត្រាទី ៥០០)
- ការចាប់រំលោភ ( មាត្រាទី ៤៨៣-៨៦)
- ការរំលោភលើខ្លួនប្រាណដ៏ទៃទៀត ( មាត្រាទី ៤៩៤-៩៩)
- ការចាប់ ឬការឃុំខ្លួនដោយទទឹងទិស ( មាត្រាទី ៤៨២-៨៦)
- ការបរិហារទៅលើសាសនា ( មាត្រាទី ២០៩-១៨)
- ការរំលោភដ៏ទៃទៀតទៅលើអាជ្ញាធររដ្ឋាភិបាល ( មាត្រាទី ២៤០-៤៤) ។

បន្ថែមពីលើបទល្មើសខាងលើ ច្បាប់របស់តុលាការយោធា ផ្សព្វផ្សាយជាមួយគ្នានឹងក្រមព្រហ្មទ័ណ្ឌដែរនោះ បានចែងអំពីបទឧក្រិដ្ឋបន្ថែម បើសិនជាប្រព្រឹត្តឡើងដោយបុគ្គលិកយោធា ។ បទឧក្រិដ្ឋ និងការផ្តន្ទាទោស ទាំងអស់នេះ ត្រូវបានកំណត់ជាទូទៅ តាមផ្លូវតែមួយដូចមានចែងនៅក្នុងក្រមព្រហ្មទ័ណ្ឌ[៥៣] ។

៨៧- ក្រមឆ្នាំ ១៩៥៦ មិនបានបញ្ចូលបទល្មើសជាអន្តរជាតិ ដូចជាបទប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមទេ ។ ទោះបីជាច្បាប់កម្ពុជាអនុញ្ញាតឱ្យធ្វើការចោទប្រកាន់ ទៅលើបុគ្គល ចំពោះឧក្រិដ្ឋកម្មអន្តរជាតិដែលអវត្តមានមិនបានចែងនៅក្នុងច្បាប់នៃឧក្រិដ្ឋកម្មទាំងនោះ នៅក្នុងព្រហ្មទ័ណ្ឌ នៅតែនៅដោះស្រាយមិនទាន់រួចនៅឡើយ[៥៤] ។

៨៨- អំពើឃោរឃៅដែលបានប្រព្រឹត្តឡើងដោយពួកខ្មែរក្រហម ហាក់ដូចជាស្របនឹងនិយមន័យនៃបទ

---

[៥៣] ច្បាប់តុលាការយោធា មាត្រាទី ១៥៥ ។

[៥៤] ចំពោះច្បាប់បារាំង សូមមើល ង្វៀង កុកឌិញ ប៉ាទ្រិកដាលិយេ និងអាឡាំងប៉េឡេ ច្បាប់សាធារណៈអន្តរជាតិ ទំព័រ ២២៨-២៩ ៦៣២-៣៣ ( ប៉ារីស៍ បណ្ណាគារទូទៅនៃច្បាប់ និងយុត្តិសាស្ត្រ បោះពុម្ពលើកទី ៥ ឆ្នាំ ១៩៩៤) អេលីហ្សាបែត ហ្សូលេ "និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" សារពិតមានច្បាប់អន្តរជាតិ សៀវភៅ ១២០ ទំព័រ ៥៤៩ ៥៥០-៥៥១ ( ឆ្នាំ ១៩៩៣) ។

ឧក្រិដ្ឋផ្សេង ៗ នៅក្នុងក្រមព្រហ្មទ័ណ្ឌកម្ពុជា ឆ្នាំ ១៩៥៦ ដូចជាដើម្បីបញ្ជាក់ ជាផ្លូវច្បាប់ បញ្ចូលវាទៅ ក្នុងយុត្តាធិការ របស់តុលាការដែលកាត់ទោសពួកខ្មែរក្រហម ។ ទាំងនេះ រួមមានឃាតកម្ម ទារុណកម្ម ការចាប់រំលោភ ការឃុំខ្លួនមនុស្សដោយខុសច្បាប់ ការរំលោភលើរូបរាងកាយដ៏ទៃទៀត ការវាយប្រហារទៅលើសាសនា និងការរំលោភដ៏ទៃទៀតទៅលើអំណាចរដ្ឋាភិបាល ។ ដោយសារទាំងនេះ ជាឧក្រិដ្ឋកម្មតាម ច្បាប់នៃប្រទេសកម្ពុជា ព្រះរាជអាជ្ញាមិនចាំបាច់ត្រូវការការបញ្ជាក់អំពីកត្តាបន្ថែមចំពោះបទល្មើសជាអន្តរជាតិទៀតទេ ដូចជាគោលបំណងចង់កំទេចក្រុមមនុស្សផ្សេង ៗ (ការប្រល័យពូជសាសន៍) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬចំណងជាមួយជម្លោះដោយអាវុធ (ឧក្រិដ្ឋកម្មសង្គ្រាម) ។

## ២- <u>វិសាលភាពនៃការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់បុគ្គល</u>

៨៩- ក្រមព្រហ្មទ័ណ្ឌបានចែងថាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មផ្សេង ៗ ដូចជាការជួយ ការជំរុញ និងការប៉ុនប៉ង[៥៥] ។ ក្រមក៏បានផ្តល់នូវបញ្ជីមួយនៃការការពារពិរុទ្ធភាព រួមមាន ភាពវិកលចរិក កូនក្មេង <u>ការបង្ខំចិត្ត</u> បទបញ្ជាពីថ្នាក់លើ និងស្វ័យការពារ[៥៦] ។ ជាលទ្ធផល ជនល្មើសជាកូនក្មេង អាចរួចចាកផុតពីការចោទប្រកាន់ ជាពិសេសដោយសារការត្រួតត្រាលើអ្វី ៗ សព្វបែបយ៉ាង និងបរិយាកាសនៃការភ័យខ្លាច និងអាសន្ន ដែលគ្របដណ្តប់ប្រទេសជាតិក្នុងពេលខ្មែរក្រហម ។ លើសពីនេះទៅទៀត លក្ខណៈពិតប្រាកដនៃពាក្យថា <u>ការការពារដោយបង្ខំចិត្ត</u> ទាមទារឱ្យមានការពន្យល់ ដូចទំហំនៃការការពារបញ្ជារបស់ថ្នាក់លើដែរ ។

៩០- ទីចុងបំផុត ក្រមព្រហ្មទ័ណ្ឌបានចែងពីការកំណត់ព្រំដែន - ពោលគឺ ១០ ឆ្នាំសំរាប់បទឧក្រិដ្ឋ ៥ឆ្នាំសំរាប់បទមជ្ឈិម និង ១ ឆ្នាំសំរាប់បទលហុ ។ ពេលវេលានេះ ចាប់ផ្តើមពីការប្រព្រឹត្ត និងសួរចម្លើយធ្វើឡើងតាមបញ្ជារបស់តុលាការណាមួយ[៥៧] ។ ដូច្នេះ ការបកស្រាយណាមួយ អាចទប់ស្កាត់ការចោទប្រកាន់ ចំពោះអំពើឃោរឃៅ ដែលត្រូវបានប្រព្រឹត្តឡើងពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ចាប់តាំងពីខែមករា ឆ្នាំ ១៩៨៩

---

[៥៥] ក្រមព្រហ្មទ័ណ្ឌ មាត្រាទី ៧៧-៨៨ ។

[៥៦] ដូចគ្នា មាត្រាទី ៨៩-១០៤ ។

[៥៧] ដូចខាងលើ មាត្រាទី ១០៩-១៤ <u>សូមមើលជាទូទៅ</u> ហ្គាស់តុង ស្តេហ្វានី ហ្សឺរកឡឺវ៉ាសិសឺរ និងបែណា ប៊ូលុក <u>នីតិវិធីព្រហ្មទ័ណ្ឌ</u> ១៣៩-៥១ (ប៉ារីស៍ ដាឡូស ការបោះពុម្ពលើកទី ១៦ ឆ្នាំ ១៩៩៦) ។

ពេលគឺ ១០ ឆ្នាំ ក្រោយរដ្ឋាភិបាលខ្មែរក្រហមបាត់បង់អំណាច ។ ឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងមុនឆ្នាំ ១៩៧៩ ត្រូវធ្វើការស៊ើបអង្កេត ឬធ្វើការចោទប្រកាន់នៅមុនឆ្នាំ ១៩៨៩ ។ ក៏ប៉ុន្តែ បើឈរលើអតីតកាលដែលធ្លាប់បានកើតមានឡើងនៅក្នុងប្រទេសអឺរ៉ុបនានានោះ ដែលការចោទប្រកាន់ទៅលើពួកប្រព្រឹត្តបទល្មើសណាហ្ស៊ី បន្ទាប់ពីផុតកំណត់ពេលនៃការកំណត់ព្រំដែនអាយុកាលនោះ - ជាពិសេស ប្រទេសអាល្លឺម៉ង់ និងប្រទេសបារាំង នៅក្នុងទសវត្សឆ្នាំ ១៩៦០ និង ១៩៨០ - ការជំរើសផ្សេងទៀតនៅតែអាចធ្វើបានចំពោះប្រទេសកម្ពុជា ។ ទី ១ រដ្ឋសភាត្រូវលប់ចោលលក្ខន្តិកៈនៃការក៏រិតព្រំដែនអាយុកាល ហើយធ្វើយ៉ាងដូច្នេះថ្វីបើមានការដែលថារយៈពេលកំណត់ត្រូវបានកន្លងផុតទៅហើយក៏ដោយ ។ ទី ២ រដ្ឋសភាអាចផ្អាក ការអនុវត្តន៍លក្ខន្តិកៈពីឆ្នាំ ១៩៧៥ រហូតដល់ពេលបច្ចុប្បន្ននេះ ដោយហេតុថាតុលាការមិនត្រូវបានដំណើរការដោយពេញលេញនៅក្នុងរយៈពេលនោះ[៥៨] ។

## គ- សេចក្ដីសន្និដ្ឋាន

៩១- ឈរលើទស្សនៈខាងផ្លូវច្បាប់របស់យើងខ្ញុំ និងភស្តុតាងដែលមាន ក្រុមអ្នកជំនាញការមានជំនឿថាអាចបញ្ជាក់ថាត្រឹមត្រូវតាមផ្លូវច្បាប់បាន ដើម្បីបញ្ចូលយុត្តាធិការទៅក្នុងតុលាការណាមួយដែលត្រូវធ្វើការកាត់ទោសពួកមេដឹកនាំខ្មែរក្រហម ចំពោះអំពើរបស់ពួកគេពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នូវបទឧក្រិដ្ឋដូចតទៅៈ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ការបង្ខំមនុស្សឱ្យធ្វើការជាទម្ងន់ ទារុណកម្ម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សដែលត្រូវបានការពារជាអន្តរជាតិ ក៏ដូចជាបទឧក្រិដ្ឋទាំងឡាយដែលបានធ្វើការកត់សំគាល់ខាងលើ ។ តុលាការមួយបែបនេះ ក៏មានការចាំបាច់ត្រូវយកចិត្តទុកដាក់អំពីគោលការណ៍ទាក់ទិនទៅនឹងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋរបស់បុគ្គល ដូចដែលបាននិយាយខាងលើនេះ ជាពិសេសការទទួលខុសត្រូវរបស់អ្នកបញ្ជា និងចុងចោទខ្លះដែលអាចរកបាន ។ លើសពីនេះទៅទៀត ក្រុមអ្នកជំនាញការឃើញថា ឧក្រិដ្ឋកម្មទាំងអស់នេះ ក្នុងការជាក់ស្ដែងត្រូវបញ្ចូលទៅក្នុងយុត្តាធិការរបស់តុលាការដែលយើងខ្ញុំស្នើឡើង នឹងដែលត្រូវបកស្រាយនៅក្នុងផ្នែក VIII.B.2 ខាងក្រោមនេះ ។

## VI- ខ្មែរក្រហម នៅក្នុងក្របខ័ណ្ឌនយោបាយ និងសង្គម នាសម័យបច្ចុប្បន្ន

[៥៨] សំរាប់ការពិភាក្សានូវអតីតកាលនេះ សូមមើល រ៉ាត់ណើរ និងអាប្រាម ដូចបានរៀបរាប់ខាងលើ ១២៦-២៧ ។

៩២- ផ្នែកនានានៃរបាយការណ៍របស់យើងខ្ញុំរហូតមកដល់ចំណុចនេះ ជាបឋមមានធាតុជាប្រវត្តិសាស្ត្រ ជាច្បាប់ និងជាបច្ចេកទេស ។ ប៉ុន្តែ ចាប់ពីចំណុចនេះការសិក្សារបស់យើងខ្ញុំពិនិត្យទៅលើលទ្ធភាពនៃការនាំខ្លួនពួកមេដឹកនាំខ្មែរក្រហមទៅកាន់តុលាការ និងលើកឡើងនូវសេចក្តីស្នើយោបល់ស្តីអំពីវិធីអប្បបរមា ដើម្បីបំពេញបាននូវការណ៍នេះ ។ នៅក្នុងការវិភាគ និងការស្នើយោបល់របស់យើងខ្ញុំនេះ សមាជិកនៃក្រុមមិនអាច ដើរតួជាអ្នកជំនាញការខាងច្បាប់នោះទេ ។ ផ្ទុយទៅវិញ យើងខ្ញុំត្រូវគិតគូរពិចារណាទៅលើកត្តានយោបាយដែលគ្មានពីរនៅក្នុងប្រទេសកម្ពុជា និងជាពិសេសការយល់ឃើញរបស់ប្រជាពលរដ្ឋកម្ពុជា និងតួនាទីរបស់ខ្មែរក្រហមនៅក្នុងនយោបាយក្នុងស្រុកនៃកម្ពុជា ។ កត្តាទាំងនេះ ផ្តល់ឱ្យយើងបានដឹងយ៉ាងជិតស្និទ្ធនូវផ្នែកដែលត្រូវធ្វើតាម និងដែលគួរមកវិភាគដោយលំអិតនៅក្នុងចំណុចនេះ ។

## ក- ទស្សនះរបស់រដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា

៩៣- របាយការណ៍មួយបែបនេះ ត្រូវធ្វើឡើងដោយចាប់ផ្តើមពីចំណុចនៃទស្សនះរបស់ប្រជាពលរដ្ឋកម្ពុជា និងរដ្ឋាភិបាលរបស់គេ ។ វាជាការបញ្ជាក់ដ៏មានតម្លៃណាស់ ដែលក្រុមអ្នកជំនាញការត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងសេចក្តីស្នើសុំរបស់រដ្ឋាភិបាលកម្ពុជា ។ នៅក្នុងការជួបប្រជុំរបស់យើងខ្ញុំជាមួយមន្ត្រីកម្ពុជានានា ទាំងអស់គ្នាតែងតែបានបញ្ជាក់ឡើងវិញនូវការគាំទ្ររបស់ពួកគេចំពោះការកាត់ទោសពួមេដឹកនាំ ខ្មែរក្រហម ។ ការនេះបានបញ្ជាក់ដល់យើងខ្ញុំដោយពុំមានការស្រពិចស្រពិលនៅនាថ្នាក់ខ្ពស់បំផុត ដោយ សម្តេច ហ៊ុន សែន បច្ចុប្បន្ននាយករដ្ឋមន្ត្រី និងសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ បច្ចុប្បន្នប្រធានរដ្ឋសភា ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ក្រុមពុំមានវាសនាបានចូលគាល់ព្រះមហាក្សត្រសីហនុទេ ដោយព្រះអង្គបានយាងចេញពីប្រទេសកម្ពុជាទៅព្យាបាលព្រះរោគ យើងខ្ញុំបានកត់សំគាល់ឃើញថាព្រះមហាក្សត្រទ្រង់បានសំដែងនូវការគាំទ្រយ៉ាងខ្លាំងក្លារបស់ព្រះអង្គ ក្នុងការយកពួកមេដឹកនាំខ្មែរក្រហមទៅកាត់ទោស និងឱ្យតុលាការជំនុំជំរះរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ។ ឧទាហរណ៍ នៅចុងឆ្នាំ ១៩៩៨ ព្រះអង្គបានប្រកាសថា "តុលាការអន្តរជាតិគឺជាការល្អបំផុត ក្នុងការទទួលយកករណីប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជា ពី

ព្រោះវាទាក់ទិនទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងមនសិការរបស់សហគមន៍ពិភពលោកទាំងមូល[៥៩] ។ ហើយទោះបីជាក្រុមមិនបានជួបជាមួយមេដឹកនាំប្រឆាំងនៅក្នុងរដ្ឋសភា លោក សម រង្ស៊ី ដែលស្ថិតនៅក្រៅប្រទេសនៅក្នុងពេលទស្សនៈកិច្ចរបស់យើងខ្ញុំក៏ដោយ ក៏លោកធ្លាប់បានសំដែងជាសាធារណៈផងដែរនូវការគាំ ទ្រទរបស់លោកចំពោះការកាត់ទោសពួកមេ ដឹកនាំខ្មែរក្រហម ជាច្រើនលើកមកហើយដែរ ។

៩៤- ចំពោះសាធារណៈមតិកម្ពុជាវិញក្នុងរយៈពេល ២០ ឆ្នាំ ចាប់តាំងពីពួកខ្មែរក្រហមត្រូវបានបណ្តេញចេញពីអំណាចមក ពុំមានការស្ទាបស្ទង់មតិជាខ្សែសង្វាក់ណាមួយត្រូវបានធ្វើឡើង ស្តីអំពីបញ្ហានៃការទទួលខុសត្រូវរបស់ខ្មែរក្រហមទេ[៦០] ។ ជាមួយគ្នានេះ ក្រុមមានជំនឿទៅលើទស្សនៈដែលបានសំដែងចេញឡើងចំពោះយើងខ្ញុំ ដោយខ្លះជាលក្ខណៈឯកជន ខ្លះទៀតប្រកាសថាថាឈរលើការវាយតម្លៃចំពោះសាធារណៈមតិ - ដោយមនុស្សដែលយើងខ្ញុំបានជួបនៅក្នុងប្រទេសកម្ពុជា និងនៅទីកន្លែងដ៏ទៃទៀត ក៏ដូចជាភស្តុតាងដែលនិយាយត ៗ គ្នា ។ ចេញពីការសាកសួរយោបល់ជាមួយជនកម្ពុជាក្នុង និងក្រៅរដ្ឋាភិបាល យើងខ្ញុំបានឮការទាមទារដោយឥតស្រពិចស្រពិលឱ្យការកាត់ទោសខ្មែរក្រហមនេះ ។ ទាំងអស់គ្នាបាននិយាយអំពីសារៈសំខាន់នៃយុត្តិធម៌សំរាប់សន្តិភាព ស្ថេរភាព និងការបង្រួបបង្រួមជាតិ ។ នេះគឺជាការឆ្លើយតបទៅនឹងការព្រួយបារម្ភខ្លះរបស់ក្រុមពីដំបូង ថាតើជនកម្ពុជាអាចមើលឃើញ នៅក្នុងកាលៈទេសៈពិសេសនៃប្រទេសរបស់ខ្លួនថា ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មវាមិនស៊ីសង្វាក់គ្នាជាមួយនឹងការសំរេចឱ្យបាននូវភាពស្ងប់ស្ងាត់ក្នុងសង្គម និងលទ្ធិប្រជាធិបតេយ្យដ៏នឹងនរមួយឬយ៉ាងណា ។ ដូចគូចរចាថ្នាក់ខ្ពស់បំផុតរបស់រដ្ឋាភិបាលម្នាក់បាន

---

[៥៩] ទីភ្នាក់ងារពិតមានរ៉ឺទ័រ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ១៩៩៨ សូមមើលផងដែរ បទសម្ភាសន៍របស់ព្រះមហាក្សត្រជាមួយកាសែត ខាំបូឌាដេលី ទំព័រ៩-១១ ខែឧសភា ឆ្នាំ ១៩៩៧ ទំព័រទី ១ និង កាសែតខាបូឌាធូដេ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ ១៩៩៦ ទំព័រទ្រី ១ ។

[៦០] ដើម្បីជាការបំភ្លឺមួយ តាមការស្ទង់មតិដែលមិនមានលក្ខណៈវិទ្យាសាស្ត្រ ដោយឈរលើសម្ភាសន៍ជាមួយជនកម្ពុជាចំនួន ២១ នាក់ មកពីមជ្ឈដ្ឋានផ្សេង ៗ ពីគ្នា សូមមើល ហ្សាយ៉ា វ៉ាំហ្ស៊ី និងគ្រីស្ទីន បាតុង ការទទួលខុសត្រូវចំពោះឧក្រិដ្ឋរបស់ពួកខ្មែរក្រហម ១៩៧៥-១៩៧៩ បទសម្ភាសន៍ជាមួយជនជាតកម្ពុជា (ភ្នំពេញៈ មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ ១៩៧៧) ។ នៅថ្ងៃទី ២៧ ខែមករា ឆ្នាំ ១៩៩៩ វិជ្ជាស្ថានបារាំងខាងស្ថិតិ ការស្ទាបស្ទង់មតិ និងខាងការស្រាវជ្រាវពីកម្ពុជា បានចេញផ្សាយលទ្ធផលនៃការស្ទាបស្ទង់មតិមួយនៅឆ្នាំ ១៩៩៨ ដែលនៅក្នុងនោះ ៨១.១ ភាគរយ នៃជនកម្ពុជាចំនួន ១ ៥០៣ នាក់ មកពីមជ្ឈដ្ឋានផ្សេង ៗ បានឆ្លើយជាវិជ្ជមានទៅនឹងសំណួរដែលថា "តើអ្នកចង់យកមេដឹកនាំខ្មែរក្រហម នៅក្នុងរបប ប៉ុល ពត ទៅកាត់ទោសឬទេ " ។ ទីបំផុត នៅក្នុងលិខិតមួយច្បាប់ផ្ញើជូនលោកអគ្គលេខាធិការ ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ ១៩៩៩គណៈកម្មាធិការប្រតិកម្មសិទ្ធិមនុស្សកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលចំនួន ១៧ អង្គការរួមគ្នា បានថ្លែងថាមានជនជាតខ្មែរចំនួន ៨៤ ១៩៥ បានចុះហត្ថលេខា ឬផ្តិតមេដៃលើញត្តិមួយយល់ព្រមឱ្យមានការកាត់ទោស ។

ប្រាប់យើងខ្ញុំថា "យុត្តិធម៌ គឺជាផ្នែកមួយនៃរបបប្រជាធិបតេយ្យ" ។ អ្នកខ្លះទៀតនិយាយដោយច្បាស់លាស់អំពីការស៊ីសង្វាក់គ្នារវាងយុត្តិធម៌ចំពោះភាពឃោរឃៅទ្រង់ទ្រាយធំ និងគោលការណ៍សំខាន់ ៧ នៃព្រះពុទ្ធសាសនា បានដក់ជាប់ជ្រៅណាស់ក្នុងសង្គមកម្ពុជា ។ សេចក្តីថ្លែងការណ៍មួយ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ របស់អង្គការក្រៅរដ្ឋាភិបាលដ៏ធំ ៧ ជាច្រើន បានអំពាវនាវឱ្យមានការកាត់ទោស "ទាំងសំរាប់ការបង្រួបបង្រួមជាតិ ទាំងសំរាប់ធ្វើឱ្យមានការស្រុះស្រួលគ្នាវិញនៃប្រជាពលរដ្ឋកម្ពុជា ហើយនឹងជាការប្រមានមួយចំពោះអ្នករំលោភសិទ្ធិមនុស្ស ថាពួកគេមិនអាចគេចរួចពីការផ្តន្ទាទោសទេ" ។

## ខ- ការទាក់ទងរវាងគណបក្សនយោបាយបច្ចុប្បន្ននានា និងខ្មែរក្រហម

៩៥- ទោះបីបច្ចុប្បន្ននេះ ពួកខ្មែរក្រហមអស់មានកម្លាំងប្រយុទ្ធ ហើយអ្នកដឹកនាំកំពូលរបស់ពួកគេបានស្លាប់ទៅហើយក៏ដោយ ក៏ប្រវត្តិ នយោបាយ និងបុគ្គលិករបស់ចលនានេះកំពុងស្ថិតនៅមានអត្ថន័យសំខាន់ជាច្រើននៃនយោបាយក្នុងស្រុកនៃកម្ពុជានៅឡើយ ។ នៅក្នុងពេលបំពេញការងាររបស់ខ្លួន ក្រុមបានដឹងយ៉ាងច្បាស់ថា ជំរើសណាមួយដើម្បីនាំខ្លួនពួកមេដឹកនាំខ្មែរក្រហមទៅកាន់តុលាការ ត្រូវតែធ្វើឡើងដោយមានការយោគយល់ដោយពេញលេញនូវសភាពការណ៍បច្ចុប្បន្ននៃនយោបាយនៃប្រទេសកម្ពុជា ។ ការប្រមូលផ្តុំទៅលើកម្លាំងនយោបាយតែមួយគត់របស់វា ធ្វើឱ្យក្របខ័ណ្ឌកម្ពុជាមិនអាចរកឃើញនូវការដោះស្រាយបានដោយស្រួលនោះទេ ។

៩៦- ទី ១ ទាំងគោលការណ៍របស់គណបក្សនយោបាយនានា ធ្លាប់មានការទាក់ទងយ៉ាងខ្លាំងជាមួយពួកខ្មែរក្រហមអស់រយៈពេលជាច្រើនឆ្នាំមកហើយ និងធ្លាប់បានបញ្ចូលអតីតខ្មែរក្រហមជាសមាជិករបស់ខ្លួនផងក្នុងនេះរួមទាំងអ្នកខ្លះដែលអាចជាទិសដៅនៃការស៊ើបអង្កេតណាមួយក្នុងបញ្ហានៃអំពើឃោរឃៅ ដែលបានកើតមានឡើងនៅក្នុងទសវត្សឆ្នាំ ១៩៧០ ផង ។ នាយករដ្ឋមន្ត្រីបច្ចុប្បន្ន និងសហការីជាច្រើននាក់របស់លោកក្នុងគណបក្សប្រជាជនកម្ពុជា ធ្លាប់ជាសមាជិករបស់ពួកខ្មែរក្រហម មុនពួកគេគេចខ្លួនចូលទៅក្នុងប្រទេសវៀតណាម ទោះបីជាយើងពុំមានហេតុផលអ្វីនឹងជឿថានាយករដ្ឋមន្ត្រី នឹងក្លាយទៅជាកម្មវត្ថុនៃការចោទប្រកាន់ខាងផ្លូវច្បាប់ណាមួយដែលស្ថិតនៅក្នុងអាណត្តិរបស់យើង និងដែលយើងនឹងលើកឡើងនូវការស្នើ មតិបែបនេះណាមួយក៏ដោយ ។ ដូចគ្នានេះដែរ

គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សដ៏ទៃទៀត ធ្លាប់បានចង សម្ព័ន្ធភាពយ៉ាងជិតស្និទ្ធិជាមួយពួកខ្មែរក្រហម នៅក្នុងពេលតស៊ូប្រឆាំងវៀតណាម និងសាធារនរដ្ឋប្រជា មានិតុកម្ពុជា/រដ្ឋកម្ពុជា ។ កត្តានេះបង្កើតជាផ្នែកមួយនៃក្របខ័ណ្ឌ ដែលនៅក្នុងនោះជំរើសនានាសំរាប់ធ្វើ ការចោទប្រកាន់ ត្រូវយកមកពិចារណា ។

៩៧- ទី ២ ទាំងគោលការណ៍របស់គណបក្សនយោបាយនានា តែងតែស្វែងរកការគាំទ្រពីសំណាក់អតីត សមាជិកខ្មែរក្រហម និងពីសំណាក់ប្រជាពលរដ្ឋនៅក្នុងតំបន់ដែលពួកគេកាន់កាប់ ។ (ទោះបីជាមានការប្រ-ព្រឹត្តអំពើឃោរឃៅទាំងអស់នេះរបស់ពួកគេក៏ដោយ ក៏ពួកខ្មែរក្រហមនៅតែត្រូវបានទទួលការគោរពពី សំណាក់ជនកម្ពុជាជាច្រើនរូប ចំពោះស្មារតីស្នេហាជាតិដ៏ខ្លាំងក្លារបស់ពួកគេ និងជាពិសេសការប្រឆាំងដ៏ខ្លាំង ក្លារបស់ពួកគេចំពោះឥទ្ធិពលនៃពួកបរទេសរបស់ពួកគេ -(ជាពិសេសពួកវៀតណាម)- ។ រដ្ឋាភិបាលបាន ប្រកាសថា អាទិភាពរបស់ខ្លួនគឺបញ្ចប់ការគំរាមកំហែងខាងយោធាពីចលនាខ្មែរក្រហម ។ ដូចបានរៀបរាប់ ខាងលើមកហើយថា យុទ្ធសាស្រ្តមួយផ្នែករបស់រដ្ឋាភិបាលនៅក្នុងបញ្ហានេះ គឺក្នុងការដាក់ស្ដែងផ្តល់នូវការ លើកលែងទោសដល់ពួកខ្មែរក្រហមទាំងអស់ ចំពោះសកម្មភាពរបស់ពួកគេក្រោយឆ្នាំ ១៩៧៩ តាមច្បាប់ ព្រហ្មទ័ណ្ឌធម្មតា ឬច្បាប់ដាក់ខ្មែរក្រហមឱ្យនៅក្រៅច្បាប់ ឆ្នាំ ១៩៩៤ (លើកលែងតែករណីមួយដែលទាក់ទិន នឹងការសម្លាប់ជនបរទេសចេញ) ក៏ដូចជាឈប់ធ្វើការចោទប្រកាន់ពួកមេដឹកនាំខ្មែរក្រហម ចំពោះឧក្រិដ្ឋកម្ម ដែលពួកគេបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គ្រាន់តែដើម្បីឱ្យមានយុត្តិធម៌ត្រឹមត្រូវ និងមិន លំអៀង ក៏ទាមទារឱ្យមានការសំរេចដោយឯករាជ្យទៅលើអ្នកត្រូវចោទប្រកាន់ និងត្រូវកាត់ទោសដោយ គ្មានការគាបសង្កត់ខាងនយោបាយដែរ យុទ្ធសាស្រ្តនេះអាចបញ្ជាក់ថាជាឧបសគ្គមួយទៅហើយ ។

៩៨- ទី ៣ គណបក្សប្រជាជនកម្ពុជា ដែលបានគ្រប់គ្រងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៧៩ មក បាន រិះរកការគាំទ្រពីប្រជាពលរដ្ឋ តាមរយៈចំណងទាក់ទងរបស់ខ្លួនជាមួយពួកខ្មែរក្រហមដែលត្រូវបានបណ្ដេញ ចេញទៅហើយ និងបញ្ចប់ការគំរាមកំហែងរបស់ចលនានេះមកលើប្រទេសជាតិ ។ ក៏ប៉ុន្តែ នៅក្នុងពេលជា មួយគ្នានេះ តាំងពីមួយជំនាន់មកហើយ បានបញ្ជាក់នូវទស្សនៈជាផ្លូវការផ្ទាល់របស់ខ្លួនថាអ្នកណាដែលទទួល ខុសត្រូវចំពោះអំពើឃោរឃៅរបស់កម្ពុជាប្រជាធិបតេយ្យ ដោយសង្រួមជាឃ្លាមួយថា "បនប្រល័យពូជ សាសន៍ ប៉ុល ពត - អៀង សារី" ដែលជាពាក្យមួយដែលត្រូវបានប្រើនៅក្នុងពេលកាត់ទោស ដោយកំបាំងមុខ

កាលពីឆ្នាំ ១៩៧៩ ។ ចំពោះវិសាលភាពដែលថាការកាត់ទោសដោយត្រឹមត្រូវ អាចទម្លាយឱ្យឃើញនូវទិដ្ឋ-ភាពប្រវត្តិសាស្ត្រមួយផ្សេងពីអ្វីដែលបានអះអាងដោយគណបក្សប្រជាជនកម្ពុជា ជាមួយនឹងការជាប់ពាក់ព័ន្ធដលក់មនុស្សផ្សេងថែមទៀតនោះ រដ្ឋាភិបាលអាចមានការព្រួយបារម្ភអំពីតុលាការមួយដែលខ្លួនមិនអាចត្រួតត្រាពីលើបាននោះ ។

## គ- ការគំរាមកំហែងដែលអាចដឹងបានចំពោះប្រទេសកម្ពុជា បណ្តាលមកពីការទទួលខុសត្រូវ

៩៩- យើងខ្ញុំក៏សូមឆ្លើយតបទៅនឹងទស្សនៈដែលថា កម្ពុជាត្រូវធ្វើដំណើរទៅមុខ ហើយមិនត្រូវគិតគូរពីអតីតកាលរបស់ខ្លួនទេ ។ នេះគឺជាទស្សនៈភាគតិចដោយឡែកមួយទេ នៅក្នុងពេលទស្សនៈកិច្ចរបស់យើងខ្ញុំនៅកម្ពុជា (ហើយវាមិនមានទេនៅក្នុងចំណោមជនកម្ពុជាទាំងឡាយដែលយើងបាននិយាយជាមួយនោះ) ។ ចម្លើយដ៏ងាយបំផុតមួយ គឺថាឧក្រិដ្ឋកម្មដូចដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហមនោះ វាសមនឹងទទួលទោស ណាស់ ដោយវាជាបញ្ហាសីលធិមផង និងការយកចិត្តទុកដាក់ជាមូលដ្ឋាននៃភាពយុត្តិធិមផង ។ អ្នកដែលប្រ កែកប្រឆាំងនឹងការទទួលខុសត្រូវ អាចទទួលយកគោលការណ៍សីលធិមនោះ តែវាគ្រាន់តែមិនជាក់ស្តែង ឬ មិនផ្តល់នូវផលប្រយោជន៍អ្វីនៅក្នុងក្រមខ័ណ្ឌនៃប្រទេសកម្ពុជាទេៈ ជនកម្ពុជាទាំងនោះមិនចង់ឱ្យមានការទទួលខុសត្រូវទេ ឬថាការទទួលខុសត្រូវនោះនឹងនៅដោយឡែកពីសង្គមកម្ពុជា ។

១០០- ចំពោះមតិរបស់សាធារណៈជនវិញ ក្រុមអ្នកជំនាញការបានដឹងឮនូវបំណងយ៉ាងខ្លាំងក្លាមួយចង់បានសន្តិភាពក្នុងចំណោមជនកម្ពុជា ទាំងនៅខាងក្នុងរដ្ឋាភិបាល ទាំងនៅខាងក្រៅរដ្ឋាភិបាល ។ តែពុំមាននរណាម្នាក់យល់ឃើញថា សន្តិភាព និងការកាត់ទោស មិនអាចសំរុះសំរួលគ្នាបាន ឬថាជនកម្ពុជាគិតថាសន្តិភាពគឺជាអ្វីមួយសំរាប់ជំនួសយុត្តិធិមនោះ ក៏ទេដែរ ។ម្យ៉ាងទៀត ចំពោះទស្សនៈរបស់យើងខ្ញុំ ការប្រេះស្រាំនៅក្នុងសង្គមកម្ពុជាមិនអាចផ្សាផ្ជាប់គ្នាវិញបានជាដាច់ខាត ហើយថាសន្តិភាព និងស្ថេរភាពនឹងអាចពង្រឹងទៅបាន លុះត្រាតែមានការទទួលខុសត្រូវដ៏ត្រឹមត្រូវមួយនូវអ្វីដែលសាំពីអតីតកាល (ឬលទ្ធភាពថាវាអាចនឹងសាំរួចមកហើយនោះ) ឱ្យចេញមកពីនយោបាយនាពេលបច្ចុប្បន្ននេះ ។ យើងខ្ញុំជឿជាក់ថាសង្គមកម្ពុជា នឹងអាចយល់បាន និងជៀសឱ្យផុតពីអតីតកាលរបស់ខ្លួន ល្គឹកណាតែខ្លួនឃើញថា ពួកអ្នកដែលបាន

ប្រព្រឹត្តអំពើឃោរឃៅដោយទ្រង់ទ្រាយធំ ត្រូវបានបញ្ជូនទៅកាន់តុលាការមិនលំអៀងមួយ ពោលគឺតុលាការ មួយ ដែលគ្មានការប៉ុនប៉ងបង្ខំដាក់ទស្សនៈផ្ទាល់របស់ខ្លួនចំពោះប្រវត្តិសាស្ត្រ ទៅលើពលជាពលរដ្ឋកម្ពុជា ។ ការកាត់ទោសក៏ត្រូវយកមកប្រើប្រាស់ផងដែរ ដើម្បីបង្កើតឡើងសំរាប់សហគមន៍កម្ពុជា នូវអ្វីដែលជាចរិយា មារយាទដែលមិនអាចទទួលយកបាន និងអ្វីដែលជាបច្ច័យដោយជៀសមិនផុតរបស់វានោះ ។ យើងមិនមែន ឆោតល្ងង់រហូតដល់គិតថា ការកាត់ទោសទាំងឡាយណាមួយអាចនឹងផ្លាស់ប្តូរដ៏អស្ចារ្យនូវរូបភាពសិទ្ធិមនុស្ស នៅក្នុងប្រទេសកម្ពុជាបានក្នុងរយៈពេលភ្លាម ៗ នោះទេ ប៉ុន្តែវាគឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅឱ្យមាន កិច្ចដំណើរការផ្លាស់ប្តូរនេះប៉ុណ្ណោះ ។

១០១- ចំពោះទល្លីករទាក់ទិនទៅនឹងលទ្ធផលជាវិជ្ជមានចំពោះការកាត់ទោសបែបនេះនោះ ហើយជាពិសេស ទល្លីករដែលថាការកាត់ទោសបែបនេះនឹងធ្វើឱ្យបាត់លំនឹងសំរាប់ប្រទេសកម្ពុជានោះ ការវិភាគខាងក្រោមនេះ នឹងពិចារណាលើគោលជំហរនេះដោយប្រយ័ត្នប្រយែងបំផុត ។ អនុសាសន៍របស់យើងខ្ញុំ គឺ មានលក្ខណៈ ស្ថាបនា ដូចជាការគិតគូរដល់សេចក្តីត្រូវការឱ្យមានទាំងការទទួលខុសត្រូវរបស់បុគ្គល និងការបង្រួបបង្រួម ជាតិជាដើម ។ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំមិនបានគិតថាការកាត់ទោសនឹងធ្វើឱ្យបាត់បង់នូវស្ថេរ ភាពដោយឯកឯង និងធ្វើឱ្យការខិតខំទាំងឡាយជាការឥតប្រយោជន៍នោះទេ ។ ផ្ទុយទៅវិញ ដោយឈរលើ ការសាកសួរយោបល់របស់យើងខ្ញុំនៅក្នុងប្រទេសកម្ពុជានោះ យើងខ្ញុំយល់ថាបន្ទាប់ពីការរង់ចាំអស់រយៈពេល ២០ ឆ្នាំ មក ជនកម្ពុជាបានត្រៀមខ្លួនជាស្រេចចំពោះការកាត់ទោសនេះ និងសុខចិត្តឱបក្រសោបយកវា ។

## VII- លទ្ធភាពនៃការនាំខ្លួនពួកមេដឹកនាំខ្មែរក្រហមទៅកាន់តុលាការ

### ក- ទិសដៅនៃការស៊ើបអង្កេត

១០២- បញ្ហាសំខាន់ជាបឋម ក្នុងការវាយតម្លៃអំពីលទ្ធភាពនៃការនាំខ្លួនពួកមេដឹកនាំទៅកានលតុលាការ និងការធ្វើការស្នើយោបល់ស្តីអំពីជំរើសសំរាប់ធ្វើកិច្ចការនេះ គឺចំនួនមនុស្សដែលត្រូវនាំខ្លួនទៅកាន់តុលាការ នៃយុត្តាធិការដ៏សមស្របមួយ ។ ដូចបានកត់សំគាល់នៅក្នុងការវិភាគផ្នែកប្រវត្តិសាស្ត្រខាងលើនេះស្រាប់

អំពើឃោរឃៅដែលបានកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានប្រព្រឹត្តឡើងដោយបុគ្គលរាប់ពាន់នាក់ តាមកំរិតនៃការទទួលខុសត្រូវផ្សេង ៗ គ្នា នៅទូទាំងប្រទេស ។ ភាគច្រើននៃពួកគេនេះកំពុងរស់នៅនៅក្នុងប្រទេសកម្ពុជានៅឡើយ ភាគច្រើននៅជិតបង្កើយនឹងអ្នករងគ្រោះរបស់ពួកគេ ចំណែកអ្នកខ្លះផ្សេងទៀតត្រូវបានគេសម្លាប់ ឬបានរត់ចេញពីប្រទេសទៅហើយ ។ ក្រុមអ្នកជំនាញការ បានផ្តោតការយកចិត្តទុកដាក់ខ្លាំងបំផុតចំពោះការដែលថា តើមានមនុស្សប៉ុន្មាននាក់ដែលត្រូវបញ្ជូទៅកាត់ទោសនោះ ហើយការនេះត្រូវបានធ្វើការសាកសួរយោបល់យ៉ាងទូលំទូលាយជាមួយតំណាងនានា នៅក្នុងរដ្ឋាភិបាល និងនៅក្រៅរដ្ឋាភិបាល ។

១០៣- ជំរើសមួយដែលជាក់ស្តែងជាកំណត់ គឺជំរើសរបស់ប្រជាពលរដ្ឋកម្ពុជា ។ ក្នុងចំណោមមនុស្សទាំងឡាយដែលក្រុមបានជួប ភាគច្រើនបំផុតបានយល់ឃើញថាមានតែ "មេដឹកនាំ" ខ្មែរក្រហមប៉ុណ្ណោះទេដែលត្រូវជាទិសដៅនៃការស៊ើបអង្កេត ហើយមិនមែនកម្មាភិបាលថ្នាក់ទាបទេ ទោះបីជាកម្មាភិបាលនោះគឺជាមនុស្សដែលធ្លាប់បានប្រព្រឹត្តអំពើឃោរឃៅផ្សេង ៗ ក៏ដោយ ។ មានការយល់ឃើញថា ការកាត់ទោសអ្នកជាប់ចោទដែលមានចំនួនច្រើនពេកមិនអាចធ្វើទៅកើតទេក្នុងការជាក់ស្តែង ហើយជាសក្តានុភាពវាអាចធ្វើឱ្យខូចខាតដល់ការបង្រួបបង្រួមជាតិ។ មានតែមនុស្សមួយចំនួនតូចទេដែលយល់ថា មនុស្សទាំងអស់ដែលបានប្រព្រឹត្តអំពើឃោរឃៅ ត្រូវយកទៅកាត់ទោស ដោយមិនចាំបាច់គិតពីទំហំ និងបច្ច័យរបស់វាទេនោះ ។

១០៤- ក្នុងចំណោមជនកម្ពុជាជាច្រើននាក់ ដែលបានសំដែងនូវបំណងថាមានតែ "មេដឹកនាំ" ខ្មែរក្រហមទេដែលត្រូវប្រឈមមុខនឹងការចោទប្រកាន់ពីបទព្រហ្មទណ្ឌនោះ វាមានការខុសគ្នាយ៉ាងខ្លាំងមួយចំពោះអត្ថន័យ នៃពាក្យនេះ ។ មន្ត្រីរដ្ឋាភិបាលខ្លះយល់ឃើញថា ការកាត់ទោសត្រូវកំណត់ត្រឹមតែអតីតមន្ត្រីថ្នាក់ខ្ពស់ខ្មែរ ក្រហមមួយក្តាប់តូចប៉ុណ្ណោះ ដែលនៅក្នុងពេលទស្សនៈកិច្ចបេសលយើងខ្ញុំពួកនេះបានបដិសេធមិនព្រមសុំចុះ ចូលជាមួយរដ្ឋាភិបាល ។ អ្នកខ្លះទៀត យល់ឃើញថាត្រូវកាត់ទោសពួកមេដឹកនាំថ្នាក់ខ្ពស់ខ្មែរក្រហមចំនួន មួយក្រុមធំជាងនេះ ដែលទទួលខុសត្រូវខ្លាំងជាងគេចំពោះអំពើឃោរឃៅនៅក្នុងរយៈពេលនោះ ។ ក្រុមក៏ត្រូវបានផ្តល់ឱ្យដឹងផងដែរនូវទស្សនៈ (ជាពិសេសពីសំណាក់អ្នកដែលមិនមែនជាជនកម្ពុជា) ដែលថាថាការកាត់ទោសពួកមេដឹកនាំខ្មែរក្រហមនាទសវត្សឆ្នាំ ១៩៧០ ដែលបានយល់ព្រមបញ្ឈប់ធ្វើការតស៊ូប្រឆាំង

រដ្ឋាភិបាល ដើម្បីប្តូរនឹងការបញ្ចេញឱ្យឃើញ និងការធានាជាឯកជន ចំពោះការមិនធ្វើការចោទប្រកាន់ទៅលើពួកគេនោះ វានឹងបណ្តាលឱ្យកើតមានអស្ថេរភាពសំរាប់ប្រទេសកម្ពុជា និងអាចរហូតដល់នាំទៅឱ្យប្រទេសជាតិ ត្រឡប់ធ្លាក់ចូលទៅក្នុងស្ថានភាពនៃសង្គ្រាមស៊ីវិល ដែលបានរាលដាលកាលពីទសវត្សឆ្នាំ ១៩៨០ មកហើយនោះ ជាពុំខាន ។

១០៥- ក្រុមសូមកត់សំគាល់ថា អាណត្តិរបស់ក្រុមគឺការជូនការស្នើយោបល់ ទាក់ទិនទៅនឹងការនាំខ្លួន "ពួកមេដឹកនាំខ្មែរក្រហម" ទៅកាន់តុលាការ ។ អត្ថន័យរបស់យើងខ្ញុំចំពោះពាក្យនេះ គឺត្រូវបានណែនាំដោយសេចក្តីសំរេចចិត្តលេខ ៥២/១៣៥ ដែលអំពាវនាវឱ្យក្រុមយើងខ្ញុំ "លើកឡើងនូវវិធានការបន្ថែម ដើម្បីជាមធ្យោបាយមួយនាំទៅឱ្យមានការបង្រួបបង្រួមជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គល" ដោយគ្មានកំរិតព្រំដែនបញ្ហាត្រឹមតែ "មេដឹកនាំ" នោះទេ ហើយតាមរយៈលិខិតរបស់រដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ ១៩៩៧ ដែលធ្វើការយោងតែត្រឹម "មនុស្សទទួលខុសត្រូវទាំងនោះ" ចំពោះបទឧក្រិដ្ឋរបស់កម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ ។

១០៦- ដោយហេតុដូចបានរៀបរាប់ខាងលើនេះ ក្រុមបានដើរដល់សេចក្តីសន្និដ្ឋាន ៥ ទាក់ទិនទៅនឹងទិសដៅនៃការស៊ើបអង្កេត ។ ទី១ យើងខ្ញុំមិនជឿថាការកាត់ទេសត្រូវប៉ុនប៉ងនាំមនុស្សទាំងអស់ ឬក៏មនុស្សយ៉ាងច្រើនបំផុត ដែលបានប្រព្រឹត្តការរំលោភច្បាប់អន្តរជាតិ និងច្បាប់កម្ពុជានៅក្នុងរយៈពេលដែលមានទាក់ទងខាងលើ ទៅកាន់តុលាការនោះទេ ។ ឆាកមួយបែបនេះ គឺទី ១ និងជាដំបូងបង្អស់ ធ្វើទៅមិនរួចទេទាំងខាងសម្ភារៈ ទាំងខាងថវិការ សំរាប់តុលាការប្រភេទណាមួយ ដែលគោរពទៅតាមសិទ្ធិត្រឹមត្រូវរបស់ចុងចោទ ។ ម្យ៉ាងទៀត វាជាការយល់ឃើញរបស់យើងខ្ញុំដែលថា ការមើលឃើញបែបណាមួយក៏ដោយអំពីសេចក្តីត្រូវការសំរាប់ការបំភ្លឺព្រឹត្តិការណ៍នៃអតីតកាល ការបញ្ចេញមកវិញនូវព្រឹត្តិការណ៍ទាំងឡាយតាមរយៈការកាត់ទោសពីបទព្រហ្មទ័ណ្ឌ ដោយទ្រង់ទ្រាយធំនោះ វានឹងបង្អាក់នូវការបង្រួបបង្រួមជាតិដ៏សំខាន់សំរាប់ប្រទេសកម្ពុជា និងដែលបានគូសបញ្ជាក់នៅក្នុងសេចក្តីសំរេចចិត្តលេខ ៥២/១៣៥ ។ នៅទីចុងបំផុត បញ្ហាច្បាប់ជុំវិញការទទួលខុសត្រូវនៃមនុស្សស្ថិតនៅថ្នាក់ក្រោមជាច្រើននាក់ ជាពិសេសជនល្មើសដែលមានអាយុនៅក្មេង ៗ នោះ មានលក្ខណៈស្មុគស្មាញណាស់ និងនាំយល់ថាមនុស្សអស់នេះមិនត្រូវកាត់ទោសទេ ។

១០៧- ទី ២ ក្រុមបានពិនិត្យដោយយកចិត្តទុកដាក់ សេចក្តីព្រួយបារម្ភដែលបានកត់សំគាល់ខាងលើ ស្តីពីលទ្ធភាពនៃបច្ច័យបណ្តាលមកពីការកាត់ទោសមនុស្ស ដែលបានសុំចុះចូលមកខាងរដ្ឋាភិបាល ឬដែលបានត្រឡប់មករស់នៅក្នុងជីវភាពស៊ីវិលធម្មតាឡើងវិញ ប៉ុន្តែមិនមានជំនឿថា ដោយឈរលើការវាយតម្លៃរបស់យើងពួកគេនឹងច្រានចោលជាមុននូវការកាត់ទោសមួយបែបនេះនោះទេ ។ បញ្ហាជាបឋម យើងបានកត់សំគាល់ឃើញថាការក៏រិតព្រំដែនមួយបែបនេះ គឺមានលក្ខណៈមិនត្រឹមត្រូវក្នុងន័យ ២ យ៉ាង ពោកគឺ: វាជាការធ្វើមិនដឹងមិនឮថាគោលការណ៍នៃការជាប់ចោទពីបទព្រហ្មទ័ណ្ឌ ត្រូវភ្ជាប់ទៅនឹងក៏រិតនៃការទទួលខុសត្រូវផ្ទាល់ខ្លួន និងមិនមែនជាកត្តាបក្សពួកនយោបាយទេ - តុលាការនោះ គឺខ្វាក់ភ្នែក ហើយវាផ្តល់ឱ្យដល់ពាក្យថា "មេដឹកនាំ" នូវន័យមួយដែលប្លែកពីការយល់អំពីពាក្យនេះ ។ ម្យ៉ាងទៀត ជាបច្ច័យឡូហ្សិកនៃទល្ហីកររបៀបនេះ គឺថាដោយសារតែមកពីមេដឹកនាំខ្មែរក្រហមស្ទើរតែទាំងអស់បានសុខចិត្តចុះចូលហើយនោះទើបមិនត្រូវឱ្យមានការកាត់ទោសនេះ ។ ការនេះវាផ្ទុយនឹងទស្សនៈដែលយើងធ្លាប់ឮនៅពេលដែលយើងនៅក្នុងប្រទេសកម្ពុជា ក៏ដូចជា ការយល់ដឹងជា បឋមអំពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនានាដ៏ទៃទៀតដែរ ។

១០៨- ប៉ុន្តែ អ្វីដែលធ្ងន់ធ្ងរជាងនេះទៅទៀត គឺថាអ្វីដែលជារឿងពិតជាក់ស្តែងមួយនោះ អ្នកដែលអាចជាប់សង្ស័យជាច្រើននាក់នោះ ឥឡូវនេះគ្មានកម្លាំងប្រដាប់អាវុធរបស់ពួកគេទេ ។ ចំពោះលទ្ធភាពដែលថាអ្នកខ្លះដែលបានចុះចូលរួចមកហើយ អាចនឹងបង្កបង្កើតកម្លាំងរបស់ពួកគេឡើងវិញ ដើម្បីបង្កឡើងនូវការប្រយុទ្ធមួយថ្មីទៀតប្រឆាំងរដ្ឋាភិបាលនោះ

យើងខ្ញុំយល់ឃើញថាអ្នកដែលដើរតាមពួកគេជាទូទៅមុខជាមិនបង្ហាញឱ្យ ឃើញនូវប្រភេទនៃការស្មោះត្រង់និងវិន័យយោធាជាចាំបាច់សំរាប់នាំទៅឱ្យមានលទ្ធផលមួយបែបនេះទេ

ប៉ុន្តែពួកគេគិតគូរអំពីការធានាដល់ជីវិតដ៏សមរម្យរបស់ពួកគេ និងគ្រួសារពួកគេទៅវិញទេ ។ អ្វីដែលជាការសំខាន់បំផុតនោះ គឺថាទិសដៅនៃការស៊ើបអង្កេតនឹងកំណត់ត្រឹមតែពួកអ្នកដែលមានឋានៈជាអ្នកដឹកនាំ ពីឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ដែលទទួលខុសត្រូវ ចំពោះអំពើឃោរឃៅនិងអ្នកដែលមិនមែនជាមន្ត្រីខ្មែរក្រហម ដែលបានក្លាយទៅជាមេដឹកនាំកងឈ្លប ក្រោយឆ្នាំ ១៩៧៩ និងដែលមិនដែលបានប្រព្រឹត្តអ៊ីពីឃោរឃៅ នៅ ក្នុងរយៈពេលឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ លទ្ធភាពនៃការរត់ចោលជួរជាថ្មីម្តងទៀតអាចមានតិចតួចណាស់ ។ ទុលាការេ

ដែលមើលទៅឃើញហាក់ដូចជាហ្មត់ចត់ ក្នុងការការពារសិទ្ធិខាងផ្លូវច្បាប់នៃអ្នកចុងចោទ ក៏នឹងត្រូវប្រុងប្រយ័ត្នចំពោះលទ្ធភាពនោះដែរ ។ ដូច្នេះ យើងខ្ញុំមិនជឿចំពោះការភ័យខ្លាចអំពីការផ្ទុះឡើងនូវសង្គ្រាមឡើងវិញនោះទេ ។

១០៩- ទី ៣ ក្រុមមិនជឿថាពាក្យថា "មេដឹកនាំ" មានន័យដូចគ្នានឹងមនុស្សទាំងអស់ដែលស្ថិតនៅថ្នាក់លើរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬក៏រហូតដល់នៅក្នុងគណបក្សកុម្មុយនិស្តកម្ពុជានោះទេ។ បញ្ជីឈ្មោះរបស់មន្ត្រីថ្នាក់ខ្ពស់របស់រដ្ឋាភិបាល និងបក្ស អាចមិនស៊ីសង្វាក់គ្នាជាមួយនឹងបញ្ជីឈ្មោះមនុស្សដែលទទួលខុសត្រូវជាងគេបំផុត ចំពោះការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្ស ដោយសារថាអ្នកដឹកនាំថ្នាក់កំពូល ៧ របស់រដ្ឋាភិបាលខ្លះ អាចត្រូវបានគេដកចេញ មិនឱ្យដឹងរឿង និងការធ្វើសេចក្តីសំរេចអ្វីមួយ ហើយអ្នកខ្លះទៀតដែលមិនបាននៅក្នុងរចនាសម្ព័ន្ធនៃមេដឹកនាំថ្នាក់លើផងនោះ អាចបានដើរតួនាទីសំខាន់នៅក្នុងអំពើឃោរឃៅ ។ ការនេះហាក់ដូចជាមានការពិតជាពិសេសទាក់ទិនទៅនឹងអ្នកដឹកនាំខ្លះ នៅតាមភូមិភាគ ក៏ដូចជាមន្ត្រីនៃមជ្ឈមណ្ឌលធ្វើទារុណកម្ម និងសួរចម្លើយនានា ដូចជាទួលស្លែងជាដើម ។

១១០- ហេតុដូច្នេះ ទី ៤ ក្រុមសូមស្នើថាតុលាការណាមួយក៏ដោយ ត្រូវតែផ្តោតអារម្មណ៍ទៅលើមនុស្សទាំងឡាយណាដែលទទួលខុសត្រូវជាងគេ ចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរជាងគេបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នេះមានរួមបញ្ចូល មេដឹកនាំថ្នាក់ខ្ពស់ដែលទទួលខុសត្រូវចំពោះការរំលោភ ក៏ដូចជាពួកអ្នកដែលនៅថ្នាក់ទាប ៗ ដែលបានជាប់ពាក់ព័ន្ធផ្ទាល់ក្នុងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរបំផុតនោះ ។ យើងគ្មានបំណងនឹងផ្តល់នូវការក៏រិតចំនួននៃចំនួនមនុស្សប្រភេទនេះ ដែលអាចជាទិសដៅនៃការស៊ើបអង្កេតនោះទេ ។ ទោះបីយ៉ាងណាក៏ដោយ តាមរយៈនៃការសាកសួរយោបល់ និងការស្រាវជ្រាវរបស់ខ្លួន ក្រុមយល់ឃើញថាមនុស្សដែលត្រូវកាត់ទោស អាចមានចំនួនពី ២០ ទៅ ៣០ នាក់។ ចំពោះការសំរេចថាតើអ្នកណានិងនៅពេលណាដែលត្រូវធ្វើការចោទប្រកាន់នោះ វាស្ថិតនៅលើការសំរេចរបស់ព្រះរាជអាជ្ញាតែមួយគត់ប៉ុណ្ណោះ
ក្រុមជឿជាក់ថាយុទ្ធសាស្ត្រដែលនឹងចាត់ឡើងដោយព្រះរាជអាជ្ញារបស់តុលាការណាមួយនោះត្រូវតែគិតគូរដោយហ្មត់ចត់អំពីទិសដៅ ២ ពោលគឺការទទួលខុសត្រូវរបស់បុគ្គល និងការបង្រួបបង្រួមជាតិ ។

១១១- ទី ៥ និងជាទីបញ្ចប់ ក្រុមសង្ឃឹមថាអត្ថន័យដូចបានពោលខាងលើ ស្តីអំពីទំហំនៃការស៊ើបអង្កេត គ្រាន់តែជាការណែនាំមួយសំរាប់ព្រះរាជអាជ្ញាប៉ុណ្ណោះ មិនមែនជាបែបបទនៃយុត្តាធិការរបស់តុលាការណាមួយនោះទេ ។ ដូច្នេះ ឯកសារច្បាប់ណាមួយទាក់ទិនទៅនឹងតុលាការ ត្រូវផ្តល់យុត្តាធិការផ្ទាល់ខ្លួនដល់តុលាការស្តីអំពីមនុស្សណាខ្លះ ដែលសកម្មភាពរបស់ពួកគេធ្លាក់ចូលទៅក្នុងកម្មវត្ថុនៃយុត្តាធិការនៃតុលាការនោះ ហើយសេចក្តីសំរេចអំពីថាតើអ្នកណាខ្លះត្រូវធ្វើការចោទប្រកាន់គឺត្រូវស្ថិតនៅលើព្រះរាជអាជ្ញាតែម្នាក់គត់ដោយបំពាក់នូវការណែនាំខាងលើនៅក្នុងអារម្មណ៍របស់ខ្លួន ។ ទោះបីជាយ៉ាងណាក៏ដោយ ក្រុមសូមជំទាស់នឹងការបង្កើតតុលាការមួយដែលកំរិតព្រំដែនជាមុនដោយច្បាស់លាស់ថា នឹងធ្វើការកាត់ទោសបុគ្គលនានាទាំងឡាយណាដែលឱ្យដឹងឈ្មោះជាមុនហើយនោះ ។

## ខ- ទីកន្លែងស្នាក់នៅរបស់ជនជាប់សង្ស័យ

១១២- មនុស្សភាគច្រើន ដែលអាចជាទិសដៅនៃការស៊ើបអង្កេត កំពុងរស់នៅក្នុងប្រទេសកម្ពុជា ។ ពួកគេភាគច្រើនបានចូលខ្លួនដោយស្វាត់ ៗ ដោយខ្លួនឯង មករស់នៅក្នុងជីវភាពជាជនកម្ពុជាធម្មតា ។ ពួកគេស្ទើរតែទាំងអស់គ្នា មើលទៅឃើញហាក់ដូចជាអ្នកធ្លាប់រស់នៅក្នុងតំបន់ស្ថិតនៅក្រោមការគ្រប់គ្រងជាផ្លូវការរបស់រដ្ឋាភិបាលកម្ពុជា អ្នកខ្លះទៀតរស់នៅក្នុងតំបន់ជាប់នឹងព្រំដែនប្រទេសថៃ ក្រោមការត្រួតត្រារបស់ពួកអតីតខ្មែរក្រហម ។ ទីកន្លែងរស់នៅរបស់មេដឹកនាំថ្នាក់ខ្ពស់ម្នាក់ (គឺ តា ម៉ុក) គឺមិនច្បាស់លាស់ទេ នៅក្នុងពេលសរសេររបាយការណ៍នេះ ។ យោងតាមរបាយការណ៍ដែលគួរឱ្យជឿទុកចិត្តបាន ក្រុមហាក់ដូចជាយល់ថាគាត់កំពុងស្ថិតនៅក្នុងតំបន់មួយនៃព្រំដែនថៃ-កម្ពុជា ដែលគាត់អាចឆ្លងទៅមកសង្ខាងព្រំដែនបាននៅគ្រប់ពេលវេលា ។ អ្នកដែលអាចជាទិសដៅនៃការស៊ើបអង្កេតដ៏ទៃទៀត ក៏អាចកំពុងរស់នៅក្នុងប្រទេសផ្សេង ៗ ក្នុងនេះរួមមានជនកម្ពុជារស់នៅបរទេសជាច្រើននាក់ផង ដូចជាប្រទេសអូស្ត្រាលី បារាំង និងសហរដ្ឋអាមេរិកជាដើម ។

## គ- លទ្ធភាពនៃការចាប់ខ្លួន និងការឃុំខ្លួន ជនជាប់សង្ស័យ

១១៣- ក្រុមបានលើកឡើងអំពីបញ្ហានៃការចាប់ខ្លួន និងការឃុំខ្លួន ជនជាប់សង្ស័យ នៅក្នុងការប្រជុំជាច្រើនរបស់ខ្លួន ។ លទ្ធភាពនៃការធ្វើសកម្មភាពនេះ ចោទឡើងនូវបញ្ហាជាមូលដ្ឋាន ២: លទ្ធភាពដែលរដ្ឋាភិបាលមានពាក់ព័ន្ធនានាធ្វើការចាប់ខ្លួននេះ និងបំណងរបស់ពួកគេថានឹងធ្វើយ៉ាងដូច្នេះ ។ ជាការពិតហើយ កត្តាទាំង ២ នេះ មិនមែនស្ថិតនៅនឹងថ្កល់ ឬប្រែប្រួលទៅតាមតែចិត្តវានោះទេ ប៉ុន្តែវាអាចផ្លាស់ប្តូរទៅបានអាស្រ័យទៅលើលក្ខណៈនយោបាយ ការពាក់ព័ន្ធនឹងជំនួយមកពីខាងក្រៅ និងកត្តាផ្សេងទៀត ។ ការវាយតម្លៃ គឺធ្វើឡើងដោយឈរលើស្ថានការណ៍ដែលអាចកំណត់បាននៅក្នុងពេលបេសកកម្មរបស់យើងខ្ញុំ ។

១១៤- មិនថាជាតុលាការប្រភេទណាក៏ដោយ មុននឹងចុងចោទត្រូវបង្ហាញខ្លួន ការទទួលខុសត្រូវទី ១ ក្នុងការចាប់ខ្លួន និងការឃុំខ្លួនជនជាប់សង្ស័យ គឺស្ថិតនៅលើរដ្ឋដែលពួកគេកំពុងរស់នៅ ។ នេះមានន័យថាចំពោះចុងចោទភាគច្រើនលើសលប់ ការចាប់ខ្លួនពួកគេ គឺជាការទទួលខុសត្រូវទី ១ របស់រដ្ឋាភិបាលកម្ពុជា ។ រីឯលទ្ធភាពរបស់រដ្ឋាភិបាល ក្នុងការចាប់ខ្លួន និងឃុំខ្លួនជនជាប់សង្ស័យនោះ ក្រុមបានកត់សំគាល់ឃើញថាទីកន្លែងនៃជនជាប់សង្ស័យភាគច្រើនត្រូវបានដឹងហើយ ហើយពួកគេមិនត្រូវបានការពារពីការចាប់ខ្លួនទេ ។ ជាក់ស្តែង មេដឹកនាំ ៣ នាក់ នៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានទទួលស្វាគមន៍ដោយរដ្ឋាភិបាលនៅក្នុងទីក្រុងភ្នំពេញ កាលពីខែធ្នូ ឆ្នាំ ១៩៩៨ កន្លងទៅនេះ ។ នៅក្នុងពេលជាមួយគ្នានេះ យើងបានកត់សំគាល់ឃើញអំពីអសមត្ថភាពរបស់នគរបាលកម្ពុជា ក្នុងការស្វែងរក និងចាប់ខ្លួនមនុស្សជាច្រើននាក់ដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម និងការរំលោភផ្សេង ៗ កាលពីពេលថ្មី ៗ កន្លងទៅនេះ ។ លើសពីនេះទៅទៀត ចំពោះបុគ្គលខ្លះ ចាំបាច់ត្រូវមានសហប្រតិបត្តិការរបស់ប្រទេសថៃ ដើម្បីចាប់ខ្លួនពួកគេ ។

១១៥- ចំពោះបំណងរបស់កម្ពុជា ក្នុងការចាប់ខ្លួន និងឃុំខ្លួនជនជាប់សង្ស័យនោះ ក្រុមកត់សំគាល់ឃើញថាទោះបីជា ២០ ឆ្នាំបានកន្លងផុតទៅហើយចាប់តាំងពីពួកខ្មែរក្រហមត្រូវបានបណ្តេញចេញនោះ ពុំទាន់មានមន្ត្រីខ្មែរក្រហមណាម្នាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនខ្លួនទៅកាន់តុលាការកម្ពុជាណាមួយនៅឡើយទេ ដើម្បីឱ្យ ទៅឆ្លើយអំពីអំពើឃោរឃៅដែលបានប្រព្រឹត្តឡើងក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែក្នុងការ ជួបប្រជុំរបស់យើងខ្ញុំជាមួយនាយករដ្ឋមន្ត្រីទី ២ នាពេលនោះ និងបច្ចុប្បន្ននាយករដ្ឋមន្ត្រី ហ៊ុន សែន លោក បានប្រាប់យើងខ្ញុំថា រដ្ឋាភិបាលនឹងចាប់ខ្លួនមនុស្សណាដែលត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញាឯករាជ្យ

របស់តុលាការដែលកាត់ទោសពួកមន្ត្រីខ្មែរក្រហម ។ តាមយោបល់របស់លោក កិច្ចដំណើរការនេះអាចជាប់ពាក់ព័ន្ធនឹងដំណាក់កាលមួយចំនួន ដែលអាចនឹងអនុញ្ញាតឱ្យមានការចុះចូលដោយស្មគ្រចិត្តរបស់បុគ្គល ប៉ុន្តែបើសិនជាដំណាក់កាលនេះត្រូវបរាជ័យ រដ្ឋាភិបាលនឹងធ្វើការចាប់ខ្លួនពួកគេ ។ ក្រុមសូមស្វាគមន៍ចំពោះការចូលជាប់ពាក់ព័ន្ធដល់ការគាំទ្រចំពោះការកាត់ទោសមេដឹកនាំខ្មែរក្រហម ជាផ្លូវការ និងពីសំណាក់ថ្នាក់កំពូលនេះ ដោយសារថាការគាំទ្រនេះមានសារសំខាន់ណាស់ សំរាប់ជោគជ័យនៃការកាត់ទោសនេះ ។

១១៦- ទាក់ទិនទៅនឹងការចាប់ខ្លួន និងឃុំខ្លួនមនុស្សដែលកំពុងស្ថិតនៅក្នុងប្រទេសដទៃ លទ្ធភាពដែលថាជនសង្ស័យថាជាខ្មែរក្រហមអាច នាពេលសព្វថ្ងៃ ឬនាពេលអនាគត ស្ថិតនៅផ្នែកខាងថៃនៃព្រំដែនកម្ពុជា លើកឡើងជាបញ្ហាអំពីលទ្ធភាព និងគោលបំណងរបស់រដ្ឋាភិបាលថៃ ក្នុងការចាប់ខ្លួនមនុស្សនោះ ។ ឈរនៅលើការប្រជុំរបស់យើងជាមួយមន្ត្រីថៃ និងអ្នកដទៃទៀត ក្រុមមានជំនឿថារដ្ឋាភិបាលថៃអាចនឹងចាប់មនុស្សដែលនៅតាមព្រំដែនផ្នែកខាងថៃ ។ ចំពោះបំណងរបស់រដ្ឋាភិបាលថៃដែលថានឹងធ្វើយ៉ាងដូច្នេះនោះ ក្រុមត្រូវបានប្រាប់ឱ្យដឹងដោយអនុរដ្ឋមន្ត្រីក្រសួងការបរទេសថៃ សុឃុំផាន់ ប៉ារីបាត្រា ថាវាមិនមែនជានយោបាយរបស់រដ្ឋាភិបាលទេ ដែលអនុញ្ញាតឱ្យមនុស្សបែបនេះ ហើយថាបើសិនជារដ្ឋាភិបាលកម្ពុជាសុំឱ្យមានការកាត់ទោសមនុស្សបែបនេះ និងថាពួកគេបានស្ថិតនៅក្នុងទឹកដីយ៉ាងច្បាស់នោះ រដ្ឋាភិបាលនឹងចាត់វិធានការដ៏ចាំបាច់ស្របតាមច្បាប់ប្រទេសថៃ បញ្ជូនពួកគេទៅកាន់តុលាការដ៏សមស្រប ។ (សូមមើលការពិភាក្សា ក្នុងផ្នែកទី VII.D ខាងក្រោមនេះ ទាក់ទិនទៅនឹងបត្យប័ន និងការចុះចូល) ។ ក្រុមក៏ត្រូវបានឱ្យដឹងផងដែរថាក្នុងយថាហេតុដែលរដ្ឋាភិបាលកម្ពុជាប៉ុនប៉ងចាប់មនុស្សបែបនេះ នោះរដ្ឋាភិបាលថៃនឹងទប់ស្កាត់មិនឱ្យពួកគេទៅលបលាក់ខ្លួននៅក្នុងដីថៃបានទេ ។ ក្រុមសូមស្វាគមន៍ចំពោះសេចក្តីថ្លែងការណ៍ទាំងនេះ ។

១១៧- ក្រុមអ្នកជំនាញការ មិនបានធ្វើការស៊ើបអង្កេតនូវភាពលំអិតណាមួយស្តីពីលទ្ធភាពនៃការចាប់ខ្លួន និងឃុំខ្លួនជនសង្ស័យដែលស្ថិតនៅក្នុងប្រទេសដទៃទេ ។ ក៏ប៉ុន្តែ គឺជាទស្សនៈរបស់ក្រុមដែលថាប្រទេសដែលមានលទ្ធភាពច្រើនថាមានមនុស្សប្រភេទនេះនៅលើទឹកដីរបស់ខ្លួនមុខជានឹងចាប់ពួកគេ ហើយក្រុមគិតថាប្រទេសទាំងនេះនឹងពេញចិត្តនឹងធ្វើការនេះ បើសិនជាតុលាការដែលមានសមត្ថភាពមួយស្នើសុំនូវកិច្ចសហការបែបនេះនោះ ។

១១៨- ក្រុមសូមគូសបញ្ជាក់បន្ថែមអំពីការយល់ដឹងរបស់ខ្លួនថា ជោគជ័យនៃការកាត់ទោសណាមួយ គឺវាអាស្រ័យទៅលើសុច្ឆន្ទៈរបស់ប្រទេសនានា និងជាពិសេសប្រទេសកម្ពុជា ក្នុងការចាប់ខ្លួនជនសង្ស័យដែលមិនសុខចិត្តសុំចុះចូលនោះ ។ វត្តមាននៃអ្នកជាប់ចោទខ្លះ និងអវត្តមាននៃអ្នកដទៃទៀត នៅក្នុងតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី គឺជាភស្តុតាងយ៉ាងច្បាស់នៃបញ្ហានេះ ។ ក្នុងករណីនៃប្រទេសកម្ពុជា វាហាក់ដូចជាមិនអាចទៅរួចទេ ដែលថាកម្លាំងអន្តរជាតិនឹងធ្វើកិច្ចការនៃការចាប់ខ្លួនជនសង្ស័យនេះ ។ ដូច្នេះការទទួលខុសត្រូវក្នុងបញ្ហានេះ នឹងធ្លាក់ទៅលើរដ្ឋនានា ចាត់វិធានការដោយឡែក ឬដោយរួមគ្នា ដើម្បីចាត់ឱ្យមានឡើងនូវកិច្ចដំណើរការនេះ ។

## ឃ- លទ្ធភាពនៃការធ្វើបត្យាប័ន ការចុះចូលនៃជនសង្ស័យ

១១៩- បត្យាប័ន ឬការចុះចូល នៃមនុស្សជាប់សង្ស័យ គឺទាក់ទងទៅលើការពិចារណាថាតើជនសង្ស័យនោះស្ថិតនៅក្នុងប្រទេសដែលមិនមែនជាប្រទេសទទួលខុសត្រូវក្នុងការកាត់ទោសពួកគេឬយ៉ាងណា ។ ដូច្នេះ ការនេះមានសារសំខាន់ណាស់ដែលថា តើប្រទេសកម្ពុជានឹងធ្វើការកាត់ទោសមនុស្សដែលស្ថិតនៅក្រៅប្រទេស ឬក៏តុលាការអន្តរជាតិមួយត្រូវធ្វើការកាត់ទោសមនុស្សទាំងនោះ ។ ក្នុងក្របខ័ណ្ឌនេះ ហត្ថលេខីនៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ ត្រូវទទួលកាតព្វកិច្ចដើម្បី "ជួយជំរុញ និងលើកទឹកចិត្តឱ្យមានការគោរព និងអនុវត្តន៏សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅក្នុងប្រទេសកម្ពុជា ដូចដែលមានចែងនៅក្នុងឯកសារអន្តរជាតិមានពាក់ព័ន្ធនានា ជាពិសេសដើម្បីទប់ស្កាត់ការកើតមានឡើងវិញនូវការរំលោភសិទ្ធិមនុស្ស[៦១] ។ នេះជាការបញ្ជាក់ដោយពុំមានការសង្ស័យអ្វីទេនូវករណីនៃកិច្ចគាំទ្រការខិតខំទាំងឡាយ ដើម្បីនាំខ្លួនជនល្មើស ខ្មែរក្រហមទៅកាន់តុលាការ ។

១២០- ក្នុងករណីនៃការកាត់ទោសដោយតុលាការកម្ពុជា ក្រុមបានដឹងថាពុំមានសន្ធិសញ្ញាបត្យាប័នរវាងប្រទេសកម្ពុជា និងប្រទេសណាមួយផ្សេងទៀតដែលមានធរមានភាពនាពេលបច្ចុប្បន្ននេះទេ ។ កម្ពុជា និង

[៦១] កិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងការមិនរំលោភលើទឹកដី អព្យាក្រិតភាព និងឯកភាពជាតិនៃកម្ពុជា ចុះថ្ងៃទី ២៣ ខែតុលា ឆ្នាំ ១៩៩១ មាត្រាទី ៣ (២) (ខ) ។

ថៃ បានសំរេចនូវសន្ធិសញ្ញាមួយបែបនេះកាលពីឆ្នាំ ១៩៩៨ តែនៅមិនបានឱ្យសច្ចាប័ននៅឡើយទេ[៦២] ។ បើសិនជាសន្ធិសញ្ញានេះបានចូលជាធរមានភាពហើយ ប្រទេសថៃត្រូវតែអនុវត្តវាតាមរយៈច្បាប់នៅក្នុងប្រទេស រួមមានលក្ខន្តិកៈបត្យាប័នឆ្នាំ ១៩២៩ របស់គេ ដែលមានចែងពីបែបបទផ្សេង ៗ ។ ក្នុងករណីពុំមាន សន្ធិសញ្ញាបត្យាប័ន ប្រទេសខ្លះ រួមទាំងប្រទេសថៃផង អាចនិរទេសខ្លួនមនុស្សសំរាប់ឱ្យមកកាត់ទោសនៅ តុលាការកម្ពុជា ស្របតាមលក្ខន្តិកៈអន្តោប្រវេសន៍ និងនិរទេសផ្សេង ៗ ដែលជារឿយ ៗ អនុគ្រោះឱ្យធ្វើ ការផ្ទេរមនុស្សបានលឿន[៦៣] ។ បើសិនជាជនជាប់ចោទត្រូវកាត់ទោសនៅក្នុងតុលាការអន្តរជាតិ សន្ធិសញ្ញាបត្យាប័នទ្វេភាគីមិនអាចអនុវត្តបានទេ តែមនុស្សទាំងនេះអាចត្រូវផ្ទេរបានតាមបទបញ្ញត្តិនិរទេសខ្លួន នៃច្បាប់អន្តោប្រវេសន៍ ឬតាមរយៈលក្ខន្តិកៈអនុវត្តជាពិសេសដើម្បីផ្តល់ជាមូលដ្ឋានច្បាប់មួយសំរាប់កិច្ចសហប្រតិបត្តិការបែបនេះ[៦៤] ។

១២១- ទាក់ទិននឹងបំណងរបស់រដ្ឋនានា ក្នុងការធ្វើបត្យាប័ន ឬការចុះចូលនៃជនជាប់ចោទ ក្រុមបានរំលឹកឡើងវិញនូវចំណុចដែលបានលើកឡើងនៅក្នុងផ្នែក VII.C ខាងលើ និងជាពិសេស គោលជំហរជាផ្លូវការរបស់រដ្ឋាភិបាលថៃ ដែលបានជំរាបជូនដល់ក្រុមដោយអនុរដ្ឋមន្ត្រីក្រសួងការបរទេស ។ ក្រុមសង្ឃឹមថាប្រទេសដ៏ទៃទៀតជាច្រើន ដែលអាចមានជនជាប់សង្ស័យនៅលើទឹកដីរបស់ខ្លួននោះ ក៏នឹងមានបំណងធ្វើបត្យាប័ន ឬបញ្ជូលពួកគេ ជូនដល់តុលាការតាមយុត្តាធិការត្រឹមត្រូវ ។

## VIII- ជំរើសនានា ក្នុងការនាំខ្លួនមនុស្សទៅកាន់តុលាការ

---

[៦២] សន្ធិសញ្ញា រវាងព្រះរាជាណាចក្រថៃឡង់ដ៏ និងព្រះរាជាណាចក្រកម្ពុជា ស្តីពីបត្យប័ន ថ្ងៃទី ៦ ខែឧសភា ឆ្នាំ ១៩៩៨ ។

[៦៣] សូមមើលច្បាប់អន្តោប្រវេសន៍ B,E. 2522(1979)ដែលបានធ្វើវិសោធនកម្មដោយច្បាប់អន្តោប្រវេសន៍ (No 2) B.E. 2523 (1980) ជំពូក VI

[៦៤] សូមមើល តុលាការអន្តរជាតិសំរាប់កាត់ទោសមនុស្សទទួលខុសត្រូវចំពោះបទរំលោភធ្ងន់ធ្ងរនានា ទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ដែលបានប្រព្រឹត្តឡើងនៅលើទឹកដីនៃប្រទេសអតីតយូហ្គោស្លាវី ចាប់តាំងពីឆ្នាំ ១៩៩១ មក សៀវភៅប្រចាំឆ្នាំ ១៩៩៦ ទំព័រ ២៣៣ (ឆ្នាំ ១៩៩៧) (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ Sales លេខ E. 97. III.P.1) អត្ថបទសំរាប់អនុវត្តន៍ ច្បាប់ដែលបានអនុម័តដោយរដ្ឋនានា សំរាប់សហប្រតិបត្តិការជាមួយតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី) ។

## ក- តុលាការមួយបង្កើតឡើងតាមច្បាប់កម្ពុជា

១២២- ជំរើសទី ១ ដែលក្រុមបានពិចារណានោះ គឺការកាត់ទោសពីបទព្រហ្មទ័ណ្ឌតាមច្បាប់កម្ពុជា ដោយតុលាការក្នុងស្រុក ក្រោមការឧបត្ថម្ភរបស់រដ្ឋាភិបាលកម្ពុជា ។ ក្នុងឋានៈជាភាគីមួយនៃអនុសញ្ញាស្តីពីការប្រល័យពូជសាសន៍ កម្ពុជាត្រូវមានកាតព្វកិច្ចផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ដែលបានកើតមានឡើងនៅលើទឹកដីរបស់ខ្លួន ។ នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ ១៩៩១ កម្ពុជាត្រូវទទួលរ៉ាប់រង "ចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីធានាថានយោបាយ និងការប្រព្រឹត្តពីអតីតកាល មិនត្រូវអនុគ្រោះឱ្យវិលត្រឡប់មកវិញជាដាច់ខាត" ដើម្បី "ធានាឱ្យមានការគោរព និងអនុវត្តតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា" និង "ប្រកាន់ខ្ជាប់នូវឯកសារសិទ្ធិមនុស្សអន្តរជាតិមានពាក់ព័ន្ធនានា[៦៥] ។

## ១- ក្របខ័ណ្ឌច្បាប់សំរាប់ធ្វើការកាត់ទោសនៅក្នុងស្រុក

១២៣- ប្រទេសកម្ពុជាមានប្រព័ន្ធតុលាការមួយហើយ តែមូលដ្ឋានច្បាប់នៃតុលាការនេះមានកន្លែងខ្លះមិនច្បាស់លាស់ ហើយកិច្ចដំណើរការរបស់វានៅមានភាពទន់ខ្សោយចំពោះវិស័យសំខាន់ ៧ ខ្លះ ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ចែងអំពីឯករាជភាពរបស់តុលាការ តាមរយៈតុលាការកំពូល និងតុលាការថ្នាក់ទាប[៦៦] ។ ព្រះមហាក្សត្រតែងតាំងចៅក្រម តាមការស្នើសុំរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលត្រូវបានបង្កើតឡើងដោយ រដ្ឋសភា នៅក្នុងឆ្នាំ ១៩៩៤[៦៧] តែតាំងពីពេលនោះមកទើបតែបានប្រជុំ ២ លើកប៉ុណ្ណោះ គឺនៅក្នុងឆ្នាំ ១៩៩៧ និង ១៩៩៨ ។ ទោះបីជារដ្ឋាភិបាលដែលបានកើតឡើងក្រោយឆ្នាំ ១៩៩៣ មិនបានអនុម័តនូវច្បាប់លំអិត ណាមួយស្តីពីការរៀបចំប្រព័ន្ធតុលាការក៏ដោយ ក៏ប្រព័ន្ធតុលាការបច្ចុប្បន្ននេះ មានសាលាកាត់ក្តី សាលា ឧទ្ធរមួយ និងតុលាការកំពូលមួយដែរ ។

---

[៦៥] កិច្ចព្រមព្រៀង ទាក់ទិននឹងអធិបតេយ្យភាព ឯករាជ្យភាព បូរណភាពដែនដី និងការមិនឈ្លានពានគ្នា អព្យាក្រិតភាព និងឯកភាពជាតិនៃកម្ពុជា មាត្រាទី ៣ (២) (ក) ។

[៦៦] រដ្ឋធម្មនុញ្ញកម្ពុជា (១៩៩៣) មាត្រាទី ១០៩ ។

[៦៧] ដូចខាងលើ មាត្រាទី ១១៥ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ១៩៩៤ ។

ចំពោះបញ្ហារចនាសម្ព័ន្ធរបស់តុលាការវិញ ការកាត់សេចក្តីនៅក្នុង ប្រទេសកម្ពុជា ត្រូវបានធ្វើឡើងនៅក្នុងតុលាការធម្មតាដែលមានសព្វថ្ងៃនេះប៉ុណ្ណោះ ឬតាមរយៈការបង្កើតដោយច្បាប់នូវតុលាការពិសេសមួយតាមច្បាប់នៃប្រទេសកម្ពុជា ។

១២៤- ចំពោះច្បាប់សំខាន់ ៗ ដែលត្រូវយកមកអនុវត្តន៏ដោយតុលាការបែបនេះ គោលការណ៏ ដែលថា ពុំមានបទល្មើសព្រហ្មទ័ណ្ឌទេ បើបទល្មើសមិនត្រូវបានប្រព្រឹត្តទេនោះ តម្រូវថា បទឧក្រិដ្ឋត្រូវវិនិច្ឆ័យតែទៅតាមច្បាប់ដែលមានធរមានភាពនៅក្នុងឆ្នាំ ១៩៧៥ ប៉ុណ្ណោះ ឧទាហរណ៏ ក្រមព្រហ្មទ័ណ្ឌឆ្នាំ ១៩៥៦ (សូមមើលផ្នែក V.B. ខាងលើ)។ ពុំមានគោលការណ៏នៃច្បាប់អន្តរជាតិ ឬច្បាប់ជាតិណាមួយទប់មិនឱ្យអនុវត្តន៏ក្រមឆ្នាំ ១៩៥៦ នៅក្នុងការកាត់សេចក្តីទេ ដោយមិនគិតដល់ច្បាប់ព្រហ្មទ័ណ្ឌដែលនៅជាធរមានភាព នៅក្នុងពេលកាត់សេចក្តីនោះទេ។ ដើម្បីធ្វើឱ្យការអនុវត្តន៏ច្បាប់មានភាពច្បាស់លាស់ រដ្ឋសភាអាចអនុម័តលក្ខន្តិកៈពិសេសមួយទទួលស្គាល់ការអនុវត្តន៏ច្បាប់បែបនេះ ចំពោះបទឧក្រិដ្ឋនៅក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ប្រហែលជាដោយមានជំនួយក្នុងការរៀបចំច្បាប់នេះពីសំណាក់អ្នកជំនាញការបរទេសផង ។បទបញ្ញត្តិណាដែលវិសមិតភាពជាមួយនឹងរដ្ឋធម្មនុញ្ញ ជាពិសេសទោសប្រហារជីវិតចំពោះបទឧក្រិដ្ឋខ្លះនោះ មិនត្រូវទុកឱ្យនៅមានជាធរមានភាពទេ[៦៨] ។ ទោះបីជាយ៉ាងណាក៏ដោយ ការខ្វះខាតនូវទម្លាប់របស់ចៅក្រមកម្ពុជាជាមួយនឹងច្បាប់ចាស់ ៗ អាចធ្វើឱ្យការប្រើប្រាស់វានៅក្នុងការកាត់សេចក្តីមានការលំបាកយ៉ាងខ្លាំង ។លក្ខន្តិកៈ ពិសេសនេះក៏អាចបង្កើតបទបញ្ញត្តិសំរាប់ចោទប្រកាន់ចុងចោទចំពោះឧក្រិដ្ឋអន្តរជាតិដែលបានទទួលស្គាល់រហូតមកដល់ឆ្នាំ ១៩៧៥ ផងដែរ ទោះបីជាបទឧក្រិដ្ឋបែបនេះមិនត្រូវបានបញ្ចូលទៅក្នុងក្រមព្រហ្មទ័ណ្ឌក៏ដោយ ។

១២៥- នីតិវិធីព្រហ្មទ័ណ្ឌកម្ពុជាសព្វថ្ងៃ កំពុងស្ថិតនៅក្នុងដំណើរប្រែប្រួល ។ ការនេះត្រូវបានគ្រប់គ្រងជាទ្រឹស្តី ដោយរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ព្រមទាំងច្បាប់នានាមុន និងក្រោយមួយចំនួន ។ ទី ១ រដ្ឋធម្មនុញ្ញ ចែងថាការចាប់ខ្លួន ការចេញដីកាបណ្តោះអាសន្ន ឬការឃុំខ្លួនមនុស្សណាម្នាក់ ត្រូវធ្វើឡើងស្របទៅតាមច្បាប់ ហើយហាមឃាត់ការបង្ខិតបង្ខំ ប្រព្រឹត្តកម្មយង់ឃ្នងទៅលើខ្លួនប្រាណ ក៏ដូចជាសេចក្តីសារភាពបានមកដោយ

---

[៦៨] សូមមើលរដ្ឋធម្មនុញ្ញកម្ពុជា មាត្រាទី ៣២ ។

ការប្រើកម្លាំងដែរ ។ វាក៏មានបញ្ចូលផងដែរនូវសិទ្ធិទទួលបានទីប្រឹក្សា និងការសន្មត់ថាគ្មានទោសពៃរ៍ ដោយបន្ថែមថា "ការសង្ស័យណាមួយត្រូវដោះស្រាយឱ្យខាងចុងចោទមានប្រៀប"[៦៩] ។ ទី ២ ក្រិត្យស្តីពី ច្បាប់ និងនីតិវិធីព្រហ្មទ័ណ្ឌ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ឆ្នាំ ១៩៩២ ដែលបានព្រាងឡើងដោយមន្ត្រី អង្គការសហប្រជាជាតិ នៅក្នុងរយៈពេលអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា បាន ចែងអំពីក្របខ័ណ្ឌមូលដ្ឋាននៃតុលាការព្រហ្មទ័ណ្ឌ មាន ៧៥ មាត្រា ។ ច្បាប់នេះស្ថិតនៅជាធរមានភាពនៅ ឡើយ ស្របតាមមាត្រាទី ១៣៩ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣[៧០] ។ តាមច្បាប់ ចៅក្រម "ត្រូវធ្វើការសំរេច ដោយមិនលំអៀងពេញទី ដោយឈរលើមូលដ្ឋាននៃព្រឹត្តិការណ៍ជាក់ស្តែងដែលបានដាក់ជូនពួកគេ និង ដោយ ស្របទៅតាមច្បាប់ បដិសេធការគាបសង្កត់ ការគំរាមកំហែង ឬការបំភិតបំភ័យ ដោយផ្ទាល់ ឬដោយ ប្រយោល ពីភាគីណាមួយក្នុងជម្លោះ ឬអ្នកណាដ៏ទៃទៀត"[៧១] ។ វាមានប្រព័ន្ធសាមញ្ញមួយនៃនីតិវិធីព្រហ្ម ទ័ណ្ឌ ដែលមានសិទ្ធិជាមូលដ្ឋានសំរាប់ជនជាប់ចោទ[៧២] ។ ទី ៣ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័តច្បាប់មួយស្តី ពីនីតិវិធីព្រហ្មទ័ណ្ឌ កាលពីថ្ងៃទី ២៨ ខែមករា ឆ្នាំ ១៩៩៣ ដែលក្រុមប្រឹក្សារដ្ឋ បានប្រកាសដាក់ឱ្យប្រើនៅ ថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៩៣ ។ ច្បាប់នេះ ដែលកំពុងស្ថិតនៅជាធរមានបាពនៅឡើយ ស្របតាមមាត្រាទី ១៣៩ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មានចែងអំពីទាំងការចោទប្រកាន់ជាសាធារណៈ ទាំងជាឯកជន[៧៣] ។ តុលាការនៅក្នុងប្រទេសកម្ពុជាបានផ្អែកលើច្បាប់នេះដើម្បីធ្វើបែបបទរបស់គេ ដោយមិនគិតគូរអំពីការការ ពារដ៏ខ្លាំងដែលត្រូវបានផ្តល់ឱ្យចុងចោទ នៅក្នុងច្បាប់ឆ្នាំ ១៩៩២ ទេ ។ ក្រៅពីឧត្តមភាពរបស់រដ្ឋធម្មនុញ្ញ - យ៉ាងហោចណាស់ក៏ជាបញ្ហាគោលការណ៍ដែរនោះ- ការទាក់ទងរវាងច្បាប់ផ្សេង ៗ នៃនីតិវិធីព្រហ្មទ័ណ្ឌ នៅតែមានភាពស្រពិចស្រពិលនៅឡើយ ។

---

[៦៩] ដូចគ្នា មាត្រាទី ៣៨ ។

[៧០] "ឯកសារច្បាប់ និងបទដ្ឋាន នៅកម្ពុជាដែលកាពារទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងកម្មសិទ្ធិឯកជនស្របច្បាប់ និងដោយ ស្របទៅនឹងផលប្រយោជន៍ជាតិ ត្រូវស្ថិតនៅជាបន្តរហូតដល់ត្រូវរលាយ ឬលប់ចោលដោយអត្ថបទថ្មី លើកលែងតែបទបញ្ញត្តិទាំង ឡាយណា ដែលផ្ទុយនឹងស្មារតី នៃរដ្ឋធម្មនុញ្ញនេះ" ។

[៧១] បទបញ្ញត្តិទាក់ទងទៅនឹងតុលាការ និងច្បាប់ និងនីតិវិធីព្រហ្មទ័ណ្ឌអនុវត្តនៅក្នុងប្រទេសកម្ពុជា នៅក្នុងដំណាក់កាលឆ្លងកាត់ សេចក្តីសំរេចចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២ មាត្រាទី ១ ។

[៧២] ដូចខាងលើ មាត្រាទី ១០-៣០ ។

[៧៣] ច្បាប់ស្តីពីនីតិវិធីព្រហ្មទ័ណ្ឌ មាត្រាទី ៧៦ ៩៧-៩៨ ១៦១ ។

## ២- ការប្រព្រឹត្តទៅនៃតុលាការកម្ពុជា

១២៦- ដើម្បីធ្វើការវាយតម្លៃចំពោះជំរើសនៃការកាត់ទោសនៅក្នុងតុលាការកម្ពុជា ក្រុមបានបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាទៅលើស្ថានភាពរបស់តុលាការកម្ពុជា ។ ក្រុមបានសាកសួរយោបល់មន្ត្រីរដ្ឋាភិបាលកម្ពុជាដែលទទួលខុសត្រូវខាងការគ្រប់គ្រងប្រព័ន្ធយុត្តិធម (រួមមានប្រធានចៅក្រមតុលាការកំពូល) អង្គការ ក្រៅរដ្ឋាភិបាលអន្តរជាតិ និងជាតិ និងរបាយការណ៍របស់លោកតំណាងពិសេសរបស់លោកអគ្គលេខាធិការ ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ។ តាមមតិរបស់ក្រុម តុលាការកម្ពុជាបច្ចុប្បន្នខ្វះលក្ខណៈ ៣ ជាគន្លឹះ សំរាប់តុលាការមួយត្រឹមត្រូវ និងមានប្រសិទ្ធភាព គឺក្របខ័ណ្ឌចៅក្រម មេធាវីនិងអ្នកស៊ើបអង្កេតដែលមាន ការហ្វឹកហ្វឺនត្រឹមត្រូវ រចនាសម្ព័ន្ធសមស្រប និងវប្បធម៌នៃការគោរពតាមច្បាប់ ។

១២៧- ទី ១ កេរ្តិ៍ដំណែលមួយក្នុងចំណោមកេរ្តិ៍ដំណែល នៃសង្គ្រាមស៊ីវិលរាប់ទសវត្សមកហើយនៅកម្ពុជា គឺ ការខ្វះនូវវិជ្ជាជីវៈខាងច្បាប់ប្រកបដោយគុណភាពមួយនៅក្នុងប្រទេសកម្ពុជា ។ មេធាវី និង អ្នកសិក្សាស្រាវ ជ្រាវ បាននាំគ្នារត់ចេញពីប្រទេសក្នុងទសវត្សឆ្នាំ ១៩៦០ និង ១៩៧០ ឬត្រូវបានសម្លាប់ដោយពួកខ្មែរក្រហម អ្នកដែលបានចូលបំពេញវិជ្ជាជីវៈនេះនៅក្នុងពេលសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា បានទទួលការហ្វឹកហ្វឺនតាមប្រព័ន្ធមួយដែលតុលាការគ្មានភាពឯករាជ្យ ។ ការខ្វះនូវបទពិសោធន៍ ក្នុងការស្វែងរកនូវភស្តុតាងជារឿយ ៗ តែងតែនាំឱ្យតុលាការប្រើប្រាស់របាយការណ៍ដ៏អន់ថយរបស់នគរបាល ធ្វើជាមូលដ្ឋានតែមួយគត់សំរាប់ធ្វើការសំរេច ។ ចំនួនចៅក្រមមានគុណភាព មានតិចណាស់ ប្រហែលជាមានចំនួនមិនគ្រប់សំរាប់បង្កើតជាក្រុមមួយសំរាប់ធ្វើការកាត់ទោសខ្មែរក្រហមផងទេមើលទៅ ។ ប៉ុន្តែទំហំដ៏ធំធេងនៃអំពើឃោរឃៅរបស់ពួកខ្មែរក្រហម និងបច្ច័យរបស់វាទៅលើគ្រួសារនិមួយៗ នាំឱ្យយល់ថាវានឹងមានការលំបាកណាស់ដើម្បីស្វែងរកឱ្យបាននូវចៅក្រមណាម្នាក់ដែលមិនលំអៀង និងមិនមានការវិនិច្ឆ័យទុកជាមុនហើយទេនោះ។

១២៨- ទី ២ រចនាសម្ព័ន្ធនៃប្រព័ន្ធច្បាប់កម្ពុជា គឺទន់ខ្សោយណាស់ ទោះបីជាសំរាប់ពិភពកំពុងអភិវឌ្ឍន៍ក៏ដោយ ។ តុលាការមានការខ្វះខាតសៀវភៅ អង្គលីលេខ និងអ្វី ៗ ដែលជាការចាំបាច់ដ៏ទៃទៀត

ជាពិសេស នៅតាមខេត្តនានា ។ អាគាររខេករខាក ។ ពន្ធធានាគារ ស្ថិតក្នុងសភាពគួរឱ្យអណោចអធមជាពន់ពេក ។

១២៩- ទី ៣ និងដែលជាកង្វល់ធំបំផុតចំពោះការជំរើសយកការកាត់ទោសនៅក្នុងស្រុកនោះ គឺការដែលប្រទេសកម្ពុជាខ្វះខាតនូវវប្បធម៌នៃការគោរពចំពោះប្រព័ន្ធតុលាការព្រហ្មទ័ណ្ឌដែលមិនលំអៀង ។ តុលាការព្រហ្មទ័ណ្ឌទទួលតែបានតែមួយភាគនៃ ១ ភាគរយនៃថវិកាជាតិប៉ុណ្ណោះ ហើយចៅក្រមទទួលប្រាក់ខែតែបន្តិចបន្តួចប្រមាណ ២០ ដុល្លារ ក្នុងមួយខែប៉ុណ្ណោះ។ ជាបច្ច័យ ទោះបីជាមានមនុស្សមានលក្ខណៈខ្លះ ៗ របស់តុលាការក៏ដោយ ក៏វាមានការជឿជាក់ថាចៅក្រមនោះអាចត្រូវទិញបានដោយចុងចោទ ឬដើមចោទជាមិនខាន ។ ចៅក្រមភាគច្រើនយ៉ាងទូលំទូលាយថាមានការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយគណបក្សប្រជាជនកម្ពុជា ។ បុគ្គលនានាដែលមានអំណាចនៅក្នុងរដ្ឋាភិបាល ដូចជាអ្នកនយោបាយសំខាន់ ៗ ផ្នែកសន្តិសុខ និងក្រសួងយុត្តិធម៌ ត្រូវបានគេដឹងយ៉ាងទូលំទូលាយថាបានប្រើឥទ្ធិពលទៅលើសេចក្តីសំរេច របស់ចៅក្រមស៊ើបអង្កេត និងការកាត់ទោសនៅក្នុងតុលាការ ។ ទាំងនេះរួមមាន ការគំរាមកំហែង និងការវាយប្រហារទៅលើរូបរាងកាយរបស់ចៅក្រម ឬគ្រាន់តែមានការដឹងខ្លួនដោយខ្លួនឯងក្នុងចំណោមចៅក្រមនានាថាស្ថានភាព ហើយជារឿយ ៗ ការគិតគូរទៅលើជីវិតអានាគតរបស់ពួកគេ គឺស្ថិតនៅលើការយល់ស្របរបស់អ្នកនយោបាយ ។ ម្យ៉ាងទៀតមេធាវីនៃអ្នកចុងចោទពីបទឧក្រិដ្ឋ ទោះបីជាមានការហ្វឹកហ្វឺនបានត្រឹមត្រូវហើយក៏ដោយ ក៏ត្រូវបានធ្វើឱ្យរាំងស្ទះការងាររបស់ពួកគេដែរ ។ ចៅក្រមនានាតែងបាននិយាយថា ពួកគេមានការយកចិត្តទុកដាក់ទល្ងឹករខាងផ្លូវច្បាប់យ៉ាងតិចតួចបំផុត ទោះបីជាចំពោះករណីទូទៅក៏ដោយ ។ តុលាការ និងនគរបាល ត្រូវហាមមិនឱ្យមានការទាក់ទងជាមួយកូនក្តីរបស់គេ ទោះបីជានៅក្នុងសវនាការក៏ដោយ ។ អ្នកការពារក្តីក៏អាចប្រឈមមុខនឹងការគំរាមកំហែង ពីសំណាក់គ្រួសារ និងមិត្តភក្តិរបស់ជនរងគ្រោះផងដែរ ។ ប្រព្រឹត្តកម្មចំពោះពួកអ្នកជាប់ឃុំរង់ចាំការកាត់សេចក្តី ឬអ្នកទោសនៅក្នុងគុក នៅតែស្ថិតនៅឆ្ងាយក្រោមបទដ្ឋានអន្តរជាតិ ។ ជាសរុបមក ប្រព័ន្ធតុលាការកម្ពុជាស្ថិតនៅឆ្ងាយពីបទដ្ឋានអន្តរជាតិនៃយុត្តិធម៌ផ្នែកព្រហ្មទ័ណ្ឌដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និងនៅក្នុងឯកសារដទៃទៀត[៧៤] ។

---

[៧៤] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រាទី ៩ ១៤ ។ បទដ្ឋានអប្បបរមាស្តីពីប្រព្រឹត្តកម្មចំពោះអ្នកទោស អនុម័តសន្និបាតទី ១ របស់អង្គការសហប្រជាជាតិ ស្តីពីការទប់ស្កាត់ ឧក្រិដ្ឋកម្ម

១៣០- បញ្ហាទាក់ទិនមួយទៀត គឺបញ្ហាសន្តិសុខ បើសិនជាការកាត់ទោសប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា។ ការកាត់ទោសសមាជិកកម្លាំងសន្តិសុខ ធ្លាប់ត្រូវបានរំខាន ឬរារាំង ដោយអង្គភាពរបស់រដ្ឋាភិបាល ដោយពុំមានទទួលទោសពៃរ៍អ្វីឡើយ ។ ការកាត់ទោសពួកខ្មែរក្រហម ប្រហែលជាអាចមានមនុស្សមកមើលច្រើន ជាការទាមទារឱ្យមានការប្រុងប្រយ័ត្ន និងការមើលការខុសត្រូវប្រកបដោយវិជ្ជាជីវៈនូវហ្វូងមហាជន ។ មានលទ្ធភាពថាការកាត់ទោស អាចធ្វើឱ្យឆេះឆួលឡើងនូវកំហឹងចាស់ក្នុងចំណោមអ្នកឈរមើល ។ ចុងចោទ ព្រះរាជអាជ្ញា ចៅក្រម និងសាក្សី អាចក្លាយទៅជាទិសដៅនៃការវាយប្រហារ ហើយទាមទារឱ្យមានការការពារឱ្យបានគ្រប់គ្រាន់ ។ ចំពោះករណីនៃកសិណសាក្សីវិញអាចត្រូវបានទទួលការការពាររយៈពេលយូរទៀតក្រោយការកាត់ទោស ។ ការរត់ចេញពីគុកគឺជាបញ្ហាទូទៅមួយ ។ ដូច្នេះ មិនច្បាស់ជាថាកងនគរបាលខ្មែរបានទទួលការហ្វឹកហ្វឺនត្រឹមត្រូវ ដើម្បីទប់ទល់នឹងសភាពការណ៍ប្រភេទនេះបាននោះទេ ។

## ៣- អនុសាសន៍

១៣១- ដើម្បីធ្វើការកាត់ទោសនៅក្នុងស្រុក ឱ្យបានត្រឹមត្រូវទៅតាមបទដ្ឋានអន្តរជាតិ ប្រទេសកម្ពុជាតែឯង ឬដោយមានការគាំទ្រពីបរទេសផង ត្រូវចាត់ឱ្យមានឡើងនូវជំហានសំខាន់ ៧ មួយចំនួន រួមមាន (ក) ការបំភ្លឺឱ្យបានច្បាស់ នូវច្បាប់ និងនីតិវិធី ដែលត្រូវយកមកអនុវត្តចំពោះការកាត់ទោសបែបនេះ ឧទាហរណ៍ តាមរយៈច្បាប់ពិសេស (ខ) ការផ្តល់នូវមេធាវី និងអ្នកស៊ើបអង្កេត ដើម្បីធ្វើការចោទប្រកាន់ (គ) ការផ្តល់នូវទីកន្លែងសំរាប់ធ្វើការមួយចំនួន រួមមានបន្ទប់សវនាការ ព័ន្ធនាគារ និងការិយាល័យស៊ើបអង្កេត និងព្រះរាជ អាជ្ញា និង (ឃ) ធានាឱ្យមានចៅក្រមមួយក្រុមដែលត្រឹមត្រូវ និងមិនលំអៀង ដោយពុំមានការត្រួតត្រា ឬ ការគាបសង្កត់ខាងនយោបាយ ។

---

និងប្រព្រឹត្តកម្មចំពោះជនល្មើស ថ្ងៃទី ៣០ ខែសីហា ឆ្នាំ ១៩៥៥ (ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ លេខ ៨៨ XIV.1) ។

១៣២- ក្រុមអ្នកជំនាញការយល់ឃើញច្បាស់ណាស់អំពីចំណុចខ្លាំង នៃការរៀបចំការកាត់ទោសតាមច្បាប់កម្ពុជា ។ ច្បាស់ជាងនេះទៅទៀតនោះ គឺវាដាក់ការទទួលខុសត្រូវនៅលើរដ្ឋដែលមានការពាក់ព័ន្ធផ្ទាល់បំផុត និងជៀសវាងនូវភាពស្មុគ្រស្មាញខាងនយោបាយ ថវិការ និងរដ្ឋបាលជាប់ជាមួយនឹងការបង្កើតឡើងនូវតុលាការអន្តរជាតិណាមួយនោះ ។ ក៏ប៉ុន្តែ ចំពោះហេតុផលដូចខាងក្រោមនេះ ក្រុមយល់ឃើញថា ការកាត់ទោសនៅក្នុងស្រុក ដែលរៀបចំឡើងតាមច្បាប់កម្ពុជានោះ មិនអាចធ្វើទៅកើតទេ ហើយមិនអាចទទួលបានជំនួយជាហិរញ្ញវត្ថុពីអង្គការសហប្រជាជាតទេ ។

១៣៣- ទី ១ តាមអ្វីដែលយើងខ្ញុំបានឮ ក្នុងពេលបេសកកម្មរបស់យើងខ្ញុំទៅកាន់ប្រទេសកម្ពុជា ដែលមានខ្លះបានមកពីប្រភពជាផ្លូវការថ្នាក់ខ្ពស់ គឺក៏រិតនៃអំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ និងការរណបជាប្រចាំនៃសេចក្តីសំរេចរបស់តុលាការទៅលើឥទ្ធិពលនយោបាយ ធ្វើឱ្យព្រះរាជអាជ្ញា អ្នកស៊ើបអង្កេត និងចៅក្រមធ្វើអ្វីស្ទើរតែមិនកើតដើម្បីគេចឱ្យផុតពីការគាបសង្កត់បែបនេះនៅពេលធ្វើការកាត់សេចក្តីនូវការចោទប្រកាន់ខាងនយោបាយដ៏ខ្លាំងក្លាដែលមិនអាចជៀសផុតបាននោះ ។ សេចក្តីសំរេចអំពីថាតើអ្នកណាដែលត្រូវដាក់ឱ្យស្ថិតនៅក្រោមការស៊ើបអង្កេត និងថាតើអ្នកណាត្រូវទទួលការចោទប្រកាន់ អ្នកណាត្រូវផ្តន្ទាទោស ឬអ្នកណាត្រូវឱ្យរួចខ្លួន ត្រូវសំរេចដោយឈរភស្តុតាងដែលទទួលបាន មិនមែនឱ្យប្រៀបទៅលើក្រុមនយោបាយណាមួយនោះទេ ។ ភាពមិនលំអៀង គឺជាការចាំបាច់ ដើម្បីធានាភាពត្រឹមត្រូវនៃនីតិវិធី និងធានានូវភាពត្រឹមត្រូវជាមូលដ្ឋានដល់អ្នកជាប់ចោទ ។

១៣៤- ទី ២ ការកាត់ទោសពួកមេដឹកនាំខ្មែរក្រហម ត្រូវធ្វើឡើងឱ្យសមស្របទៅតាមសុភាសិតដែលថា មិនត្រឹមតែត្រូវធ្វើឱ្យមានយុត្តិធម៌តែប៉ុណ្ណោះទេ តែត្រូវឱ្យសាធារណជនមើលឃើញថាវាមានយុត្តិធម៌ផងដែរ ។ ដើម្បីបំរើទិសដៅនៃយុត្តិធម៌ផ្នែកព្រហ្មទ័ណ្ឌ ដូចដែលបានរៀបរាប់នៅក្នុងសេចក្តីផ្តើមនៃរបាយការណ៍របស់យើងខ្ញុំនេះ ប្រជាពលរដ្ឋកម្ពុជាត្រូវមានការទុកចិត្តចំពោះភាពត្រឹមត្រូវនៃនីតិវិធី ។ បើមិនដូច្នោះទេ ពួកគេនឹងចាត់ទុកការនេះថាវាគ្រាន់តែជាសកម្មភាពនៃបក្សពួកនយោបាយមួយតែប៉ុណ្ណោះ។ ម្យ៉ាងទៀត លទ្ធភាពនៃការទាញយកមេរៀនពីការកាត់ទោសដោយត្រឹមត្រូវ និងមិនលំអៀង ដែលប្រជាពលរដ្ឋកម្ពុជាទទួលបាននោះ ត្រូវចុះថយមកត្រឹមការគ្មានជំនឿលើកិច្ចដំណើរការនេះតែប៉ុណ្ណោះ ។ នៅក្នុងពេលធ្វើកិច្ចការរបស់ខ្លួន ក្រុមទទួលបាននូវមតិដែលថានៅក្នុងពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋកម្ពុជាពុំមានជំនឿគ្រប់

គ្រាន់ទៅលើទៅលើតុលាការរបស់ពួកគេទេ ។ មតិនេះត្រូវបានសំដែងឱ្យយើងខ្ញុំដឹងដោយតំណាងរបស់រដ្ឋាភិបាល តំណាងអង្គការក្រៅរដ្ឋាភិបាល មន្ត្រីអង្គការអន្តរជាតិ និងអ្នកសង្កេតការណ៍អន្តរជាតិឯករាជ្យ ហើយក្រុមយើងខ្ញុំពុំមានហេតុផលអ្វីនឹងសង្ស័យចំពោះការនេះទេ ។ មតិនេះនាំឱ្យយល់ថា ពុំមានរូបមន្តនៃការកាត់ទោសណាមួយដោយប្រទេសកម្ពុជា ដែលប្រជាពលរដ្ឋកម្ពុជាអាចទទួលយកបាននោះទេ ។ ក្រុមបានកត់សំគាល់ឃើញថា នៅក្នុងលិខិតផ្ញើជូនលោកអគ្គលេខាធិការចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៩៩៧ នាយក រដ្ឋមន្ត្រីទាំង ២ រូប បានថ្លែងអំពីកិច្ចដំណើរការកាត់ទោសពីបទព្រហ្មទ័ណ្ឌចំពោះក្រុមមេដឹកនាំខ្មែរក្រហមថា "ប្រទេសកម្ពុជាពុំមានធនធាន ឬជំនាញ ដ៏ចាំបាច់ដើម្បីកិច្ចដំណើរការដ៏សែនសំខាន់នេះបានទេ" ។

១៣៥- ដើម្បីឆ្លើយតបចំពោះសេចក្តីព្រួយបារម្ភនេះ ត្រូវចោទជាសំណួរថាតើមានលទ្ធភាពអាចស្ថាបនាឡើងនូវរូបមន្តមួយដែលឈរលើមូលដ្ឋាននៃច្បាប់កម្ពុជា និងដែលសំរួលចំណុចខ្សោយនៃប្រព័ន្ធរបស់វា និងការមិនទុកចិត្តរបស់សាធារណជនបានឬទេ ។ ក្រុមបានពិនិត្យយ៉ាងយកចិត្តទុកដាក់ជាទីបំផុតនូវវិធីជាច្រើនដែល អាចយកមកប្រើបាន ។ វិធីទាំងនោះជារួមអាចចែកចេញជា ២ ប្រភេទ: ការគាំទ្រជាថវិកា ពីអង្គការអន្តរ ជាតិ និងរដ្ឋាភិបាលបរទេសនានា ហើយនឹងការចូលរួមរបស់បុគ្គលិកមកពីអង្គការ និងរដ្ឋាភិបាលទាំងនេះ ។

១៣៦- ចំពោះការគាំទ្រផ្នែកថវិកា ក្រុមយល់ថាជំនួយប្រភេទនេះប្រហែលជាអាចធ្វើឱ្យដោះស្រាយឧបសគ្គខ្លះដែលបានរៀបរាប់ខាងលើនេះបានខ្លះ ឧទាហរណ៍ដូចជាការផ្តល់នូវថវិកាសំរាប់ស្ថាបនាទីកន្លែងឱ្យបានត្រឹមត្រូវសំរាប់ការបើកសវនាការ ផ្តល់ជាប្រាក់កាសឱ្យបានគ្រប់គ្រាន់ជូនដល់ចៅក្រម ព្រះរាជអាជ្ញា និងអ្នកស៊ើបអង្កេត ដើម្បីបន្ថយការស៊ីសំណូក ផ្តល់នូវសេវាកម្មខាងមេធាវីដែលមានសមត្ថភាពដល់ជនជាប់ចោទ និងដោយផ្តល់បច្ចេកទេសស៊ើបអង្កេតទំនើបដែលមានសារសំខាន់ណាស់ ដោយសារថាភស្តុតាងមានអាយុចាស់ណាស់ទៅហើយដូចជានៅក្នុងករណីនេះ ។ ក៏ប៉ុន្តែ លុយកាក់តែមួយមុខគត់ វាមិនគ្រប់គ្រាន់ទេដើម្បីដោះស្រាយឧបសគ្គសំខាន់ ៧ ដូចបានរៀបរាប់មកខាងលើនេះ ពោលគឺភាពងាយស្រួលរបស់មនុស្សទាំងអស់ដែលពាក់ព័ន្ធក្នុងកិច្ចដំណើរការនេះ ទៅនឹងការគាបសង្កត់ខាងនយោបាយ ។

១៣៧- ការរួមចំណែករបស់បុគ្គលិកដែលបានទទួលការហ្វឹកហ្វឺនត្រឹមត្រូវ មកពីអង្គការអន្តរជាតិ និងរដ្ឋាភិបាល នឹងជួយកែលំអការកាត់ទោសតាមច្បាប់កម្ពុជា ។ ឧទាហរណ៍ បុគ្គលិកប្រភេទនេះអាចជួយដល់ផ្នែកខាងកម្ពុជាជារដ្ឋអាជ្ញា ជាអ្នកស៊ើបអង្កេត និងជាមេធាវីខាងចុងចោទជាដើម ។ មានលទ្ធភាពអាចបង្កើតជាតុលាការចំរុះមួយ ដោយមានរួមបញ្ចូលជនកម្ពុជា និងបរទេស ដែលមានចំនួនស្មើគ្នា ឬក៏តុលាការមួយ ដែលមិនមែនជាតុលាការកម្ពុជាតែម្តង ដែលបង្កើតឡើងស្របតាមច្បាប់កម្ពុជា និងអនុវត្តតាមច្បាប់កម្ពុជា ច្បាប់អន្តរជាតិ ឬតាមច្បាប់ទាំងពីរនេះតែម្តង ។ ក្រុមបានពិនិត្យដោយយកចិត្តទុកដាក់ នូវរូបមន្តតុលាការចំរុះ ឬតុលាការបរទេសដែលបង្កើតឡើងដោយកម្ពុជា ។ ក៏ប៉ុន្តែ ក្រុមបានសំរេចថាមិនលើកស្នើឡើងនូវរូបមន្តនេះទេ ដោយមានការភ័យខ្លាចថា ដោយឈរលើការធ្វើការវាយតម្លៃផ្ទាល់របស់ខ្លួនចំពោះសភាពការណ៍នៅកម្ពុជា ទោះបីជារូបមន្តបែបនេះក៏អាចត្រូវប្រឈមមុខជាមួយឧបាយកលរបស់កម្លាំងនយោបាយនៅក្នុងប្រទេសកម្ពុជាដែរ ។ លទ្ធភាពនៃការបញ្ចូលឥទ្ធិពលនយោបាយទៅក្នុងតុលាការប្រភេទនេះមានច្រើន ជាពិសេសក្នុងការកំណត់និយមន័យនៃលក្ខន្តិកៈរបស់តុលាការ និងនៅក្នុងការអនុវត្តន៍នាពេលក្រោយមក និងនៅក្នុងតួនាទីដែលត្រូវអនុវត្តរបស់ជនកម្ពុជាដែលត្រូវបានតែងតាំងឱ្យធ្វើជាចៅក្រម ឬជាព្រះរាជអាជ្ញា និងជាអ្នកស៊ើបអង្កេត ឬធ្វើជាមេធាវីរបស់ពិរុទ្ធជន ។ តុលាការកម្ពុជា និងប្រព័ន្ធព្រះរាជអាជ្ញាកម្ពុជា ទោះបីជាមានការចូលរួមដោយបុគ្គលិកអន្តរជាតិជាចំនួនច្រើនក៏ដោយ ក៏នៅតែត្រូវការការអនុញ្ញាតិពីសំណាក់រដ្ឋាភិបាលសិន មុននឹងចាប់ផ្តើមអនុវត្តកិច្ចការភាគច្រើនរបស់ខ្លួន និងអាចបាត់បង់នូវឯករាជភាពរបស់ខ្លួននៅ ក្នុងកាលៈទេសៈសំខាន់ ៗ ។

១៣៨- សេចក្តីសំរេចរបស់យើងខ្ញុំ ក្នុងការសុំឱ្យអង្គការសហប្រជាជាតិបង្កើតឡើងនូវតុលាការកម្ពុជាមួយមិនមែនជាការស្រួលទេ ហើយអាចនឹងធ្វើឡើងបានលុះត្រាតែមានការគិតគូរពិចារណាដោយប្រុងប្រយ័ត្នអំពីសភាពការណ៍នៃប្រទេសកម្ពុជា ដោយឈរលើការស្រាវជ្រាវ និងបទសម្ភាសន៍នានារបស់យើងខ្ញុំជាមុនសិន ។ ជាការពិតណាស់ អ្នកខ្លះមានការលំបាកនឹងទទួលយកមតិរបស់យើងខ្ញុំ ដែលថាទោះបីជាមានជំនួយជាថវិកា ជាដុំកំភួនពីអន្តរជាតិ និងការបញ្ចូលបុគ្គលិកអន្តរជាតិក៏ដោយ ក៏មិនគួរសាកល្បងវាទេ ដោយវានឹងត្រូវប៉ះ ទង្គិចនឹងឧបសគ្គជាច្រើន ដែលអាចនឹងកើតឡើងពីល្បែងនៃកម្លាំងនយោបាយកម្ពុជានានា ។ ប៉ុន្តែ យើងខ្ញុំ មានជំនឿជឿជាក់ថា វាគឺជាការទទួលខុសត្រូវរបស់យើងខ្ញុំក្នុងការបដិសេធនូវរូបមន្តទាំងឡាយណាដែលមិន អាចនឹងធ្វើទៅរួច

និងមិនលើកទឹកចិត្តដល់អង្គការសហប្រជាជាតិឱ្យផ្តល់ថវិកាដល់តុលាការណា ដែលមិនអាចបំពេញបាននូវបទដ្ឋាននៃយុត្តិធម៌ជាអប្បបរមាបានទេនោះ ។

## ខ- តុលាការបង្កើតឡើងដោយអង្គការសហប្រជាជាតិ

១៣៩- ជំរើសទី ២ ដែលក្រុមបានយកមកពិចារណា គឺការបង្កើតឡើងនូវតុលាការអន្តរជាតិចំពោះកិច្ចមួយដោយអង្គការសហប្រជាជាតិ ។ បន្ទាប់ពីបានធ្វើការថ្លឹងថ្លែងនូវគ្រប់លទ្ធភាព និងដូចបានពន្យល់យ៉ាងពិស្តានៅក្នុងផ្នែកទី ៧ ខាងក្រោមនេះមក រូបមន្តនេះ គឺជារូបមន្តដែលក្រុមមានសំណូមពរឱ្យបង្កើតឡើងខ្លាំងជាងគេបំផុត ។

### ១- វិធីបង្កើត

១៤០- រហូតមកទល់ពេលនេះ អង្គការតែមួយគត់របស់អង្គការសហប្រជាជាតិ ដែលបានបង្កើតតុលាការព្រហ្មទ័ណ្ឌអន្តរជាតិចំពោះកិច្ចនោះ គឺក្រុមប្រឹក្សាសន្តិសុខ ដែលជាអ្នកបង្កើតតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ្វាន់ដា ។ តុលាការទាំង ២ នេះ ត្រូវបានបង្កើតឡើងស្របតាមជំពូកទី ៧ នៃធម្មនុញ្ញសហប្រជាជាតិ ដើម្បីធ្វើជាមធ្យោបាយមួយឆ្លើយតបទៅនឹងការគំរាមកំហែងដល់សន្តិភាពនៃតំបន់ទាំងនោះ ។

១៤១- ចំពោះករណីកម្ពុជា ក្រុមយល់ឃើញថា ជាបញ្ហាផ្លូវច្បាប់ ក្រុមប្រឹក្សាសន្តិសុខអាចបង្កើតតុលាការថ្មីមួយសំរាប់ប្រទេសកម្ពុជា ស្របទៅតាមផ្នែកនានារបស់ធម្មនុញ្ញ ។ ទី ១ ក្រុមប្រឹក្សាអាចយកតាមគំរូនៃតុលាការដែលមានពីមុន ៗ មក ហើយបង្កើតតុលាការស្របតាមជំពូកទី ៧ ។ ក្រុមយល់ឃើញថា ទស្សិករនោះអាចធ្វើទៅបាន ដោយសារថាការបន្តនូវនិទ័ណ្ឌភាពរបស់ពួកខ្មែរក្រហម នៅចំពោះមុខការទាមទាររបស់ប្រជាពលរដ្ឋដែលសុំឱ្យមានយុត្តិធម៌នោះ គឺជាការគំរាមកំហែងមួយចំពោះសន្តិភាពនៅក្នុងតំបន់ និងថាការទទួលខុសត្រូវចំពោះបទព្រហ្មទ័ណ្ឌនឹងអាចជួយដោះស្រាយបញ្ហានេះបាន ។ តាមពិតទៅ សេចក្តីថ្លែងការណ៍

នានាស្តីពីគ្រោះថ្នាក់នៃអំពើឃោរឃៅខាងសិទ្ធិមនុស្ស ចំពោះសន្តិភាពអន្តរជាតិ ត្រូវបានដឹងឮទៅអង្គការសហប្រជាជាតិ ទាំងនៅក្នុងពេលថ្មី ៗ នេះ ទាំងតាំងពីច្រើនឆ្នាំកន្លងមកហើយ[៧៥] ។

១៤២- ក្រុមបានដឹងហើយអំពីសេចក្តីព្រួយបារម្ភដែលថា សេចក្តីសំរេចមួយបែបនេះរបស់ក្រុមប្រឹក្សាមិនធ្លាប់ដែលមានទេនាពេលកន្លងមក នៅក្នុងពេលដែលជម្លោះដោយអាវុធត្រូវបានបញ្ចប់ទៅហើយនៅក្នុងប្រទេសកម្ពុជា ដែលជាលទ្ធផលនៃព្រឹត្តិការណ៍ដែលបានកើតឡើងកាលពីក្នុងខែថ្មី ៗ កន្លងមកនេះ បញ្ហាជនភៀសខ្លួនត្រូវបានដោះស្រាយជាទូទៅហើយ ហើយពុំមានភាពតានតឹងដ៏ធ្ងន់ធ្ងររវាងប្រទេសកម្ពុជា និងប្រទេសជិតខាងដែលបណ្តាលមកពីបញ្ហាខ្មែរក្រហមទៀតទេ ។ ដូច្នេះ បើសិនជាក្រុមប្រឹក្សាសន្តិសុខមានបំណងចង់លើកយកជំពូកទី ៧ មកដោះស្រាយនោះ ក្រុមគិតថាគេអាចបង្កើតតុលាការមួយស្របទៅតាមជំពូកទី ៦ ដែលផ្តល់ដល់តុលាការនេះនូវអំណាចយ៉ាងទូលំទូលាយទៅលើបញ្ហាទាំងឡាយ ដែលទាក់ទងទៅនឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ។ ជំពូកនេះ (ជាពិសេសមាត្រាទី ១៦) ត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានមួយសំរាប់ការស្រុះស្រួលគ្នាក្នុងការថែរក្សាសន្តិភាព និងបង្កើតជាមូលដ្ឋានមួយសំរាប់ការស្រុះស្រួលគ្នាចំពោះសកម្មភាពផ្សេង ៗ គ្នារបស់ក្រុមប្រឹក្សា ។ លើសពីជំពូកទី ៦ ទៅទៀត ក្រុមប្រឹក្សាមានលទ្ធភាពអាចធ្វើអ្វី ៗ ស្របតាមផ្នែកផ្សេង ៗ ទៀតនៃធម្មនុញ្ញ ដូចជាមាត្រាទី ២៩ ដែលអនុញ្ញាតឱ្យក្រុមប្រឹក្សា "បង្កើតឡើងនូវអង្គការបន្ទាប់បន្សំផ្សេង ៗ ដែលខ្លួនយល់ថាជាការចាំបាច់សំរាប់ប្រសិទ្ធភាពនៃការងាររបស់ខ្លួននោះ" ។

១៤៣- ភាពខុសគ្នារវាងតុលាការមួយដែលបង្កើតឡើងស្របតាមជំពូកទី ៧ និងតុលាការមួយដែលបង្កើតឡើងតាមផ្នែកផ្សេងទៀតនៃធម្មនុញ្ញ អាចនឹងមិនអាចមានអត្ថន័យជាគោលការណ៍ ឬក្នុងការអនុវត្តនីទេ ។ បញ្ហាជាគន្លឹះហាក់ដូចជាមានលក្ខណៈបង្ខំខាងផ្លូវច្បាប់ ចំពោះការសំរេចបង្កើតនូវតុលាការបែបនេះមួយ-ជាពិសេសបទបញ្ញត្តិទាំងឡាយដែលសុំឱ្យមានកិច្ចសហប្រតិបត្តិការជាមួយតុលាការនេះ ។ សេចក្តីសំរេចរបស់ជំពូកទី ៧ ជានិច្ចកាលតែងតែដាក់ការបង្ខំខាងផ្លូវច្បាប់ទៅលើរដ្ឋទាំងអស់ ។ ក៏ប៉ុន្តែ ដូចដែលបានសំរេច

[៧៥] សូមមើលលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងសេចក្តីផ្តើម វាក្យខ័ណ្ឌ ៣ ("ទទួលស្គាល់ថាឧក្រិដ្ឋកម្មធ្ងន់ធ្ងរបែបនេះគំរាមកំហែងដល់សន្តិភាព សន្តិសុខ និងការរស់នៅ នៃពិភពលោក") ការកត់ត្រាជាផ្លូវការរបស់មហាសន្និបាត គណៈកម្មាធិការទី ៦ សម័យប្រជុំលើកទី ៣ ការប្រជុំលើកទី ១០០ ទី ១០១ A/633 (1948) (សេចក្តីស្នើសុំដោយអ្នកធ្វើពង្រាង អនុសញ្ញាស្តីពីការបង្កា និងការទ័ន្ឋកម្មដល់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលថាករណីប្រល័យពូជសាសន៍ទាំងអស់មានការជាប់គ្នាយ៉ាងជិតស្និទ្ធទៅនឹងការគំរាមកំហែងដល់សន្តិភាពអន្តរជាតិ) ។

ដោយតុលាការអន្តរជាតិស្តីពីករណីណាមីប៊ី ក្រុមប្រឹក្សាសន្តិសុខអាចធ្វើសេចក្តីសំរេចដោយបង្ខំ ដោយឈរលើ ផ្នែកផ្សេង ៗ នៃធម្មនុញ្ញ ដោយមិនឈរតែទៅលើជំពូកទី ៧ តែមួយប៉ុណ្ណោះទេ[៧៦] ។ នេះគឺជាកាតព្វកិច្ច របស់រដ្ឋនានាដែលត្រូវគោរពតាមសេចក្តីសំរេចនានារបស់ក្រុមប្រឹក្សា តាមមាត្រាទី ២៥ នៃធម្មនុញ្ញ ដែល ត្រូវពង្រីកចំពោះសេចក្តីសំរេចទាំងអស់របស់ក្រុមប្រឹក្សា ពោលគឺមិនត្រឹមតែសេចក្តីសំរេចធ្វើឡើងតាមតែ ជំពូកទី ៧ តែមួយប៉ុណ្ណោះនោះទេ ។

១៤៤- បើសិនជាក្រុមប្រឹក្សាចាត់វិធានការដូចដែលមានចែងយ៉ាងជាក់លាក់នៅក្នុងជំពូកទី ៦ នោះ ក្រុមប្រឹក្សាត្រូវយល់ថាមាត្រាទាំងឡាយដែលពាក់ព័ន្ធនឹងជំពូកនេះ និយាយតែអំពីការស្នើយោបល់របស់ក្រុមប្រឹក្សាតែប៉ុណ្ណោះទេ ។ ដូច្នេះ បើសិនជាក្រុមប្រឹក្សាបង្កើតតុលាការមួយតាមជំពូកទី ៦ តាមផ្លូវច្បាប់ តុលាការត្រូវរំពឹងតែទៅលើការសុខចិត្តសុខកាយរបស់រដ្ឋមានពាក់ព័ន្ធ ក្នុងការអនុវត្តន៍សេចក្តីស្នើយោបល់ទាំងនោះតែប៉ុណ្ណោះ ។ តុលាការបែបនេះ ប្រាកដជាខ្វះអំណាចក្នុងការចេញបទបញ្ជាទៅលើរដ្ឋដ៏ទៃទៀត[៧៧] ហើយរដ្ឋខ្លះអាចរកវិធីដោះសាបានយ៉ាងស្រួលដើម្បីបញ្ជាក់អំពីការធ្វើតាមតែមណ្ឌលផ្ទាល់របស់ពួកគេ ចំពោះ សេចក្តីស្នើសុំរបស់តុលាការ បើសិនជាតុលាការនេះត្រូវបានបង្កើតឡើងតាមជំពូកទី ៧ នោះ ។ បញ្ហាយុត្តាធិការលើចុងចោទ ក៏ប្រហែលជាតម្រូវឱ្យយកមកពិចារណាផ្សេងផងដែរ ពីអ្វីដែលត្រូវបានយល់ព្រមដោយតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី នៅក្នុងសេចក្តីសំរេចខាងយុត្តាធិការថាឌីក ឆ្នាំ ១៩៩៥[៧៨] ។

១៤៥- ទោះបីជាយ៉ាងណាក៏ដោយ ក៏ភាពខុសគ្នារវាងជំពូកទី ៦ និងជំពូកទី ៧ អាចនឹងក្លាយទៅជាបញ្ហាតូច តាចទៅវិញនៅក្នុងការអនុវត្តន៍ ។

---

[៧៦] បច្ច័យស្របច្បាប់សំរាប់រដ្ឋនានា ក្នុងបន្តវត្តមាននៃប្រទេសអាហ្វ្រិកខាងត្បូងនៅក្នុងប្រទេសណាមីប៊ី (អាហ្វ្រិកផ្នែកនិរតី) ថ្វីបើមាន សេចក្តីសំរេចចិត្តលេខ ២៧៦ (ឆ្នាំ ១៩៧០) របាយការណ៍នានារបស់តុលាការអន្តរជាតិ ឆ្នាំ ១៩៧១ ទំព័រ ១៦ ៥៣ ក៏ដោយ ។ សូម មើលផងដែរ ប្រុយណ្ លី ស៊ីម៉ា ធម្មនុញ្ញសហប្រជាជាតិៈ សេចក្តីអត្ថាធិប្បាយ ទំព័រ ៤១០-១១ (អុកស្វ៊តៈ រោងពុម្ពសកលវិទ្យាល័យ អុកស្វ៊ត ឆ្នាំ ១៩៩៥) ។

[៧៧] សូមមើល រដ្ឋអាជ្ញា ប្លាស់ស្គី ការកាត់សេចក្តីតាមការស្នើសុំរបស់សាធារណរដ្ឋក្រូអេស្យ៉ា ដើម្បីពិនិតឡើងវិញសេចក្តីសំរេចរបស់សាលាកាត់ក្តីទី ២ នាថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ១៩៩៧ សាលាឧទ្ធរយូហ្គោស្លាវី ថ្ងៃទី ២៩ ខែតុលា ឆ្នាំ ១៩៩៧ ។

[៧៨] បណ្តឹងឧទ្ធរឆ្លើយឆ្លងថាឌីក វាក្យខ័ណ្ឌ ២៦-៤៨ ។

បទពិសោធអំពីតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និង តុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា បណ្តាលឱ្យយល់ថាកិច្ចសហប្រតិបត្តិការដោយស្ម័គ្រចិត្ត របស់រដ្ឋមានសារសំខាន់ណាស់ ក្នុងចំណោមករណីទាំង ២ នេះ ហើយទោះបីជាអាណត្តិរបស់ជំពូកទី ៧ ក៏មិនបានធានានូវការគោរពតាមបញ្ជានានារបស់តុលាការដែលមានស្រាប់មកហើយនោះទេ ។ម្យ៉ាងទៀត ទោះបីជាតុលាការមួយត្រូវបានបង្កើតឡើងស្របតាមជំពូកទី ៦ ក៏ដោយ ក៏ក្រុមប្រឹក្សាមិនអាចសំរេចធ្វើសេចក្តីសំរេចជាបុគ្គលដូចមានចែងនៅក្នុងជំពូកទី ៧ លើបញ្ហាដោយឡែក ៗ ដែលរដ្ឋមានពាក់ព័ន្ធមិនសុខចិត្ត និង មិនអនុវត្តន៍តាម បានឡើយ ។ កន្លងមក ក្រុមប្រឹក្សាបានប្រើយុទ្ធសាស្ត្រនេះប្តូរពីជំពូកទី ៧ មកជំពូកទី ៦ វិញ[៧៩] ។ ហើយ ដូចបានកត់សំគាល់មកហើយ ក្រុមប្រឹក្សាមានលទ្ធភាពអាចធ្វើសេចក្តីសំរេចចិត្តមានលក្ខណៈបង្ខំបាន ដោយឈរលើផ្នែកដ៏ទៃទៀតរបស់ធម្មនុញ្ញ ។

១៨៦- លទ្ធភាពទី ៣ តម្រូវឱ្យបង្កើតតុលាការមួយដោយមហាសន្និបាតក្រោមអំណាចផ្តល់អនុសាសន៍របស់ខ្លួន ស្របតាមជំពូកទី ៤ នៃធម្មនុញ្ញ ជាពិសេសមាត្រាទី ១១ (២) និងទី ១៣ ។ កាលពីអតីតកាល មហាសន្និបាតបានបង្កើតអង្គការបន្ទាប់បន្សំដែលមានអំណាចផ្សេង ៗ ពីគ្នា ដូចជាកម្លាំងក្នុងភាពអាសន្នទី ១ របស់អង្គការសហប្រជាជាតិ ក្រុមប្រឹក្សារបស់អង្គការសហប្រជាជាតិសំរាប់ប្រទេសណាមីប៊ី និងបេសកកម្មសំរាប់ផ្ទៀងផ្ទាត់ការបោះឆ្នោតនៅប្រទេសហៃទី ឆ្នាំ ១៩៩០[៨០] ។ ដូចជានៅក្នុងករណីបង្កើតតុលាការមួយស្របតាមជំពូកទី ៦ តុលាករមួយបង្កើតឡើងដោយសន្និបាត គឺត្រូវរំលាបទាំងស្រុងទៅលើឆន្ទៈរបស់រដ្ឋនានា ក្នុងការគោរពតាមសេចក្តីសំរេចនានា ។

១៨៧- ទីបញ្ចប់ ក្រុមមិនមែនមានបំណងច្រានចោលជាមុននូវការបង្កើតតុលាការមួយដោយអង្គការផ្សេង ៗ របស់អង្គការសហប្រជាជាតិ រួមមានក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ឬអគ្គលេខាធិការ ផងនោះទេ ។

---

[៧៩] សូមមើល ឧទាហរណ៍ សេចក្តីសំរេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខ លេខ ៧៣១ (ឆ្នាំ ១៩៩២) និងលេខ ៧៤៨ (ឆ្នាំ ១៩៩២) ការកត់ត្រាជាផ្លូវការរបស់ក្រុមប្រឹក្សាសន្តិសុខ ឆ្នាំទី ៤៧ សេចក្តីសំរេចចិត្ត និងសេចក្តីសំរេច (S/INF/48) ។

[៨០] សេចក្តីសំរេចចិត្តលេខ ១000 ការកត់ត្រាជាផ្លូវការរបស់មហាសន្និបាត សម័យប្រជុំអាសន្នពិសេសលើកទី ១ សេចក្តីបន្ថែមលេខ ១ (A/3354) ទំព័រទី ៣ សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ២២៤៨ ការកត់ត្រាជាផ្លូវការរបស់មហាសន្និបាត សម័យប្រជុំពិសេសលើកទី ៥ សេចក្តីបន្ថែមលេខ ១ (A/6657) ទំព័រទី ១ សេចក្តីសំរេចចិត្តរបស់មហាសន្និបាតលេខ ៤៥/២ ការកត់ត្រាជាផ្លូវការរបស់មហាសន្និបាត សម័យប្រជុំលើកទី ៤៥ សេចក្តីបន្ថែមលេខ ៤៩ A (A/45/49) ។

១៤៨- ក្រុមយល់ឃើញថា គួរតែបង្កើតតុលាការអន្តរជាតិមួយ ដោយក្រុមប្រឹក្សាសន្តិសុខ ស្របតាមមាត្រា ទី ៧ និងទី ៦ ឬក៏តាមផ្នែកផ្សេងទៀតនៃធម្មនុញ្ញ ។ យើងខ្ញុំសូមជំរុញឱ្យប្រើក្រុមប្រឹក្សា ពីព្រោះក្រុមប្រឹក្សាអាចធ្វើការបានលឿនដោយពួកគេមានសមាជិកតិច និងមានបទពិសោធន៍ក្នុងចំពោះសមាជិកជាច្រើននាក់របស់ខ្លួន ក្នុងការបង្កើត និងក្នុងការដំណើរការរបស់តុលាការចំពោះកិច្ច ។ បើសិនជាពុំមានតុលាការបង្កើតឡើងដោយក្រុមប្រឹក្សាទេ ក្រុមយល់ឃើញថាតុលាការនេះគួរត្រូវបង្កើតដោយមហាសន្និបាត ។ ការណ៍នេះទាមទារឱ្យមានការផ្ទេរអំណាចដើម្បីរៀបចំលក្ខន្តិកៈសំរាប់ក្រុមដ៏តូចល្មមមួយនៃរដ្ឋនានាដែលអាច រៀបចំតុលាការនោះឱ្យបានដោយរួសរាន់ ។

## ២- <u>អំពីយុត្តាធិការ</u>

១៤៩-ការកំណត់ពេលវេលានៃយុត្តាធិការរបស់តុលាការអង្គការសហប្រជាជាតិនេះ គឺជាបញ្ហារបស់អង្គការដែលបានបង្កើតវាមក ។ ក្រុមមានមតិថា ចំពោះអាណត្តិផ្ទាល់របស់វា ការកំណត់ពេលវេលានៃយុត្តាធិការរបស់តុលាការមួយបែបនេះ ត្រូវក៏រិតព្រំដែនត្រឹមរយៈពេលនៃការកាន់កាប់អំណាចរបស់កម្ពុជាប្រជាធិប-តេយ្យ ពោលគឺចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ ។ ដូចបាននិយាយមុននេះមកហើយ ចំពោះអាណត្តិរបស់ក្រុម ការគិតគូរអំពីការរំលោភសិទ្ធិមនុស្សដោយភាគីណាមួយ នៅក្នុងមុន និងក្រោយរយៈពេលនោះ នឹងធ្វើឱ្យឱនថយដល់ប្រភេទតែមួយគត់ និងមិនធម្មតា នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយពួកមេដឹកនាំនៃកម្ពុជាប្រជាធិបតេយ្យ ។

១៥០- ស្តីអំពីកម្មវត្ថុនៃយុត្តាធិការ ដូចដែលបានកត់សំគាល់នៅក្នុងផ្នែកទី ៥ ខាងលើនេះ ការរំលោភទាំងឡាយនៅក្នុងយុគសម័យនៃកម្ពុជាប្រជាធិបតេយ្យ គឺហាក់ដូចជានាំឱ្យយល់ថាតុលាការមួយត្រូវមានយុត្តា-ធិការទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើប្រព្រឹត្តដ៏ទៃទៀតដែលជាការទទួលខុសត្រូវពីបទព្រហ្មទ័ណ្ឌរបស់បុគ្គលម្នាក់ ៗ ទៅលើច្បាប់អន្តរជាតិ ក៏ដូចជាការរំលោភលើច្បាប់កម្ពុជាដែរ ។ក្រុមយល់ឃើញថា តុលាការរបស់អង្គការសហប្រជាជាតិមួយត្រូវមានយុត្តាធិការ

លើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រល័យពូជសាសន៍ ។ ឧក្រិដ្ឋកម្មទាំង ២ នេះ ពិសេសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺបានកើតឡើងយ៉ាងច្រើនបំផុតនៅក្នុងអំពើឃោរឃៅរបស់ពួកខ្មែរក្រហម ។

១៥១- ចំពោះឧក្រិដ្ឋកម្មសង្គ្រាមវិញ ទោះបីជាការកត់ត្រាខាងប្រវត្តិសាស្ត្របានបញ្ជាក់យ៉ាងច្បាស់ហើយក៏ដោយ ក្រុមកត់សំគាល់ឃើញថា ក្នុងការបង្កើតតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី អង្គការសហប្រជាជាតិបានធ្វើឱ្យមានអតីតកាលដ៏សំខាន់មួយដែលថាការកាត់ទោសចំពោះឧក្រិដ្ឋកម្មសង្គ្រាម មិនត្រូវ ក៏រឹតព្រំដែនតែទៅលើផ្នែកមួយនៅក្នុងជម្លោះនោះទេ ។ គោលការណ៍នេះមានន័យថា បើសិនជាឧក្រិដ្ឋកម្ម សង្គ្រាមត្រូវបញ្ចូលទៅក្នុងយុត្តាធិការរបស់តុលាការមួយសំរាប់ប្រទេសកម្ពុជានោះ គេត្រូវបញ្ចូលឧក្រិដ្ឋកម្ម សង្គ្រាម ដែលបានប្រព្រឹត្តឡើងដោយនៃប្រទេសដ៏ទៃទៀតនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យដែរ ។ ចំពោះហេតុផលដូចបានពោលខាងលើ យើងខ្ញុំយល់ឃើញថាការណ៍នេះវានឹងបង្វែការយកចិត្តទុកដាក់ របស់តុលាការពីអំពើឃោរឃៅដ៏ច្រើនលើសលប់ ហើយអាស្រ័យហេតុនេះយើងខ្ញុំយល់ឃើញថាមិនត្រូវបញ្ចូលឧក្រិដ្ឋកម្មសង្គ្រាមទេ ។

១៥២- ចំពោះឧក្រិដ្ឋកម្មអន្តរជាតិដ៏ទៃទៀតដូចបានកត់សំគាល់ខាងលើនេះ - ការបង្ខំឱ្យធ្វើការជាទម្ងន់ទារុណកម្ម និងឱ្យក្រិដ្ឋកម្មប្រឆាំងទៅលើមនុស្សដែលត្រូវបានការពារជាអន្តរជាតិ - ក្រុមកត់សំគាល់ឃើញថាទាំងនេះមិនត្រូវបញ្ចូលជាឧក្រិដ្ឋកម្មដោយឡែកទៅក្នុងយុត្តាធិការ នៃតុលាការនានាដែលមានស្រាប់នោះទេ ។ ទោះបីជាក្រុមយល់ឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ទាំងនោះ អាចមានលក្ខណៈគ្រប់គ្រាន់សំរាប់យុត្តាធិការរបស់តុលាការហើយក៏ដោយ ក៏យើងខ្ញុំនៅតែសុំឱ្យយកចិត្តទុកដាក់ដល់ការបញ្ចូលឧក្រិដ្ឋកម្មដោយឡែក ពោលគឺការបង្ខំឱ្យធ្វើការជាទម្ងន់ និងទារុណកម្ម ផងដែរ ដោយសារថាការចោទប្រកាន់ទាំងនេះមិនទាមទារភស្តុតាងនៃកត្តាពិសេស ៗ ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬប្រល័យពូជសាសន៍នោះទេ ។

១៥៣- ក្រុមក៏បានពិនិត្យផងដែរ ថាតើតុលាការអន្តរជាតិគួរធ្វើការកាត់ទោសជនល្មើសតាមច្បាប់កម្ពុជា ឬយ៉ាងណានោះ ។ ជំរើសបែបនេះមួយមានលទ្ធភាពអាចធ្វើទៅបានតាមផ្លូវច្បាប់ ហើយដូចជាបានកត់សំគាល់

ខាងលើអឺចឹង គឺថាវាហាក់ដូចជាស្រួលជាងដើម្បីបញ្ជាក់អំពីការរំលោភច្បាប់កម្ពុជា ជាជាងការរំលោភលើច្បាប់អន្តរជាតិ ដោយវាមានការជាប់ជំពាក់ទៅនឹងអវត្តមាននៃកត្តាពិសេសនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងប្រល័យពូជសាសន៍ ។ ក៏ប៉ុន្តែ ការកាត់ទោសបទព្រហ្មទណ្ឌបែបនេះអាចនឹងមិនមែនជាការចំណាយពេលវេលាប្រកបដោយគតិបណ្ឌិតរបស់បុគ្គលិក និងចៅក្រមកាត់សេចក្តីទេ ដោយសារមានការលំបាកក្នុងការស្វែងរកប្រភពនានាដែលបរិយាយឱ្យបានល្អិតល្អន់នូវច្បាប់នោះ ។ ទោះបីជាពួកគេអាចនឹងធ្វើការយោងទៅលើប្រព័ន្ធច្បាប់ដែលមានពាក់ព័ន្ធនានា ជាពិសេសច្បាប់បារាំងក៏ដោយ ក៏ការណ៍នេះនឹងត្រូវពាក់ព័ន្ធយ៉ាងច្បាស់ទៅនឹងការបន្ថែមពេលវេលាហួសពីសេចក្តីត្រូវការ សំរាប់ធ្វើការកាត់ទោសឧក្រិដ្ឋកម្មអន្តរជាតិនានាដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ បើសិនជាអ្នករៀបចំលក្ខន្តិកៈរបស់តុលាការមានសំណូមពរចង់បង្កើតមូលដ្ឋានច្បាប់បន្ថែមសំរាប់ធ្វើការកាត់ទោសនោះ សេចក្តីសន្និដ្ឋាននៃការរំលោភច្បាប់កម្ពុជានៅក្នុងយុត្តាធិការតុលា-ការ គួរតែត្រូវយកមកពិចារណាផងដែរ ។

១៥៤- ជាទីបញ្ចប់ ចំពោះយុត្តាធិការផ្ទាល់ខ្លួនម្នាក់ ៗ បញ្ហានៃមុខសញ្ញាសមស្របនៃការស៊ើបអង្កេតត្រូវបានពិភាក្សាយ៉ាងវែងនៅក្នុងផ្នែកទី ៧ ខាងក្រោមនេះ ។ ទោះបីជាក្រុមយល់ឃើញថារដ្ឋអាជ្ញាត្រូវកំណត់ព្រំដែននៃការស៊ើបអង្កេតរបស់ខ្លួនតែត្រឹមប្រភេទមនុស្សដែលបានរៀបរាប់នៅទីនោះក៏ដោយ - មនុស្សណាដែលទទួលខុសត្រូវខ្លាំងជាងគេចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរជាងគេបំផុត ក្នុងរជ្ជកាលកម្ពុជាប្រជាធិបតេយ្យ - លក្ខន្តិកៈរបស់តុលាការត្រូវប្រើភាសាដោយគ្មានកំណត់ព្រំដែនដូចនៅក្នុងតុលាការសំរាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា ឧទាហរណ៍ដូចជា "មនុស្សទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា" ជាដើម ។ វាជាការមានប្រយោជន៍ក្នុងការលើកឡើងថា មានតែបុគ្គលទេដែលត្រូវធ្លាក់ចូលទៅក្នុងយុត្តាធិការរបស់តុលាការ ។

## ៣- រចនាសម្ព័ន្ធ

១៥៥- តុលាការដែលមានស្រាប់នានា ធ្វើការតែក្នុងបន្ទប់កាត់ក្តី ២ ឬ ៣ ដោយចៅក្រម ៣ នាក់ និងតុលាការឧទ្ធរណ៍មួយមានចៅក្រម ៥ នាក់ ។ ក្រុមយល់ឃើញថា ការសំរបសំរួលដូចគ្នានេះមួយ

នឹងតម្រូវឱ្យមានឡើងសំរាប់តុលាការកម្ពុជាមួយ ឧទាហរណ៏ដូចជា យ៉ាងហោចណាស់ត្រូវមានបន្ទប់កាត់ក្តី ២ សំរាប់ចៅក្រម ៣ នាក់ និងបន្ទប់ឧទ្ធរណ៏ ១ សំរាប់ចៅក្រម ៥ នាក់ ។ ការនេះទាមទារឱ្យមានការតែងតាំង ចៅក្រមថ្មី ៧ ដើម្បីបំរើការងារនៅក្នុងបន្ទប់កាត់ក្តី ។ ដោយបានឃើញទំហំការងារដែលមានស្រាប់របស់ចៅក្រមឧទ្ធរណ៏នៃតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី ដែលបង្កើតសាលាឧទ្ធរសំរាប់តុលាការដែលមានស្រាប់ទាំង ២ នេះ យើងខ្ញុំយល់ស្របឱ្យមានក្រុមថ្មីមួយនៃចៅក្រមឧទ្ធរណ៏។ ក្រុមនេះអាចជាក្រុម ចំពោះកិច្ចមួយ មកពីចៅក្រមនៃសាលាកាត់ក្តីរបស់តុលាការថ្មី ឬអាចជាអង្គការដាច់ដោយឡែកមួយដែល កោះប្រជុំពេលណាឱកាសតម្រូវឱ្យ ។

១៥៦- ចំពោះការបង្កើតតុលាការជាតិ ក្រុមបានធ្វើការថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្នអំពីការខាត និងចំណេញក្នុងការដាក់បញ្ចូលអ្នកច្បាប់ខ្មែរម្នាក់ ឬច្រើននាក់ទៅក្នុងតុលាការ ហើយបានពិភាក្សាបញ្ហានេះជាមួយសហភាគីរបស់យើងខ្ញុំនៅក្នុងទីក្រុងភ្នំពេញ ។ ការដាក់បញ្ចូលចៅក្រមបែបនេះ នឹងជួយខាងផ្នែកទម្រង់ការតាមបទពិសោធន៏នៃប្រទេសកម្ពុជា និងបង្កើនលទ្ធភាពដែលថាទម្រង់ការត្រូវជនកម្ពុជាមើលឃើញថាមានការទាក់ទងទៅនឹងពួកគេដែរ ។

១៥៧- ទោះបីជាយ៉ាងណាក៏ដោយ ក្រុមមានសេចក្តីព្រួយបារម្ភចំពោះកត្តា ៣ ដែលកើនឡើងតាមលំដាប់នៃសារសំខាន់របស់វា កត្តានិមួយ ៗ ក៏ត្រូវបានពាក់ព័ន្ធដល់ការយកចិត្តទុកដាក់នៃជំរើសនៃការកាត់ទោសនៅក្នុងតុលាការកម្ពុជាដែរ ។ ទី ១ ដោយឈរលើការបំផ្លិចបំផ្លាញដែលប្រព័ន្ធច្បាប់កម្ពុជាបានឆ្លងកាត់ក្នុងជំនាន់ចុងក្រោយនេះ អាចធ្វើឱ្យអង្គការសហប្រជាជាតិមានការលំបាករកឱ្យបាននូវចៅក្រមដែលមានការហ្វឹកហ្វឺនគ្រប់គ្រាន់ ដែលមានជំនាញដ៏ចាំបាច់ដើម្បីចូលរួមជាមួយក្រុមនេះ ។ មន្ត្រីផ្នែកច្បាប់ថ្នាក់ខ្ពស់នៅក្នុង រដ្ឋាភិបាលកម្ពុជា បានបញ្ជាក់ថាពុំមានចៅក្រមខ្មែរណាម្នាក់ដែលបានទទួលការហ្វឹកហ្វឺនខាងច្បាប់ និងនីតិវិធីព្រហ្មទ័ណ្ឌអន្តរជាតិ មុននឹងទៅបំរើការងារនៅក្នុងក្រុមទេ ។

១៥៨- ទី ២ ទោះបីជាមនុស្សបែបនេះអាចត្រូវរកបានក៏ដោយ ក៏ក្រុមមានសេចក្តីព្រួយបារម្ភថាពួកគេនឹងត្រូវប្រឈមមុខការគាបសង្កត់ខាងនយោបាយ ដើម្បីឱ្យដោះស្រាយទៅតាមផ្លូវណាមួយដែលគេចង់បាននោះ។ អនាគតវិជ្ជាជីវៈចៅក្រមរបស់គេនៅក្នុងប្រទេសកម្ពុជា - ទោះបីជាសុវិត្ថភាពរបស់រូបគេផ្ទាល់ និងរបស់ក្រុមគ្រួសាររបស់ពួកគេ - គឺអាស្រ័យទាំងស្រុងទៅលើរបៀបដែលគេធ្វើការកាត់ក្តីនេះឯង។ ទោះបីជាយ៉ាងណាក៏ដោយ មានលទ្ធភាពថាការគាបសង្កត់ខាងនយោបាយបែបនេះអាចនឹងត្រូវយកជំនះបានប្រហែលជាតាមរយៈការចាត់តាំងជនជាតិខ្មែរណាម្នាក់ដែលមានឋានៈឯករាជ្យមិនធម្មតា ឬក៏រហូតដល់ជនជាតិខ្មែររស់ នៅបរទេស- ឬក៏គ្រាន់តែជាចៅក្រមខ្មែរដែលតាមធម្មតាធ្លាប់ធ្វើការយ៉ាងជិតស្និទ្ធជាមួយសហការីអន្តរជាតិរបស់គេក៏ដោយ ។

១៥៩- ទី ៣ ក្រុមមានសេចក្តីព្រួយបារម្ភបំផុតថា ដោយសារថាទំហំនៃអំពើឃោរឃៅរបស់ពួកខ្មែរក្រហម គេពុំមានលទ្ធភាពនឹងអាចរកបាននូវចៅក្រមណាម្នាក់ដែលពុំមានបុរេវិនិច្ឆ័យ យ៉ាងហោចណាស់ក៏តាមរយៈរូបភាពខាងក្រៅដែរ។ តាមការយល់ឃើញរបស់យើងខ្ញុំ គឺថាទោះបីជាចៅក្រមនោះមិនមែនជាអ្នករងគ្រោះផ្ទាល់ពីពួកខ្មែរក្រហមក៏ដោយ ក៏ម្នាក់ ៗ តែងតែមានមិត្តភក្តិ ឬបងប្អូន ដែលត្រូវបានរងគ្រោះដោយពួកនោះជាមិនខាន ។ គឺដោយសារបញ្ហាដូចគ្នានេះឯងហើយ ដែលទីចុងបំផុតបាននាំឱ្យអង្គការសហប្រជាជាតិបានដកជនជាតិយូហ្គោស្លាវី និងរ៉ាន់ដា ចេញពីតុលាការបែបនោះ ។

១៦០- អាស្រ័យដូចបានពោលមកខាងលើនេះ ក្រុមយល់ឃើញថា យកល្អតុលាការរបស់អង្គការសហប្រជាជាតិគួរតែបញ្ចូលឱ្យមានចៅក្រមខ្មែរម្នាក់ដែរយ៉ាងហោចណាស់ តែក៏អាចបញ្ចូលតែចៅក្រមដែលសុទ្ធតែមិនមែនជាខ្មែរក៏បានដែរ ។ យើងខ្ញុំទទួលស្គាល់ថាមានចំណុចខ្សោយចំពោះការឱ្យមានតុលាការអន្តរជាតិទាំងស្រុងនេះ ។ ក៏ប៉ុន្តែ ដើម្បីភាពត្រឹមត្រូវនៃកិច្ចដំណើរការ វាគឺជាសញ្ញាសំគាល់នៃតុលាការរបស់អង្គការសហប្រជាជាតិ ហើយវាជាកត្តាចំបងញែកវាឱ្យដាច់ពីតុលាការកម្ពុជា ក្រុមយល់ឃើញថានេះគឺជាការចាំបាច់ដែលត្រូវតែធ្វើយ៉ាងដូច្នេះ ។ ព្រមជាមួយគ្នានេះដែរ យើងខ្ញុំសូមស្នើយោបល់ថា អង្គការសហប្រជាជាតិត្រូវស្វែងរកដោយសកម្មឱ្យបាននូវជនជាតិខ្មែរណាម្នាក់ដែលមានសមត្ថភាព មិនលំអៀង និងត្រឹមត្រូវ ។

១៦១- ចំពោះរដ្ឋអាជ្ញា និងបុគ្គលិករបស់គេវិញ បន្ទាប់បានធ្វើការពិចារណាដោយប្រុងប្រយ័ត្នមក យើងខ្ញុំយល់ឃើញថារដ្ឋអាជ្ញារបស់តុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទ័ណ្ឌអន្តរ-ជាតិសំរាប់ប្រទេសរ៉្វាន់ដា គួរតែយកមកប្រើជារដ្ឋអាជ្ញាសំរាប់តុលាការថ្មីនេះ ។ ទោះបីជាយើងខ្ញុំយល់ឃើញថាបញ្ហាខ្មែរក្រហមមានសារសំខាន់គ្រប់គ្រាន់ដើម្បីបញ្ជាក់អំពីភាពត្រឹមត្រូវនៃការប្រើរដ្ឋអាជ្ញាផ្ទាល់របស់ខ្លួននោះក៏ដោយ ក៏ទីបំផុតយើងខ្ញុំគាំទ្រគំរូនៃរដ្ឋអាជ្ញាដែលកំពុងត្រូវបានប្រើប្រាស់នៅក្នុងតុលាការទាំងនោះ ។ អត្តភាព និងបទពិសោធន៍របស់រដ្ឋអាជ្ញានៃតុលាកការដែលមានស្រាប់នោះ អាចនឹងយកមកប្រើប្រាស់សំរាប់ការកាត់ទោសថ្មីនេះបានល្អប្រសើរទៅបាននោះ លុះត្រាតែមនុស្សដដែលនេះអាចមើលការខុសត្រូវ និងទទួលខុសត្រូវបានក្នុងការរៀបចំបុគ្គលិករដ្ឋអាជ្ញាខ្មែរ ។ នៅពេលដែលបន្ទុកការងារដ៏ធ្ងន់ធ្ងររបស់បុគ្គលិករដ្ឋអាជ្ញា បច្ចុប្បន្ននៃតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេស រ៉្វាន់ដា មិនអាចអនុគ្រោះឱ្យបន្ថែមនូវការកាត់ទោសថ្មី ៧ ទៅក្នុងការទទួលខុសត្រូវរបស់ពួកគេទេនោះ ការចែករំលែកជំនាញរបស់ពួកគេប្រហែលជាអាចធ្វើទៅបានបើសិនជាបុគ្គលិកថ្មីធ្វើសេចក្តីរាយការណ៍ទៅជូនមនុស្សដដែលនោះ។ លើសពីនេះទៅទៀត យើងខ្ញុំយល់ឃើញថាភាពមិនប្រែប្រួលនៃនយោបាយចោទប្រកាន់ ក្នុងន័យធ្វើការយោងទៅលើតួអង្គពីខាងក្រៅនោះ (រដ្ឋ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល) សំរាប់ជាកិច្ចសហប្រតិបត្តិការ ការឆ្លើយតបទៅនឹងការស្នើសុំរបស់ចុងចោទ និងបញ្ហាដ៏ទៃទៀត គឺមានសារសំខាន់ណាស់ ។

១៦២- យើងខ្ញុំទទួលស្គាល់ និងយល់ស្រមអំពីលទ្ធភាពដែលថា រដ្ឋអាជ្ញារួមមួយ អាច ឬត្រូវទប់ស្កាត់មិនឱ្យលើកឡើងនូវទឡ្ហីករខ្លះនៅចំពោះមុខតុលាការអន្តរជាតិសំរាប់ប្រទេសកម្ពុជា ដើម្បីកុំឱ្យអន់ថយដល់គោលជំហរដែលបានលើកឡើងនៅចំពោះមុខតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី ឬតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា ។ ការនេះត្រូវតែប្រឆាំងជាដាច់ខាត ។ ការកាត់ទោសនៅកម្ពុជាត្រូវទទួលបាននូវអត្ថន័យដែលសមនឹងទទួលបាន ។ ទីបញ្ចប់យើងខ្ញុំយល់ឃើញថា វាជាការសំខាន់បំផុតដែលរដ្ឋអាជ្ញាត្រូវមានរដ្ឋអាជ្ញារងដែលមានសមត្ថភាពខ្ពស់ចាត់តាំងឡើងជាពិសេស សំរាប់ការកាត់ទោសនៅកម្ពុជា ដោយមានអំណាចសំខាន់ក្នុងការយកសេចក្តីសំរេចប្រចាំថ្ងៃ ។

១៦៣- វាគឺជាការមានប្រយោជន៍នឹងកត់សំគាល់ថា ការស្នើយោបល់របស់យើងខ្ញុំច្រានចោលជាមុននូវការជ្រើសរើសយកព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារងខ្មែរ ដែលនេះជាការសំរេចមួយមានសារសំខាន់បំផុត ដើម្បីផ្ដាច់ពួកគេចេញពីការគាបសង្កត់ខាងនយោបាយដូចដែលបានកត់សំគាល់ខាងលើនេះ និងផ្ដល់ដល់ពួកគេនូវឯករាជភាពក្នុងការធ្វើការចោទប្រកាន់ និងកាត់ទោសមនុស្ស ដែលពួកគេមើលឃើញថាសមស្របសំរាប់អត្ថប្រយោជន៍របស់យុត្តិធម៌ និងការបង្រួបបង្រួមជាតិ ។ ចំពោះការដាក់ជនកម្ពុជាជាបុគ្គលិករបស់រដ្ឋអាជ្ញានោះ យើងខ្ញុំយល់ថាការដាក់បញ្ចូលបុគ្គលិកបែបនេះគួរតែត្រូវឱ្យមាន ដោយសារថាពួកគេមិនអាចធ្វើឱ្យប៉ះពាល់ដល់ឯករាជភាពរបស់រដ្ឋអាជ្ញាបានទេ ។ ឧទាហរណ៍ ការនេះទាមទារឱ្យមានការធានាថា បុគ្គលិករបស់រដ្ឋអាជ្ញាអាចរក្សាបាននូវការសម្ងាត់របស់ការិយាល័យទាក់ទិនទៅនឹងមុខសញ្ញានៃការស៊ើបអង្កេត និងយុទ្ធ-សាស្ត្រសំរាប់ការកាត់ទោស ។ ការធ្វើការងារបានល្អប្រពៃរបស់បុគ្គលិកខ្មែរនៅក្នុងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា
អង្គការសិទ្ធិមនុស្សជាច្រើននិងមជ្ឈមណ្ឌល ឯកសារ
បញ្ជាក់ឱ្យឃើញថាពួកគេអាចរួមវិភាគទានដ៏សំខាន់មួយក្នុងការកាត់ទោស ។ ទោះបីជាយ៉ាងណាក៏ ដោយវាជាការពិតណាស់ ដែលថាជនកម្ពុជាអាចនឹងត្រូវទទួលការគាបសង្កត់តាមគ្រប់រូបភាពនោះ ។

## ៤- <u>ទីកន្លែង</u>

១៦៤- ទីកន្លែងរបស់តុលាការអន្តរជាតិ គឺស្ថិតនៅក្នុងចំណោមបញ្ហាសំខាន់បំផុតរបស់អង្គការសហប្រជាជាតិ និងជាការយកចិត្តទុកដាក់ដ៏ចំបងមួយរបស់ក្រុមអ្នកជំនាញការ ។ ក្រុមបានពិនិត្យពិចារណាលើជំរើស ៣ : ការកាត់ទោសនៅក្នុងប្រទេសកម្ពុជា ការកាត់ទោសនៅទីក្រុងឡាអេ ឬការកាត់ទោសនៅកន្លែងណាមួយដ៏ទៃទៀត ។

១៦៥- ជាគោលការណ៍ ការកាត់ទោសនៅក្នុងប្រទេសកម្ពុជា ផ្ដល់នូវចំណុចខ្លាំងដោយឡែកចំពោះកិច្ចដំណើរការ ។ ជនកម្ពុជាអាចបានឃើញទម្រង់ការកាត់ទោសនោះដោយផ្ទាល់ ប្រព័ន្ធផ្សាយពិតមានក្នុងស្រុកអាចនឹងធ្វើការផ្សព្វផ្សាយបានយ៉ាងពេញបន្ទុក ហើយអ្វី ៗ ដែលបានកើតឡើងនៅក្នុងជំនាន់ខ្មែរក្រហម

ត្រូវបាននាំមកដាក់នៅចំពោះមុខនៃការយកចិត្តទុកដាក់របស់មហាជន តាមរយៈការកាត់ក្តីមួយដែលមិនលំអៀង ។ ដូច្នេះ ការកាត់ទោសនៅក្នុងប្រទេសកម្ពុជា បញ្ជាក់ឱ្យឃើញថាមានសារសំខាន់ណាស់ចំពោះទិសដៅជាគន្លឹះមួយពោលគឺការទទួលខុសត្រូវ - ការលើកតម្កើងការបង្រួបបង្រួមជាតិ តាមរយៈការយល់អំពីអតីតកាល និងការចោទប្រកាន់ទៅលើពួកអ្នកទទួលខុសត្រូវនៃអំពើឃោរឃៅ ។ លើសពីទិសដៅនេះទៅទៀត ប្រទេសកម្ពុជាគឺជាទីកន្លែងដ៏ល្អប្រពៃយ៉ាងច្បាស់ ។

១៦៦- ប៉ុន្តែ កត្តាដ៏ទៃទៀតដែលទាញការយកចិត្តទុកដាក់របស់ក្រុម នៅក្នុងពេលបេសកកម្មរបស់ពួកគេនៅក្នុងប្រទេសកម្ពុជានោះ គឺការប្រយុទ្ធនឹងការកាត់ទោសនៅក្នុងប្រទេសកម្ពុជា ។ ទី ១ ក្រុមមានការព្រួយ បារម្ភថា ក្នុងករណីនៃប្រទេសកម្ពុជា ការធ្វើការកាត់ទោសនៅក្នុងបេះដូងនៃប្រទេសដែលអំពើឃោរឃៅ បានកើតមានឡើងនោះ វានឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់សន្តិសុខនៃទម្រង់ការកាត់ទោស ។ ក្រុមមានការ ព្រួយបារម្ភថា ទីកន្លែងកាត់ទោសអាចនឹងត្រូវប្រឈមមុខនឹងការគំរាមកំហែងពីក្រុមផ្សេង ៗ ដែលកាន់ជើង ម្ខាង ៗ ។ ជាការពិតហើយដែលថា បញ្ហាទាំងនេះអាចដោះស្រាយទៅបានតាមរយៈវត្តមានភ្នាក់ងារសន្តិសុខដ៏ចំនួនច្រើនរបស់អង្គការសហប្រជាជាតិ ដូចជាការការពារយ៉ាងមាំទាំបរិវេណរបស់តុលាការជាដើម ។

១៦៧- ទី ២ និងដែលសំខាន់ជាងនេះទៅទៀតនោះ ក្រុមមានការភ័យខ្លាចថាទីកន្លែងនៃតុលាការ នៅក្នុងកម្ពុជានឹងអាចជាកម្មវត្ថុនៃការគាបសង្កត់ដោយវិធីផ្សេង ៗ ពីសំណាក់កម្លាំងនយោបាយនៅក្នុងស្រុក ផ្សេង ៗ ។ ដូចបានថែងនៅក្នុងផ្នែកទី ៦ ខាងលើនេះស្រាប់ បញ្ហាលើកឡើងអំពីការកាត់ទោសពួកខ្មែរក្រហមមានការផុសផុលណាស់សព្វថ្ងៃនេះ ។ កម្លាំងនយោបាយផ្សេង ៗ អាចនឹងមានការប៉ះពាល់ដោយកិច្ចដំណើរការ និងលទ្ធផល នៃការកាត់ទោសណាមួយជាមិនខាន ។ ការនេះអាចសំដែងចេញជាការប៉ុនប៉ងទៅរកជួប ឬប្រើឥទ្ធិពលលើចៅក្រម ឬព្រះរាជអាជ្ញា ការបដិសេធតាមរូបភាពផ្សេង ៗ មិនព្រមសហការដ៏ចាំបាច់សំរាប់ឱ្យមានកិច្ចដំណើរការដោយត្រឹមត្រូវរបស់តុលាការនៅក្នុងប្រទេសកម្ពុជា ឬក៏រហូតដល់មានបញ្ហាធ្ងន់ធ្ងរជាងនេះថែមទៀតផង ។ ក្រុមយល់ឃើញថា កិច្ចសហប្រតិបត្តិការរបស់រដ្ឋាភិបាលគឺជាលក្ខណៈខានមិនបានសំរាប់ការកាត់ទោសដ៏មានជោគជ័យណាមួយនោះ ប៉ុន្តែយើងខ្ញុំយល់ឃើញថាជាការចាំបាច់ណាស់ដែលកិច្ចដំណើរការកាត់ទោសត្រូវរក្សាវាឱ្យដាច់ពីការជ្រៀតជ្រែកខាងនយោបាយជាដាច់ខាត ។

១៦៨- ដូចបានរៀបរាប់មកខាងលើនេះ ក្រុមមានការស្ទាក់ស្ទើរនឹងធ្វើសេចក្តីសន្និដ្ឋានថា ការកាត់ទោសនៅក្នុងប្រទេសកម្ពុជាគឺពោរពេញទៅដោយគ្រោះថ្នាក់ច្រើនពេក ហើយថាតុលាការរបស់អង្គការសហប្រជាជាតិមួយគួរតែស្ថិតនៅទីកន្លែងដ៏ទៃវិញ ។ ជាការគួរឱ្យកត់សំគាល់ថា មតិនេះក៏ជាមតិដែលបានសំដែងចេញមកដោយឯករាជ្យជូនដល់ក្រុមដោយជនកម្ពុជាមួយចំនួនផងដែរ ។

១៦៩- ទីកន្លែងទី ២ ដែលបានលើកឡើងជូនដល់ក្រុម ដោយគូសន្ទនានានារបស់យើង គឺទីក្រុងឡាអេដែលជាអាសនៈរបស់តុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី ក៏ដូចជាតុលាការអន្តរជាតិ និងអនាគតតុលាការព្រហ្មទ័ណ្ឌអន្តរជាតិផងដែរនោះ ។ ពួកអ្នកគាំទ្រឱ្យមានជំរើសនេះដល់យើងខ្ញុំ យល់ឃើញថាទីកន្លែងរបស់តុលាការអង្គការសហប្រជាជាតិនៅទីក្រុងឡាអេ នឹងផ្តល់ភាពស្របច្បាប់កំរិតខ្ពស់ ចំពោះភ្នែកនៃប្រជាពលរដ្ឋកម្ពុជា និងបង្ហាញឱ្យឃើញថាបញ្ហានេះត្រូវបានទទួលការយកចិត្តទុកដាក់ដោយហ្មត់ចត់ពីសំណាក់សហគមន៍អន្តរជាតិ ។ អ្នកខ្លះទៀតគិតថា ការកំណត់ទីកន្លែងឱ្យនៅជាមួយតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី នឹងជួយសន្សំសំចៃលុយកាក់ និងពេលវេលារបស់អង្គការសហប្រជាជាតិ ដោយសារទីកន្លែង និងបុគ្គលិកខ្លះអាចចែកគ្នាប្រើប្រាស់បាន ។ រីឯអ្នកខ្លះទៀតនៅតែគូសបញ្ជាក់ថា បើកម្ពុជាមិនមែនជាជំរើសមួយនោះទេ វាមិនចោទជាបញ្ហាថាតុលាការនោះត្រូវស្ថិតនៅកន្លែងណាទេ ដូច្នេះទីក្រុងឡាអេហាក់ដូចជាកន្លែងដ៏សមរម្យមួយហើយ ។

១៧០- ក្រុមបានយកចិត្តទុកដាក់ទស្សនៈទាំងនេះដោយប្រុងប្រយ័ត្នបំផុត តែទីចុងបំផុតមិនអាចស្នើយកទីក្រុងឡាអេថាជាទីកន្លែងដ៏ល្អប្រសើរបំផុតនោះទេ ។ ទី ១ យើងខ្ញុំមានសេចក្តីព្រួយបារម្ភថា ស្ថិតនៅឆ្ងាយពេកពីទីកន្លែងដែលអំពើឃោរឃៅបានកើតមានឡើង សំរាប់ធ្វើការកាត់ទោស ដើម្បីឱ្យមានឥទ្ធិពលដល់ប្រជាពលរដ្ឋ និងមេដឹកនាំរបស់គេ ។ ក្នុងន័យនេះ យើងខ្ញុំគាំទ្រហេតុផលរបស់ក្រុមប្រឹក្សាសន្តិសុខដែលបានដាក់តុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា នៅអាហ្វ្រិកខាងកើត ។ ទីកន្លែងនៃទីក្រុងឡាអេស្ថិតនៅតំបន់មួយដែលមានពេលម៉ោងខុសគ្នាយ៉ាងច្រើនពីប្រទេសកម្ពុជា ក៏នាំឱ្យមានការស្មុគស្មាញយ៉ាងខ្លាំងក្នុងការទទួលពិតមានតាមទូរទស្សន៍ និងវិទ្យុ សំរាប់ប្រជាពលរដ្ឋកម្ពុជា អំពីការកាត់ទោសនៅក្នុងពេលម៉ោងណាមួយឱ្យបានសមស្របនោះ ។ ទី ២ យើងខ្ញុំមិនជឿថាការដាក់ឱ្យនៅកន្លែងតែមួយជាមួយតុលាការ

ដែលមានស្រាប់មកហើយនោះ នឹងជួយសន្សំលុយកាក់បានច្រើននោះទេ ។ ទោះបីជាមានលទ្ធភាពយកបន្ទប់កាត់ក្តីដែលមានស្រាប់មកប្រើនៅពេលនោះក៏ដោយ ក៏តុលាការសំរាប់ប្រទេសកម្ពុជាអាចត្រូវការទីកន្លែងរបស់ខ្លួនមួយចំនួនដែរ ក្នុងនេះរួមមានទាំងបន្ទប់កាត់ក្តីថ្មីផង ។ ទីចាត់ការធំនៃតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី សព្វថ្ងៃសឹងតែត្រូវបានអង្គុយពេញទៅដោយបុគ្គលិករបស់តុលាការនោះទៅហើយ។ ដូចបានធ្វើការកត់សំគាល់ខាងលើស្រាប់ តុលាការថ្មីមួយនឹងត្រូវការចៅក្រម និងក្រុមរដ្ឋអាជ្ញា និងអ្នកស៊ើបអង្កេតផ្ទាល់របស់វា យើងមិនអាចត្រឹមតែខ្ចីពីតុលាការយូហ្គោស្លាវីបាននោះទេ ។

១៧១- សេចក្តីសន្និដ្ឋានចុងក្រោយរបស់ក្រុម បន្ទាប់ពីបានធ្វើការពិនិត្យពិច័យលើជំរើសទាំងអម្បាលម៉ានខាងលើនេះមក គឺថាទីកន្លែងដែលល្អបំផុតសំរាប់តុលាការអង្គការសហប្រជាជាតិ ត្រូវស្ថិតនៅក្នុងទីក្រុងនៃប្រទេសណាមួយនៃតំបន់អាស៊ី-ប៉ាស៊ីហ្វិក ។ តុលាការដែលស្ថិតនៅក្នុងទីក្រុងមួយបែបនេះ អាចធ្វើឱ្យប្រជាពលរដ្ឋកម្ពុជារក្សាបាននូវអត្ថន័យ ដែលថាការកាត់ទោសត្រូវបានធ្វើឡើងនៅក្នុងតំបន់នៃពិភពលោកផ្ទាល់របស់ពួកគេ ហើយឧទាហរណ៍ដូចជាថាវាមិនមែននៅឆ្ងាយដូចជាអឺរុបជាដើមនោះទេ ហើយការនេះនឹងអាចឱ្យប្រជាពលរដ្ឋកម្ពុជាអាចតាមដានបានយ៉ាងជិតស្និទ្ធ ។ នៅក្នុងពេលជាមួយគ្នានេះ ទីកន្លែងនេះស្ថិតនៅដាច់ពីការគាបសង្កត់ខាងនយោបាយនៃកម្ពុជាផង ។

១៧២- ចំពោះយើង មានលក្ខណៈសម្បត្តិមួយចំនួន ដែលទីក្រុងមួយបែបនេះអាចនឹងបំពេញបាន ដូចជាៈ ការស្ថិតនៅជិត និងស្រួលចេញចូលមកម្ពុជា អនុគ្រោះឱ្យបុគ្គលិករដ្ឋអាជ្ញា អ្នកស៊ើបអង្កេត និងមេធាវី និងសាក្សី អាចធ្វើដំណើរបានរហ័ស ពេលម៉ោងនៃកន្លែងប្រហាក់ប្រហែលគ្នានឹងនៅកម្ពុជាដែលជាការអនុគ្រោះឱ្យសហគមន៍កម្ពុជា អាចតាមដានការកាត់ទោសដោយផ្ទាល់ តាមរយៈប្រព័ន្ធផ្សាយពិតមានអេឡិចត្រូនិចក្នុងស្រុកបាន ហើយមានទីកន្លែង ហេដ្ឋារចនាសម្ព័ន្ធ និងទីកន្លែងស្នាក់នៅ ដែលងាយស្រួលនឹងទាក់ទាញចៅក្រមល្បីឈ្មោះនានានៃតុលាការអន្តរជាតិ និងមន្ត្រីស៊ីវិលអន្តរជាតិដ៏ទៃទៀត បាន ។ វាក៏ជាការងាយស្រួលផងដែរ បើសិនជាភាសាប្រើប្រាស់នៅក្នុងប្រទេសនោះជាភាសាមួយរបស់តុលាការ ហើយបើសិនជាប្រទេសនោះមានអ្នកប្រកបវិជ្ជាជីវៈខាងច្បាប់ដែលមានរៀបចំបានល្អ ដែលអាចផ្តល់ក្រុមប្រឹក្សាដល់ចុងចោទបាន ។ ប៉ុន្តែលក្ខណៈសំខាន់ជាងគេបំផុតគឺរដ្ឋនោះ មិនមែនជារដ្ឋមួយដែលត្រូវបានគេដឹង ជាពិសេសជនកម្ពុជា ថាធ្លាប់មានការជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយព្រឹត្តិការណ៍ក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ ។ ក្រុមសូម

ស្នើថា ដោយឈរលើលក្ខណៈសម្បត្តិទាំងនេះ អង្គការសហប្រជាជាតិ ត្រូវរកឱ្យបាននូវទីកន្លែងមួយបែបនេះ សំរាប់ដាក់ទីតាំងរបស់តុលាការ ។ ក្រុមមានសេចក្តីសង្ឃឹមយ៉ាងមាំថា រដ្ឋមួយចំនួនត្រូវលើកស្នើឡើង និងសុំ ឱ្យយល់ព្រមទទួលដាក់ទីតាំងរបស់តុលាការនេះ ។

១៧៣- បើសិនជាសេចក្តីស្នើយោបល់នេះត្រូវបានអនុម័តយកហើយនោះ វាជាការចាំបាច់ដែលអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ដោយសហការជាមួយប្រទេសទទួលឱ្យដាក់តុលាការនេះ បង្កើតឡើងនូវយន្តការដ៏មានប្រសិទ្ធភាពដើម្បីផ្សព្វផ្សាយអំពីការកាត់ក្តីសំរាប់ប្រទេសកម្ពុជា ។ ស្ថានីយវិទ្យុ និង ស្ថានីយទូរទស្សន៍មួយ ដែលមិនស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋាភិបាល ត្រូវបង្កើតឱ្យមានឡើង ។ វិធីនេះបានបញ្ជាក់ឱ្យឃើញថាមានសារសំខាន់ណាស់ នៅក្នុងរយៈពេលអ៊ុនតាក់ ដែលមានលទ្ធភាពអាចផ្សព្វផ្សាយពិតមានស្តីអំពីការបោះឆ្នោតដោយត្រឹមត្រូវ ក៏ដូចជាសាររបស់គណបក្សនយោបាយផ្សេង ៗ និងរៀបចំមូលដ្ឋានសំរាប់ការបោះឆ្នោត ដែលខ្លួនបានរៀបចំធ្វើនៅក្នុងខែឧសភា ឆ្នាំ ១៩៩៣ ។ (ជាផ្នែកមួយនៃការខិតខំនេះ រដ្ឋាភិបាលជប៉ុនបានផ្តល់វិទ្យុចាប់សម្លេងតូច ៗ រាប់ពាន់សំរាប់ចែកនៅទូទាំងប្រទេស) ។ បើគ្មានការផ្សព្វផ្សាយការជជែកវែកញែកឱ្យបានទូលំទូលាយទេនោះ បច្ច័យ និងផលប្រយោជន៍សំរាប់កម្ពុជានឹងត្រូវបាត់ បង់ ទោះបីជាធ្វើនៅកន្លែងណាក៏ដោយ ។

១៧៤- ជាទីបញ្ចប់ ក្រុមបានពិចារណារកទីកន្លែងដែលល្អបំផុតសំរាប់រដ្ឋអាជ្ញារង និងសមាជិករបស់រដ្ឋអាជ្ញា ដោយឈរលើអ្វីដែលបានរៀបរាប់មកខាងលើនេះ ។ (ពីព្រោះរដ្ឋអាជ្ញា គឺជារដ្ឋអាជ្ញាដដែលនៃតុលាការដែលមានស្រាប់ ការិយាល័យរបស់គេត្រូវតែស្ថិតនៅទីក្រុងឡាអេដដែល) ។ តាមយោបល់របស់យើងខ្ញុំ ការិយាល័យធំរបស់រដ្ឋអាជ្ញារង ត្រូវស្ថិតទីកន្លែងជាមួយតុលាការតែម្តង ជាជាងនៅឡាអេ ឬនៅកម្ពុជា ។ ការធ្វើដូច្នេះអាចបំរើទិសដៅជាគន្លឹះ ៣ ។ ទី ១ ការស្ថិតនៅជិតតុលាការ ការិយាល័យមានលទ្ធភាពអាចលើកឡើងនូវយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពសំរាប់ដឹកនាំការកាត់ក្តី ។ ទី ២ ការនេះជួយរួមចំណែកការពារការសម្ងាត់នៃឯកសារដែលការិយាល័យប្រមូលបាន ទប់ទល់នឹងការផ្សព្វផ្សាយដោយខុសច្បាប់ ឬការប៉ុនប៉ងកំទេចចោលឯកសារ ឬធ្វើឱ្យច្របូកច្របល់ដល់កិច្ចដំណើរការរបស់ការិយាល័យ ។ ទី ៣ វាកាត់បន្ថយបានយ៉ាងច្រើនលទ្ធភាពដែលភាគីមានពាក់ព័ន្ធនានានៃកម្ពុជា ប្រើឥទ្ធិពលទៅលើសេចក្តីសំរេចរបស់រដ្ឋអាជ្ញា

ទាក់ទិនទៅនឹងការចោទប្រកាន់ និងការកាត់ក្តី ដោយលទ្ធភាពទាំងនេះអាចកាត់បន្ថយបានយ៉ាងច្រើនបើទីកន្លែងរបស់រដ្ឋអាជ្ញាស្ថិតនៅក្រៅប្រទេសកម្ពុជា ទៅនៅទីក្រុងឡាអេនោះ ។

១៧៥- នៅក្នុងពេលជាមួយគ្នានេះ ក្រុមយល់ឃើញថាគឺជាការចាំបាច់ណាស់ដែលការិយាល័យរបស់រដ្ឋអាជ្ញាមានវត្តមានដ៏សំខាន់មួយនៅភ្នំពេញ តាមរយៈការបង្កើតការិយាល័យស៊ើបអង្កេតមួយនៅក្នុងទីក្រុងភ្នំពេញ។ ការិយាល័យនេះ ដែលមានបុគ្គលិកជាអ្នកស៊ើបអង្កេត ហើយជាការចាំបាច់ត្រូវមានរដ្ឋអាជ្ញាផងដែលមកប្រមូលផ្តុំគ្នានៅក្នុងប្រទេសកម្ពុជា ដើម្បីដឹកនាំកិច្ចដំណើរការធ្វើការស៊ើបអង្កេត ។ អង្គការសហប្រជាជាតិត្រូវផ្តល់សន្តិសុខដល់ពួកគេដោយប្រសិទ្ធភាព តែវិធានការទាំងនេះមិនសូវមានសារសំខាន់ទេបើសិនជាបុគ្គលិករដ្ឋអាជ្ញាទាំងអស់ត្រូវបានដាក់ឱ្យនៅទីនោះ ។

## ៥- កិច្ចដំណើរការតាមដំណាក់ ២

១៧៦- ដើម្បីជៀសវាងស្ថានភាពដែលអង្គការសហប្រជាជាតិចំណាយធនធានដ៏ច្រើន សំរាប់តុលាការមួយដែលក្រោយមករកមិនឃើញថាមានជនសង្ស័យនោះ ក្រុមសូមស្នើថាឱ្យអង្គការសហប្រជាជាតិធ្វើការជាដំណាក់ ២ ក្នុងដំណើរការរបស់តុលាការនេះ ។ បន្ទាប់ពីតែងតាំងរដ្ឋអាជ្ញារង និងអង្គភាពអ្នកស៊ើបអង្កេតការស៊ើបអង្កេតអាចចាប់ផ្តើមធ្វើ និងដាក់ជូននូវការចោទប្រកាន់ទៅក្រុមចៅក្រមចំពោះកិច្ចដ៏តូចមួយ ។ ចំនួនពេញលេញនៃចៅក្រមដែលបានគ្រោងទុកជាមុន នឹងចាប់ផ្តើមធ្វើការដោយពេញម៉ោងតែនៅក្រោយពេលចាប់ខ្លួនជនជាប់ចោទបានមួយចំនួនហើយប៉ុណ្ណោះ ។ កិច្ចដំណើរការដូចគ្នានេះ ត្រូវបានយកមកប្រើសំរាប់បង្កើតតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា ។

## ៦- អំពីថវិកា

១៧៧- តុលាការអង្គការសហប្រជាជាតិមួយត្រូវការមានថវិកាជាប់ជាបន្ត ដែលធានាផ្តល់ឱ្យដោយអង្គការសហប្រជាជាតិ តាមរយៈការរៃអង្គាសពីរដ្ឋជាសមាជិក ។ ដើម្បីសំរួលដល់ការចាប់ផ្តើមកិច្ចដំណើរការ របស់តុលាការ គឺជាការសំខាន់ណាស់ដែលត្រូវបង្កើតនូវមូលនិធិនៃវិភាគទានដោយស្មក្រចិត្ត ឬមូលនិធិដ៏ទៃផ្សេង

ទៀតណាមួយដែលបានមកពីការរួមវិភាគទានរបស់រដ្ឋ ឬបុគ្គលនានា ។ ពុំមានការសង្ស័យទេថា តុលាការមួយបែបនេះត្រូវការឱ្យមានធនធានច្រើន ដូចជាថវិការបស់តុលាការអន្តរជាតិសំរាប់អតីតប្រទេស យូហ្គោស្លាវី សំរាប់ឆ្នាំ ១៩៩៨ មានចំនួនរួម ៦៨ ៨២៩ ៨០០ ដុល្លារ ហើយថវិការបស់តុលាការព្រហ្មទ័ណ្ឌសំរាប់ប្រទេសរ៉ាន់ដា ៥៦ ៧៣៦ ៣០០ ដុល្លារ ។ ប៉ុន្តែ ក្រុមយល់ឃើញថា គេអាចសន្សំសំចៃប្រាក់បានយ៉ាងច្រើនចំពោះករណីនៃតុលាការសំរាប់ប្រទេសកម្ពុជា ពីព្រោះថាមុខសញ្ញានៃការស៊ើបអង្កេតហាក់ដូចជាមានចំនួនតិច ហើយនឹងហេតុផលដូចបានលើកឡើងនៅក្នុងអនុសាសន៍របស់យើងខ្ញុំនៅក្នុងផ្នែក X-A ខាងលើនេះ ។

## ៧- អនុសាសន៍

១៧៨- ការវិភាគខាងលើនេះ បរិយាយអំពីថាតើតុលាការអន្តរជាតិមួយត្រូវមានរចនាសម្ព័ន្ធយ៉ាងដូចម្តេចដើម្បីសំរេចឱ្យបាននូវទិសដៅយុត្តិធម ។ ក្រុមបានពិនិត្យពិច័្ឆយយ៉ាងប្រុងប្រយ័ត្នបំផុតនូវជំរើសនេះ ហើយយល់ឃើញថាវាគឺជាលទ្ធភាពដ៏ល្អបំផុតសំរាប់ការទទួលខុសត្រូវរបស់ពួកមេដឹកនាំខ្មែរក្រហម ហើយឆ្លើយតបប្រកបដោយប្រសិទ្ធភាពបំផុតទៅនឹងសេចក្តីស្នើសុំជំនួយពីអន្តរជាតិរបស់រដ្ឋាភិបាលកម្ពុជា កាលពីឆ្នាំ ១៩៩៧ កន្លងទៅនេះ ។ ជាការពិតហើយដែលថា ផ្នែកនៃការវិភាគរបស់យើងខ្ញុំ ដើម្បីលើកឡើងជាការស្នើជូនយោបល់នេះ មានលក្ខណៈជាអវិជ្ជមាន ដោយសារថាវាឈរលើការបដិសេធរបស់យើងខ្ញុំចំពោះជំរើសនៃការកាត់ទោសដោយតុលាការកម្ពុជា ដោយហេតុផលដូចបានចែងមកខាងលើនេះស្រាប់ ។ តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏វាជាការតម្រូវឱ្យក្រុមធ្វើការបញ្ជាក់ថាជំរើសនេះវាល្អប្រសើរជាងអ្វីដែលយើងខ្ញុំបានបដិសេធមុននេះ ហើយដែលគួរតែធ្វើតាម ទោះបីជាមានការលំបាកជាពិសេសផ្ទាល់របស់វាក៏ដោយ ។

១៧៩- ដើម្បីលើកឡើងនូវការស្នើយោបល់របស់ខ្លួនឱ្យបង្កើតតុលាការអន្តរជាតិមួយនោះ គឺក្រុមមានជំនឿជឿជាក់យ៉ាងដាច់ខាតថា មានតែតុលាការរបស់អង្គការសហប្រជាជាតិតែមួយប៉ុណ្ណោះទេ ដែលអាចស្ថិតនៅដាច់ដោយឡែកយ៉ាងពិតប្រាកដបាន ពីការតានតឹងនៃនយោបាយកម្ពុជាដូចដែលយើងខ្ញុំបាននិយាយដោយលំអិតនៅក្នុងផ្នែកទី ៤ ខាងលើនេះ ហើយដែលយើងខ្ញុំយល់ឃើញថា នៅទីចុងបំផុតវានឹងបញ្ជាក់អំពីជោគវាសនា ដែលកំណត់ទុកជាមុននៃការសំរេចរបស់តុលាការកម្ពុជានោះ ។ តុលាការអង្គការសហប្រជាជាតិមួយអាចបង្កើតបានដោយមានការគាំទ្ររបស់រដ្ឋាភិបាលកម្ពុជា តែពុំមានការទាមទារឱ្យរដ្ឋាភិបាលលើកឡើង

នូវការផ្ដួចផ្ដើមគំនិតផ្សេង ៗ ខាងផ្លូវច្បាប់ និងខាងផ្លូវរដ្ឋបាល ដែលអាចអនុគ្រោះឱ្យកត្តានយោបាយសំខាន់ ៗ ជ្រៀតជ្រែកចូល និងពន្យាពេលបញ្ហានោះបានឡើយ ។ ជាមួយតុលាការរបស់អង្គការសហប្រជាជាតិ នៅពេលដែលរដ្ឋាភិបាលកម្ពុជាបានផ្ដល់នូវសេចក្ដីយល់ព្រមរបស់ខ្លួនឱ្យបង្កើតតុលាការហើយនោះ បញ្ហាបុគ្គលិក និងកិច្ចប្រតិបត្តិការ គឺស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អង្គការសហប្រជាជាតិទាំងស្រុង ។ ទោះបីជាមានការទាមទារកិច្ចសហប្រតិបត្តិការនៃរដ្ឋាភិបាលកម្ពុជាក៏ដោយ ក៏វាមិនចាំបាច់ត្រូវធ្វើដោយផ្ទាល់ ក្នុងន័យវិជ្ជមាននោះទេ ។ ម្យ៉ាងទៀត មន្ត្រីរបស់អង្គការសហប្រជាជាតិមានភាពឯករាជ្យទាំងស្រុង ហើយស្ថិតនៅឆ្ងាយពីការគាបសង្កត់នៃនយោបាយក្នុងស្រុករបស់កម្ពុជា ។

១៨០- អតីតកាលសំខាន់ ៗ ចំនួន ២ ធ្វើឱ្យយើងខ្ញុំយកចិត្តទុកដាក់ចំពោះចំណុចនេះ ។ ទី ១ គឺការងាររបស់អ៊ុនតាក់ ពីឆ្នាំ ១៩៩២ ដល់ ១៩៩៣ ។ ពួកអ្នកវិភាគចំពោះប្រតិបត្តិការនោះ បានយល់ស្របគ្នាថា ផ្នែកដែលមានប្រសិទ្ធភាពជាងគេបំផុតរបស់អ៊ុនតាក់ គឺផ្នែកខាងការរៀបចំការបោះឆ្នោត ពីព្រោះផ្នែកនេះគឺជាផ្នែកតែមួយគត់ដែលមានអាណត្តិកំណត់ដោយច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ដោយឱ្យបំពេញការងារដោយម្ចាស់ការដោយខ្លួនឯង -ក្នុងការរៀបចំ និងការដឹកនាំការបោះឆ្នោត- ដោយមិនគិតគូរពីទស្សនៈរបស់ភាគីនយោបាយផ្សេង ៗ ឡើយ ហើយហេតុដូច្នេះវាមិនអាស្រ័យទៅលើការគាំទ្រដ៏សកម្មរបស់ពួកគេទេ[៨១] ។ ចំណែកផ្នែកផ្សេង ៗ ដ៏ទៃទៀតរបស់អ៊ុនតាក់ ដែលមានការងារទាក់ទងទៅនឹងជាមួយភាគីនយោបាយនោះ -មិនថានៅក្នុងវិស័យកងទ័ព រដ្ឋបាលស៊ីវិល ឬសិទ្ធមនុស្សទេ- តែងបានទទួលជោគជ័យតិចជាង នៅក្នុងការបំពេញកិច្ចការដែលមានចែងនៅក្នុងអាណត្តិរបស់ខ្លួន ។ ទី ២ ការខកខានរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការអនុមតិច្បាប់ព្រហ្មទ័ណ្ឌថ្មីមួយ ក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនេះ ចាប់តាំងពីពេលដែលអ៊ុនតាក់ចាកចេញទៅនោះ ទោះបីជាមានវត្តមានអ្នកជំនួយការពីអង្គការអន្តរជាតិ ពីរដ្ឋាភិបាលបរទេស និងអង្គការក្រៅរដ្ឋាភិបាល ក៏ដោយ ។ តាមទស្សនៈរបស់យើងខ្ញុំ មានតែតម្រូវដាក់ការទទួលខុសត្រូវទៅលើការបង្កើតតុលាការ តាមបំណងរបស់អង្គការសហប្រជាជាតិទេ ទើបកិច្ចដំណើរការយឺតយ៉ាវដូចគ្នា និងបន្ទុកនយោបាយដ៏ធ្ងន់ធ្ងរ អាចជៀសវាងទៅបាន ។

[៨១] សូមអាន រ៉ាតិណើរ (១៩៩៥) ដូចបានរៀបរាប់ខាងលើ ១៧៧-៨១ ម៉ៃខិល ដុល "អំណាច និងការបោះឆ្នោត នៅកម្ពុជា" នៅក្នុង ម៉ៃខិល ដុល អ៊ាន ចនស្តូន និង រ៉ូប៊ីត អិរ ការក្សាសន្តិភាពៈ ប្រតិបត្តិការពហុព្ហាយរបសលអង្គការសហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជា និង អែល សាល់វ៉ាឌ័រ ទំព័រ ១៣៤ ១៦១-៦៤ (រោងពុម្ព សកលវិទ្យាល័យ ឃែមប្រីដ្ស ឆ្នាំ ១៩៩៧) ។

១៨១- ពិតហើយ ក្រុមបានដឹងថា ទោះបីជាតុលាការរបស់អង្គការសហប្រជាជាតិក៏ដោយ ក៏នឹងត្រូវការកិច្ចសហប្រតិបត្តិការពីសំណាក់រដ្ឋាភិបាលកម្ពុជា នៅក្នុងវិស័យសំខាន់ ៧ ជាច្រើន ជាពិសេសការចាប់ខ្លួនចុងចោទ និងការធានាក្នុងការស្វែករកសាក្សី និងភស្តុតាង ជាដើម ។ វានឹងមិនមានកម្លាំងដែលមានស្ថេរភាពណាមួយនៅក្នុងប្រទេសកម្ពុជា ដើម្បីបំពេញកិច្ចការទាំងនេះបានទេ ។ ទោះបីយ៉ាងណាក៏ដោយ តាមទស្សនៈរបស់យើងខ្ញុំ តុលាការអាចធ្វើការបានល្អប្រសើរទៅបាន លុះត្រាតែវាស្ថិតនៅដាច់ពីនយោបាយក្នុងប្រទេស ។

១៨២- ដូចគ្នានេះដែរ ដែលធ្វើឱ្យយើងខ្ញុំកំណត់បាននូវពេលវេលា និងចំនួនទឹកប្រាក់ដ៏ចាំបាច់ សំរាប់បង្កើតឡើងនូវតុលាការរបស់អង្គការសហប្រជាជាតិមួយនោះ ។ ឈរលើបទពិសោធន៏របស់តុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ៉្វាន់ដា ការណ៏នេះអាចទាមទារពេលវេលាយ៉ាងហោចណាស់មួយឆ្នាំ ហើយប្រហែលជា ២ ឆ្នាំ ផង មុននឹងតុលាការអាចចាប់ផ្ដើមដំណើរការ និងមានលទ្ធភាពអាចកាត់ទោសចុងចោទបាន ។ ទាំងនេះហាក់ដូចជាត្រូវរង់ចាំពេលវេលាដ៏យូរមួយដើម្បីស្វែងរកយុត្តិធម ហើយវាអាចធ្វើឱ្យឃើញថា ប្រតិបត្តិការរបស់អង្គការសហប្រជាជាតិប្រព្រឹត្តទៅយឺតជាងតុលាការកម្ពុជា ។ (តុលាការអង្គការសហប្រជាជាតិមួយសំរាប់ប្រទេសកម្ពុជា អាចបង្កើតបានលឿនជាងតុលាករសំរាប់ប្រទេសយូហ្គោស្លាវី និងរ៉្វាន់ដា ហើយយើងនឹងធ្វើការស្នើយោបល់ចំពោះបញ្ហានេះ នៅក្នុងផ្នែក X.A ខាងក្រោមនេះ) ។ តែទោះបីជាវាត្រូវការពេលវេលា ២ ឆ្នាំពេញក៏ដោយ ក៏យ៉ាងហោចណាស់នៅទីចុងបំផុតទៅ សហគមន៏អន្តរជាតិនឹងដឹងដោយមានការទុកចិត្តខ្លះថា មានការរីកចំរើន និងថាតុលាការប្រាកដជានឹងដំណើរការបាន ។ បើសិនជាការទទួលខុសត្រូវត្រូវធ្លាក់មកលើប្រទេសកម្ពុជា ទោះបីជាមានការផ្ដល់ថវិកា និងបុគ្គលិកអន្តរជាតិជាដុំកំភួនយ៉ាងណាក៏ដោយ ក៏វាមានភាពមិនច្បាស់លាស់ថាតុលាការនោះ នឹងអាចដំណើរការបាននៅថ្ងៃណាមួយនោះឡើយ ។

១៨៣- ចំពោះការពាក់ព័ន្ធខាងហិរញ្ញវត្ថុវិញ តាមទស្សនៈរបស់យើងខ្ញុំ តម្លៃជាទឹកប្រាក់របស់តុលាការអង្គការសហប្រជាជាតិ អាចនឹងថ្លៃជាងទឹកប្រាក់ចាំបាច់សំរាប់វិនិយោគទៅក្នុងតុលាការកម្ពុជាមួយដែលជួយដោយវត្តមានអន្តរជាតិដ៏ច្រើនផងនោះ ។ ប៉ុន្តែ ការខុសគ្នាអាចនឹងមិនជាធំដុំប៉ុន្មានទេ ដោយធនធានអន្តរជាតិចាំបាច់សំរាប់ករណីទាំង ២ នេះអាចនឹងមានទំហំធំដូចគ្នា ។ យើងខ្ញុំយល់ឃើញថា វាអាចនឹងមាន

គ្រោះថ្នាក់តិចជាង ក្នុងការចំណាយប្រាក់កាសដោយឥតប្រយោជន៍ បើសិនជាអង្គការសហប្រជាជាតិបង្កើតតុលាការដោយខ្លួនឯង ជាជាងឱ្យរដ្ឋាភិបាលកម្ពុជាបង្កើតនោះ ។

១៨៤- ក្រុមទទួលស្គាល់ថា ការបង្កើតតុលាការចំពោះកិច្ចអន្តរជាតិមួយ នឹងតម្រូវឱ្យមានសុច្ឆន្ទៈនយោបាយ និងទឹកប្រាក់ ក្នុងនាមសហគមន៍អន្តរជាតិ ។ ចំពោះតួនាទីរបស់ប្រទេសកម្ពុជាវិញ យើងខ្ញុំសង្ឃឹមថារដ្ឋាភិបាលកម្ពុជា នឹងប្រកាន់ខ្ជាប់នូវស្មារតីនៃលិខិតចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៩៩៧ របស់ខ្លួន ជូនលោកអគ្គលេខាធិការ និងគាំទ្រដោយពេញទំហឹងនូវការបង្កើត និងកិច្ចដំណើរការ នៃតុលាកាបង្កើតឡើងដោយអង្គការសហប្រជាជាតិ ។

## គ- តុលាការកម្ពុជាមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិ

១៨៥- សេចក្តីស្នើទី ៣ ដែលក្រុមយកមកពិនិត្យពិចារណា គឺតុលាការបង្កាត់គ្នាមួយចេញមកពីគំរូទាំង ២ ខាងលើ ពោលគឺតុលាការបង្កើតឡើងតាមច្បាប់កម្ពុជា តែស្ថិតនៅក្រោមការត្រួតត្រា និងប្រតិបត្តិការរបស់អង្គការសហប្រជាជាតិ ។

១៨៦- ការបង្កើតឡើងនូវតុលាការមួយបែបនេះ នឹងត្រូវធ្វើឡើងដោយមធ្យោបាយនៃកិច្ចប្រតិបត្តិការខាងផ្លូវច្បាប់ពីរជាលំដាប់លំដោយ ។ ទី ១ អង្គការសហប្រជាជាតិ តាមរយៈលោកអគ្គលេខាធិការ ធ្វើឱ្យសំរេចឡើងនូវកិច្ចព្រមព្រៀងអន្តរជាតិមួយ ជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីកំណត់អំពីលក្ខន្តិកៈច្បាប់របស់តុលាការកាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ និងកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ។ ទី ២ រដ្ឋាភិបាលកម្ពុជា ត្រូវអនុម័តនូវច្បាប់មួយដើម្បីបង្កើតឡើងជាផ្លូវការនូវតុលាការនោះ ស្របតាមខ្លឹមសារនៃកិច្ចព្រមព្រៀងរបស់ខ្លួនជាមួយអង្គការសហប្រជាជាតិ ។ លក្ខន្តិកៈរបស់តុលាការ នឹងត្រូវដាក់ភ្ជាប់ជាឧបសម្ព័ន្ធនៃច្បាប់កម្ពុជា និងកិច្ចព្រមព្រៀងផងដែរ ។ យុត្តាធិការរបស់តុលាការមួយបែបនេះ អាចពង្រីកបានត្រឹមតែឧក្រិដ្ឋកម្មអន្តរជាតិ ត្រឹមតែឧក្រិដ្ឋកម្មនៅកម្ពុជា ឬក៏ឧក្រិដ្ឋកម្មទាំង ២ ប្រភេទនេះតែម្តង ។

១៨៧- ចំពោះកិច្ចដំណើរការរបស់តុលាការវិញ វាជាការសំខាន់ណាស់ដែលថា ដើម្បីរក្សាឱ្យបាននូវឯករាជភាពរបស់តុលាការ និងដោះស្រាយនូវសេចក្ដីព្រួយបារម្ភដូចដែលបានកត់សំគាល់ខាងលើនេះស្ដីអំពីការជ្រៀតចូលខាងនយោបាយនោះ អង្គការសហប្រជាជាតិត្រូវត្រួតត្រាលើកត្តាជាគន្លឹះខ្លះនៃកិច្ចដំណើរការរបស់តុលា-ការ ។ ទាំងនេះ រួមមានការសិរិតសំរាំងចៅក្រម និងការជ្រើសរើសរដ្ឋអាជ្ញា និងបុគ្គលិក ឯករាជភាពរបស់ពួកគេ ទីកន្លែងឃុំឃាំងជនជាប់ចោទ និងអ្នកទោស សន្តិសុខសំរាប់ចៅក្រម មេធាវី អ្នកស៊ើបអង្កេត អ្នកទោស និងសាក្សី ព្រមទាំងបញ្ហាសំខាន់ ៗ ដ៏ទៃទៀត សំរាប់ឯករាជភាពរបស់តុលាការ ។ ទីកន្លែង អាចជាកម្មវត្ថុនៃការចរចាគ្នា ទោះបីជាឈរលើមូលដ្ឋាននៃទស្សនៈដូចខាងលើនេះក៏ដោយ ក៏ការកាត់ទោសនៅក្រៅកម្ពុជា គួរតែជាការត្រូវជ្រើសរើសយកយ៉ាងច្បាស់លាស់ ហើយនៅក្នុងករណីនេះ ត្រូវឱ្យមានកិច្ចព្រមព្រៀងមួយជាមួយរដ្ឋដែលទទួលឱ្យដាក់តុលាការនេះ ។

១៨៨- តុលាការមួយបែបនេះមិនដែលមានទេពីមុនមក តែមូលដ្ឋានច្បាប់របស់វាមានភាពដូចគ្នានឹងស្ថាប័នដែលគាំទ្រដោយអង្គការសហប្រជាជាតិដ៏ទៃទៀត ដែលបង្កើតឡើងតាមរយៈនៃកិច្ចព្រមព្រៀងជាមួយរដ្ឋនានាជាសមាជិក ។ ទាំងនេះរួមមាន វិជ្ជាស្ថានអាស៊ី និងចុងបូពា សំរាប់បង្កាអំពើឧក្រិដ្ឋ និងប្រព្រឹត្តកម្មទៅលើជនល្មើសច្បាប់ វិជ្ជាស្ថានអាមេរិកឡាទីន សំរាប់បង្កាអំពើឧក្រិដ្ឋ និងប្រព្រឹត្តកម្មទៅលើជនល្មើសច្បាប់ វិជ្ជាស្ថានអន្តរជាតិសំរាប់មនុស្សចាស់ និងវិជ្ជាស្ថានអន្តរជាតិសំរាប់ថ្នាំបង្ការោគ[៨២] ។

១៨៩- ជំរើសនេះនឹងរិះរកការរួមបញ្ចូលគ្នានូវចំណុចខ្លាំងនៃតុលាការអង្គការសហប្រជាជាតិ ក្នុងន័យជាឯករាជភាពរបស់វា ជាមួយនឹងការភ្ជាប់មកការកាត់ទោសក្នុងស្រុកនៃកម្ពុជា ហើយនឹងជៀសវាងនូវឧបសគ្គផ្សេង ៗ ដែលអាចស្ថិតមានក្នុងការបង្កើតតុលាការអង្គការសហប្រជាជាតិមួយនោះ ។ ការនេះមិនមានការទាមទារឱ្យមានសេចក្ដីសំរេចចិត្តមួយរបស់ក្រុមប្រឹក្សាសន្តិសុខ ឬរបស់មហាសន្និបាតទេ ទោះបីជាលោកអគ្គលេខាធិការ អាចនឹងមានសំណូមពរឱ្យសាកសួរយោបល់របស់អង្គការទាំងនេះក៏ដោយ ។ ថវិកាត្រូវទទួល

---

[៨២] សូមមើល កិច្ចព្រមព្រៀង (រួមទាំងឧបសម្ព័ន្ធ) សំរាប់ទង្កើតវិជ្ជាស្ថានអាស៊ី និងចុងបូពា សំរាប់បង្កាអំពើឧក្រិដ្ឋ និងប្រព្រឹត្តកម្មទៅលើជនល្មើសច្បាប់ អង្គការសហប្រជាជាតិ-ជប៉ុន ថ្ងៃទី ១៥ ខែមីនា ឆ្នាំ ១៩៦១ អង្គការសហប្រជាជាតិ សេរីសន្ធិសញ្ញា សៀវភៅ ៣៩៧ លេខ ៥៧០៦ កិច្ចព្រមព្រៀងបង្កើតវិជ្ជាស្ថានអាមេរិកឡាទីន សំរាប់បង្កាអំពើឧក្រិដ្ឋ និងប្រព្រឹត្តទៅលើជនល្មើសច្បាប់ អង្គការសហប្រជាជាតិ-កូស្តារីកា ថ្ងៃទី ១១ ខែកក្កដា ឆ្នាំ ១៩៧៥ អង្គការសហប្រជាជាតិ សេរីសន្ធិសញ្ញា សៀវភៅ ៩៧៣ លេខ ១៤១០៧ ។

បានមកពីការរួមវិភាគទានដោយស្មគ្រចិត្ត ជាជាងតាមរយៈថវិកាផ្ទាល់របស់អង្គការសហប្រជាជាតិ។ លោកអគ្គលេខាធិការ ទទួលបន្ទុកធ្វើការជ្រើសរើសចៅក្រមពីក្នុងបញ្ជីឈ្មោះបេក្ខជន ដែលបានផ្តល់ជូនលោក ។ ទោះបីជាអង្គការសហប្រជាជាតិ រក្សាការត្រួតពិនិត្យលើការជ្រើសរើសក៏ដោយ ក៏បទបញ្ជាផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិ ដែលកំរិតចំនួនបុគ្គលិកដែលផ្តល់ឱ្យដោយរដ្ឋាភិបាលនានានោះ នឹងមិនត្រូវយកមកអនុវត្តទេ ធ្វើយ៉ាងដូច្នេះអាចនាំឱ្យការជ្រើសរើសបុគ្គលិក និងការបង្កើតតុលាការបានលឿន ហើយនឹងចំណាយថវិកាអស់តិច ។

១៩០- ក៏ប៉ុន្តែ ចំណុចខ្សោយនៃការស្នើមួយបែបនេះ គឺហាក់ដូចជាក្រុមឱ្យទម្ងន់ធ្ងន់ទៅលើចំណុចខ្លាំងណាមួយនោះ ។ ការព្រួយបារម្ភជាសំខាន់នោះគឺថា ការចរចាសំរាប់ឱ្យមានកិច្ចព្រមព្រៀងមួយ និងការរៀបចំ និងការអនុមតិច្បាប់ដោយរដ្ឋសភាកម្ពុជា អាចនឹងត្រូវអូសបន្លាយ ។ បញ្ហាជាច្រើនស្តីពីតួនាទីរបស់អង្គការសហប្រជាជាតិ គឺជាផ្នែកមួយនៃការចរចានេះ ហើយពុំមានការរីកចំរើនណាមួយអាចសំរេចបានទេ មុននឹងបញ្ហាទាំងត្រូវដោះស្រាយរួច។ រដ្ឋាភិបាលកម្ពុជា អាចទទូចលើបទបញ្ញត្តិដែលអាចធ្វើឱ្យប៉ះពាល់ដល់ឯករាជភាព របស់តុលាការ ។ សេចក្តីព្រួយបារម្ភដូចគ្នានេះ យើងបានសំដែងខាងលើមកហើយស្តីពីការយកតុលាការ កម្ពុជាមកអនុវត្តនៅទីនេះ ។ ផ្ទុយទៅវិញ សេចក្តីសំរេចិត្តមួយរបស់ក្រុមប្រឹក្សាសន្តិសុខ (ឬរហូតដល់របស់ មហាសន្និបាត) ហាក់ដូចជាធ្វើឱ្យកាន់តែមានការយឺតយ៉ាវថែមទៀត ។ ទោះបីជាសមាជិកក្រុមប្រឹក្សា ត្រូវការសាកសួរយោបល់របស់រដ្ឋាភិបាលកម្ពុជាក៏ដោយ ក៏បន្ទុកនៃការធ្វើដំណើរទៅមុខ នឹងត្រូវធ្លាក់មកលើក្រុមប្រឹក្សា ជាជាងមកលើរដ្ឋាភិបាលកម្ពុជា ។

១៩១- ម្យ៉ាងទៀត ភាពមានប្រៀបខ្លះដូចបានរៀបរាប់ខាងលើនេះ អាចមិនត្រឹមត្រូវទាំងអស់ទេ នៅក្នុងការជាក់ស្តែង ។ ទោះបីជាវាជាការពិតហើយដែលថាអង្គការសហប្រជាជាតិ អាចសន្សំសំចៃបានប្រាក់កាសខ្លះ ដោយអាចធ្វើការអំពាវនាវដោយទូលំទូលាយហៅរកបុគ្គលិកផ្ទាច់ខ្លួនខ្លះ ក៏តម្លៃរួមសំរាប់សហគមន៍អន្តរជាតិមិនជាថោកប៉ុន្មានដែរទេ ។ បុគ្គលិកអន្តរជាតិ នៅតែត្រូវការឱ្យមានចំនួនច្រើនជានិច្ច ហើយក្នុងនោះរួមមានចៅក្រម បុគ្គលិករដ្ឋអាជ្ញា អ្នកស៊ើបអង្កេតភាគច្រើន និងមួយចំនួនធំជាបុគ្គលិកជំនួយ ។

លទ្ធភាពប្រើប្រាស់បុគ្គលិកផ្ទាល់ខ្លួន នឹងអាស្រ័យទៅចំណែកនៃឆន្ទៈចូលរួមរបស់ប្រទេសផ្ដល់ជំនួយ ។ ករណីនេះនឹងធ្វើឱ្យលំនឹងនៃប្រតិបត្តិការមានភាពមិនប្រាកដ ។

១៩២- ទីបញ្ចប់ ក្រុមមិនបានត្រៀមខ្លួនដើម្បីងនុម័តយកជំរើសនេះទេ ។ យើងខ្ញុំទទួលស្គាល់ថា វាជាលទ្ធភាពមួយសំរាប់ឱ្យរដ្ឋជាសមាជិកអង្គការសហប្រជាជាតិយកទៅពិចារណា ។ ជំរើសទី ១ ខាងលើ គឺប្រាកដជាជំរើសដែលត្រូវទទួលយក ។ ប៉ុន្តែ វាហាក់ដូចជាបណ្ដាលឱ្យមានបច្ច័យដល់ការពន្យាពេលនៃភាពគ្មានទោសទ័ណ្ឌរបស់ពួកមេដឹកនាំខ្មែរក្រហម រហូតដល់ពួកចុងចោទមួយចំនួនធំស្លាប់បាត់បង់ជីវិត ឬក៏អ្វីដែលជាការអាក្រក់នោះ គឺការធ្វើឱ្យអង្គការសហប្រជាជាតិចូលរួមជាភាគីមួយក្នុងកិច្ចដំណើរការ ដែលជាការមិនអាចផ្ដល់យុត្តិធម៌បានដោយមិនលំអៀងបាន ។

## ឃ- តុលាការអន្តរជាតិបង្កើតឡើងដោយសន្ធិសញ្ញាពហុភាគី

១៩៣- ជំរើសនេះនឹងនាំទៅឱ្យមានការបង្កើតតុលាការមួយ តាមគំរូតុលាការយោធាអន្តជាតិនូរំប៊ែរ តាមរយៈសន្ធិសញ្ញាមួយរវាងរដ្ឋមានពាក់ព័ន្ធនានា[៨៣] ។ ក្នុងករណីនៃប្រទេសកម្ពុជា នេះអាចជាការរួមបញ្ចូលគ្នាមួយនៃរដ្ឋទាំងឡាយនៅក្នុងតំបន់ ដែលចាំបាច់ត្រូវមានកិច្ចសហប្រតិបត្តិការ ដើម្បីធ្វើឱ្យតុលាការអាចដំណើរការទៅបានដោយប្រសិទ្ធភាព ហើយនឹងរដ្ឋមានពាក់ព័ន្ធដ៏ទៃទៀត ដែលអាចនឹងត្រូវសុំឱ្យចូលរួមចំណែកជាធនធានខាងថវិកា និងបុគ្គលិក ។ ទាំងនេះធ្វើឱ្យជៀសវាងបាននូវការបង្កើតតុលាការអង្គការសហប្រជាជាតិថ្មីមួយបាន ។ ក្រុមមិនមានសំណូមពរឱ្យជ្រើសរើសយកជំរើសនេះទេ ពីព្រោះយើងខ្ញុំមានការស្ទាក់ស្ទើរអំពីលទ្ធភាពដែលមានការយល់ព្រមគ្នារវាងរដ្ឋជាច្រើន ចំពោះរូបភាពនៃតុលាការមួយបែបនេះនោះ ។ ការចរចាដ៏វែងអន្លាយអាចនឹងមិននាំទៅឱ្យទទួលបានលទ្ធផលណាមួយបានឡើយ ។ ការវិភាគនេះគឺជាមូលដ្ឋានសំរាប់ស្នើយោបល់របស់លោកអគ្គលេខាធិការជូនដល់ក្រុមប្រឹក្សាសន្តិសុខ នៅក្នុងឆ្នាំ ១៩៩៣-១៩៩៤ ដែលនាំទៅឱ្យមានការបង្កើតតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទ័ណ្ឌអន្តរជាតិ

---

[៨៣] សូមមើលកិច្ចព្រមព្រៀងសំរាប់ការកាត់ទោស និងការផ្ដន្ទាទោសឧក្រិដ្ឋករសង្គ្រាមធំ ៗ នៃអ័ក្សអឺរ៉ុប ថ្ងៃទី ៨ ខែសីហា ឆ្នាំ ១៩៤៥ អង្គការសហប្រជាជាតិ-សៀវភៅសន្ធិសញ្ញា សៀវភៅ ៨២ លេខ II ២៥១ ។

សំរាប់ប្រទេសរ៉្វាន់ដា ដោយសេចក្តីសំរេចចិត្ត របស់ក្រុមប្រឹក្សាសន្តិសុខ គឺមិនមែនដោសន្ធិសញ្ញាទេ ហើយយើងខ្ញុំយល់ឃើញថាការវិភាគនេះ អាចយកមកប្រើប្រាស់បានដូចគ្នានៅទីនេះផងដែរ ។

## ង- ការកាត់ទោសនៅក្នុងរដ្ឋដ៏ទៃ

១៩៤- ជំរើសទី ៥ ដែលត្រូវបានលើកយកមកពិនិត្យដោយក្រុម គឺការកាត់ទោសពួកមេដឹកនាំខ្មែរក្រហមដោយ និងនៅក្នុងរដ្ឋណាមួយដ៏ទៃទៀតក្រៅពីកម្ពុជា ។ ការកាត់ទោសបែបនេះ អាចប្រព្រឹត្តទៅបានតែនៅក្នុងក្របខ័ណ្ឌនៃច្បាប់អន្តរជាតិ តាមទ្រឹស្តីនៃយុត្តាធិការសកលដែលផ្តល់ឱ្យរដ្ឋនិមួយ ៗ នូវសិទ្ធិធ្វើការចោទមនុស្សពីបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទព្រហ្មទ័ណ្ឌជាអន្តរជាតិដ៏ទៃទៀតដោយមិនគិតពីឧក្រិដ្ឋកម្មទាំងនោះកើតនៅទីកន្លែងណា ឬសញ្ជាតិរបស់ជនជាប់ចោទ ឬអ្នករងគ្រោះទេ[៨៤] ។ ការកាត់ទោសអាចប្រព្រឹត្តទៅបាន តែនៅក្នុងរដ្ឋដែលមានលក្ខន្តិកៈព្រហ្មទ័ណ្ឌអនុញ្ញាតឱ្យមានយុត្តាធិការជាសកលបែបនេះ ឬបើពុំដូច្នោះទេអាចអនុវត្តន៏ច្បាប់ព្រហ្មទ័ណ្ឌធម្មតារបស់ខ្លួន ចំពោះករណីទាំងឡាយណាដែលពុំមានចំណងអ្វីមួយរវាងរដ្ឋដែលត្រូវយកធ្វើជាកន្លែងកាត់ទោស និងទីកន្លែងដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តឡើង សញ្ជាតិរបស់ជនរងគ្រោះ ឬរបស់ជនជាប់ចោទ ។ បើសិនជាជនជាប់ចោទ ឬជនរងគ្រោះ ជាជនជាតិនៃរដ្ឋនោះ មូលដ្ឋានដ៏ទៃទៀតនៃយុត្តាធិការ ក៏អាចអនុវត្តន៏បានដូចគ្នា ។

១៩៥- ក្រុមបានដឹងថា លក្ខន្តិកៈច្បាប់ព្រហ្មទ័ណ្ឌនៃរដ្ឋមួយចំនួន ហាក់ដូចជាអនុញ្ញាតឱ្យកាត់ទោសពួកអ្នកប្រព្រឹត្តបទល្មើសព្រហ្មទ័ណ្ឌខ្មែរក្រហមបាន ។ រដ្ឋទាំងនេះជាច្រើនមានប្រព័ន្ធតុលាការដែលមានប្រសិទ្ធភាពខ្ពស់ ក្នុងន័យជាលក្ខណៈវិនិច្ឆ័យដូចដែលយើងខ្ញុំបានធ្វើការកត់សំគាល់ខាងលើក្នុងផ្នែក VIII. A.2 ។ ក្នុងន័យនេះ តុលាការទាំងនេះចាត់ទុកថាគឺជាទីកន្លែងដែលមានស្រាប់ដើម្បីធ្វើការកាត់ទោសដែលមិនតម្រូវឱ្យមានការលំបាកខាងរដ្ឋបាល និងខាងនយោបាយ ក្នុងការបង្កើតតុលាការអន្តរជាតិ ឬជាតិឡើយ ។ ការដឹកជញ្ជូន

---

[៨៤] អេចឆ្នាន់ របាយការណ៏ច្បាប់អន្តរជាតិ សៀវភៅ ៣៦ ទំព័រ ២៦-៥៧ ២៧៩-៣០៤ បញ្ហោបត្យប័ន របស់ដាំហ្សង់ហ្សុក អ្នករាយកាណ៏សហព័ន្ធ ទី ២ សៀវភៅ ៧៧៦ ទំព័រ ៥៧១ ៥៨២-៨៣ ( ទី៦ ១៩៨៥) កាសែតអាមេរីកាំង ស្តិពីច្បាប់អន្តរជាតិ (១៩៩៨) សៀវភៅ ៩២ ទំព័រ ៧៨ (តុលាការយោធា ផ្នែកទី ១ ប្រទេសស្វីស ឆ្នាំ ១៩៩៧) អយ្យការសាធារណៈ ហ្សាហ្សិក កាសែតអាមេរីកាំង ស្តីពីច្បាប់អន្តរជាតិ សៀវភៅ ៩២ ទំព័រ ៥២៨ (ឆ្នាំ ១៩៨) (តុលាការកំពូល បាវ៉ារីយ៉ាន់ ប្រទេសអាល្លឺម៉ង់ ឆ្នាំ ១៩៩៧) ។

សាក្សី អាចមិនសូវគ្រស្នាញជាងអ្វីដែលបានជួបប្រទះនៅក្នុងតុលាការរបស់អង្គការសហប្រជាជាតិមួយនោះឡើយ ។ ចំពោះតម្លៃវិញ ទោះបីវាជាការមិនសមគួរក្នុងការកំណត់តម្លៃរបស់តុលាការនៅក្នុងរដ្ឋណាមួយនោះ ក៏សហគមន៍អន្តរជាតិអាចនឹងផ្តល់ជំនួយជាជុំកំភួនបានដល់តុលាការនេះ តាមរយៈនៃការផ្តល់ជំនួយជាទឹកប្រាក់ ឬជាបុគ្គលិក ។

១៩៦- ក៏ប៉ុន្តែ យើងមិនស្នើសុំឱ្យប្រើប្រាស់ប្រព័ន្ធតុលាការរបស់រដ្ឋបែបនេះជាវេទិកាសំខាន់សំរាប់ធ្វើការកាត់ទោសទេ ពីព្រោះយើងខ្ញុំគិតថា ការទទួលខុសត្រូវចំពោះការកាត់ទោសបែបនេះ គឺស្ថិតនៅក្នុងដៃរបស់រដ្ឋាភិបាលកម្ពុជា និងសហគមន៍អន្តរជាតិទាំងមូលតែម្តង ។ ម្យ៉ាងទៀត ទោះបីជាក្រុមមានជំនឿទៅលើសារសំខាន់នៃយុត្តាធិការជាសកលយ៉ាងណាក៏ដោយ ក៏យើងខ្ញុំគិតថាក្នុងករណីនៃប្រទេសកម្ពុជា សារដែលត្រូវបញ្ជូនទៅកាន់ប្រជាពលរដ្ឋកម្ពុជា ដែលជាកត្តាមួយសំខាន់បំផុតនៃរឿងក្តីរបស់ពួកខ្មែរក្រហមនេះ វានឹងបន្ទោយបើសិនជារឿងក្តីនេះធ្វើឡើងនៅចំពោះមុខតុលាការ ដែលមិនមែនជាតុលាការកម្ពុជា ឬអន្តរជាតិតែនៅក្នុងប្រទេសទី ៣ ណាមួយទៅវិញនោះ ។ ពិតហើយ យើងអាចប្រមើលមើលថារដ្ឋណាមួយអាចបង្កើតតុលាការអន្តរជាតិមួយស្របតាមច្បាប់ផ្ទៃក្នុងរបស់រដ្ឋនោះបានដែរ ដើម្បីធ្វើកាតកាត់ទោសខ្មែរក្រហមនោះ តែសេចក្តីផ្តើមគំនិតមួយបែបនេះមិនធ្លាប់ដែលមានទេពីអតីតកាល ហើយយើងខ្ញុំមើលឃើញថាវាហាក់ដូចជាមិនជាក់ស្តែងទេ ។

១៩៧- ទោះបីជាយ៉ាងណាក៏ដោយ ក្រុមយល់ឃើញថា នៅពេលដែលមិនអាចមានតុលាការអង្គការសហប្រជាជាតិទេនោះ បើសិនជារដ្ឋនានារកឃើញថាគេឃើញពួកអ្នកប្រព្រឹត្តបទល្មើសខ្មែរក្រហមនៅលើទឹកដីរបស់គេនោះ នៅពេលនោះពួកគេអាចធ្វើការចោទប្រកាន់ពួកខ្មែរក្រហមទាំងនោះតាមច្បាប់ព្រហ្មទណ្ឌរបស់គេបាន ដោយរួមទាំងអាចបង្កើតច្បាប់មួយឡើងដើម្បីធ្វើឱ្យតុលាការរបស់គេអាចមានយុត្តាធិការទៅលើមនុស្សទាំងនេះបាន ឬមួយក៏គេអាចបញ្ជូនមនុស្សទាំងនេះទៅកាន់រដ្ឋណាមួយដែលសុខចិត្តធ្វើការងារនេះ ។ ម្យ៉ាងទៀត ក្រុមមិនមានបំណងបន្ទុចបង្អាក់ការសំរុះសំរួលទាំងឡាយណា ដែលអនុគ្រោះឱ្យផ្ទេរជនជាប់ចោទទៅកាន់រដ្ឋទាំងនេះដើម្បីធ្វើការកាត់ទោសនោះទេ ។

## IX- រូបភាពដ៏ទៃទៀត នៃការទទួលខុសត្រូវរបស់បុគ្គល

១៩៨- តាមពន្លឺនៃការបកស្រាយរបស់ក្រុម ចំពោះអាណត្តិរបស់ខ្លួន ដូចដែលបានរៀបរាប់នៅក្នុងផ្នែកទី ២ ខាងលើនេះ យើងខ្ញុំបានពិចារណាទៅលើរូបភាពដ៏ទៃទៀតមួយចំនួននៃការទទួលខុសត្រូវរបស់បុគ្គល ក្រៅពីការធ្វើការកាត់ទោសពីបទព្រហ្មទ័ណ្ឌ ។

## ក- គណៈកម្មការស៊ើបអង្កេត

១៩៩- គណៈកម្មការស៊ើបអង្កេត គណៈកម្មការសាកសួរ និងគណៈកម្មការស្វែងរកការពិត បានលេចចេញឡើងនៅក្នុងរយៈពេល ១៥ ឆ្នាំ ចុងក្រោយនេះ ជាយន្តការដ៏មានសារសំខាន់បំផុត ដើម្បីការបង្រួបបង្រួមជាតិ ។ តាមរយៈនៃកិច្ចដំណើរការមួយ ដែលជនរងគ្រោះពីអំពើឃោរឃៅ ហើយនឹងនៅក្នុងករណីខ្លះ អ្នកប្រព្រឹត្តនិយាយការពិតទាំងអស់នោះ គណៈកម្មការទាំងនេះបានរួមចំណែកផ្តល់ពិតមានដល់សាធារណៈជននូវសេចក្តីលំអិតនៃដំណាក់កាលដ៏ខ្មៅងងឹតមួយនៃប្រវត្តិសាស្ត្ររបស់ប្រទេសមួយ និងផ្សះរបួសរបស់ជនរងគ្រោះ និងរបស់សង្គមជាទូទៅ ។ ដោយសារថាជាទូទៅ ការយកចិត្តទុកដាក់របស់ពួកគេប្រមូលផ្តុំទៅតែលើដំណាក់កាលនៃប្រវត្តិសាស្ត្រមួយ និងមិនមែនទៅតែលើតួនាទីរបស់ជនជាប់ចោទមួយចំនួនតូចទេនោះ គណៈកម្មការបែបនេះអាចបានត្រឹមតែគូសវាសនូវរូបភាពមួយ ដ៏ទូលំទូលាយនៃព្រឹត្តិការណ៍ទាំងឡាយដែលបានកើតឡើងនៅក្នុងដំណាក់លាកនោះតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ គណៈកម្មការបែបនេះ មិនអាចកំណត់អំពីពិរុទ្ធភាពតាមផ្លូវតុលាការបានទេ ហើយយើងខ្ញុំមានទស្សនៈថាគណៈកម្មការទាំងនេះមិនអាចជំនួសការកាត់ទោសតាមផ្លូវតុលាការនៅក្នុងប្រទេសកម្ពុជា ដើម្បីដើរដល់ទិសដៅនៃយុត្តិធម៌ និងការទទួលខុសត្រូវ និងបិទជំពូកនេះបានទេ ។

២០០- ប៉ុន្តែ គណៈកម្មការអាចបំរើនូវផលប្រយោជន៍ដ៏មានសារសំខាន់ខ្លះ នៅក្នុងប្រទេសកម្ពុជាបាន ។ តាមរយៈការនិយាយអំពីព្រឹត្តិការណ៍ទាំងឡាយ ឱ្យទៅហួសពីអ្វីដែលពាក់ព័ន្ធតែទៅលើចុងចោទតែមួយមុខនោះ ក្នុងនេះរួមមានក្របខ័ណ្ឌប្រវត្តិសាស្ត្រនៃអំពើឃោរឃៅ និងតួនាទីរបស់ពួកអ្នកប្រព្រឹត្តជាច្រើនរូប គណៈកម្មការនេះអាចជួយធ្វើឱ្យសំរេចបាននូវទិសដៅអប់រំ ចិត្តសាស្ត្រ នយោបាយ និងយុត្តិធម៌ ដូចដែលយើងខ្ញុំបានរៀបរាប់យ៉ាងពិស្តានៅក្នុងសេចក្តីផ្តើមនៃរបាយការណ៍នេះ ។ ដោយបានស្តាប់ និងបានស្គាល់ជន

រងគ្រោះ យ៉ាងដូច្នេះ គណៈកម្មការអាចផ្តល់ដល់ពួកគេ នូវរូបភាពមួយនៃការដោះស្រាយខាងផ្លូវចិត្តបានខ្លះ ។ តួនាទីរបស់គណៈកម្មការ ក្នុងការរៀបចំឡើងនូវអនុសាសន៍ ទាក់ទិនទៅនឹងវិធីដើម្បីការពារសិទ្ធិមនុស្សនាពេលអនាគត ក៏ហាក់ដូចជាមានសារសំខាន់ជាពិសេសសំរាប់ប្រទេសកម្ពុជាផងដែរ ។

២០១- ការដែលអំពើឃោរឃៅរបស់ពួកខ្មែរក្រហម ត្រូវគេដឹងយ៉ាងទូលំទូលាយនោះ មិនបានបន្ថយនូវផលប្រយោជន៍នៃតួនាទីរបស់គណៈកម្មការមួយនោះទេ ។ ទោះបីជាទិដ្ឋភាពទូទៅនៃឧក្រិដ្ឋ ត្រូវបានដឹងច្បាស់ហើយក៏ដោយ ក៏គេរកមិនទាន់ឃើញតាមរយៈប្រភពតែមួយ នូវការរៀបរាប់ព្រឹត្តការណ៍ដោយពិស្ដា គួរឱ្យជឿទុកចិត្តបាន និងមិនលំអៀង ក្នុងនេះរួមទាំងការសំគាល់អត្តសញ្ញាណច្បាស់លាស់នៃអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម និងជនរងគ្រោះផង ។ សាធារណរដ្ឋប្រជាមានិតុកម្ពុជាបានធ្វើការកាត់ទោសដោយកំបាំងមុខ លើឈ្មោះ ប៉ុល ពត និងអៀង សារីកាលពីឆ្នាំ ១៩៧៩ ដោយខ្វះនូវភាពជឿទុកចិត្តបានពីព្រោះកាលៈទេសៈពេលនោះ ត្រូវបានគេបង្ខិល ។ អង្គការសហប្រជាជាតិ មិនដែលបានធ្វើការសិក្សាជាផ្លូវការណាមួយទាល់តែសោះអំពី អំពើឃោរឃៅនេះ ។ របាយការណ៍របស់អនុគណៈកម្មការស្តីពីការបង្កាការរើសអើង និងការការពារជនជាតិ ភាគតិចរបស់គណៈកម្មការសិទ្ធិមនុស្ស នាឆ្នាំ ១៩៧៨ គ្រាន់តែជាការប្រមូលពិតមានផ្តល់ឱ្យដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានាតែប៉ុណ្ណោះ ។ ការមិនយល់ស្របគ្នាលើទិដ្ឋភាពជាច្រើននៃយុគសម័យខ្មែរក្រហម នៅតែស្ថិតមាននៅឡើយ ក្នុងនេះរួមមានការមិនឯកភាពគ្នាលើចំនួនមនុស្សដែលត្រូវបានសម្លាប់ផង។ ពួកខ្មែរក្រហម បានធ្វើយុទ្ធនាការបំភ្លែពិតមាន ស្តីពីអំពើឃោរឃៅរបស់ខ្លួនកាលពីអតីតកាល ហើយគណបក្សនយោបាយនានា បានធ្វើការបកស្រាយប្រវត្តិសាស្ត្រតាមតែការនឹកឃើញរបស់ខ្លួន ។ម្យ៉ាងទៀត ដូចដែលបានធ្វើការកត់មកហើយ កិច្ចដំណើរការនៃការសួរចម្លើយសាក្សី គឺសំរាប់តែផលប្រយោជន៍ចំពោះខ្លួនគេ និងចំពោះសង្គមតែប៉ណ្ណោះ ។

២០២- ក្នុងពេលទស្សនៈកិច្ចនៅកម្ពុជា ក្រុមបានលើកឡើងនូវគំនិតនៃគណៈកម្មការស៊ើបអង្កេតនេះជាមួយ សហភាគីខាងខ្មែររបស់យើង ទាំងក្នុងរដ្ឋាភិបាល ទាំងក្រៅរដ្ឋាភិបាល ។ ជាទូទៅប្រតិកម្មមានភាពមិន ច្បាស់លាស់ ។ ភាគច្រើនហាក់ដូចជាយល់មិនច្បាស់កិច្ចការរបស់គណៈកម្មការ ភាគច្រើននិយាយថាពួកគេ មិនជំទាស់នឹងគណៈកម្មការនេះទេ តែថាអាទិភាពសំរាប់ប្រទេសកម្ពុជា

គឺការកាត់ទោសពួកខ្មែរក្រហម

ហើយថាគណៈកម្មការមួយមិនអាចយកមកប្រើជំនួសសំរាប់ធ្វើការកាត់ទោសនោះបានទេ ។ មានមនុស្សភាគតិចណាស់ដែលគាំទ្រគំនិតនេះ ហើយពុំមាននរណាម្នាក់បញ្ជាក់ចំពោះយើងខ្ញុំ អំពីការយល់ស្របរបស់ពួកគេទេ ។ ទស្សនៈទាំងនេះ ដែលលេចចេញមកពីប្រភេទមនុស្សដែលបានទទួលការអប់រំ និងទទួលពិតមានខាងនយោបាយច្រើនជាងគេនៅក្នុងសង្គមកម្ពុជា នាំឱ្យយល់ថាជនកម្ពុជាភាគច្រើន មិនយល់អំពីអ្វីដែលជាទិសដៅរបស់គណៈកម្មការ និងទំនាក់ទំនងរបស់វាជាមួយការកាត់ទោសទេ ។

២០៣-ក្រៅពីចំណុចដែលបានលើកឡើងជាមួយសហភាគីខាងកម្ពុជារបស់ពួកគេ ក្រុមមានការចាប់អារម្មណ៍បន្ថែមទៅលើបញ្ហាគណៈកម្មការនេះ ។ ទី១ យើងខ្ញុំមិនជឿថាជនកម្ពុជាខ្លួនឯង បានត្រៀមខ្លួន ដើម្បីចូលរួមក្នុងកិច្ចដំណើរការដែលនឹងចាត់ឱ្យមានឡើងដោយគណៈកម្មការឬយ៉ាងណាទេ ឧទាហរណ៍ ការធ្វើឧទ្ទេសនាមព្រឹត្តិការណ៍នានានៃដំណាក់កាលនោះដោយសាក្សីជាច្រើននាក់ជាដើម ។ អ្នកខ្លះអាចនឹងមានការភ័យខ្លាចពួកអតីតអ្នកប្រព្រឹត្តបទល្មើស ដែលកំពុងស្ថិតនៅក្នុងភូមិរបស់គេនៅឡើយនោះ អ្នកខ្លះទៀតអាចនឹងមានផលប្រយោជន៍នឹងមិននិយាយការពិត ។ ជាការពិតហើយដែលឧបសគ្គទាំងនេះក៏ត្រូវបានជួបប្រទះនៅក្នុងរឿងក្តីព្រហ្មទ័ណ្ឌនានាដែរ តែតួនាទីរបស់មេធាវី អ្នកស៊ើបអង្កេត ចៅក្រម ហើយ បើសិនជាចាំបាច់វិធានការ នានាដើម្បីការពារសាក្សីអាចជួយរួមចំណែកក្នុងការដោះស្រាយទាំងនេះបានខ្លះ ។ គណៈកម្មការមួយ មិន ត្រូវរំលោភសាក្ខីភាពរបស់ពួកអ្នកប្រព្រឹត្តបទឧក្រិដ្ឋទេ តែបើសិនជាគណៈកម្មការត្រូវការសាក្ខីភាពមួយបែប នេះនោះ គណៈកម្មការត្រូវគិតគូរអំពីអ្វីដែលថាក្នុងការអនុវត្តន៍ គណៈកម្មការទាំងអស់មិនសុទ្ធតែទទួលបាន នូវចម្លើយសារភាពទាំងអស់នោះទេ ។ មានតែគណៈកម្មការការពិត និងបង្រួបបង្រួមជាតិ នៃប្រទេស អាហ្វ្រិកខាងត្បូងមួយទេ ដែលអាចទទួលបានកិច្ចសហប្រតិបត្តិការយ៉ាងសំខាន់ពីសំណាក់អ្នកប្រព្រឹត្តបទ ឧក្រិដ្ឋ តែការនេះអាចធ្វើទៅតែនៅក្នុងក្របខ័ណ្ឌនៃការស្រុះស្រួលគ្នាជារួមមួយ ដែលផ្តល់ដល់ពួកគេនូវទិសដៅជារូបភាពនៃការលើកលែងទោសណាមួយ ដែលការនេះយើងខ្ញុំសូមមិនលើកជាសំណូមពរទេនោះ ។

២០៤- ទី ២ នៅក្នុងករណីពីមុន ៗ មក គណៈកម្មការនានាបានធ្វើជាផ្នែកមួយនៃការសំរុះសំរួលខាងនយោបាយ រវាងរបបផ្តាច់ការឱ្យបោះបង់ចោលអំណាច ហើយពួកអ្នកប្រឆាំងរបស់គេជាអ្នករៀបចំសំរាប់

អនាគត (ដោយរួមមានទាំងលទ្ធភាពធ្វើការកាត់ទោសជាយថាហេតុផង) ។ ទាំងនេះមិនមែនជាអ្វីដែលបានកើតឡើងនៅកម្ពុជាទេ ។ ម្យ៉ាងទៀត និយាយដោយស្មោះ ក្រុមមិនប្រាកដថាថ្នាក់ដឹកនាំនយោបាយខ្មែរបានដើរដល់កំរិតនៃការបង្រួបបង្រួមជាតិចាំបាច់ដើម្បីបង្កើតឡើងនូវគណៈកម្មការមួយបាននោះទេ ។ ក្រុមមានការព្រួយបារម្ភថាការបែកបាក់គ្នានៅក្នុងសង្គមកម្ពុជា អាចនឹងធ្វើមិនឱ្យសំរេចបាននូវកិច្ចការរបស់គណៈកម្មការមួយទាក់ទិនទៅនឹងកិច្ចដំណើរការ និងការផ្សព្វផ្សាយលទ្ធផលរបស់គណៈកម្មការ ។ គណបក្សជាច្រើនអាចបដិសេធសេចក្តីសន្និដ្ឋានរបស់គណៈកម្មការ ហើយទោះបីជាយ៉ាងណាក៏ដោយ ភាពមិនចេះអក្សរដែលមានកំរិតខ្ពស់ នៅក្នុងករណីជាច្រើន វាជាឧបសគ្គក្នុងការទទួលយកដោយស្រួលនូវរបាយការណ៍របស់គណៈកម្មការ ។

២០៥- ទី ៣ ក្រុមគិតថាគណៈកម្មការស៊ើបអង្កេតណាមួយ ត្រូវបង្កើតឡើងតាមរបៀបណាមួយដែលមិនបង្កើតជាឧបសគ្គដល់កិច្ចប្រតិបត្តិការនៃការកាត់ទោសពីបទព្រហ្មទណ្ឌនោះទេ ។ ជាទូទៅ គណៈកម្មការដែលមានពីមុន ៗ មក បានខិតខំដើម្បីជៀសវាងនូវបញ្ហាទាំងនេះ ដោយសារគណៈកម្មការបានបញ្ចប់កិច្ចការមុនការកាត់ទោសបានចាប់ផ្តើម ឬពីព្រោះតែដោយពុំមានការកាត់ទោសបន្ទាប់ពីគណៈកម្មការបានដាក់ជូនរបាយការណ៍ ។ ប៉ុន្តែ បើកិច្ចដំណើរការទាំង ២ នេះ បានកើតឡើងបន្តបន្ទាប់គ្នានោះ ហើយប្រមូលផ្តុំការយកចិត្តទុកដាក់ទៅលើដំណាក់កាលពិសេសដូចគ្នានោះ ការនេះអាចបណ្តាលឱ្យការលំបាកយ៉ាងខ្លាំងកើតឡើង សំរាប់ការកាត់ក្តីមួយត្រឹមត្រូវ ក្នុងនេះរួមមានការបំភ្លៃភស្តុតាង និងការធ្វើសេចក្តីថ្លែងការណ៍ទាំងឡាយ ដែលមានលក្ខណៈផ្ទុយគ្នារបស់អង្គការទាំង ២ នេះ ។ ម្យ៉ាងទៀត នៅក្នុងស្ថានភាពមួយបែបនេះ សាធារណជនកម្ពុជាអាចមិនយល់អំពីភាពខុសគ្នារវាងកំរិតនៃភស្តុតាង ដែលត្រូវបានយកមកប្រើប្រាស់ដោយ អង្គការនិមួយ ៗ (ដោយកំរិតមួយខ្ពស់ជាងយ៉ាងច្រើននៃភស្តុតាងនៅក្នុងក្របខ័ណ្ឌនៃបទ ព្រហ្មទណ្ឌ) ។

២០៦- គេមានលទ្ធភាពអាចបន្ថយបញ្ហាទាំងនេះបាន ដោយបង្កើតគណៈកម្មការមួយ ដែលតាមពិតទៅមិនស្តាប់សំដីរបស់សាក្សីទេ ប៉ុន្តែគណៈកម្មការនេះមានសមាសភាពជាអ្នកប្រវត្តិវិទូ និងជាអ្នកជំនាញការដែលមានបំណងសរសេរកំណត់ហេតុមួយដែលអាចយកជាការបាន ដោយផ្អែកលើភស្តុតាងជាឯកសារ ឬមួយ

គណៈកម្មការដែលមិនបញ្ចេញឈ្មោះអ្នកប្រព្រឹត្តបទល្មើស ។ ក៏ប៉ុន្តែ គេអាចចោទសួរថាតើរបាយការណ៍នេះអាចឱ្យប្រជាពលរដ្ឋកម្ពុជាទទួលយកដូចម្តេចបាន ដោយសារថាវាមិនឈរលើចម្លើយរបស់សាក្សីនោះ ។ ម្យ៉ាងទៀត បែបបទមួយបែបនេះមិនអនុគ្រោះឱ្យផ្សះរបួសរបស់ជនរងគ្រោះបានទេ ដែលការនេះជាទិសដៅមួយដែលអាចសំរេចទៅបានដោយការឆ្លើយរបស់កសិណសាក្សី ។

២០៧- យោងតាមអ្វីដែលបានរៀបរាប់មកខាងលើនេះ ក្រុមយល់ឃើញថាវាជាការឆាប់ពេកក្នុងការធ្វើការស្នើយោបល់ជាក់ស្តែងណាមួយថា យល់ស្រប ឬជំទាស់ ចំពោះការបង្កើតគណៈកម្មការស៊ើបអង្កេតណាមួយនោះ។ ក្រុមគិតថា ជាការល្អគួរតែប្រជាពលរដ្ឋកម្ពុជា តាមរយៈផ្នែករដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល នាំគ្នាចាប់ផ្តើមកិច្ចដំណើរការធ្វើការពិចារណាមួយ ដើម្បីពិនិត្យរកវិធានការសមស្របទាំងឡាយ ដើម្បីស្វែងរកការពិត ។ ទាំងនេះនឹងជួយដល់ប្រជាពលរដ្ឋកម្ពុជាថាតើគួរមានគណៈកម្មការស៊ើបអង្កេតឬទេ ហើយនឹងថាតើគណៈកម្មការនេះគួរតែបង្កើតឡើងតាមរូបភាពដូចម្តេច ។ រហូតមកទល់ពេលបច្ចុប្បន្ននេះ គណៈកម្មការនិមួយ ៗ ត្រូវបានបង្កើតឡើងស្របទៅតាមកាលៈទេសៈពិសេសរបស់រដ្ឋមានពាក់ព័ន្ធទៅនឹងអង្គភាពដែលជាអ្នកបង្កើតវា អាណត្តិរបស់វា សមាសភាព លទ្ធភាពកោះហៅសាក្សីនានាឱ្យមកបង្ហាញខ្លួន សមត្ថភាពចង្អុលឈ្មោះអ្នកប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងរបាយការណ៍ចុងក្រោយរបស់ខ្លួន ការកំណត់ពេលវេលា ការទាក់ទងជាមួយការចោទប្រកាន់តាមផ្លូវតុលាការ និងកត្តាផ្សេង ៗ ទៀត ។ សំនួរដូចគ្នាទាំងនេះ ត្រូវតែលើកឡើងនៅក្នុងករណីនៃប្រទេសកម្ពុជា ។

២០៨- ដើម្បីជួយប្រជាពលរដ្ឋកម្ពុជាក្នុងកិច្ចការនេះ យើងខ្ញុំសូមស្នើថាអង្គការសហប្រជាជាតិ តាមរយៈឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សហការជាមួយផ្នែកផ្សេង ៗ នៃប្រជាពលរដ្ឋកម្ពុជា ផ្តល់ពិតមាននានាស្តីពីគណៈកម្មការទាំងនេះ និងជំរុញឱ្យមានការពិភាក្សាគ្នាមួយលើបញ្ហានេះ ។ ជា ពិសេស ឧត្តមស្នងការ តាមរយៈការិយាល័យរបស់ខ្លួនប្រចាំកម្ពុជា អាចរៀបចំសន្និសិទមួយចំនួនស្តីពីប្រធានបទនេះ ។ យើងខ្ញុំសង្ឃឹមថា ផ្នែករដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល នឹងពិនិត្យដោយយកចិត្តទុកដាក់ថាតើប្រតិបត្តិការមួយបែបនេះ វានឹងជួយបំពេញជាវិជ្ជមាននូវរឿងក្តីដែលយើងខ្ញុំនឹងលើកឡើងជាការស្នើយោបល់ដែរឬទេ ។

២០៩- ក៏ប៉ុន្តែ នៅក្នុងពេលជាមួយគ្នានេះ យើងខ្ញុំសង្ឃឹមថារដ្ឋអាជ្ញានឹងមានលទ្ធភាពដាក់ជូនករណីរបស់ខ្លួនប្រឆាំងទៅនឹងជនជាប់ចោទ ដើម្បីជាពន្លឺលើគ្រប់ប្រភេទទាំងអស់នៃអំពើឃោរឃៅ ដែលបានប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីធ្វើឱ្យជនកម្ពុជាដែលតាមដានការកាត់ទោស អាចនឹងដឹងអំពីអតីតកាលរបស់ពួកគេ ។ នេះក៏ជាវិធីមួយទៀត ដែលអាចលើកតម្កើងការយល់ដឹង និងការបេង្រួបបង្រួមជាតិ ។

## ខ- ការផ្លាស់ និងការបណ្តេញចោល ពីការិយាល័យ

២១០- ក្រុមបានកត់សំគាល់ឃើញថា ប្រទេសជាច្រើនមាននយោបាយធ្វើការផ្លាស់ប្តូរ និងបណ្តេញចោលពីមុខងារសាធារណៈ ចំពោះមនុស្សដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរទាំងឡាយ ។ ប្រទេសកម្ពុជា មានច្បាប់មួយដាក់ខ្មែរក្រហមឱ្យនៅក្រៅច្បាប់ ប៉ុន្តែគេនៅតែមានលទ្ធភាពដែលថាមនុស្សដែលជាទិសដៅនៃការស៊ើបអង្កេតចំពោះអំពើឃោរឃៅ នៅក្នុងទសវត្សឆ្នាំ ១៩៧០ អាចមានមុខតំណែងជាផ្លូវការ ឬក៏មានបំណងកាន់តំណែងនេះនាពេលអនាគត ។ ក្រុមយល់ឃើញថា មនុស្សទាំងអស់ដែលមានពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មបែបនេះ មិនត្រូវឱ្យមានតំណែងនាទីជាផ្លូវការនោះទេ ។ ដូច្នេះ ក្រុមសូមស្នើថា បន្ទាប់ពីការបង្កើតតុលាការដើម្បីធ្វើការវិនិច្ឆ័យពួកមេដឹកនាំខ្មែរក្រហមហើយ ប្រទេសកម្ពុជាត្រូវតែអនុម័តច្បាប់មួយហាមមិនឱ្យមនុស្សទាំងអស់ដែលត្រូវផ្តន្ទាទោសដោយតុលាការ មានមុខនាទីជាផ្លូវការណាមួយឡើយ ។

## គ- ការទទួលខុសត្រូវខាងថវិកា

២១១- មានការបញ្ជាក់ជារឿយ ៗ មកថា សមាជិកខ្មែរក្រហមខ្លះ បានប្រមូលធនធានដ៏ច្រើនសន្ធឹកសន្ធាប់នៅក្នុងរយៈពេលបន្ទាប់ពីពួកគេត្រូវបានដេញចេញពីអំណាចមក ។ ធនធានទាំងនេះ ជាសំខាន់បានមកពីការ កាប់រឈើលក់ និងរ៉ែត្បូង ដែលផលិតផលទាំងនេះត្រូវបានផ្តល់ជាផលប្រយោជន៏ដោយខុសច្បាប់ដល់ឈ្មួញ កម្ពុជា និងបរទេស នៅក្នុងតំបន់ត្រួតត្រាដោយពួកខ្មែរក្រហម ។ ប្រាក់ទាំងនេះមួយចំនួន ស្ថិតនៅក្នុង ធនាគារ នៅឯបរទេស ។

២១២- ក្រុមយល់ឃើញថា ធនធានរបស់ពួកមេដឹកនាំខ្មែរក្រហម ដែលត្រូវបានផ្តន្ទាទោសដោយតុលាការ ត្រូវតែយកមកប្រើជាមធ្យោបាយ ដើម្បីសងជម្ងឺចិត្តជាទឹកប្រាក់ដល់ជនរងគ្រោះរបស់ពួកខ្មែរក្រហម ។ លទ្ធភាពបង្ខំឱ្យជនជាប់ចោទសងជម្ងឺចិត្តដល់ជនរងគ្រោះ ត្រូវបានកំណត់ក្នុងលក្ខន្តិកៈនៃតុលាការពិសេស ដែលមានស្រាប់មកហើយ ហើយដែលបញ្ជាក់ជាថ្មីឡើងវិញកាលពីពេលថ្មី ៗ នេះ នៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[៨៥] ។ ដូច្នេះ យើងខ្ញុំសូមស្នើយោបល់ថា តុលាការត្រូវត្រៀមលទ្ធភាពនៃការសងជម្ងឺចិត្តដោយជនជាប់ចោទចំពោះជនរងគ្រោះ ក្នុងនេះរួមទាំងតាមរយៈនៃមូលនិធិនៃការរួមវិភាគទានដោយស្ម័គ្រចិត្តជាពិសេសផង ហើយថារដ្ឋដែលទុកធនធានទាំងនេះ ត្រូវចាត់វិធានការផ្ទេរវាមកឱ្យតុលាការ ដើម្បីធ្វើឱ្យជនជាប់ចោទអាចនឹងបំពេញកាតព្វកិច្ចរបស់ខ្លួន នៅក្នុងន័យនេះ ។ ម្យ៉ាងទៀត រដ្ឋនានាដែលរក្សាទុកធនធានខុសច្បាប់របស់ពួកខ្មែរក្រហម ត្រូវរិះរករូបមន្តណាផ្សេងទៀត ដើម្បីសងជម្ងឺចិត្តដល់ជនរងគ្រោះតាមរយៈនៃធនធានទាំងនេះ ។

## X- ទិដ្ឋភាពដ៏ទៃទៀតនៃការកាត់ទោស

### ក- <u>ការជំរុញឱ្យកិច្ចដំណើរការទៅលឿន</u>

២១៣- ក្រុមមានសេចក្តីព្រួយបារម្ភថា ការបង្កើតឱ្យមានតុលាការអង្គការសហប្រជាជាតិមួយ ដូចដែលបានលើកស្នើមកនេះ នឹងត្រូវការពេលវេលា ហើយនឹងថាបន្ទាប់មកតុលាការនេះនឹងលិចលង់ទៅដោយឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ ។ ដូច្នេះ ក្រុមសូមស្នើថា ឱ្យអង្គការសហប្រជាជាតិ ដោយឈរលើបទពិសោធទទួលបានពីតុលាការមុន ៗ មកនោះ ចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងទាំងអស់ ដើម្បីជំរុញឱ្យបានលឿននូវការបង្កើតតុលាការនេះ ។ ជាការពិតណាស់ដែលថាត្រូវត្រៀមនូវលក្ខន្តិៈលើកលែង ចំពោះកិច្ចដំណើរការនៃការហៅឱ្យដេញថ្លៃ ហើយសំខាន់ជាងនេះទៀត ការលើកលែងចំពោះការកំណត់ព្រំដែនតម្រូវទៅលើការផ្តាច់ខ្លួនរបស់បុគ្គលិក ដែលជាវិធានការដែលត្រូវមានប្រសិទ្ធភាពភ្លាម នៅពេលដែលតុលាការបានកើតឡើងត្រឹមត្រូវ ហើយនោះ ។ កិច្ចដំណើរការនៃការអនុមតិថវិកាក៏ត្រូវតែធ្វើឱ្យបានសាមញ្ញដែរ ។ ម្យ៉ាងទៀត យើងខ្ញុំគិត ថា កិច្ចការរបស់ប្រឡាបញ្ជីប្រចាំតុលាការថ្មីនេះ

---

[៨៥] លក្ខន្តិកៈរបស់តុលាការអន្តរជាតិស្តីពីអតីតប្រទេសយូហ្គោស្លាវី មាត្រាទី ២៤ (៣) លញក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រាទី ៧៥ ។

ត្រូវចែករំលែកមកពីតុលាការអន្តរជាតិសំរាប់អតីតប្រទេស យូហ្គោស្លាវី ដោយគ្រាន់តែរៀបចំដាក់ការិយាល័យតូចមួយនៅក្នុងអាគាររបស់តុលាការថ្មី ដើម្បីធ្វើការជាការ ស្រេច ។ ចំពោះយើងខ្ញុំ គួរតែជៀសវាងការបង្កើតឡើងនូវក្រឡាបញ្ជីស្វយ័តម្នាក់ធ្វើការដោយឯករាជ្យនៅក្នុងតុលាការថ្មី ដែលជាការនាំឱ្យខាតពេលវេលា និងលុយកាក់ដោយឥតប្រយោជន៍តែប៉ុណ្ណោះ ។ ទីបញ្ចប់ ក្រុមសូមស្នើថា នៅពេលតុលាការកើតហើយ ចៅក្រមត្រូវគិតគូរយ៉ាងសកម្មអំពីសំណុំរឿង ដើម្បីធ្វើឱ្យកិច្ចការនេះដោះស្រាយបានលឿន ។ ចាប់ពីចុងម្ខាងទៅចុងម្ខាងទៀតនៃកិច្ចដំណើរការ ត្រូវធ្វើការដោយសាកសួរយោបល់គ្នាយ៉ាងជិតស្និទ្ធ ជាមួយជាមួយឧបករណ៍នៃតុលាការដែលមានស្រាប់ ដើម្បីទាញយកចំណេញពីបទពិសោធន៍ដែលសំរេចបានហើយនោះ ។

## ខ- វិធីសាស្ត្រនៃការចោទប្រកាន់ និងការទទួលយកភស្តុតាង

២១៤- ទាក់ទិនទៅនឹងបញ្ហាខាងលើនេះ គឺវិធីនៃការចោទប្រកាន់ ។ ជាទូទៅ គឺជានីតិវិធីបដិបក្សអនុវត្តនៅក្នុងប្រព័ន្ធនៃយុត្តាធិការរបស់ច្បាប់ធម្មតា ដែលត្រូវបានអនុម័តដោយតុលាការពិសេសទាំង ២ ដែលមានស្រាប់ ហើយគឺនីតិវិធីនេះហើយដែលត្រូវបានយកមកប្រើនៅក្នុងតុលាការព្រហ្មទ័ណ្ឌអន្តរជាតិនោះ ។ ប្រព័ន្ធកូនកាត់មួយយកមកពីកត្តាខ្លះនៃយុត្តាធិការនៃច្បាប់រដ្ឋប្បវេណី ក៏គួរយកមកពិចារណាផងដែរ ។ នីតិវិធីរបស់ខ្មែរ ជាសំខាន់គឺយកមកពីប្រព័ន្ធរបស់បារាំង ហើយការអនុមតិកត្តានានានៃប្រព័ន្ធនេះ អនុគ្រោះឱ្យមានមូលដ្ឋាននៃតុលាការនេះ នៅបទពិសោធន៍របស់កម្ពុជា ។ នៅក្នុងពេលជាមួយគ្នានេះ ទោះបីជាអនុម័តយកប្រព័ន្ធណាមួយក៏ដោយ ក៏ត្រូវតែគោរពដោយពេញលេញនូវសិទ្ធិការពារខ្លួនរបស់ចុងចោទ ដូចដែលមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិនយោបាយ និងសិទ្ធិពលរដ្ឋ ។

២១៥- រីឯចំពោះបញ្ហាភស្តុតាងវិញ របាយការណ៍របស់យើងខ្ញុំបង្ហាញឱ្យឃើញថាភាគច្រើននៃភស្តុតាងសុទ្ធតែចាស់ ៗ ណាស់ទៅហើយ ហើយនៅក្នុងករណីជាច្រើនគេអាចរក្សាបានតែជាស្លាកស្នាមដ៏រប៉ាត់រប៉ាយតែបន្តិចបន្តួចប៉ុណ្ណោះ ។ អាស្រ័យដោយស្ថានភាពនៃភស្តុតាង និងរយៈពេលដែលបានកន្លងផុតទៅចាប់តាំងពីអំពើឧក្រិដ្ឋត្រូវបានប្រព្រឹត្តនោះ ក្រុមយល់ឃើញថា តុលាការត្រូវសំរបសំរួលទទួលយកការដោះស្រាយតាមច្បាប់រដ្ឋប្បវេណីដែលបច្ចុប្បន្នមាននៅក្នុងបទបញ្ជាស្តីពីភស្តុតាង របស់តុលាការអង្គការសហប្រជាជាតិ ដែល

មានស្រាប់ទាំង ២ ក៏ដូចជារដ្ឋជាច្រើនដ៏ទៃទៀត-ពោលគឺការទទួលយកភស្តុតាងទាំងអស់ ដែលមានពាក់ព័ន្ធ ដោយទុកឱ្យចៅក្រមធ្វើការវាយតម្លៃចំពោះភស្តុតាងទាំងនេះ[៨៦] ។ ការដោះស្រាយមួយបែបនេះ គឺធ្វើឡើង នៅក្នុងកាលៈទេសៈចាំបាច់ ជាជាងការសំអាងទៅលើច្បាប់ទូទៅ ដូចជាការព្យួតគេនិយាយថាយ៉ាងនេះយ៉ាង នោះនោះ ដែលនាំទៅឱ្យមានញើលើកលែងមួយយ៉ាងវែងនោះ ។

## គ- កិច្ចការពារភស្តុតាង និងសាក្សី

២១៦- ស្ថានភាពខ្ទេចខ្ទីនៃភស្តុតាងជារូបវន្តជាច្រើន ហើយនឹងការបារម្ភដែលសាក្សីខ្លះអាចនឹងមានក្នុងការ បង្ហាញនូវសាក្ខីភាពបេស់ខ្លួននោះ វាជាការគូសបញ្ជាក់អំពីសារសំខាន់នៃការចាត់វិធានការការពារ ដោយ តុលាការ ដែលនឹងត្រូវបង្កើតឡើងជាយថាហេតុនោះ។ ច្បាប់ដើមនៃឯកសារ ត្រូវទុកដាក់នៅក្នុងកន្លែងមាន សុវត្ថិភាព ស្ងួត និងត្រួតពិនិត្យលើអាកាសធាតុបាន ដែលធ្វើឱ្យការពារពីលទ្ធភាពផ្សេង ៗ នៃការខូចខាត ផ្សេង ៗ បាននោះ ។ សាក្សីទាំងឡាយត្រូវតែទទួលបាននូវការការពារនៅពេលមុន ក្នុងពេល និងក្រោយ ពេលកាត់ទោស ហើយបើសិនជាមានការចាំបាច់ និងដើម្បីសុវត្ថិភាពពេញលេញបាននោះ ពេលខ្លះគួរតែត្រូវ លាក់អត្តសញ្ញាណរបស់ពួកគេ ។

## ឃ- កិច្ចសហប្រតិបត្តិការស្តីពីភស្តុតាង

២១៧- យើងខ្ញុំបានគូសបញ្ជាក់នៅផ្នែកខាងលើនៃរបាយការណ៍នេះ អំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ ពីសំណាក់រដ្ឋដ៏ទៃ ស្តីពីការចាប់ខ្លួន និងការធ្វើបត្យាប័នជនជាប់សង្ស័យ ។ ក្រុមក៏បានគូសបញ្ជាក់ផងដែរ អំពី ការចាំបាច់ឱ្យមានកិច្ចសហប្រតិបត្តិការមួយដូចគ្នានេះដែរពីសំណាក់រដ្ឋនានាដែលនៅលើទឹកដីរបស់ខ្លួន មាន សាក្សី ឬភស្តុតាងនោះ ។ ជាពិសេស យើងខ្ញុំគិតថានៅប្រទេសវៀតណាម ដែលជាប្រទេសមួយដែលអាច នឹងមានឯកសារ ដែលបានបាត់ពីប្រទេសកម្ពុជា

---

[៨៦] សូមមើលតុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី បទបញ្ញាស្តីពីភស្តុតាង ((ដូចដែលបានធ្វើវិសោធនកម្ម នៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ១៩៩៨) បទបញ្ញាលេខ ៨៩ IT/32/Rev.13 ។

បន្ទាប់ពីប្រទេសនេះបានរើបំរាស់ចេញពីរបបកម្ពុជាប្រជាធិប តេយ្យ ប៉ុន្តែក៏អាចមានឯកសារដ៏ទៃទៀត ព្រមទាំងសាក្សីផងដែរ ដែលកំពុងស្ថិតនៅក្នុងប្រទេសដ៏ទៃទៀត នៅក្នុងតំបន់ផងដែរ ។

## ង- បញ្ហាដែលត្រូវដោះស្រាយបន្ទាប់ពីមានការផ្តន្ទាទោសរួចហើយ

២១៨- ជនជាប់ចោទ នៅពេលផ្តន្ទាទោសរួចហើយ ត្រូវទទួលទ័ណ្ឌកម្មរបស់ខ្លួននៅក្នុងពន្ធនាគារដែលសម ស្របទៅតាមបទដ្ឋានអន្តរជាតិ ហើយដែលលទ្ធភាពរត់ចេញពីពន្ធនាគារមានតិចតួចបំផុត ។ នេះគឺជា ទឡ្ហីករមួយទៀត បន្ថែមពីលើទឡ្ហីករដ៏ទៃទៀត ដែលយើងខ្ញុំគាំទ្រឱ្យមានការយកទៅដាក់ពន្ធនាគារនៅក្នុង រដ្ឋដ៏ទៃទៀតក្រៅពីប្រទេសកម្ពុជានោះ ។ ស្របទៅតាមលក្ខន្តិកៈរបស់តុលាការអង្គការសហប្រជាជាតិ បច្ចុប្បន្ននេះ ការសំរាលទោសត្រូវទុកលទ្ធភាពជូនប្រធានតុលាការ ដែលនឹងសំរេចបញ្ហាបែបនេះដោយឈរ លើផលប្រយោជន៍របស់យុត្តិធម៌ និងគោលការណ៍ច្បាប់[៨៧] ។

## XI- សេចក្តីសង្ខេបនៃអនុសាសន៍សំខាន់ ៗ

២១៩- យើងខ្ញុំសង្ឃឹមថា អ្វីដែលបានរៀបរាប់មកខាងលើនេះ យើងខ្ញុំបានអភិប្រាយនូវបញ្ហាទាំងអស់ ដែល លោកអគ្គលេខាធិការបានប្រគល់ជូនឱ្យក្រុមអ្នកជំនាញការធ្វើ ។ ដោយមិនចង់លើកឡើងវិញនូវអនុសាសន៍ ទាំងអស់របស់យើងខ្ញុំនោះ នៅទីនេះយើងខ្ញុំសូមលើកយកតែអនុសាសន៍ដែលយើងខ្ញុំមើលឃើញថាមានសារ សំខាន់ជាងគេតែប៉ុណ្ណោះ:

យើងខ្ញុំសូមធ្វើការស្នើយោបល់មួយចំនួនដូចតទៅ:

១- ឆ្លើយតបទៅនឹងការស្នើសុំរបស់រដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ១៩៩៧ អង្គការ សហប្រជាជាតិបានបង្កើតតុលាការអន្តរជាតិពិសេសមួយ ដែលនឹងទទួលបន្ទុកធ្វើការវិនិច្ឆ័យទោសពួកអ្នក ទទួលខុសត្រូវខ្មែរក្រហមចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ ដែលពួកគេបាន ប្រព្រឹត្តពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៧ ខែមករា ឆ្នាំ ១៩៧៩ ។

---

[៨៧] សូមមើលលក្ខន្តិកៈរបស់តុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី មាត្រាទី ២៨ ។

២- ចំពោះការធ្វើការចោទប្រកាន់ រដ្ឋអាជ្ញាឯករាជ្យតែងតាំងឡើងដោយអង្គការសហប្រជាជាតិ កំណត់ការស៊ើបអង្កេតរបស់ខ្លួនទៅលើមនុស្សទាំងឡាយដែលទទួលខុសត្រូវជាងគេ ចំពោះការរំលោភដ៏ធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយប្រើប្រាស់នូវការប្រុងប្រយ័ត្នរបស់ខ្លួន ក្នុងការស៊ើបអង្កេត ការចោទប្រកាន់ និងការកាត់ទោស ដោយយកចិត្តទុកដាក់ទៅលើទិសដៅចំនួន ២ នៃការទទួលខុសត្រូវរបស់បុគ្គល និងការបង្រួបបង្រួមជាតិ នៅក្នុងប្រទេសកម្ពុជា ។

៣-តុលាការនេះត្រូវបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខ ឬបើមិនដូច្នោះទេដោយមហាសន្និបាត។

៤- តុលាការនេះ ត្រូវចែកចេញជាសាលាកាត់ក្តី ២ និងសាលាឧទ្ធរណ៍មួយ ហើយអង្គការសហប្រជាជាតិនឹងខិតខំយ៉ាងសកម្ម ដើម្បីបញ្ចូលទៅក្នុងតុលាការនេះនូវជនជាតិខ្មែរមួយរូប ដែលអង្គការសហប្រជាជាតិយល់ឃើញថាមានសមត្ថភាព មិនលំអៀង និងសមស្របនឹងបំពេញកិច្ចការមួយបែបនេះបាន ។

៥- រដ្ឋអាជ្ញារបស់តុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងរបស់តុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសរ្វ៉ាន់ដា ត្រូវតែងតាំងឱ្យធ្វើជារដ្ឋអាជ្ញារបស់តុលាការថ្មីនេះ ដោយមានជំនួយការជារដ្ឋអាជ្ញារងម្នាក់ ដែលនឹងទទួលបន្ទុកជាពិសេសចំពោះកិច្ចដំណើរការរបស់តុលាការនេះ ។

៦- តុលាការនេះ ដោយរួមទាំងខុទ្ទកាល័យរបស់រដ្ឋអាជ្ញារងផង ត្រូវស្ថិតនៅក្នុងរដ្ឋណាមួយនៃតំបន់អាស៊ី និងប៉ាស៊ីហ្វិក តែមិនមែននៅក្នុងប្រទេសកម្ពុជាទេ ។ រដ្ឋអាជ្ញាត្រូវដាក់ឱ្យមានការិយាល័យស៊ើបអង្កេត នៅក្នុងប្រទេសកម្ពុជា ហើយអង្គការសហប្រជាជាតិ ដោយសហការជាមួយរដ្ឋាភិបាលកម្ពុជា មានលទ្ធភាពធ្វើការផ្សព្វផ្សាយដោយសេរីនៅក្នុងប្រទេសកម្ពុជាទាំងមូល តាមរយៈវិទ្យុ និងទូរទស្សន៍ អំពីការប្រព្រឹត្តទៅនៃរឿងក្តីនេះ ។

៧- ចំនួនចៅក្រមទាំងអស់តែងតាំងដោយអង្គការសហប្រជាជាតិ មិនត្រូវបានចាត់តាំងឱ្យធ្វើការដោយពេញម៉ោងទេ ល្គឹកណាតែអ្នកជាប់ចោទមួយចំនួនមិនទាន់ត្រូវបានចាប់ខ្លួនទេនោះ ។

៨- អង្គការសហប្រជាជាតិចាត់វិធានការជាពិសេស ដើម្បីរក្សាឱ្យគង់វង្សនូវភស្តុតាងជាសម្ភារៈ និងការពារសាក្សីបើមានការចាំបាច់ ហើយរដ្ឋទាំងឡាយដែលនៅលើទឹកដីរបស់ខ្លួនមានភស្តុតាង និងសាក្សី ត្រូវប្រគល់ជូនទៅឱ្យរដ្ឋអាជ្ញា ។

៩- តុលាការដែលនឹងបង្កើតឡើងនេះ ត្រូវត្រៀមអំពីលទ្ធភាពនៃការសងជម្ងឺចិត្តដល់ជនរងគ្រោះដោយជនជាប់ចោទ ក្នុងនេះរួមមានការធ្វើតាមរយៈនៃមូលនិធិនៃការរួមវិភាគទានដោយស្មគ្រចិត្ត ឬមូលនិធិពិសេសដ៏ទៃទៀត ហើយរដ្ឋដែលរក្សាទុកទ្រព្យសម្បត្តិរបស់ជនជាប់ចោទ ត្រូវសំរបសំរួលផ្ទេរវាទៅឱ្យតុលាការ តាមការទាមទាររបស់តុលាការនេះ ដើម្បីឱ្យជនជាប់ចោទបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការសងជម្ងឺ ចិត្ត ។

១០- អង្គការសហប្រជាជាតិ ដោយសហការជាមួយរដ្ឋាភិបាលកម្ពុជា និងអង្គភាពក្រៅរដ្ឋាភិបាល លើកទឹកចិត្តឱ្យមានកិច្ចដំណើរការមួយនៃការពិចារណាក្នុងចំណោមជនកម្ពុជា ដើម្បីកំណត់នូវបំណង ហើយបើសិនជាអាចទៅរួច កំណត់អំពីបែបបទនូវមន្តការស្វែងរកការពិតមួយ ដើម្បីផ្តល់នូវរូបភាពដ៏ពេញលេញមួយនៃអំពើឃោរឃៅនៅក្នុងយុគសម័យនៃកម្ពុជាប្រជាធិបតេយ្យ ។

២២០- ក្នុងការសុំជំនួយពីអង្គការសហប្រជាជាតិ រដ្ឋាភិបាលកម្ពុជា បានឆ្លើយតបទៅនឹងអ្វីដែលជាបំណងចង់ បានយុត្តិធម៌របស់ប្រជាពលរដ្ឋកម្ពុជា និងទៅនឹងមនោសញ្ចេតនាដែលថាគេមិនអាចធ្វើមិនដឹងមិនឮចំពោះ អតីតកាលបាននោះទេ ។ ផ្ទុយទៅវិញ អ្វីដែលគេត្រូវការនោះ គឺការយល់អំពីអំពីអតីតកាលនេះ និងធ្វើដំណើរឆ្ពោះទៅកាន់អនាគតដោយចង់ឃើញថាពួកអ្នកទទួលខុសត្រូវមិនអាចគេចផុតពីយុត្តិធម៌បានទេ ។ កិច្ចដំណើរការនេះ បានបន្លាយពេលយូរពេកណាស់ហើយចំពោះកម្ពុជា ហើយពេលវេលាដែលត្រូវចាត់វិធានការបានមកដល់ហើយ ។ បើសិនជាអង្គការសហប្រជាជាតិសុខចិត្តធ្វើតាមអនុសាសន៍ទាំងនេះ និងអនុសាសន៍ ទាំងអស់ដែលយើងខ្ញុំបានលើកឡើង ព្រមទាំងមានការគាំទ្រពីសំណាក់រដ្ឋាភិបាលកម្ពុជាផងនោះ យើងខ្ញុំ សង្ឃឹមថា វានឹងនាំទៅឱ្យមានកិច្ចដំណើរការមួយដែលនឹងអាចធ្វើឱ្យប្រទេសកម្ពុជាគេចចេញឱ្យឆ្ងាយពីសោកនាដកម្មពីអតីតកាលដែលមិនអាចវាយតម្លៃបាននោះយ៉ាងពិតប្រាកដ ហើយនឹងបង្កើតបាននូវទ្រង់ទ្រាយនៃការបង្រួបបង្រួមជាតិដ៏ពិតប្រាកដមួយបានសំរាប់អនាគតជាមិនខានឡើយ ។

ប្រធាន

(ហត្ថលេខា) រ៉ាហ្សិ៍ស៊ូមីរ ឡាឡា　　　　(ហត្ថលេខា) នីនៀន ស្ទីហ្វិន

(ហត្ថលេខា) ស្ទីវិន រ៉ាត់ណឺរ

ថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៩៩

## ឧបសម្ព័ន្ធ

## បញ្ជីឈ្មោះរបស់ក្រុមអ្នកជំនាញការតែងតាំង

(តាមលំដាប់ពេលវេលា តំណែងនាទីដែលមាននៅពេលប្រជុំ)

### ញ៉ូវយ៉ក ថ្ងៃទី ៨-១១ ខែកញ្ញា ឆ្នាំ ១៩៩៨

ការិយាល័យកិច្ចការច្បាប់របស់អង្គការសហប្រជាជាតិ

លោក ខូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ

តំណាងនានានៃគណៈកម្មាធិការមេធាវី សំរាប់សិទ្ធិមនុស្ស

លោក ដេវីដ សេហ្វឺរ ឯកអគ្គរដ្ឋទូតគោចររបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកបញ្ហាឧក្រិដ្ឋកម្មសង្គ្រាម

នាយកដ្ឋានកិច្ចការនយោបាយរបស់អង្គការសហប្រជាជាតិ

អាស្ដា ចាយ៉ាណាម៉ា តំណាងអចិន្ត្រៃយ៍របស់ប្រទេសថៃប្រចាំអង្គការសហប្រជាជាតិ ហ្វេលីប ម៉ាប៊ីឡង់ហ្កង់

តំណាងអចិន្ត្រៃយ៍របស់ប្រទេសហ្វីលីពីន ប្រចាំអង្គការសហប្រជាជាតិ ការ៉ែន តាន់ តំណាងអចិន្ត្រៃយ៍រង

របស់ប្រទេសសឹង្ហបូរី ប្រចាំអង្គការសហប្រជាជាតិ

តាកេស៊ី កាមីតានី រដ្ឋមន្ត្រី បេសកកម្មអចិន្ត្រៃយ៍របស់ប្រទេសជប៉ុនប្រចាំអង្គការសហប្រជាជាតិ

តំណាងរបស់បេសកកម្មនានា នៃរដ្ឋជាសមាជិករបស់សហភាពអឺរ៉ុប ប្រចាំអង្គការសហប្រជាជាតិ

ចូវ ហ្វី លេខាទី ១ បេសកកម្មអចិន្ត្រៃយ៍របស់ប្រទេសចិន ប្រចាំអង្គការសហប្រជាជាតិ

### ភ្នំពេញ ពីថ្ងៃទី ១៥ ដល់ ២២ ខែវិច្ឆិកា ឆ្នាំ ១៩៩៨

មជ្ឈមណ្ឌលឯកសារកម្ពុជា

សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២

គណៈកម្មាធិការសិទ្ធិមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា

លោក ខេណែត ក្វីន ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា

លោក ធន់ សារ៉ាយ ប្រធាន សមាគមសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ កម្ពុជា

មន្ទីរឯកសារកម្ពុជា
លោក កាស៊ី នូវ នាយកប្រតិបត្តិ នៃវិជ្ជាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស
ទស្សនៈកិច្ចនៅភូមិត្រពាំងស្វា ខេត្តកណ្តាល
សារមន្ទីរទួលស្លែង និងឯកសារ
លោក សាយ បូរី សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ
លោក អ៊ឹង ហួត នាយករដ្ឋមន្ត្រីទី១ និងជារដ្ឋមន្ត្រីក្រសួងការបរទេស
លោក ម៉ាសាគី សៃតូ ឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា
លោក ស ខេង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
តំណាងសហគមន៍ចាម
លោកស្រី លី វួចឡេង អនុរដ្ឋលេខាធិការរកសួងយុត្តិធិម  លោក ហង់រ៉ូ វ៉ាកេន អគ្គព្រះរាជអាជ្ញា
លោក ឱត មន្ទី ប្រធានតុលាការកំពូល
ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រធានគណបក្សហ៊្វុនស៊ិនប៉ិច
លោក យូ ហុកគ្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន
លោក អ៊ុម ខែម នាយកពុទ្ធសាសនបណ្ឌិត
លោក ឡាវ ម៉ុងហៃ នាយក វិជ្ជាស្ថានកម្ពុជាដើម្បីលទ្ធិប្រជាធិបតេយ្យ
លោក ឡាក់ខាន់ មេរ៉ូត្រា តំណាងផ្ទាល់របស់លោកអគ្គលេខាធិការប្រចាំកម្ពុជា
បុគ្គលិក ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា
លោក ហ្សក អែតហ្គា ឯកអគ្គរាជទូតចក្រភពអង់គ្លេស និងអាយឡិនខាងជើង ប្រចាំកម្ពុចា
សម្តេច ជា ស៊ីម ប្រធានរដ្ឋសភា

<u>បាងកក ពីថ្ងៃទី ២២-២៤ ខែវិច្ឆិកា ឆ្នាំ ១៩៩៨</u>

លោក វ៉ាស៊ីន ទាវ៉ារេវជយ៉ាន់ អគ្គនាយក នាយកដ្ឋានកិច្ចការសន្ធិសញ្ញា និងច្បាប់ របស់ក្រសួងការបរទេស
លោក ស៊ូឃុំផាន់ ប៉ារីបាត្រា អនុរដ្ឋមន្ត្រីក្រសួងការបរទេសថៃ

ឧត្តមសេនិយ សូ៊វ៉ាយុទ្ធ ជូឡាណន់ អគ្គមេបញ្ជាការ កងទ័ពភូមិន្ទថៃ

<u>ឡាអេ ថ្ងៃទី ៤ និងថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ១៩៩៨ (តែលោកសាស្ត្រាចារ្យ វ៉ាត់ណើរ ម្នាក់ទេ)</u>

លោក ហ្គាប្រ៊ីយ៉ែល ខឹក ម៉ាក់ដូណាល់ ប្រធាន តុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី
លោកស្រី ល្វីហ្ស៍ អាបួរ វដ្ឋអាដ្ឋា តុលាការអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី និងតុលាការព្រហ្មទ័ណ្ឌអន្តរជាតិសំរាប់ប្រទេសវ៉្វាន់ដា

<u>ហ្សឺណែវ ថ្ងៃទី ២៧ ខែមករា ឆ្នាំ ១៩៩៩</u>

លោកស្រី ម៉ារី រ៉ូប៊ីនសុន ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

--------------